ជំពូកទី ៥
ការពិពណ៌នាពីធនធានបរិស្ថានដែលមានស្រាប់

Draft

Draft

ជំពូកទី ៥
ការពិពណ៌នាពីធនធានបរិស្ថានដែលមានស្រាប់

ក្នុងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៃគម្រោងវិនិយោគមួយ ជាការចាំបាច់ណាស់ក្នុងការយល់ដឹងអំពីស្ថានភាពបរិស្ថានដែលមានស្រាប់នៅក្នុងតំបន់ និងក្បែរតំបន់គម្រោង ពោលគឺតើមានធនធានអ្វីខ្លះដែលមាន ហើយធនធានទាំងអស់បាន និងកំពុងទទួលរងនូវការប៉ះពាល់ក្នុងកម្រិតណាក្នុងពេលបច្ចុប្បន្ន ឬអាចនឹងទទួលរងផលប៉ះពាល់ក្នុងកម្រិតណាមួយនៅពេលដែលគម្រោងវិនិយោគនោះចូលមកអនុវត្ត។ ក្នុងគោលបំណងនេះ ក្រុមការងារបានសិក្សាលើទិន្នន័យដែលចាំបាច់មួយចំនួននៅក្នុងតំបន់គោលដៅ មានដូចជា ធនធានបរិស្ថានធម្មជាតិ ធនធានជីវសាស្ត្រ និងធនធានសង្គមនិងសេដ្ឋកិច្ច។

៥.១ បរិស្ថានធម្មជាតិ

៥.១.១ ធនធានរូបសាស្ត្រ

៥.១.១.១ អាកាសធាតុ

១. អាកាសធាតុនៅក្នុងប្រទេសកម្ពុជា ជាទូទៅមានលក្ខណៈជាអាកាសធាតុបែបសំណើមត្រូពិក ឬមូសុងត្រូពិក ជាអាកាសធាតុក្តៅ-សើម ដែលមានការប្រែប្រួលទៅតាមទីតាំងភូមិសាស្ត្រ។ សីតុណ្ហភាពមានលក្ខណៈខុសគ្នាតិចតួចទៅតាមអន្តរតំបន់ កត្តាបរិស្ថាន និងថាវរូបបន្តផ្សេងៗទៀត ដែលអាចមានឥទ្ធិពល។ ភាពខុសគ្នាខ្លាំងរបស់សីតុណ្ហភាពអាចបណ្តាលមកពីទីតាំងភូមិសាស្ត្រពោលគឺរយៈកំពស់ ដែលមានការប្រែប្រួលក្នុងចន្លោះពី ០-២០០ម ធៀបនឹងនីវ៉ូសមុទ្រ និងគម្របពពកដែលមានការផ្លាស់ប្តូរតាមរដូវកាល **(ផែនទី៥.១-ផែនទីរយៈកំពស់)**។ តាមប្រភពទិន្នន័យស្តីពីសីតុណ្ហភាពនៃខេត្តក្រចេះ នៅក្នុងរយៈពេល ១០ឆ្នាំចុងក្រោយនេះ[1] **(២០០៤-២០១៣)** បង្ហាញថា ខេត្តក្រចេះមានសីតុណ្ហភាពអតិបរមាគិតជាមធ្យម នៅក្នុងឆ្នាំមានការប្រែប្រួលក្នុងចន្លោះពី **៣៣,២-៣៥,៨អង្សាសេ**។ ចំណែកសីតុណ្ហភាពអប្បបរមាគិតជាមធ្យមនៅក្នុងឆ្នាំមានការប្រែប្រួលក្នុងចន្លោះពី **២១,២-២៤,១ អង្សាសេ**។ យោងតាមការវិភាគទិន្នន័យនៃសីតុណ្ហភាពមធ្យមប្រចាំខែក្នុងរយៈពេល១០ឆ្នាំ (២០០៤-២០១៣) បង្ហាញថា ខែដែលក្តៅជាងគេគឺខែមេសាដែលមានកម្រិតសីតុណ្ហភាពអតិបរមាប្រមាណ **៤០,០ អង្សាសេ** រីឯខែដែលត្រជាក់ជាងគេគឺខែមករាដែលមានកម្រិតសីតុណ្ហភាពអប្បបរមាចុះដល់ **១៥,០ អង្សាសេ** (តារាង៥-១, ៥-២ ដ្យាក្រាមទី១, ទី២ និងឧបសម្ព័ន្ធ៥-១)។

[1] ប្រភព: ស្ថានីយ៍ឧត្តុនិយមខេត្តក្រចេះ

តារាង៥-១៖ សីតុណ្ហភាពអតិបរមា (°C), (Longitude:1406° 10' , Latitude:12° 29', Altitude 23m) - ស្ថានីយ៍ឧតុនិយម ខេត្តក្រចេះ

ខែ	មករា	កុម្ភៈ	មិនា	មេសា	ឧសភា	មិថុនា	កក្កដា	សីហា	កញ្ញា	តុលា	វិច្ឆិកា	ធ្នូ	មធ្យម ប្រចាំឆ្នាំ
Year	1	2	3	4	5	6	7	8	9	10	11	12	13
2004	33.5	34.6	36.6	37.5	35.8	33.4	32.0	32.2	31.8	32.7	33.4	31.8	**33.8**
2005	35.5	36.6	38.2	40.0	38.5	35.7	34.2	34.4	33.6	33.6	34.0	33.0	**35.6**
2006	32.8	35.3	34.4	34.5	34.5	33.9	32.4	32.0	31.4	31.7	33.0	33.0	**33.2**
2007	36.7	36.9	36.8	37.7	36.0	35.6	35.3	35.3	34.5	33.7	33.4	34.4	**35.5**
2008	34.5	36.4	37.4	37	35.5	35.0	35.2	35.0	33.8	33.8	34.2	34.5	**35.2**
2009	33.8	36.2	37.4	38	35.5	35.0	35.2	35.0	33.8	33.8	34.2	34.5	**35.2**
2010	34.8	37.8	39	38.3	39.0	36.5	35.9	34.0	33.5	34.0	33.0	33.5	**35.8**
2011	32.7	35.5	35.6	35.5	35.6	34.5	33.8	34.0	31.5	32.0	32.5	32.0	**33.8**
2012	33.5	35.5	35.5	36.0	36.0	35.5	35.0	34.0	34.5	34.0	34.6	35.0	**34.9**
2013	34.5	37.0	37.0	38.0	36.5	34.5	35.0	32.0	39.5	33.0	35.0	35.0	**35.6**
មធ្យម ប្រចាំខែ	**36.7**	**37.8**	**38.2**	**40.0**	**39.0**	**36.5**	**35.9**	**35.3**	**39.5**	**34.0**	**35.0**	**35.0**	**35.8**

ប្រភព: នាយកដ្ឋានឧតុនិយម នៃក្រសួងធនធានទឹក និងឧតុនិយម

Draft

តារាង ៥-២ ៖ សីតុណ្ហភាពអប្បបរមា (°C), (Longitude:106° 10' , Latitude:12° 29', Altitude 23m) - **ស្ថានីយ៍ឧតុនិយម ខេត្តក្រចេះ**

ខែ	មករា	កុម្ភៈ	មិនា	មេសា	ឧសភា	មិថុនា	កក្កដា	សីហា	កញ្ញា	តុលា	វិច្ឆិកា	ធ្នូ	មធ្យមប្រចាំឆ្នាំ
Year	1	2	3	4	5	6	7	8	9	10	11	12	13
2004	21.3	22.4	24.4	25.2	25.4	24.0	24.6	25.0	25.5	24.4	24.5	22.2	**24.1**
2005	23.3	23.3	22.8	24.0	23.7	23.7	23.0	23.5	23.0	23.2	21.7	20.3	**23.0**
2006	20.3	21.9	23.0	24.6	23.9	24.5	24.5	24.2	24.5	24.5	23.2	21.3	**23.4**
2007	18.7	17.9	22.7	22.7	23.5	23.7	23.2	23.2	23.2	22.7	16.0	17.0	**21.2**
2008	18.8	20.0	20.0	24.0	23.2	23.5	23.2	22.2	23.1	23.0	19.6	19.0	**21.6**
2009	15.0	19.5	22.4	23.2	23.0	23.2	23.0	23.5	23.2	24.0	23.0	19.4	**21.9**
2010	18.0	22.0	22.8	23.6	24.0	23.6	21.6	21.0	23.2	21.5	20.0	19.2	**21.7**
2011	18.2	20.0	21.2	22.1	23.5	22.0	22.0	22.8	22.2	23.0	21.0	17.5	**21.3**
2012	20.0	20.5	22.0	22.0	23.0	23.0	23.0	23.0	23.0	22.0	23.0	20.0	**22.0**
2013	18.0	19.5	21.0	24.0	23.0	23.0	23.0	21.5	23.0	21.0	22.0	17.5	**21.4**
មធ្យមប្រចាំខែ	**15.0**	**17.9**	**20.0**	**22.0**	**23.0**	**22.0**	**21.6**	**21.0**	**22.2**	**21.0**	**16.0**	**17.0**	21.2

ប្រភព: នាយកដ្ឋានឧតុនិយម នៃក្រសួងធនធានទឹក និងឧតុនិយម

Draft

ដ្យាក្រាម៥-១៖ សីតុណ្ហភាពអប្បបរមា និងអតិបរមាមធ្យមប្រចាំខែ ក្នុងរយៈពេល ១០ឆ្នាំ



ប្រភព: នាយកដ្ឋានឧតុនិយម នៃក្រសួងធនធានទឹក និងឧតុនិយម

ដ្យាក្រាម៥-២៖ សីតុណ្ហភាពអប្បបរមា និងអតិបរមាមធ្យមប្រចាំឆ្នាំ ក្នុងរយៈពេល ១០ឆ្នាំ



ប្រភព: នាយកដ្ឋានឧតុនិយម នៃក្រសួងធនធានទឹក និងឧតុនិយម

Draft

ផែនទី៥.១-ផែនទីរយៈកំពស់



ប្រភព៖ Elevation Atlas Cambodia

Draft

៥.១.១.២ របបទឹកភ្លៀង

២. ជាទូទៅអាកាសធាតុរបស់ប្រទេសកម្ពុជា មានលក្ខណៈខុសគ្នា និងមានការប្រែប្រួលទៅតាមទីតាំងភូមិសាស្ត្រ។ ជាក់ស្តែងខ្យល់ស្ងួតបានបក់ពីភូមិភាគឦសានទៅភូមិភាគនិរតីនៃប្រទេស ដោយមាននាំទាំងទឹកភ្លៀងតិចតួចមកជាមួយផង យើងហៅរដូវនេះថាជារដូវប្រាំង ហើយរដូវនេះមានរយៈពេល៦ខែ គឺចាប់ផ្តើមពីខែវិច្ឆិកា ដល់ខែមេសា។ ចំណែកឯរដូវវស្សាបានចាប់ផ្តើមពីខែឧសភាដល់ខែតុលា ក្នុងពេលដែលខ្យល់មូសុងបានបក់ពីភូមិភាគនិរតីឆ្ពោះទៅខ្ពង់រាបឦសាននៃប្រទេស ដែលបាននាំមកនូវភ្លៀងដ៏ខ្លាំងដល់តំបន់ទំនាបកណ្តាល ហើយរបបទឹកភ្លៀងនេះ បានជះឥទ្ធិពលដល់ការរីកលូតលាស់ និងដំណុះរបស់រុក្ខជាតិ។ តាមការអធិប្បាយរបស់លោក D.Crocker ១៩៦២ និង Anonymous, ១៩៩៧, ៩៩, តំបន់ដែលទទួលភាពរាំងស្ងួតជាងគេនៅក្នុងប្រទេសកម្ពុជាគឺ អាងទន្លេសាប ដែលមានដូចជា៖ តំបន់ដីទំនាបភាគខាងជើង និងខាងត្បូងនៃជួរភ្នំដងរែក ដែលភាពរាំងស្ងួតបានអូសបន្លាយរយៈពេលរហូតដល់ទៅ០៦ខែ និងទទួលនូវរបបទឹកភ្លៀងប្រចាំឆ្នាំមានកំរិតទាបជាង ១៤៧៧ម.ម។ តាមការសិក្សាទៅលើរបបទឹកភ្លៀងដែលបានកត់ត្រានៅឯស្ថានីយ៍ខេត្តក្រចេះ បានឱ្យដឹងថា នៅក្នុងរយៈពេល១០ឆ្នាំចុងក្រោយ (**២០០៤-២០១៣**) កម្រិតកំពស់ទឹកភ្លៀងមធ្យមប្រចាំឆ្នាំ មានការប្រែប្រួលខុសៗគ្នា ក្នុងចន្លោះពី **១.២០៦,១-២.២២១,៣ម.ម** ដោយកំពស់ទឹកភ្លៀងអប្បបរមាត្រូវបានប្រទះឃើញនៅក្នុងឆ្នាំ២០០៤ ហើយកំពស់ទឹកភ្លៀងអតិបរិមាមាននៅក្នុងឆ្នាំ២០១២។ កម្រិតកំពស់ទឹកភ្លៀងប្រចាំខែមធ្យមក្នុងរយៈពេល១០ឆ្នាំចុងក្រោយ (**២០០៤-២០១៣**) នេះ មានការប្រែប្រួលក្នុងចន្លោះពី **៨០,៨-៣.១០២,៧ម.ម** ដោយមានភ្លៀងធ្លាក់ច្រើនជាងគេក្នុងខែកញ្ញា និងភ្លៀងធ្លាក់តិចជាងគេក្នុងខែធ្នូ (តារាង៥-៣ ដ្យាក្រាម ទី៣, ទី៤ និង ឧបសម្ព័ន្ធ៥-១)។

Draft

តារាង ៥-៣៖ កម្រិតកំពស់ទឹកភ្លៀងប្រចាំខែ (ម.ម), (Longitude:104°54' , Latitude:12°41', Altitude) ស្ថានីយ៍ឧតុនិយម ខេត្តក្រចេះ

ខែ	មករា	កុម្ភៈ	មិនា	មេសា	ឧសភា	មិថុនា	កក្កដា	សីហា	កញ្ញា	តុលា	វិច្ឆិកា	ធ្នូ	សរុបប្រចាំឆ្នាំ
Year	1	2	3	4	5	6	7	8	9	10	11	12	13
2004	0	0	0	96.7	70.8	413.1	74.7	176.1	231.7	127.1	15.4	0.5	**1206.1**
2005	0	0	13.8	59.7	119.9	176.3	298.8	99.2	343.3	119.4	139.4	5.4	**1375.2**
2006	0	112.7	16.3	177.2	314.3	73.7	271.6	451.2	288.5	194.1	39.3	6.5	**1945.4**
2007	0	0	65.3	158.4	174.4	281.1	95.1	167.5	95.1	281.1	105	0	**1423.0**
2008	23.1	48.9	29.7	113.9	291.3	97.6	50.6	265.7	348.5	316.2	87.6	4.2	**1677.3**
2009	0	11.6	66	164.7	197.5	[illegible]	412.6	220.7	447	141.4	15	-	**1849.1**
2010	5.6	0	0	69.2	88.8	169.6	215	291.6	231.4	230.2	48.6	-	**1350.0**
2011	0.0	0.0	57.3	256.5	216.8	321.2	259.2	230.4	379.5	239.0	26.4	0.0	**1986.3**
2012	59.8	9.8	110.8	184.1	224.4	172.1	537.8	184.6	453.8	139.9	144.2	0.0	**2221.3**
2013	0	0	1	50.2	248.3	350.1	431.3	396.5	283.9	130.2	28	64.2	**1983.7**
សរុបប្រចាំខែ	**88.5**	**183**	**360.2**	**1330.6**	**1946.5**	**2227.4**	**2646.7**	**2483.5**	**3102.7**	**1918.6**	**648.9**	**80.8**	

ប្រភព: នាយកដ្ឋានឧតុនិយម នៃក្រសួងធនធានទឹក និងឧតុនិយម

Draft

ដ្យាក្រាម៥-៣៖ កម្រិតកម្ពស់ទឹកភ្លៀងមធ្យមប្រចាំខែ ក្នុងរយៈពេល ១០ឆ្នាំ



ដ្យាក្រាម៥-៤៖ កម្រិតកម្ពស់ទឹកភ្លៀងប្រចាំឆ្នាំ ក្នុងរយៈពេល ១០ឆ្នាំ



Draft

៥.១.១.៣ អំពីរបបខ្យល់

៣. ចំពោះទិន្នន័យពាក់ព័ន្ធនឹងរបបខ្យល់ (ល្បឿន និងទិសខ្យល់) និងសំណើមបរិយាកាស នៅឯស្ថានីយឧតុនិយមខេត្តក្រចេះ ក្នុងពេលបច្ចុប្បន្ននេះ គឺមិនទាន់មានទេ។ ដោយឡែកការពិនិត្យអំពីគុណភាពខ្យល់ ក្រុមការងារនឹងលើកយកទៅបកស្រាយនៅក្នុងចំណុច ៥.៤.១.១ ខាងក្រោម។

៥.១.២ ភូគព្ភសាស្ត្រ និងឋានលេខា

៤. ដីសម្បទាននេះមានទីតាំងស្ថិតនៅក្នុងតំបន់អាងទន្លេមេគង្គផ្នែកខាងកើតរបស់ប្រទេស ក្នុងរយៈកម្ពស់ពី ០-១៣៨ម ទទួលរបបទឹកភ្លៀងជាមធ្យមប្រចាំឆ្នាំពី ១២០៦,១-២២២១,៣ម.ម សីតុណ្ហភាពមធ្យមប្រចាំឆ្នាំគឺ ១៥,៦-២៩,០អង្សាសេ ហើយមានរដូវប្រាំងវែងជាង៦ខែ។ ដីសម្បទាននេះស្ថិតនៅតំបន់ខ្ពង់រាប មានសណ្ឋានដីស្មើរាបស្មើ ក្នុងនោះដីដែលមានជំរាលធំជាង ៥,៤៤ដឺក្រេ មានចំនួនតែ ៨០ហិកតា

ប៉ុណ្ណោះនៃផ្ទៃដីសរុប។ ដីសម្បទានរបស់ក្រុមហ៊ុន **ជូទីសាយហ្គន-ប៊ីញហឿក (អេស ប៊ី ខេ)** មានទីតាំងភូមិសាស្ត្រស្ថិតនៅក្នុងឃុំថ្មី និងឃុំកន្ទួត ស្រុកចិត្របុរី ខេត្តក្រចេះ។ ដើម្បីចូលទៅដល់ទីតាំងក្រុមហ៊ុននេះ យើងអាចធ្វើដំណើរតាមផ្លូវជាតិលេខ៦អា ពីភ្នំពេញ-ស្គន់ (ទីរួមស្រុកជើងព្រៃ) ផ្លូវជាតិលេខ៧ ពីប្រជុំជនស្គន់-ទីរួមស្រុកស្នួល-ទីរួមខេត្តក្រចេះ ក្នុងចម្ងាយប្រមាណ ៦២គ.មពីទីរួមស្រុកស្នួល ដល់ភូមិអាលចក្នុងឃុំកន្ទួត រួចបត់ស្តាំតាមផ្លូវលំក្រាលគ្រួសក្រហមចំងាយប្រមាណ ២គ.ម នឹងទៅដល់ព្រំដីសម្បទាន ហើយបត់ឆ្វេងទៅមុខប្រមាណជា ០៣គ.ម ទៀតទើបទៅដល់ទីស្នាក់ការរបស់ក្រុមហ៊ុន (**ផែនទី៥.២-ផែនទីឋានលេខា**)។

៥. ដីជាតិដីអាចកំណត់ដោយសិលាមេដែលមានស្ថិតៈនៅស្រទាប់ក្រោម និងដោយការអង្កេតទៅលើប្រភេទព្រៃ និងគម្របព្រៃ។ លក្ខណៈគីមីរបស់ដីតែងតែបញ្ជាក់អំពីកំរិត និងលំនាំនៃការបំបែកជាតុរបស់សិលាមេ ក្នុងយុគសម័យភូគព្ភសាស្ត្រ និងលក្ខណៈរបស់ថ្មដែលជាសិលាមេ។ ដំណើរប្រព្រឹត្តទៅនៃបាតុភូតភូគព្ភសាស្ត្របានទទួលរងនូវឥទ្ធិពលអាកាសធាតុ ពេលវេលា ឋានលេខា និងដំណើរប្រព្រឹត្តទៅតាមលក្ខណៈ ជីវសាស្ត្រធម្មជាតិ លក្ខណៈជីវសាស្ត្រដែលបង្កឡើងដោយមនុស្ស សត្វ និងបាក់តេរី។ កត្តាទាំងអស់នេះអាចបញ្ជាក់ដោយផ្ទាល់ និងដោយប្រយោលអំពីដីដែលមានលក្ខណៈជាអាស៊ីត រចនាសម្ព័ន្ធដីជាតិ លទ្ធភាពផលិតកម្ម និងភាពជ្រាបទឹក (D.Crocker ១៩៦២ និង Anonymous, ១៩៩៧, ៩៩)។ យោងតាមផែនទីភូគព្ភសាស្ត្របង្ហាញថា ដីសម្បទាននេះមានសិលាមេ៧ប្រភេទគឺៈ (១) សិលាមេប្រភេទ Basalt មានទំហំ ៥៣៣ហិកតា ស្មើនឹង ៥,៨០ភាគរយ (២) សិលាមេប្រភេទ Conglomerate, breccia មានទំហំ ៦៩ហិកតា ស្មើនឹង ០,៧០ភាគរយ (៣) Floodplains មានទំហំ ៤៤៥ហិកតា ស្មើនឹង ៤,៥៧ភាគរយ (៤) Formation of Sandstone and microbreccia មានទំហំ ៣.៨១៧ហិកតា ស្មើនឹង ៣៩,២០ភាគរយ (៥) No Classified rock មានទំហំ ១.៤៤៦ហិកតា ស្មើនឹង ១៤,៨៥ភាគរយ (៦) Pediments មានទំហំ ២.២២៧ហិកតា ស្មើនឹង ២២,៨៧ភាគរយ និង (៧) Red Terrace (Red Sandstone) មានទំហំ ១២០០ហិកតា ស្មើនឹង ១២,៣២ភាគរយ នៃផ្ទៃដីសរុប (**ផែនទី៥.៣-ផែនទីភូគព្ភសាស្ត្រ**)។

តារាង៥-៤៖ ប្រភេទសិលាមេ

ប្រភេទសិលាមេនៅក្នុងតំបន់សម្បទាន	ផ្ទៃដី (ហិកតា)	ភាគរយ
Basalt	៥៣៣,០០	៥,៨០
Conglomerate, breccia	៦៩,០០	០,៧០
Floodplains	៤៤៥,០០	៤,៥៧
Formation of Sandstone and microbreccia	៣.៨១៧,០០	៣៩,២០
No classified rock	១.៤៤៦,០០	១៤,៨៥
Pediments	២.២២៧,០០	២២,៨៧
Red Terrace (Red Sandstone)	១.២០០,០០	១២,៣២
សរុបរួម	៩.៧៣៧,០០	១០០

Draft

៥.១.៣ ចំណាត់ថ្នាក់ប្រភេទដី នៅក្នុងតំបន់សម្បទាន

៦. នៅក្នុងរយៈពេលនៃការសិក្សា ក្រុមការងារបានធ្វើអង្កេតទៅលើវាយនៈភាព និងលក្ខណៈរបស់ដី តាមរយៈការខួងពិនិត្យស្ទូល ដោយផ្ទៀងផ្ទាត់ជាមួយនឹងរបាយការណ៍របស់លោក D.Crocker ១៩៦២ និង Anonymous, ១៩៩៧,៩៩ ជាមូលដ្ឋានក្នុងការប្រៀបធៀប។ ជាលទ្ធផលបង្ហាញអោយឃើញថា ពុំមានការប្រែប្រួលជាពិសេសណាមួយ បានកើតឡើង គិតចាប់តាំងពីពេលនោះរហូតមកទល់នឹងបច្ចុប្បន្ន នេះទេ លើកលែងតែការផ្លាស់ប្តូរមួយផ្នែកតូចប៉ុណ្ណោះ ដែលកើតមានជាពិសេសចំពោះដីល្បាប់។ ការប្រែប្រួលនេះអាចធ្វើការបកស្រាយបាន ដោយយោងទៅលើមូលហេតុនៃទឹកជំនន់ទៅតាមរដូវនៅក្នុងតំបន់ទំនាបរបស់ដីសម្បទាន។ យោងលើលក្ខណៈដើមរបស់ដី និងលក្ខណៈនៃឋានលេខា ដីសម្បទានរបស់ក្រុមហ៊ុន **ដូទីសាយហ្គន-ប៊ិញហឿក (អេស ប៊ី ខេ)** នេះមានដី០២ប្រភេទគឺ៖ (១) Grey Hydromorphics មានទំហំ ៨៤២ហិកតា ស្មើនឹង ៨,៦៥ភាគរយ និង **(២)** Plinthite podozols មានទំហំ ៨.៨៩៥ហិកតា ស្មើនឹង ៩១,៣៥ភាគរយ នៃផ្ទៃដីសរុប (**ផែនទី៥.៤-ផែនទីចំណាត់ថ្នាក់ប្រភេទដី**)។

តារាង៥-៥៖ តារាងចំណាត់ថ្នាក់ប្រភេទដី

ប្រភេទដីនៅក្នុងដីសម្បទាន	ផ្ទៃដី (ហិកតា)	ភាគរយ
Grey hydromorphics	៨៤២,០០	៨,៦៥
Plinthite podzols	៨.៨៩៥,០០	៩១,៣៥
សរុបរួម	**៩.៧៣៧,០០**	**១០០**

៥.១.៤ ចំណាត់ថ្នាក់ផលិតភាពដី

៧. យោងតាមចំណាត់ប្រភេទគុណភាពដីជាតិរបស់ដី នៅក្នុងតំបន់សម្បទានទាំងមូលមាន ០២ ប្រភេទគឺ៖ ដីមានដីជាតិខ្ពស់មានទំហំ ៨២២ហិកតា ឬស្មើនឹង ៨,៤៤ភាគរយ ស្ថិតនៅខាងជើងឆៀងខាងលិចនៃដីសម្បទាន និងដីមានដីជាតិទាបមានទំហំ ៨.៩១៥ហិកតា ឬស្មើនឹង ៩១,៥៦ភាគរយ លាតសន្ធឹងស្ទើរពេញផ្ទៃដីសម្បទានទាំងមូល (**ផែនទី៥.៥-ផែនទីចំណាត់ថ្នាក់ផលិតភាពដី**)។

តារាង៥-៦៖ តារាងចំណាត់ថ្នាក់ផលិតភាពដី

ចំណាត់ថ្នាក់ផលិតភាពដីនៅក្នុងតំបន់សម្បទាន	ផ្ទៃដី (ហិកតា)	ភាគរយ
High Productivity Soil	៨២២	៨,៤៤
Low Productivity Soil	៨.៩១៥	៩១,៥៦
សរុបរួម	៩៧៣៧	១០០

Draft

Draft

ផែនទី៥.២-ផែនទីឋានលេខា

ផែនទី ឋានលេខា ក្នុងតំបន់អភិវឌ្ឍដំណាំកៅស៊ូរបស់ក្រុមហ៊ុន ឌូងី សាយហ្គន ស្រុកចិត្របុរី ខេត្តក្រចេះ

ប្រភព៖ JICA Dataset 2002

ផែនទី៥.៣-ផែនទីភូគព្ភសាស្ត្រ



ប្រភព៖ JICA Dataset 2002

ផែនទីទី៥.៤-ផែនទីចំណាត់ថ្នាក់ប្រភេទដី



ប្រភព៖ JICA Dataset 2002

ផែនទី៥.៥-ផែនទីចំណាត់ថ្នាក់ផលិតភាពដី



ប្រភព៖ DANIDA 2002

៥.១.៥ ចំណាត់ថ្នាក់ទីជម្រាល ការហូរច្រោះ និងការប្រើប្រាស់ដី

៨. យោងតាមការអង្កេតលើចំណាត់ថ្នាក់ទីជម្រាល (Slope Classification) ដីសម្បទាននេះមានទីជម្រាល ០៥ប្រភេទគឺៈ

៩. **ចំណាត់ថ្នាក់ទី១ៈ** ០-០,៥៧ដឺក្រេ មានទំហំ ៨.៦៩៨ហិកតា ស្មើនឹង៨៩,៣៣ភាគរយ នៃផ្ទៃដីសរុប ជាសណ្ឋានដីដែលមានលក្ខណៈរាបស្មើ។ ផ្អែកលើទស្សនៈនៃការអភិរក្សទឹកនិងដី ការប្រើប្រាស់ដីតំបន់នេះមានលក្ខណៈទូលំទូលាយ សម្រាប់ដំណាំស្រូវដំណាំកសិកម្ម និងព្រៃឈើ។

១០. **ចំណាត់ថ្នាក់ទី២ៈ** ០,៥៨-១,៦៤ដឺក្រេ មានទំហំ ៥៣៨ហិកតា ស្មើនឹង៥,៥២ភាគរយ នៃផ្ទៃដីសរុប ជាសណ្ឋានដីដែលមានលក្ខណៈរាបស្មើ មិនតម្រូវឲ្យមានការអភិរក្សទឹកនិងដីទេ។ ផ្អែកលើទស្សនៈនៃការអភិរក្សទឹកនិងដី ការប្រើប្រាស់ដីតំបន់នេះមានលក្ខណៈទូលំទូលាយ អាចប្រើប្រាស់សម្រាប់កសិកម្ម និងព្រៃឈើ។

១១. **ចំណាត់ថ្នាក់ទី៣ៈ** ១,៦៥-៣,២៩ដឺក្រេ មានទំហំ ២៦១ហិកតា ស្មើនឹង ២,៦៨ភាគរយ នៃផ្ទៃដីសរុប មានលក្ខណៈចោទបន្តិចម្តងៗ ហើយចោទធំជាងចំណាត់ថ្នាក់ទី២ខាងលើ។ ផ្អែកលើទស្សនៈនៃការអភិរក្សទឹកនិងដី ការប្រើប្រាស់ដីតំបន់នេះអាចមានលក្ខណៈជាការដាំឈើបែបពាណិជ្ជកម្ម វាលស្មៅ និងការដាំរួមរវាងឈើ និងដំណាំកសិកម្ម។

១២. **ចំណាត់ថ្នាក់ទី៤ៈ** ៣,៣-៥,៤៣ដឺក្រេ ចំនួន ១៦១ហិកតា ស្មើនឹង ១,៦៥ភាគរយ នៃផ្ទៃដីសរុប ជាសណ្ឋានដីនេះមានលក្ខណៈចោទល្មម។ សណ្ឋានដីប្រភេទនេះមិនសូវរងភាពរេចរឹលដោយការហូរច្រោះទេ។ ការប្រើប្រាស់ដីតំបន់នេះ គឺសំរាប់ការអភិរក្ស ឬគំរោងដាំព្រៃ (ដាំកៅស៊ូ) ប្រសិនបើអនុវត្តវិធានការអភិរក្សបានខ្ជាប់ខ្ជួន។

១៣. **ចំណាត់ថ្នាក់ទី៥ៈ** ៥,៤៤-៩,១១ដឺក្រេ ចំនួន ៨០ហិកតា ស្មើនឹង ០,៨២ភាគរយ នៃផ្ទៃដីសរុប ជាសណ្ឋានដីនេះមានលក្ខណៈចោទបង្គួរ។ សណ្ឋានដីប្រភេទនេះងាយប្រឈមនឹងភាពរេចរឹលដោយការហូរច្រោះ។ ត្រូវប្រើប្រាស់ដីតំបន់នេះ សំរាប់គោលដៅនៃការអភិរក្ស ឬគំរោងដាំព្រៃ តែត្រូវអនុវត្តវិធានការអភិរក្សឲ្យបានខ្ជាប់ខ្ជួន (**ផែនទី៥.៦-ផែនទីចំណាត់ថ្នាក់ទីជម្រាល**)ដូចខាងក្រោម។

តារាង៥-៧ៈ ចំណាត់ថ្នាក់ទីជម្រាលនៅក្នុងតំបន់ដីសម្បទាន

ចំណាត់ថ្នាក់ទីជម្រាលដីនៅក្នុងតំបន់ដីសម្បទាន	ផ្ទៃដី (ហិកតា)	ភាគរយ
០-០,៥៧°	៨.៦៩៨	៨៩,៣៣
០,៥៨-១,៦៤°	៥៣៨	៥,៥២
១,៦៥-៣,២៩°	២៦១	២,៦៨
៣,៣០-៥,៤៣°	១៦១	១,៦៥
៥,៤៤-៩,១១°	៨០	០,៨២
សរុបរួម	៩៧៣៧	១០០

Draft

ផែនទី៥.៦-ផែនទីចំណាត់ថ្នាក់ទីជម្រាល



ប្រភព៖ MRC 2007

Draft

៥.១.៦ របបជលវិទ្យា

១៤. តាមការពិនិត្យទៅលើផែនទីប្រព័ន្ធផ្លូវទឹក (**ផែនទី៥.៧-ផែនទីប្រព័ន្ធផ្លូវទឹក**) បង្ហាញថា នៅក្នុងតំបន់ដីសម្បទាននេះសម្បូរណ៍ប្រភពទឹកស្រទាប់លើជាមធ្យម ដោយក្នុងនោះមានប្រព័ន្ធទន្លេសំខាន់មួយមានឈ្មោះហៅថា ព្រែកទេរ (ចំណុចនិយាមកា ៦៤៣៦៦៥-១៣៧២៦៧០)។ ព្រែកទេរនេះ មានទឹកដក់គ្រប់រដូវកាល មានទំហំប្រមាណ ១៨ម ស្ថិតនៅតាមព្រំខាងកើតហូរសំយ៉ុងចុះមកខាងត្បូង និងហូរចេញផុតពីដីសម្បទាននៅចំណុចភូមិស្រែននៅជ្រុងខាងលិចចុងខាងត្បូង ហើយហូរចាក់ចូល ទៅទន្លេមេគង្គនៅត្រង់ចំណុចនិយាមកា ៦១៤៨៣៣-១៣៦៣២៧៣ ក្នុងចម្ងាយប្រមាណ ២២គ.ម ពីទីតាំងដីសម្បទាន។ ក្រុមការងារបានពិនិត្យឃើញមានអូរតូចៗចំនួន១០ ដែលអូរទាំងនេះខ្លះមានប្រភពនៅខាងក្រៅ និងខ្លះទៀតមានប្រភពនៅក្នុងដីសម្បទានផ្នែកខាងលិច។ មានដៃអូរតូចៗចំនួន០៥ ដែលជាដៃរបស់ព្រែកទេរ មានឈ្មោះគឺអូរធ្យូង (ចំណុចនិយាមកា៦៤០៤៤៦-១៣៨១៩៧៨), អូរប្រើម ឬអូរព្រាម (ចំណុចនិយាមកា ៦៣៩៥៧៣-១៣៨១២៦៨), អូរឈ្មូង (ចំណុចនិយាមកា ៦៣៨២៩៦-១៣៧៩៣ ០១) , ព្រែកព្រូស (ចំណុចនិយាមកា ៦៣៨៤៩៨-១៣៧៨៣០៥) និងអូរក្រុង (ចំណុចនិយាមកា ៦៤១[illegible]១ -១៣៧២៦៧០) ដែលហូរពុះកាត់ព្រំដីសម្បទាននៅភាគខាងជើងឆៀងខាងលិច ខាងលិច និងខាងត្បូង។ នៅខាងក្នុងដីសម្បទាននេះ អូរដែលមានទឹកគ្រប់រដូវមានប្រវែង ៩៥៩ម៉ែត្រ និងអូរដែលគ្មាន ទឹកនៅរដូវប្រាំងមានប្រវែង ៥៦.៩៣៣ម៉ែត្រ។

៥.១.៦.១ ប្រភពដែលអាចបង្កនៃភាពក្រខ្វក់ដល់ទឹក

១៥. តាមការអង្កេតជាក់ស្តែងនៅក្នុងរយៈពេលសិក្សាបានបង្ហាញថា បច្ចុប្បន្នមិនទាន់មានការបំពុលទឹកអ្វីគួរអោយចាប់អារម្មណ៍នៅក្នុងតំបន់នោះទេ (សូមពិនិត្យលទ្ធផលវិភាគទឹក) ពីព្រោះក្រុមហ៊ុនបានរក្សាព្រៃទ្រនាប់ប្រព័ន្ធផ្លូវទឹកបានត្រឹមត្រូវ។ ម៉្យាងវិញទៀត ក្រុមហ៊ុននៅមិនទាន់ធ្វើការឈូសឆាយ និងដាំរួចរាល់ជាស្ថាពរ ហើយប្រើប្រាស់ជីនៅទូទាំងដីសម្បទានទាំងមូលនៅឡើយ។ ប៉ុន្តែទៅថ្ងៃអនាគត ពោលគឺនៅពេលដែលមានការឈូសឆាយ និងដាំដុះរួចរាល់ នឹងមានការប្រើប្រាស់ជីច្រើន ដែលអាចបង្កឱ្យមានការបំពុលដល់គុណភាពទឹក ជាពិសេសនៅពេលដែលម្ចាស់គម្រោងមិនបានយកចិត្តទុកដាក់ក្នុងការគ្រប់គ្រងគុណភាពបរិស្ថានបានត្រឹមត្រូវទេនោះ (**ផែនទី៥.៨-ផែនទីបង្ហាញទីតាំងយកសំណាកទឹក និងឡូត៍នៃសាទត្រី**)។

Draft

ផែនទី៥.៧-ផែនទីប្រព័ន្ធផ្លូវទឹក



ប្រភព៖ River 2012, Dept. of LU, MLUPC

ផែនទីទី៥.៨-ផែនទីបង្ហាញទីតាំងយកសំណាកទឹក និងឡូត៍នេសាទត្រី



ប្រភព៖ GIS Unit of Forestry Administration

៥.២ លក្ខណៈទូទៅនៃធនធានជីវសាស្ត្រ

៥.២.១ សហគមន៍សារព័ន្ធរុក្ខជាតិ និងការប្រើប្រាស់ដី

១៦. កំណើតដើមនៃប្រភេទព្រៃទាំងអស់នៅក្នុងតំបន់សម្បទាននេះ គឺអាស្រ័យទៅនឹងអាកាសធាតុរបស់តំបន់ លក្ខណៈភូមិសាស្ត្រ សណ្ឋានដី និងសមាសភាពនៃប្រភេទឈើ ហើយប្រភេទព្រៃសំខាន់ៗទាំងនេះបានកើតឡើងដោយសារអនុប្រភេទជាច្រើនទៀត។ ឯកសារយោងដែលបានប្រើជាមូលដ្ឋាននៅក្នុងរយៈពេលនៃការសិក្សា និងអង្កេតក្នុងតំបន់នេះ គឺរូបភាពពីផ្កាយរណបរបស់ FA GIS Dataset ឆ្នាំ ២០០២, ២០០៦ និង២០១០ របស់រដ្ឋបាលព្រៃឈើ (**ផែនទី៥.៩-១១-ផែនទីប្រើប្រាស់ដី និងគម្របព្រៃឈើឆ្នាំ ២០០២, ២០០៦ និង ២០១០**)។ នៅក្នុងរយៈពេលនៃការវាយតំលៃអំពីអេកូឡូស៊ី និងពាណិជ្ជកម្មរបស់ព្រៃបានបញ្ជាក់ថា ស្ថានភាពអេកូឡូស៊ីនៅក្នុងតំបន់នេះត្រូវទទួលរងការរំខានធ្ងន់ធ្ងរ។ ឈើដែលមានតម្លៃពាណិជ្ជកម្មត្រូវបានដកហូតស្ទើរតែទាំងស្រុងអស់ហើយ។ ឧទាហរណ៍ជាក់ស្តែង បច្ចុប្បន្នប្រជាពលរដ្ឋនៅក្នុងតំបន់កំពុងតែប្រមូលផលឈើធ្វើកប្រភេទឈើលេខ-១ ពីក្នុងព្រៃល្បោះ ដែលការប្រើប្រាស់នេះអាចបញ្ជាក់អំពីការធ្លាក់ចុះដ៏ធ្ងន់ធ្ងររបស់ឈើពាណិជ្ជកម្មនៅក្នុងតំបន់នោះ។ ចំពោះប្រភេទឈើលេខ៣ និងឈើក្រៅលំដាប់ថ្នាក់មាននៅសេសសល់បង្គួរតែក៏ពុំមានអង្កត់ផ្ចិតធំដែរ។ ការសិក្សាអំពីការប្រែប្រួលស្ថានភាពសារពើរុក្ខជាតិក្នុងតំបន់សម្បទាននេះ ក្នុងចន្លោះឆ្នាំ ២០០២-២០១០ បានបង្ហាញថាៈ

- **ឆ្នាំ២០០២៖** តំបន់គំរោងវិនិយោគនេះមានសហគមន៍សារព័ន្ធរុក្ខជាតិពីរប្រភេទគឺ ព្រៃល្បោះ និងដីគ្មានព្រៃ។
- **ឆ្នាំ២០០៦៖** តំបន់សម្បទាននេះមានសហគមន៍សារព័ន្ធរុក្ខជាតិបួនប្រភេទគឺ ព្រៃពាក់កណ្តាលស្រោង ព្រៃល្បោះ ព្រៃគុម្ពោតស្ងួត និងដីគ្មានព្រៃ។
- **ឆ្នាំ២០១០៖** តំបន់សម្បទាននេះមានសហគមន៍សារព័ន្ធរុក្ខជាតិបួនប្រភេទគឺ ព្រៃពាក់កណ្តាលស្រោង ព្រៃល្បោះ ព្រៃគុម្ពោតស្ងួត និងដីគ្មានព្រៃ។

៥.២.២ ស្ថានភាព និងការប្រែប្រួលរបស់គម្របព្រៃឈើ

១៧. តាមរយៈការវិភាគអំពីការប្រែប្រួលនៃស្ថានភាពរបស់គំរបព្រៃក្នុងតំបន់ដែនសម្បទានទាំងមូលនៅក្នុងរយៈពេល៨ឆ្នាំចុងក្រោយដោយប្រើប្រាស់ប្រព័ន្ធទិន្នន័យរបស់ FA GIS Dataset ២០០២,២០០៦ និង ២០១០ បានបង្ហាញអោយដឹងថា ស្ថានភាពនៃការប្រើប្រាស់ដី និងគំរបព្រៃមានការប្រែប្រួលគួរអោយចាប់អារម្មណ៍ (**ផែនទី៩-១១-ផែនទីប្រើប្រាស់ដី និងគម្របព្រៃឈើឆ្នាំ ២០០២, ២០០៦ និង ២០១០**)។ ដំណើរការបំរែបំរួលនេះមានបង្ហាញជូននៅក្នុងតារាង ៥-៨ ខាងក្រោម៖

តារាង៥-៨៖ ដំណើរប្រែប្រួលស្ថានភាពនៃការប្រើប្រាស់ដី និងគម្របព្រៃឈើរយៈពេល៨ឆ្នាំ

ប្រភេទព្រៃ	២០០២	២០០៦	២០១០
ព្រៃពាក់កណ្តាលស្រោង (ហិកតា)	-	២៩៩	២៩៩
ព្រៃល្បោះ (ហិកតា)	៩២៤៩	៨៨៣៤	៧០៤៣
ព្រៃគុម្ពោតស្ងួត (ហិកតា)	-	៧២	៧២
ដីគ្មានព្រៃ (ហិកតា)	៤៨៨	៥៣២	២៣២៣
សរុប	៩៧៣៧	៩៧៣៧	៩៧៣៧

Draft

ផែនទី៥.៩-ផែនទីប្រើប្រាស់ដី និងគម្របព្រៃឈើឆ្នាំ ២០០២

ផែនទី គម្របព្រៃឈើឆ្នាំ ២០០២ ក្នុង ទំហំបន់អភិវឌ្ឍដំណាំកៅស៊ូរបស់ក្រុមហ៊ុន ឌុងធី សាយហ្គន ស្រុកចិត្របុរី ខេត្តក្រចេះ



ប្រភព៖ GIS Unit of Forestry Administration

ផែនទី៥.១០-ផែនទីប្រើប្រាស់ដី និងគម្របព្រៃឈើឆ្នាំ ២០០៦



Draft

ប្រភព៖ GIS Unit of Forestry Administration

ផែនទី៥.១១-ផែនទីប្រើប្រាស់ដី និងគម្របព្រៃឈើឆ្នាំ ២០១០



ប្រភព៖ GIS Unit of Forestry Administration

Draft

៥.២.៣ តំបន់ប្រព័ន្ធមជ្ឈដ្ឋានហៃឡ្រនអាងទន្លេមេគង្គខាងកើត

១៨. ដីគំរោងអភិវឌ្ឍន៍របស់ក្រុមហ៊ុន **ដូទីសាយហ្គន-ប៊ិញហឿក (អេស ប៊ី ខេ)** ស្ថិតនៅក្នុងផ្នែកខាងលិចនៃតំបន់អាងទន្លេមេគង្គខាងកើត ដែលក្នុងនោះរាប់បញ្ចូលទាំងតំបន់ផលិតកៅស៊ូសំខាន់ៗ បង្កើតបានជាប្រព័ន្ធមជ្ឈដ្ឋានហៃ្សនរបស់តំបន់អាងទន្លេមេគង្គខាងកើត។ តំបន់អាងទន្លេមេគង្គខាងកើតនេះមានព្រំប្រទល់ផ្នែកខាងលិចជាប់នឹងតំបន់ដីទំនាបកណ្តាល ខាងជើងជាប់នឹងតំបន់ជួរភ្នំអណ្ណាមកណ្តាល ខាងកើតជាប់នឹងចុងខាងត្បូងនៃអណ្ណាមកណ្តាល និងខាងត្បូងជាប់នឹងតំបន់ជួរភ្នំអណ្ណាមខាងត្បូង ដែលជាអាងស្តុកទឹកសំខាន់មុនហូរចាក់ចូលទៅក្នុងទន្លេមេគង្គ។

១៩. ប្រព័ន្ធមជ្ឈដ្ឋានហៃឡ្រនរបស់តំបន់នេះ អាចកំណត់បានតាមរយៈរបបទឹកភ្លៀងទាប (១.២០៦,១-២.២២១,៣ម.ម) និងដីដែលមានប្រភេទដូចគ្នា។ ខុសពីប្រព័ន្ធមជ្ឈដ្ឋានហៃឡ្រនតំបន់ពាយ័ព្យ ដែលភាគច្រើនគ្របដណ្តប់ទៅដោយដីដីជាតិដែលមានអាយុផ្សេងៗគ្នា លក្ខណៈរបស់រុក្ខជាតិ និងសារព័ន្ធរបស់វានៅក្នុងព្រៃពាក់កណ្តាលស្រោងនៅក្នុងតំបន់អាងទន្លេមេគង្គខាងកើតភាគច្រើនគ្របដណ្តប់ទៅដោយ *Irvingia, Mimosops, Pahudia, Pterocarpus, Shorea, Sindora and Vitex* (Legris & Blasco, 1972; Rollet 1972)។

៥.២.៤ សក្តានុពលភាពរបៀងសត្វព្រៃនៅក្នុងតំបន់

២០. ក្រុមហ៊ុន **ដូទីសាយហ្គន-ប៊ិញហឿក (អេស ប៊ី ខេ)** បានរក្សាទុកផ្ទៃដីព្រៃសរុបចំនួន១.១៧៦ហិកតា និងព្រៃទ្រនាប់តាមដងអូរ ៥៩៥ហិកតា។ ការរក្សាទុកនូវផ្ទៃដីព្រៃនិងតំបន់ទ្រនាប់ប្រព័ន្ធផ្លូវទឹក ដើម្បីធ្វើការអភិរក្សនេះ មិនត្រឹមតែអាចការពារការខូចខាតផ្នែកបរិស្ថានប៉ុណ្ណោះទេ តែថែមទាំងអាចដើរតួនាទីជាតំបន់របៀងសម្រាប់សត្វព្រៃតូចៗរស់នៅ និងធ្វើបំលាស់ទីទៀតផង (**ផែនទី៥.១២-ផែនទីបែងចែកការប្រើប្រាស់ដីរបស់ក្រុមហ៊ុន**)។

៥.៣ ធនធានសង្គម និងសេដ្ឋកិច្ច

៥.៣.១ ការអភិវឌ្ឍន៍សេដ្ឋកិច្ច

២១. ក្រៅពីក្នុងទីរួមខេត្ត ដីដែលនៅតាមសងខាងបណ្តោយផ្លូវជាតិភាគច្រើនគឺជនបទ។ ប្រជាជនរស់នៅក្នុងភូមិក្បែរដីសម្បទានរបស់ក្រុមហ៊ុន **ដូទីសាយហ្គន-បិញហឿក (អេស ប៊ី ខេ)** មានភូមិអាលច ភូមិស្រែនន (ភូមិឧបសម្ព័ន្ធរបស់ភូមិអាលច) ភូមិប្អៀរ ភូមិក្រសាំង ភូមិស្វាយជ្រុំ ភូមិថ្មី និងភូមិត្នោត (ចំណុចយ៉ៃជាភូមិឧបសម្ព័ន្ធរបស់ភូមិត្នោត)។ ក្រៅពីរបរធ្វើស្រែចំការ ជាពិសេសក្រោយពេលប្រមូលផលស្រូវរួច មានគ្រួសារខ្លះទៅកាប់អុស និងឈើសំណង់ផ្សេងៗ លក់ឱ្យទៅឈ្មួញកណ្តាលដែលមកទិញដល់កន្លែង ហើយមានគ្រួសារខ្លះប្រកបរបរលក់ដូរបន្តិចបន្តួចតាមដងផ្លូវលំក្នុងឃុំ និងតាមភូមិនីមួយៗ សម្រាប់បំរើសេចក្តីត្រូវការក្នុងភូមិ-ឃុំ និងអ្នកធ្វើដំណើរ។ មានគ្រួសារខ្លះទៀតដាំដំណាំ និងបន្លែបង្ការបន្តិចបន្តួចនៅក្បែរៗផ្ទះ ឬតាមមាត់អូរនានាសម្រាប់ផ្គត់ផ្គង់សេចក្តីត្រូវការក្នុងគ្រួសារ និងដោះដូរជាមួយអ្នកភូមិផងរបងជាមួយ។

២២. ការសិក្សាបានបង្ហាញថា ប្រភពចំណូលរបស់ពួកគាត់គឺការធ្វើស្រែចំការ (ទិន្នផលស្រូវជាមធ្យមពី ១-៣,៥តោន លក់បានតម្លៃពី ៧០០-១០០០រៀលក្នុងមួយគីឡូក្រាម)។ អ្នកខ្លះធ្វើកម្មករក្នុងក្រុមហ៊ុនចំការកៅស៊ូ បានទទួលប្រាក់កម្រៃ ១៥០០០-២០០០០រៀលក្នុងមួយថ្ងៃ។ ក្រៅពីនេះ ពួកគាត់បានចិញ្ចឹមសត្វ (គោ ក្របី ជ្រូក មាន់ ទា) ដោយជ្រូករស់មួយក្បាលអាចលក់បានតម្លៃពី ៤០-៤៥ម៉ឺនរៀល ឬតម្លៃ ៩,០០០រៀលក្នុងមួយគីឡូក្រាម ឯមាន់ និងទា អាចលក់បានតម្លៃ១៨.០០០-២០.០០០រៀលក្នុងមួយគីឡូក្រាម។ ចំពោះគ្រួសារដែលអាស្រ័យតែលើការធ្វើស្រែ ពួកគាត់មិនមានជីវភាពធូរធារឡើយ មានគ្រួសារខ្លះគ្មានស្បៀងអាហារហូបគ្រប់គ្រាន់ផង។

២៣. ចំពោះការប្រើប្រាស់សេវាសាធារណៈមាន៖ គមនាគមន៍ ការផ្គត់ផ្គង់ទឹកស្អាត អគ្គិសនី អប់រំ និងសុខាភិបាល នៅក្នុងសហគមន៍ទាំងនេះស្ថិតនៅក្រោមបន្ទាត់នៃតម្រូវការ បើប្រៀបធៀបជាមួយនឹងគ្រួសារសហគមន៍នៅក្នុងតំបន់ដទៃទៀតជុំវិញទីរួមខេត្តក្រចេះ។

២៤. ជាទូទៅ ប្រជាពលរដ្ឋក្នុងតំបន់នេះភាគច្រើនទទួលបានការប្រើប្រាស់ប្រព័ន្ធផ្លូវគមនាគមន៍ល្អបង្គួរ លើកលែងតែអ្នកភូមិប្អៀរប៉ុណ្ណោះ ដែលពិបាកក្នុងការធ្វើដំណើរ ពីព្រោះភូមិនេះស្ថិតនៅដាច់ស្រយាលពីភូមិដទៃទៀត។ ចំពោះការប្រើប្រាស់ទឹកស្អាតរបស់ប្រជាពលរដ្ឋភាគច្រើន (លើកលែងតែភូមិអាលចចេញ) គឺនៅមានកម្រិតទាបខ្លាំងណាស់ ជាពិសេសគឺភូមិស្វាយជ្រុំ ភូមិស្រែនន និងចំណុចយ៉ៃ។ ការសិក្សាបានបង្ហាញថា ការប្រើប្រាស់អគ្គិសនីរបស់អ្នកភូមិដែលរស់នៅតាមដងផ្លូវ (ជាពិសេសគឺភូមិអាលច) មានលក្ខណៈល្អបង្គួរ (ប្រើភ្លើងឯកជន និងភ្លើងអាគុយ)។ ចំណែកនៅភូមិស្វាយជ្រុំ ភូមិប្អៀរ ចំណុចយ៉ៃ និងភូមិស្រែនន ការរស់នៅមានលក្ខណៈអន់ថយបន្តិច ដោយពុំមានការផ្គត់ផ្គង់អគ្គិសនីជាមូលដ្ឋានទេ មានតែ ១០-២០% ប៉ុណ្ណោះប្រើប្រាស់អាគុយ ក្រៅពីនេះគឺប្រើប្រាស់ប្រេង និងចន្លុះសម្រាប់បំភ្លឺនៅពេលយប់។ រីឯប្រភពថាមពលសំខាន់សម្រាប់ការចំអិនអាហាររបស់ពួកគាត់ គឺអុសដែលអាចរកបានពីក្បែរៗភូមិ និងពីក្នុងតំបន់ដីសម្បទាន។ ចំណែកឯការទទួលយកសេវាអប់រំ និងសុខាភិបាលក៏នៅមានកម្រិតទាបខ្លាំងដែរ ជាពិសេសគឺប្រជាពលរដ្ឋនៅក្នុងភូមិប្អៀរ ស្រែនន និងចំណុចយ៉ៃ។

Draft

៥.៣.២ ធនធានសង្គម និងវប្បធម៌

៥.៣.២.១ របាយប្រជាជន

២៥. ដីសម្បទានរបស់ក្រុមហ៊ុន **ដូទីសាយហ្គន-ប៊ីញហឿក (អេស ប៊ី ខេ)** មានទីតាំងភូមិសាស្ត្ររដ្ឋបាល ស្ថិតក្នុងឃុំថ្មី និងឃុំកន្ទួត ស្រុកចិត្របុរី ខេត្តក្រចេះ។ យោងឯកសារព័ត៌មានស្តីពីស្ថានភាពឃុំឆ្នាំ ២០១៣ ឃុំថ្មីមានភូមិចំនួន១០គឺ៖ (១) ភូមិថ្មី (២) ភូមិត្នោត (៣) ភូមិស្វាយជ្រុំ (៤) ភូមិល្បៀ (៥) ភូមិប្រនោល (៦) ភូមិខ្លាច (៧) ភូមិក្រសាំង (៨) ភូមិមានជ័យ (៩) ភូមិទ្រាប និង (១០) ភូមិវាលសំបូរ។ យោងតាមស្ថិតិប្រជាពលរដ្ឋឆ្នាំ ២០១៤ បង្ហាញថាភូមិទាំងអស់នេះមានចំនួនគ្រួសារ និងប្រជាពលរដ្ឋសរុប ដូចមានបញ្ជាក់ជូនក្នុងតារាង ៥-៩ ខាងក្រោម:

តារាង ៥-៩៖ តារាងស្ថិតិប្រជាពលរដ្ឋឆ្នាំ ២០១៤ រស់នៅក្នុងឃុំថ្មី ស្រុកចិត្របុរី ខេត្តក្រចេះ

លរ.	ឈ្មោះភូមិ	ចំនួនគ្រួសារ	ប្រជាពលរដ្ឋសរុប (នាក់)	ស្រីសរុប (នាក់)
១	ថ្មី	២៤៦	១.២៧២	៦៥២
២	ត្នោត	១៤៣	៨៤៤	៤៣២
៣	ស្វាយជ្រុំ	៧៤	៤២៩	២១០
៤	ល្បៀ	២២៩	១.២១៤	៦១៩
៥	ប្រណោល	២០៥	១.០៦៣	៥៤០
៦	ខ្លាច	៣៩៨	១.៩០៧	៩៣២
៧	មានជ័យ	១២២	៦៥២	៣១៨
៨	ក្រសាំង	១២១	៦២៦	៣០៩
៩	ទ្រាប	៤០៤	២.២៣៤	១.១៣៣
១០	វាលសំបូរ	១៨៣	៩៦៦	៤៩៣
សរុបរួម		២.១២៥	១១.២០៧	៥.៦៣៨

ប្រភព៖ តារាងសម្រង់ព័ត៌មានស្ថិតិប្រជាពលរដ្ឋក្នុងឃុំថ្មីឆ្នាំ២០១៤

២៦. ចំណែកឃុំកន្ទួតមានភូមិចំនួន ០៥ និងភូមិឧបសម្ព័ន្ធ ០១ គឺ៖ (១) ភូមិកន្ទួត (២) ភូមិច្រវ៉ា (៣) ភូមិអន្លង់វៀន (៤) ភូមិអាលច (មានភូមិឧបសម្ព័ន្ធមួយឈ្មោះភូមិស្រែនន) និង (៥) ភូមិស្រែនន ដែលចំនួនគ្រួសារ និងប្រជាពលរដ្ឋសរុប ដូចមានបញ្ជាក់ជូនក្នុងតារាង **៥-១០** ខាងក្រោម:

តារាង ៥-១០៖ តារាងស្ថិតិប្រជាពលរដ្ឋឆ្នាំ ២០១៤ រស់នៅក្នុងឃុំកន្ទួត ស្រុកចិត្របុរី ខេត្តក្រចេះ

ល.រ.	ឈ្មោះភូមិ	ចំនួនគ្រួសារ	ប្រជាពលរដ្ឋសរុប(នាក់)	ស្រីសរុប(នាក់)
១	កន្ទួត	៣០៥	១.៥៤៦	៧៧៧
២	ច្រវ៉ា	២៧៣	១.២២៨	៦១៩
៣	អន្ទង់រៀន	៣៣៩	១.៤២៩	៧១០
៤	អាលច	៣៣៣	១.៥៨៥	៧១១
៥	ស្រែនន	២២៣	៩៩៨	៥៣២
សរុបរួម		**១.៤៧៣**	**៦.៧៨៦**	**៣.៣៤៩**

ប្រភព៖ តារាងសម្រង់ព័ត៌មានស្ថិតិប្រជាពលរដ្ឋក្នុងឃុំកន្ទួតឆ្នាំ២០១៤

២៧. លំនាំនៃការតាំងទីលំនៅក្នុងតំបន់នេះ មានលក្ខណៈប្រមូលផ្ដុំជាភូមិករក្នុងព្រៃឃ្លាតគ្នាឆ្ងាយៗពីមួយទៅមួយ ក្នុងនោះសង្កេតឃើញមានភូមិរៀរ ស្រែនន និងចំណុចយ៉ៃ។ ភូមិទាំងនេះស្ថិតនៅជាប់ទីតាំងដីសម្បទានរបស់ក្រុមហ៊ុន តែផ្លូវចូលទៅភូមិជាផ្លូវរទេះ និងផ្លូវលំក្នុងព្រៃ (អាចជិះម៉ូតូ ឬដើរដោយជើង) តែនៅរដូវវស្សាផ្លូវនេះមានសភាពទ្រុឌទ្រោម ពិបាកធ្វើដំណើរ។

២៨. ការសិក្សាបានបង្ហាញថា នៅក្នុងតំបន់ដីសម្បទានរបស់ក្រុមហ៊ុន **ដូទីសាយហ្គន-ប៊ីញហ្វៀក (អេស ប៊ី ខេ)** ពុំមានសំណង់ប្រវត្តិសាស្ត្រ ឬសម្បត្តិវប្បធម៌ ឬកន្លែងដែលជាទីសក្ការៈបូជា របស់សហគមន៍មូលដ្ឋានទេ។

៥.៣.២ .២ លក្ខណៈប្រជាសាស្ត្រ

២៩. ការសិក្សាបានបង្ហាញឱ្យឃើញថា ក្នុងចំណោមប្រជាពលរដ្ឋរស់នៅក្នុងឃុំថ្មី និងឃុំកន្ទួតមានជនជាតិដើមភាគតិចជា ក្នុង ខោញ និងក្ងួយប៉ុន្តែពួកគាត់ចេះនិយាយភាសាខ្មែរបានទាំងអស់គ្នា ចំណែកឯប្រពៃណីវប្បធម៌ និងសាសនាព្រះពុទ្ធ។

៣០. ទំនៀមទំលាប់ប្រពៃណី នៃការរស់នៅរបស់ប្រជាជនក្នុងតំបន់នេះមានលក្ខណៈប្រហាក់ប្រហែលគ្នានឹងប្រជាជនរស់នៅតំបន់ផ្សេងៗទៀតនៃស្រុកចិត្របុរីដែរ។ ឧទាហរណ៍ ដូចជាពិធីរៀបអាពាហ៍ពិពាហ៍គឺធ្វើតាមប្រពៃណីខ្មែរ ដោយការតុបតែង ឬសំអាងការខ្លួនកូនក្រមុំការប្រគុំភ្លេងប្រពៃណី សែនព្រេន និងការអញ្ជើញភ្ញៀវចូលរួមជប់លៀងសាយភោជន៍ ដើម្បីជូនពរនៅថ្ងៃមង្គលការរបស់កូនកំលោះកូនក្រមុំជាដើម។ តាមការរៀបរាប់របស់ប្រជាពលរដ្ឋតាមឃុំនិមួយៗ ដើម្បីទុកដាក់កូនចៅឱ្យមានគូរស្រករពួកគាត់ត្រូវចំណាយលុយអស់ប្រហែល៤.៦លានរៀល។ ក្រៅពីនោះប្រជាពលរដ្ឋរស់នៅក្បែរ ឬជិតតំបន់គម្រោងនៅមានជំនឿផ្សេងៗទៀត ដូចជា ការសែនព្រេន ជាន់អារក្ស អ្នកតាទឹក អ្នកតាដី អ្នកតាភ្នំជាដើម។

Draft

៣១. យោងតាមលក្ខណៈរស់នៅ និងការប្រកបរបរចិញ្ចឹមជីវិតដែលពឹងអាស្រ័យទៅលើការធ្វើស្រែ និងចំការនោះអាចបញ្ជាក់ឱ្យឃើញថា អ្នកដែលជាបង្គោលដើរតួសំខាន់ក្នុងការទ្រទ្រង់ជីវភាពគ្រួសារភាគច្រើនជាបុរសភេទ។ ទោះជាយ៉ាងណាក៏ដោយភាពចាំបាច់នៃការរស់នៅត្រូវតែមានការចូលរួមពីស្ត្រីផងដែរ។ ជាក់ស្តែងស្ត្រីបានចូលរួមយ៉ាងសំខាន់ក្នុងសកម្មភាពការងារគ្រួសារ នយោបាយ និងសង្គម។ ប៉ុន្តែប្រពៃណីទំនៀមទំលាប់ និងសង្គមរស់នៅរបស់ប្រជាជននៅតំបន់នេះ នៅមានលក្ខណៈអភិរក្សនិយម និងនៅប្រកាន់របៀបបុរាណច្រើន។ ក្នុងការប្រជុំពិគ្រោះយោបល់នេះ មានការចូលរួមជាច្រើន ទាំងបុរស និងស្ត្រី ដែលស្ថិតនៅក្នុងភាពជាអ្នកនៅលីវ អ្នករៀបការហើយ និងមួយចំនួនទៀតជាស្ត្រីមេម៉ាយ ហើយពួកគាត់ភាគច្រើនមានអាយុស្ថិតនៅចន្លោះពី១៨-៧០ឆ្នាំ។ ទោះបីជាសាលារៀនមាននៅគ្រប់ភូមិក្តីតែមានគ្រួសារខ្លះពួកគាត់មិនបានបញ្ជូនកូនទៅរៀនទេបានគ្រប់គ្នានៅឡើយទេ ដោយសារថាសាលានៅឆ្ងាយហើយផ្លូវមានការលំបាកនៅរដូវវស្សា និងបញ្ហាជីវភាពពួកគាត់មានកំរិតកំណត់នៅឡើយ។

៥.៣.៣ ស្ថានភាពផ្ទះសម្បែង និងទ្រព្យសម្បត្តិរបស់គ្រួសារ

៣២. ជាទូទៅប្រជាពលរដ្ឋក្នុងតំបន់នេះមានជីវភាពរស់នៅក្នុងកម្រិតមធ្យម។ ផ្ទះសម្បែងរបស់ពួកគាត់មានទំហំធំ ឬតូចគឺអាស្រ័យទៅនឹងលទ្ធភាពនិងចំនួនសមាជិកគ្រួសារ។ សង្កេតឃើញមានផ្ទះប្រក់ស្បូវនិងស្លឹក ច្រើនជាងគេ បន្ទាប់មកផ្ទះស័ង្កសី ចំណែកផ្ទះក្បឿងមានមិនច្រើនទេ។ ផ្ទះដែលមានទំហំតូចជាងគេគឺ២០ម² និងទំហំធំជាងគេគឺ ៩០ម² ជាផ្ទះដែលសង់ខ្ពស់ផុតពីដី។

៣៣. ប្រជាពលរដ្ឋទាំងនោះរស់នៅក្នុងភូមិចាស់ តាមផ្លូវចូលទៅក្រាលក្រួសក្រហម និងកន្លែងខ្លះជាផ្លូវលំធម្មតា ជាធម្មតាពួកគាត់ប្រើប្រាស់ ឡាន ម៉ូតូ កង់ ឬធ្វើដំណើរថ្មើរជើងតែម្តង។

៣៤. មធ្យោបាយអូសទាញក្នុងការធ្វើកសិកម្មនៅក្នុងឃុំទាំងពីរគឺពឹងផ្អែកទៅលើគោក្របី ហើយការធ្វើស្រែចំការរបស់ពួកគាត់នៅមានលក្ខណៈជាយថាផល។ ប្រជាពលរដ្ឋនិយមចិញ្ចឹមគោក្របីទុកជាកម្លាំងអូសទាញនិងទុកសម្រាប់លក់ផងដែរ។ តាមទិន្នន័យឃុំបានឱ្យដឹងថា ឃុំថ្មីមានគោសរុបចំនួន ៦.៥៩៨ក្បាល និងក្របីសរុបចំនួន ៣.៣០៤ក្បាល។ គ្រួសារចិញ្ចឹមជ្រូកសរុបចំនួន ១.០៥៩គ្រួសារ ចិញ្ចឹមមាន់សរុប ១.៧៧៧គ្រួសារ ចិញ្ចឹមទាសរុបចំនួន១៤០គ្រួសារ។ ចំពោះមធ្យោបាយផ្សេងៗ មានដូចជា រថយន្តតូចប្រើប្រាស់ក្នុងគ្រួសារ ០៩គ្រឿង រថយន្តកែច្នៃ ០២គ្រឿង រថយន្តដឹកទំនិញធុនតូច ០៥គ្រឿង រទេះគោមាន៣៦៩រទេះ កង់ ២០៥គ្រឿង ម៉ូតូមានចំនួន ៧៩៤គ្រឿង ម៉ាស៊ីនកិនស្រូវខ្នាតតូច ០៧កន្លែង ម៉ាស៊ីនច្រូតនិងបោកស្រូវ ០៦គ្រឿង ម៉ាស៊ីនបោកស្រូវមាន ៧៦គ្រឿង ម៉ាស៊ីនគោយន្តមាន ២១គ្រឿង ត្រាក់ទ័រមាន ២គ្រឿង កាណូតដឹកទំនិញធុនតូច ០២គ្រឿង ទូកម៉ាស៊ីនសម្រាប់នេសាទ ០៣គ្រឿង និងទូកអុំ-ចែវសម្រាប់នេសាទ ៥៥គ្រឿង កន្លែងបញ្ចូលអាគុយមាន ៤កន្លែង។

៣៥. ឃុំកន្ទួតមានគោសរុបចំនួន ៤.២០៧ក្បាល ក្របី ២៥៤ក្បាល ចិញ្ចឹមជ្រូកសរុបចំនួន ៨២៣ក្បាល មាន់សរុប ៤.៦០៤ក្បាល ចិញ្ចឹមទាសរុបចំនួន ៩៤១ក្បាល។ ចំពោះមធ្យោបាយផ្សេងៗក្នុងឃុំកន្ទួត មានដូចជា រថយន្តដឹកទំនិញធុនតូច ០៧គ្រឿង រថយន្តដឹកទំនិញធុនធំ ១០គ្រឿង រថយន្តគ្រួសារ ៣៣គ្រឿង គ្រឿងយន្ត ឬគ្រឿងចក្រផ្សេងៗ ០៥គ្រឿង រទេះគោមានចំនួន ៥៩រទេះ កង់មានចំនួន ៤១៥គ្រឿង

ម៉ូតូមានចំនួន ៧០៨គ្រឿង កាណូតដឹកទំនិញធុនធំ ០១គ្រឿង កាណូតដឹកទំនិញធុនតូច ០៩គ្រឿង និងទូកអុំ-ចែវសម្រាប់នេសាទ ០៦គ្រឿង ម៉ាស៊ីនកិនស្រូវខ្នាតតូច ០៣កន្លែង ម៉ាស៊ីនបោកស្រូវមាន ២៩គ្រឿង ម៉ាស៊ីនច្រូតនិងបោកស្រូវ ០២គ្រឿង ម៉ាស៊ីនគោយន្តមាន ៣៧គ្រឿង ត្រាក់ទ័រមាន ០១គ្រឿង ម៉ាស៊ីនស្ទូងស្រូវ ១៥គ្រឿង កន្លែងបញ្ចូលអាគុយមាន ០៤កន្លែង។

៥.៣.៤ ប្រភពធនធានធម្មជាតិ និងលទ្ធភាពនៃការទទួលយកធនធានធម្មជាតិ

៣៦. ធនធានព្រៃឈើដែលប្រជាជនទទួលយកបានមានដូចជា ឈើមូល ឬស្សី ទំពាំង ផ្សិត និង នេសាទត្រីបន្តិចបន្តួចនៅតាមអូរ ដៃព្រែក និងតាមព្រែកទេរ ជាដើម។ តាមការសាកសួរពីប្រជាជនមូលដ្ឋាន បានអោយដឹងថា ធនធានព្រៃឈើមានការធ្លាក់ចុះយ៉ាងខ្លាំងក្នុងអំឡុងពេល២ទស្សវត្សចុងក្រោយនេះ ដោយសារការកាប់ព្រៃយ៉ាងអានាធិបតេយ្យ ហើយបច្ចុប្បន្ននេះឈើដែលមានតំលៃពាណិជ្ជកម្មគឺគ្មាននៅសេសសល់ទៀតទេ (តាមការអះអាងរបស់ប្រជាជនដែលបានចូលរួមពិគ្រោះយោបល់)។

៥.៣.៥ ការគ្រប់គ្រងការប្រើប្រាស់ដី និងការស្នើសុំចុះបញ្ជីដីធ្លីរបស់ក្រុមហ៊ុន

៣៧. ក្រុមហ៊ុន **ដូទីសាយហ្គន-ប៊ីញហឿក (អេស ប៊ី ខេ)** មានជាប់ពាក់ព័ន្ធនឹងភូមិចំនួន ០៣ គឺ **(១)** ភូមិអាលច មាន ២៣៣ក្បាលដី ស្មើនឹង ៤៦៨,២៣៧៦ហិកតា **(២)** ភូមិភ្លៀរ មាន ៧៦ក្បាលដី ស្មើនឹង ១២១,១៦១៩ហិកតា និង **(៣)** ភូមិស្វាយជ្រុំ មាន ៥១ក្បាលដី ស្មើនឹង ១៣១,៤២ហិកតា (**ផែនទី៥-១៣ ផែនទីបង្ហាញពីការកំណត់ទំហំក្បាលដី និងផ្ទៃដីពាក់ព័ន្ធជាមួយប្រជាពលរដ្ឋ**) ដែលដីពាក់ព័ន្ធទាំងអស់នេះស្ថិតនៅក្នុងព្រំដី (ដែនសម្បទាន) របស់ក្រុមហ៊ុន។ កន្លងមកក្រុមហ៊ុនបានគោរពតាមបទបញ្ជា ០១ របស់រាជរដ្ឋាភិបាល សហការណ៍ជាមួយក្រុមនិស្សិតស្ម័គ្រចិត្តរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** បានចុះទៅធ្វើការកាត់ដីមួយចំនួនចេញរួចហើយ មានដូចជា៖ អនុតំបន់ទី-១ មានចំនួន១៨៥,៤១ហិកតា អនុតំបន់ទី-២ មានចំនួន ២៦៣,៩២ហិកតា អនុតំបន់ទី-៣ មានចំនួន ១១៨,៣៦ហិកតា និងអនុតំបន់ទី៤ មានចំនួន ១៣១,៤២ហិកតា (**ផែនទី៥-១៤ -ផែនទីចុះបញ្ជីដោយនិស្សិតស្ម័គ្រចិត្ត**)។ ដីដែលបានកាត់ចេញទាំងអស់ខាងលើ គឺជាដីស្រែចម្ការ តែមិនមែនជាដីលំនៅដ្ឋានទេ។

៣៨. ប្រជាពលរដ្ឋភូមិភ្លៀរបានទាមទារដីចំនួន ៥៤៥,២៤ហិកតា និងដី៤៣០ម៉ែត្រពីបង្គោលឡាក់ មានចំនួនស្មើនឹង ១១,៥ហិកតា សម្រាប់ធ្វើផ្លូវថ្នល់សរុបស្មើនឹង៥៥៦,៧៤ហិកតា បន្ថែមទៀត ក្រុមហ៊ុនបានដោះស្រាយជាមួយនឹងអាជ្ញាធរដែនដីពាក់ព័ន្ធ និងប្រជាពលរដ្ឋភូមិភ្លៀរនេះចំនួន ១១ដង រួចមកហើយ។ នៅថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១៤ កន្លងទៅនេះ ដោយមានការសម្របសម្រួលពីអាជ្ញាធរខេត្ត ក្រុមហ៊ុនបានកាត់ដីចំនួន ៥៥៦,៧៤ហិកតា ឲ្យទៅប្រជាពលរដ្ឋភូមិភ្លៀររួចហើយ។ បច្ចុប្បន្នក្រុមហ៊ុនក៏បានធ្វើការដោះស្រាយបញ្ហាដីធ្លីពាក់ព័ន្ធក្នុងអនុតំបន់ទី៣ និងទី៤ ជាមួយប្រជាពលរដ្ឋបានចប់ជាស្ថាពរផងដែរ។

៣៩. ទន្ទឹមនឹងគោលជំហរដោះស្រាយបញ្ហាដីធ្លីឲ្យទៅប្រជាពលរដ្ឋ ប្រកបដោយស្មារតីសម្បទានខ្ពស់នេះ បច្ចុប្បន្នក្រុមហ៊ុនក៏មានការជម្រុញឲ្យមានការចុះបញ្ជីដីធ្លីរដ្ឋរបស់ក្រុមហ៊ុនផងដែរ ជាក់ស្តែងក្រុមហ៊ុន **ដូទីសាយហ្គន-ប៊ិញហ្វៀក (អេស ប៊ី ខេ)** បានធ្វើលិខិតទៅមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តក្រចេះ តាមលិខិតលេខៈ១១២០១៣ ដទ.បហ ចុះថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ២០១៣ ដើម្បីស្នើសុំចុះបញ្ជីដីធ្លីរដ្ឋរបស់ក្រុមហ៊ុន (ដូចមានបង្ហាញជូនភ្ជាប់ក្នុងឧបសម្ព័ន្ធ៥-២)។

Draft

ផែនទី៥.១៣ ផែនទីបង្ហាញពីការកំណត់ទំហំក្បាលដី និងផ្ទៃដីពាក់ព័ន្ធជាមួយប្រជាពលរដ្ឋ

ប្រភព៖ Dau Tu Saigon-Binh Phuoc (SBK) Co., Ltd

ផែនទី៥.១៤-ផែនទីបង្ហាញដីដែលបានវាស់វែង កាត់ចេញ និងចុះបញ្ជីដោយនិស្សិតស្ម័គ្រចិត្ត



ប្រភព៖ Dau Tu Saigon-Binh Phuoc (SBK) Co., Ltd

ផែនទី៥.១៥ ទីតាំងផ្ទៃដីដែលប្រជាពលរដ្ឋភូមិរៀវបានទាមទារ និងស្នើសុំដី៤៣០ម៉ែត្រពីបង្គោលឡាក់បន្ថែម

ផែនទី: ទីតាំងដែលប្រជាពលរដ្ឋបានស្នើរសុំបន្ថែម ៤៣០ម៉ែត្រពីបង្គោលឡាក់ ហើយបានចុះធ្វើក្រវ៉ាត់ព្រំរួចរាល់ជាក់ស្តែង



ប្រភព៖ Dau Tu Saigon-Binh Phuoc (SBK) Co., Ltd

៥.៣.៦ បន្ទាត់ និងអត្រានៃភាពក្រីក្រនៅក្នុងតំបន់

៤០. យោងតាមតាមទិន្នន័យរបស់ "ការអង្កេតសេដ្ឋកិច្ចសង្គមកម្ពុជាឆ្នាំ ២០០៩" CSES (Cambodian Socio-Economic Survey, 2009), និងជំរឿនប្រជាសាស្ត្រទូទៅ ឆ្នាំ ២០០៨ បង្ហាញអោយឃើញថា ប្រជាពលរដ្ឋរស់នៅក្នុងឃុំថ្មី និងឃុំកន្ទួត ស្រុកចិត្របុរី ខេត្តក្រចេះ មានអត្រានៃភាពក្រីក្រ ៥០ភាគរយ និង ៥២ភាគរយ ផ្សេងៗពីគ្នា។ ការសិក្សាបានបង្ហាញថា ចំណាយសរុប ឬកម្រិតបន្ទាត់នៃភាពក្រីក្រ (Net Consumption Expenditure or Poverty Line Rate) និងចំណាយសម្រាប់អាហារ ឬកម្រិតបន្ទាត់នៃភាពក្រីក្រសម្រាប់អាហារ (Food Consumption Expenditure or Food Poverty Line) គឺមានលក្ខណៈដូចគ្នានៅក្នុងប្រទេសកម្ពុជាទាំងមូលពោលគឺ ៤៣១៤,៧៥រៀល/ម្នាក់/ម្នាក់ ចំពោះ Poverty Line និង២៧៧៨,៧០រៀល/ម្នាក់/ថ្ងៃ ចំពោះFood Consumption Expenditure or Food Poverty Line ។

តារាង៥-១១៖អាត្រានៃភាពក្រីក្ររបស់ប្រជាពលរដ្ឋក្នុងឃុំថ្មី និងឃុំកន្ទួត ស្រុកចិត្របុរី ខេត្តក្រចេះ

លេខកូដ	ខេត្ត	ស្រុក	ឃុំ	ចំនួនប្រជាជន	អត្រានៃភាពក្រីក្រ
១០០៦១០	ក្រចេះ	ចិត្របុរី	ថ្មី	១០.៤៩៩	៥០
១០០៦០៤	ក្រចេះ	ចិត្របុរី	កន្ទួត	៦.១២២	៥២

ប្រភព៖ ការអង្កេតសេដ្ឋកិច្ចសង្គមកម្ពុជាឆ្នាំ ២០០៩

សំគាល់: ចំនួនប្រជាជនសរុបឆ្នាំ ២០០៩ របស់ឃុំថ្មីមានចំនួនតិចជាងស្ថិតិឃុំឆ្នាំ ២០១៤ ចំនួន ៧០៨នាក់ និងចំនួនប្រជាជនឃុំកន្ទួតក្នុងឆ្នាំ ២០០៩ មានចំនួនតិចជាងស្ថិតិឃុំឆ្នាំ ២០១៤ ចំនួន ៦០៣នាក់។

៥.៤ លទ្ធផលសិក្សាស្រាវជ្រាវ

៥.៤.១ ធនធានរូបសាស្ត្រ

៥.៤.១.១ គុណភាពខ្យល់

៤១. ការសិក្សាអំពីគុណភាពខ្យល់បានធ្វើឡើងរយៈពេល ២៤ម៉ោង (ថ្ងៃយប់)។ ថ្ងៃគឺគិតពីក្រោយម៉ោង០៦ព្រឹក ទៅម៉ោង០៦ល្ងាច និងយប់ពីក្រោយម៉ោង០៦ល្ងាច ទៅម៉ោង០៦ព្រឹក។ លទ្ធផលនៃការសិក្សាមានបកស្រាយជូនខាងក្រោម (តារាង ៥-១២[១] និង៥-១២[២])។

៥.៤.១.១.១ ធូលី (PM_1, $PM_{2.5}$ and PM_{10})

៤២. ធូលី (PM) ជាពាក្យបច្ចេកទេសដែលត្រូវបានគេប្រើសម្រាប់បកស្រាយអំពីការលាយបញ្ចូលគ្នានៃភាគល្អិតរឹងតូចៗ និងដំណក់រាវតូចៗដែលអណ្តែតក្នុងខ្យល់។ ធូលីទាំងអស់នោះមានប្រភពផ្សេងៗគ្នាដូចជា រោងចក្រថាមពល ដំណើរការនៃឧស្សាហកម្ម និងលានដឹកដែលប្រើម៉ាស៊ូត។ ធូលីទាំងនេះកើតមាននៅក្នុងបរិយាកាសដោយការបំលែងរបស់ប្រេងឥន្ធនៈនៅក្នុងដំណើរចំហេះ។ លក្ខណៈរូប និងលក្ខណៈគីមីរបស់វាគឺអាស្រ័យទៅនឹងទីតាំង រដូវកាល និងអាកាសធាតុ។ ធូលីត្រូវបានបែងចែកជាល្អិត និងគ្រើម។

៤៣. ធូលីគ្រើម មានអង្កត់ផ្ចិតឌីណាមិកអាកាសប្រែប្រួលក្នុងចន្លោះពី 2.5μ ទៅ 10μ។ ពួកវាកកើតឡើងនៅក្នុងបរិយាកាសដោយមានការរំខានមេកានិច (ឧទាហរណ៍ ដំណើរបំបែកការកិនកម្ទេច , និងដំណើរសំណឹកនៃផ្ទៃខាងលើ) រំហួតនៃការបាញ់ថ្នាំ និងធូលីអណ្តែត។ ធូលីគ្រើម មានជាតុផ្សំជា Alumiosilicate និងសមាសជាតុអុកស៊ីដផ្សេងទៀត ដែលមាននៅស្រទាប់របស់ផែនដី។ ប្រភពសំខាន់ៗរបស់ធូលី គឺការហើរចេញនៃធូលីពីផ្លូវថ្នល់ ឧស្សាហកម្ម កសិកម្ម សំណង់ និងការបំផ្ទុះដើម្បីកម្ទេចអគាររចាល និងការសោយភាយកម្ទេចផង់ផេះចេញពីរោងចក្រអគ្គីសនីដែលដើរដោយប្រេងហ្វូស៊ីល។ អាយុកាលរបស់ធូលីគ្រើម គឺស្ថិតនៅចន្លោះពីនាទីទៅម៉ោង និងអាចធ្វើដំណើរបានពី ១គម.គ១០ម ទៅ .។

៤៤. ធូលីល្អិតមានអង្កត់ផ្ចិតឌីណាមិកអាកាសតូចជាង 2,5μ។ ធូលីល្អិត ខុសពីធូលីគ្រើម ដោយសារប្រភពកំណើត និងលក្ខណៈគីមីរបស់វា។ ធូលីល្អិតទាំងនេះត្រូវបានបង្កើតឡើងពីឧស្ម័ន និងកំណកនៃចំហាយដែលមានសីតុណ្ហភាពខ្ពស់ក្នុងអំឡុងពេលដែលមានចំហេះ ដោយផ្សំឡើងពីការរួមបញ្ចូលគ្នានៃសមាសជាតុស៊ុលហ្វាត, នីត្រាត, កាបូន, អាម៉ូញ៉ូម, អ៊ីយ៉ុងអ៊ីដ្រូសែន, រូជាតុសរីរាង្គ, លោហៈធាតុ (Pb, Cd, V, Ni, Cu, Zn, Mn និង Fe) និងធូលី ដែលមានម៉ូលេគុលទឹក។ ប្រភពសំខាន់របស់ធូលីល្អិត គឺកើតមកពីចំហេះឥន្ធនៈ ការដុតរុក្ខជាតិ និងការរំលាយលោហៈ។ អាយុកាលរបស់ធូលីល្អិត គឺស្ថិតនៅចន្លោះពីថ្ងៃទៅច្រើនសប្តាហ៍ និងធ្វើដំណើរបានចំងាយពី ១០០គម. ទៅ ១០០០គម.។

៤៥. ការសិក្សាអំពីកំរិតអប្បបរមា និងអតិបរមារបស់ធូលី ដែលបានកត់ត្រាទុកដោយឧបករណ៍ AQM60 នៅក្នុងតំបន់សិក្សាបានបង្ហាញថា ធូលី PM_1 មានបរិមានប្រែប្រួលក្នុងចន្លោះពី ២៥,១២១ ទៅ ៣៦,៤១០μg/m³។ ធូលី $PM_{2.5}$ ប្រែប្រួលក្នុងចន្លោះពី ២៦,៨៧៤ ទៅ ៩២,០១៤ μg/m³។ ធូលី PM_{10} ប្រែប្រួលក្នុងចន្លោះពី ៣៣,៥១៩ ទៅ ៩៤,៩០៣μg/m³។

៤៦. នៅមិនទាន់មានការកំណត់អំពីបរិមាណធូលីគ្រើម និងធូលីល្អិត នៅក្នុងកម្រិតបទដ្ឋានគុណភាពខ្យល់ថ្នាក់ជាតិ នៅក្នុងតំបន់ជនបទនៅឡើយទេ។ ប៉ុន្តែបើប្រៀបធៀបជាមួយស្តង់ដារគុណភាពខ្យល់ថ្នាក់ជាតិសម្រាប់ទីក្រុង ពិនិត្យឃើញថាមានតម្លៃ ៤៩,៧μg/m³។

៥.៤.១.១.២ ស្ពាន់ធ័រឌីអុកស៊ីដ (SO_2)

៤៧. ស្ពាន់ធ័រឌីអុកស៊ីដ (SO_2) ជាឧស្ម័នពុលមិនមែនសរីរាង្គ។ ការបំភាយឧស្ម័នស្ពាន់ធ័រឌីអុកស៊ីដត្រូវបានគេរំពឹងថា ត្រូវបានបំភាយចេញពីគ្រប់កន្លែងដែលមានចំហេះប្រេងឥន្ធនៈដែលមានផ្ទុកស្ពាន់ធ័រ។ ស្ពាន់ធ័រនៅក្នុងប្រេងឥន្ធនៈនិងភ្ជាប់ជាមួយអុកស៊ីសែនដើម្បីបង្កើតជាស្ពាន់ធ័រឌីអុកស៊ីដ។ ស្ពាន់ធ័រទ្រីអុកស៊ីដ និងអាស៊ីដស៊ុលផួរិកជាសមាសជាតុពុលសំខាន់ក្នុងក្រុមស៊ុលផួរ។ ជាទូទៅប្រភពសំខាន់មួយចំនួននៃស្ពាន់ធ័រឌីអុកស៊ីដគឺស្ថានីយ៍ថាមពល រោងចក្រអាស៊ីតស៊ុលផួរិក កន្លែងសំអាតប្រេង និងការដុតដោយប្រើឧស-ធ្យូង។ ប្រភពនៃស្ពាន់ធ័រឌីអុកស៊ីដទាំងនេះត្រូវបានកំណត់ក្នុងតំបន់នៃការសិក្សា។

៤៨. អត្ថន័យរបស់ស្ពាន់ធ័រឌីអុកស៊ីដក្នុងបរិយាកាស គឺជាភាពពុលរបស់វា។ ស្ពាន់ធ័រឌីអុកស៊ីតអាចធ្វើអោយមានជម្ងឺ និងការខូចសួត។ លើសពីនេះទៅទៀតវាអាចភ្ជាប់ជាមួយទឹកក្នុងខ្យល់បង្កើតជាអាស៊ីដពុលដែលធ្វើឲ្យខូចផ្ទៃខាងលើនៃលោហៈ ក្រណាត់ និងស្លឹកឈើ។ ស្ពាន់ធ័រឌីអុកស៊ីតធ្វើឲ្យមានការរំខានដល់

Draft

ភ្នែក និងប្រព័ន្ធដកដង្ហើម។ ការប៉ះពាល់ស្ពាន់ធ័រឌីអុកស៊ីតច្រើនហួសធ្វើមានជម្ងឺហឺត និងជម្ងឺមួយចំនួនទៀតដែលទាក់ទងនឹងការដកដង្ហើមព្រោះវាជះឥទ្ធិពលអាក្រក់ដល់សួត។

៤៩. ការសិក្សាបានបង្ហាញថាកំរិតអប្បបរមា និងអតិបរមារបស់ស្ពាន់ធ័រឌីអុកស៊ីដ ដែលបានកត់ត្រាទុកដោយឧបករណ៍ AQM60 គឺគឺស្ថិតក្នុងចន្លោះ ០.០៤៨ ទៅ ០.១៥៨ppm។ នៅមិនទាន់មានការកំណត់អំពីបរិមាណស្ពាន់ធ័រឌីអុកស៊ីដ នៅក្នុងកម្រិតបទដ្ឋានគុណភាពខ្យល់ថ្នាក់ជាតិ នៅក្នុងតំបន់ជនបទនៅឡើយទេ។ ប៉ុន្តែបើប្រៀបធៀបជាមួយស្តង់ដារគុណភាពខ្យល់ថ្នាក់ជាតិសម្រាប់ទីក្រុង ពិនិត្យឃើញថាមានតំម្លៃ ៤៣,២μg/m^3។

៥.៤.១.១.៣ អាសូតអុកស៊ីដ (NOx)

៥០. អាសូតអុកស៊ីដ (NOx) ជាឧស្ម័នពុលដូចជាស្ពាន់ធ័រឌីអុកស៊ីដដែរ។ ការបំភាយអាសូតអុកស៊ីដត្រូវបានរំពឹងទុកថាបានភាយចេញពីទីកន្លែងដែលមានចំហេះនៅសីតុណ្ហភាពខ្ពស់។ អាសូតអុកស៊ីដ និងអាស៊ីដនីទ្រិក ជាសារជាតុពុលផ្សេងទៀតក្នុងក្រុមអាសូតមិនមែនសរីរាង្គ។ ជាទូទៅប្រភពសំខាន់នៃការបញ្ចេញអាសូតអុកស៊ីដមានការប្រើប្រាស់ការដាំទឹកយកចំហាយក្នុងឧស្សាហកម្ម (Boiler) និងបំពង់ស៊ីម៉ាំងឡាន។ ក្នុងទីក្រុងទំនើប កម្រិតរបស់អាសូតអុកស៊ីដ ភាគច្រើនគឺសាយភាយចេញពីយានយន្ត។

៥១. អាសូតអុកស៊ីដមានសារសំខាន់ក្នុងប្រតិកម្ម នៃផ្សែងអាកាតីមី [Photochemical Smog - (ផ្សែងលាយអ័ព្ទ)] ដែលមានឥទ្ធិពលអវិជ្ជមានជាងឧស្ម័នពុលផ្សេងទៀត។ នៅពេលអាសូតអុកស៊ីដ ជួបនឹងពន្លឺព្រះអាទិត្យនឹងទទួលប្រតិកម្មជាមួយសមាសជាតុសរីរាង្គផ្សេងៗទៀត ដើម្បីបង្កើតឲ្យមានផ្សែងអាកាតីមី។ អាសូតអុកស៊ីដ មានសមត្ថភាពបង្កឲ្យមានផលប៉ះពាល់ដល់សុខភាពក្នុងទំរង់ជាសារជាតុពុល។ វាធ្វើឲ្យស្ទះផ្លូវដង្ហើមនៅពេលវាប្រមូលផ្តុំច្រើន ព្រោះវាធ្វើឲ្យចំនួនអុកស៊ីសែនក្នុងខ្យល់ថយចុះ។

៥២. ការសិក្សាបានបង្ហាញថា កំរិតអប្បបរមា និងអតិបរមារបស់អាសូតអុកស៊ីដ ដែលបានកត់ត្រាទុកដោយឧបករណ៍ AQM60 គឺស្ថិតក្នុងចន្លោះ ០,០១០μg/m^3 ទៅ០,០២១μg/m^3។ នៅមិនទាន់មានការកំណត់អំពីបរិមាណអាសូតអុកស៊ីដ នៅក្នុងកម្រិតបទដ្ឋានគុណភាពខ្យល់ថ្នាក់ជាតិ នៅក្នុងតំបន់ជនបទនៅឡើយទេ។ ប៉ុន្តែបើប្រៀបធៀបជាមួយស្តង់ដារគុណភាពខ្យល់ថ្នាក់ជាតិសម្រាប់ទីក្រុង ពិនិត្យឃើញថាមានតម្លៃ ៤៣,២μg/ m^3 ឬស្មើនឹង ០,០០៨ ppm។

៥.៤.១.១.៤ អាសូតឌីអុកស៊ីដ (NO_2)

៥៣. អាសូតឌីអុកស៊ីដស្ថិតនៅក្នុងក្រុមនៃឧស្ម័នបំពុលបរិយាកាស ដែលកើតចេញពីការធ្វើចរាចរណ៍តាមដងផ្លូវ និងនៅក្នុងចំហេះប្រេងឥន្ធនៈរបស់ម៉ាស៊ីន។ វត្តមានរបស់អាសូតឌីអុកស៊ីដនៅក្នុងបរិយាកាសបានរួមចំណែកនៅក្នុងដំណើរករកើត និងធ្វើឲ្យប្រែប្រួលនូវសារជាតុបំពុលបរិយាកាសដ៏ទៃទៀតដូចជា ធូលី, អូសូន និងអាស៊ីដទឹកភ្លៀង។

៥៤. ការសិក្សាអំពីឥទ្ធិពលអាក្រក់របស់អាសូតឌីអុកស៊ីដទៅលើសុខភាពមនុស្ស បានបង្ហាញថា ការរស់នៅក្នុងមជ្ឍដ្ឋានមួយដែលមានអាសូតឌីអុកស៊ីដខ្ពស់រយៈពេលវែង នឹងនាំឲ្យមានការថមថយនូវមុខងាររបស់សួត និងការប្រឈមនឹងកំណើនហានិភ័យនៃលេចចេញនូវរោគសញ្ញានៃការរលាកទងសួតស្រួចស្រាវ, ក្អក និងកាពោឡើងស្លេស។

៥៥. ការសិក្សាបានបង្ហាញថា កំរិតអប្បបរមា និងអតិបរមារបស់អាសូតឌីអុកស៊ីដ ដែលបានកត់ត្រាទុកដោយឧបករណ៍ AQM60 គឺស្ថិតក្នុងចន្លោះ ០,០$\mu g/m^3$ ទៅ០,០០៤$\mu g/m^3$។ នៅមិនទាន់មានការកំណត់អំពីបរិមាណអាសូតអុកស៊ីដ នៅក្នុងកម្រិតបទដ្ឋានគុណភាពខ្យល់ថ្នាក់ជាតិ នៅក្នុងតំបន់ជនបទនៅឡើយទេ។

៥.៤.១.១.៥ កាបូនឌីអុកស៊ីដ (CO_2)

៥៦. កំហាប់កាបូនឌីអុកស៊ីត (CO_2) ត្រូវបានប្រើប្រាស់ជាសុចនាករសម្រាប់វាយតម្លៃអំពីគុណភាពខ្យល់ក្នុងអាគារ។ ប្រសិនបើកំហាប់កាបូនឌីអុកស៊ីតក្នុងអាគារមានបរិមាណខ្ពស់ពេក បរិមាណដែល) បានកំណត់គឺ 1000ppm(នឹងមានអារម្មណ៍ថាខ្យល់អាប់អួរ។

៥៧. ការសិក្សាបានបង្ហាញថា កំរិតអប្បបរមា និងអតិបរមារបស់អាសូតឌីអុកស៊ីដ ដែលបានកត់ត្រាទុកដោយឧបករណ៍ AQM60 គឺស្ថិតក្នុងចន្លោះ ១៥៦,៧៣៣ ទៅ ៨០៨,២៦៧ppm ។

៥.៤.១.១.៦ អ៊ីដ្រូសែនស៊ុលភីត (H_2S)

៥៨. អ៊ីដ្រូសែនស៊ុលភីត (H_2S) ជាឧស្ម័នគ្មានពណ៌ ពុលខ្លាំង និងងាយឆេះដាមួយនិងក្លិនអាក្រក់ដូចស៊ុតស្អុយ។ អ៊ីដ្រូសែនស៊ុលភីត នៃការធ្វើប្រតិកម្មអាណាអេរ៉ូប៊ិករបស់បាក់តេរី ទៅលើអង្គធាតុសរីរាង្គដូចជាវាលភក់ និងប្រព័ន្ធលូ។ វាក៏បានកើតឡើងក្នុងឧស្ម័ននៅពេលបន្ទុះភ្នំភ្លើង ឧស្ម័នធម្មជាតិ និងទឹកអណ្តូងមួយចំនួន។

៥៩. ការសិក្សាបានបង្ហាញថា កំរិតអប្បបរមា និងអតិបរមារបស់អ៊ីដ្រូសែនស៊ុលភីត ដែលបានកត់ត្រាទុកដោយឧបករណ៍ AQM60 គឺស្ថិតក្នុងចន្លោះ ០,០ ទៅ ០,០៦៦ ppm។

៥.៤.១.១.៧ រស្មីព្រះអាទិត្យ (Solar Radiation)

៦០. ព្រះអាទិត្យបញ្ចេញថាមពលនៅក្នុងទម្រង់ជា កាំរស្មីអេឡិកត្រូម៉ាញ៉េទិក (ME Radiation - Electromagnetic Radiation) ទៅក្នុងលំហរអាកាស។ ថាមពលព្រះអាទិត្យដែលបញ្ចេញមកលើផែនដីគឺគិតជា វ៉ាត់ ហើយក្នុងផ្ទៃផែនដីមួយម៉ែត្រការ៉េគឺ ១.៣៦៨វ៉ាត់។

៦១. ការសិក្សាអំពីកម្រិតកាំរស្មីព្រះអាទិត្យនៅលើកន្លែងសិក្សាបង្ហាញថា មានតម្លៃសូន្យវ៉ាត់/ម២ (0.0watts/m^2) ចន្លោះពីក្រោយម៉ោង០៦ល្ងាច ទៅម៉ោង០៦ព្រឹក។ តម្លៃនេះមានការប្រែប្រួលពីក្រោយម៉ោង០៦ព្រឹក ទៅម៉ោង០៦ល្ងាច (៦,២៣៣-៨១៧,៩០វ៉ាត់/ម២) ហើយតម្លៃអតិបរិមាពិនិត្យឃើញមាននៅវេលាម៉ោង ១២ថ្ងៃត្រង់។

៥.៤.១.១.៨ អូសូន (O3)

៦២. ស្រទាប់អូសូនគឺជាតំបន់ Stratosphere របស់ផែនដីដែលស្រូបយកស្ទើតែទាំងនូវរស្មីអ៊ុលត្រាវីយ៉ូឡេរបស់ព្រះអាទិត្យ។ កំហាប់របស់អូសូនក្នុងតំបន់គឺខ្ពស់បើប្រៀបធៀបទៅនឹងតំបន់ផ្សេងៗទៀតក្នុងបរិយាកាស ប៉ុន្តែបរិមាណនេះគឺទាបប្រសិនប្រៀបធៀបជាមួយនិងឧស្ម័នដ៏ទៃដែលមាននៅក្នុងស្រទាប់ Stratosphere[1]។ ស្រទាប់អូសូន មានបរិមាណអូសូនតិចជាង 10ppm ក្នុងពេលដែលអូសូនរបស់បរិយា

[1] Stratosphere ស្រទាប់អូសូនពិនិត្យឃើញមានជាពិសេសនៅផ្នែកដែលទាបជាងគេរបស់ស្រទាប់ Stratosphere ដែលមានកំពស់ប្រមាណពី ២០ ទៅ ៣០គម ពីសំបកផែនដី។

កាសផែនដី (Earth's Atmosphere and/or Ground Ozone) គិតជាមធ្យមមានប្រមាណតែ 0.3ppm ប៉ុណ្ណោះ។

៦៣. ការសិក្សាបានបង្ហាញថា កំរិតអប្បបរមា និងអតិបរមារបស់អូសូន ដែលបានកត់ត្រាទុកដោយឧបករណ៍ AQM60 គឺស្ថិតក្នុងចន្លោះ 0.005ppm ទៅ 0.01ppm។

៥.៤.១.១.៩ សម្លេង

៦៤. ការសិក្សាបានបង្ហាញថា កំរិតអប្បបរមា និងអតិបរមារបស់សម្លេង ដែលបានកត់ត្រាទុកដោយឧបករណ៍ AQM60 ស្ថិតក្នុងចន្លោះពីម៉ោង០៦ព្រឹកទៅម៉ោង០៦ល្ងាច បង្ហាញថាប្រែប្រួលពី 20.423-58.657dBA។ ចំណែកឯពីម៉ោង០៦ល្ងាចទៅម៉ោង០៦ព្រឹក បង្ហាញថាប្រែប្រួលពី 55.44-59.33dBA។ នៅមិនទាន់មានការកំណត់អំពីកម្រិតសម្លេង នៅក្នុងកម្រិតបទដ្ឋានគុណភាពខ្យល់ថ្នាក់ជាតិនៅតំបន់ជនបទនៅឡើយ ដូច្នេះមិនអាចធ្វើការប្រៀបធៀបបានទេ។

Draft

តារាង៥-១២⁹៖ គុណភាពខ្យល់រយៈពេល២៤ម៉ោងនៅក្បែរស្នាក់ការមេ (ចំណុចនិយាមកា ៦៣៥៧១៦-១៣៧១៩១៩)

Time	O_3-ppm	NO_2-ppm	NOx-ppm	H_2S-ppm	SO_2-ppm	CO_2-ppm	PM_1/μg/m³	$PM_{2.5}$/μg/m³	PM_{10}/μg/m³	Noise/dBA	SR/w/m²
1am	0.013	0.000	0.016	0.010	0.123	396.600	47.971	51.633	55.252	57.470	0.000
2am	0.006	0.000	0.014	0.010	0.116	385.733	46.509	49.999	53.022	59.330	0.000
3am	0.002	0.000	0.015	0.010	0.120	390.100	48.421	52.087	54.878	58.727	0.000
4am	0.002	0.000	0.015	0.010	0.113	388.067	40.386	43.510	45.433	57.840	0.000
5am	0.008	0.000	0.015	0.011	0.120	395.833	43.553	46.923	48.711	58.577	0.000
6am	0.018	0.000	0.015	0.016	0.123	403.400	49.291	53.166	55.181	57.897	0.000
7am	0.105	0.000	0.021	0.066	0.205	440.600	83.854	90.034	91.916	54.870	0.000
8am	0.473	0.000	0.019	0.029	0.147	411.633	62.452	70.014	79.225	54.573	21.733
9am	0.014	0.001	0.019	0.007	0.106	385.867	49.626	54.894	61.178	54.560	171.700
10am	0.037	0.003	0.015	0.000	0.086	374.633	35.225	39.460	45.430	55.110	412.400
11am	0.033	0.003	0.014	0.001	0.088	808.267	27.493	30.405	34.627	53.287	623.200
12am	0.031	0.004	0.010	0.002	0.097	802.300	28.323	31.193	35.247	55.023	755.300
1pm	0.010	0.000	0.017	0.011	0.116	387.000	50.065	54.853	60.294	54.933	817.900
2pm	0.001	0.000	0.015	0.010	0.119	389.600	47.078	50.642	53.144	58.657	194.770
3pm	0.015	0.000	0.015	0.015	0.123	400.667	46.527	50.081	51.920	58.037	102.067
4pm	0.549	0.000	0.020	0.053	0.185	435.167	75.823	82.847	88.434	54.893	63.167
5pm	0.023	0.000	0.018	0.014	0.123	396.367	53.100	59.231	66.600	54.523	43.333
6pm	0.003	0.001	0.011	0.010	0.058	156.733	19.382	23.595	32.687	20.423	14.230
7pm	0.002	0.000	0.019	0.008	0.158	434.200	52.893	67.642	96.271	58.440	6.233
8pm	0.002	0.000	0.020	0.019	0.137	433.100	50.051	61.355	79.486	57.033	0.000
9pm	0.016	0.000	0.021	0.026	0.138	433.667	62.061	73.742	90.166	56.210	0.000
10pm	0.006	0.000	0.017	0.020	0.127	425.267	62.426	68.899	75.540	55.440	0.000
11pm	0.009	0.000	0.019	0.002	0.127	450.600	59.122	65.596	73.128	55.557	0.000
12pm	0.026	0.000	0.019	0.029	0.129	475.400	61.694	68.337	75.488	55.450	0.000

ប្រភព៖ ETS Service Co., Ltd

តារាង៥-១២[២]៖ គុណភាពខ្យល់រយៈពេល២៤ម៉ោងនៅក្បែរផ្ទះកម្មករ (ចំណុចនិយាមកា ៦៤៤៩៤០-១៣៧៥៩៣៤)

Time	O_3-ppm	NO_2-ppm	NOx-ppm	H_2S-ppm	SO_2-ppm	CO_2-ppm	$PM_1/\mu g/m^3$	$PM_{2.5}/\mu g/m^3$	$PM_{10}/\mu g/m^3$	Noise/dBA	SR/w/m^2
1am	0.028	0.000	0.019	0.027	0.126	477.833	64.372	70.032	74.774	55.423	0.000
2am	0.203	0.000	0.023	0.048	0.158	481.133	86.410	92.014	94.903	55.253	0.000
3am	0.059	0.000	0.006	0.018	0.048	108.700	25.121	26.874	27.373	12.857	0.000
4am	0.070	0.000	0.022	0.037	0.141	483.700	76.583	82.049	85.438	55.330	0.000
5am	0.027	0.000	0.013	0.000	0.091	376.833	34.702	37.019	39.038	55.513	0.000
6am	0.039	0.000	0.009	0.000	0.078	367.533	30.564	32.698	35.160	55.547	0.000
7am	0.033	0.001	0.012	0.006	0.082	374.200	33.197	35.840	39.187	55.483	21.933
8am	0.041	0.000	0.010	0.001	0.078	365.767	34.261	36.443	39.423	55.483	171.700
9am	0.009	0.001	0.018	0.012	0.091	360.800	42.574	45.652	48.425	50.310	412.400
10am	0.024	0.000	0.013	0.000	0.095	380.267	35.714	38.115	40.156	55.520	623.200
11am	0.033	0.000	0.010	0.002	0.082	359.100	30.652	32.787	34.866	53.580	755.300
12am	0.037	0.000	0.009	0.000	0.077	355.400	29.430	31.450	33.519	53.700	817.900
1pm	0.042	0.000	0.009	0.000	0.073	365.333	31.052	33.175	35.839	55.480	194.770
2pm	0.042	0.000	0.011	0.002	0.078	365.100	36.515	38.695	41.715	55.303	97.067
3pm	0.044	0.000	0.011	0.001	0.077	365.133	37.851	40.037	42.690	55.130	52.167
4pm	0.045	0.000	0.011	0.000	0.070	364.267	36.037	38.062	40.407	55.517	43.333
5pm	0.048	0.000	0.010	0.000	0.069	364.300	34.444	36.417	39.299	55.797	9.230
6pm	0.028	0.000	0.013	0.016	0.089	377.233	36.593	44.284	62.025	55.483	3.233
7pm	0.001	0.000	0.019	0.022	0.095	357.733	40.545	48.007	64.487	50.127	0.333
8pm	0.013	0.000	0.018	0.026	0.116	438.067	46.851	55.229	71.457	55.940	0.000
9pm	0.023	0.000	0.017	0.019	0.091	411.700	39.278	51.158	71.947	48.520	0.000
10pm	0.015	0.000	0.018	0.019	0.097	463.400	52.225	59.229	66.633	55.610	0.000
11pm	0.028	0.000	0.019	0.022	0.101	489.300	55.182	59.667	62.828	55.663	0.000
12pm	0.009	0.000	0.015	0.026	0.101	431.467	66.459	69.900	72.423	55.347	0.000

ប្រភព៖ ETS Service Co., Ltd

Draft

ដ្យាក្រាម៥-៥ គំនូសតាងគុណភាពខ្យល់រយៈពេល២៤ម៉ោងនៅក្បែរស្នាក់ការមេ



ប្រភព៖ ETS Service Co., Ltd

ដ្យាក្រាម៥-៦ គំនូសតាងគុណភាពខ្យល់រយៈពេល២៤ម៉ោងនៅក្បែរផ្ទះកម្មករ



ប្រភព៖ ETS Service Co., Ltd

៥.៤.១.២ គុណភាពទឹកលើដី និងទឹកក្រោមដី

៦៥. **ការយកសំណាកទឹក និងការវិភាគៈ** ក្រុមការងារបានយកសំណាកទឹក ០៥កន្លែង ក្នុងនោះមានទឹកក្រោមដីមួយកន្លែង (ទឹកអណ្ដូងពីស្នាក់មេរបស់ក្រុមហ៊ុនមួយកន្លែង កាលពីថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ ២០១៤ និង០៤កន្លែងផ្សេងទៀត ជាទឹកលើដីយកពីអូរក្រេងក្នុងភូមិសាស្ត្រភូមិស្រែសនន (០២កន្លែង) ពីព្រែកទេរ (០១កន្លែង) ក្នុងភូមិសាស្ត្រភូមិរៀរ និងពីអូរប្រើមឬអូរព្រាម (០១កន្លែង) ក្នុងភូមិសាស្ត្រភូមិស្វាយជ្រុំ ឃុំថ្មី ស្រុក ចិត្របុរី ខេត្តក្រចេះ កាលពីថ្ងៃទី ០៦ ខែកញ្ញា ឆ្នាំ ២០១៤ ដើម្បីធ្វើការវិភាគអំពីលក្ខណៈរូប និងលក្ខណៈគីមី។ សំណាកនេះត្រូវបានបញ្ជូនទៅមន្ទីរពិសោធន៍របស់ក្រសួងបរិស្ថាន ដើម្បីធ្វើការវិភាគ។ លទ្ធផលតារាងសង្ខេបទាំង៥សំណាកដូចមានបង្ហាញក្នុងតារាងទី៥-១២ ។

៦៦. តាមរយៈលទ្ធផលនៃការវិភាគគុណភាព**ទឹកសំណាកទី១** (ទឹកអណ្ដូងក្នុងទីស្នាក់ការក្រុមហ៊ុន ដូទីសាយហ្គន-ប៊ិញហ្វឿក (អេស ប៊ី ខេ) ភូមិអាលច ឃុំកន្ទួត ស្រុកចិត្របុរី ខេត្តក្រចេះ និយាមកា ៦៣៥៧១៨-១៣៧១៩២៤) ដែលទទួលបានពីមន្ទីរពិសោធន៍របស់ក្រសួងបរិស្ថានបានបង្ហាញថាៈ

៦៧. **មីក្រូសរីរាង្គៈ** បរិមាណកូលីហ្វម (Coliform) និងបាក់តេរី (Bacteria) ដែលពិនិត្យឃើញមាននៅក្នុងទឹកអណ្ដូងរបស់ក្រុមហ៊ុន គឺមានចំនួន ២.០០០ និង ៣៨៥ ដោយឡែកៗពីគ្នា គឺមានបរិមាណខ្ពស់ បើប្រៀបធៀបជាមួយនឹងកម្រិតបទដ្ឋានគុណភាពទឹកផឹកថ្នាក់ជាតិរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៃព្រះរាជាណាចក្រកម្ពុជា។

៦៨. **លក្ខណៈរូបៈ** ចំពោះតុល្យភាពអ៊ីយ៉ុងអ៊ីដ្រូសែន pH = 6.64/6.50-8.5 ពោលគឺមានលក្ខណៈចន្លោះស្តង់ដារ។ ចំពោះភាពចម្លងអគ្គិសនី (EC) គឺមានចំនួន 116.0μs/m/NV ពោលគឺមានបរិមាណខ្ពស់ជាងកំរិតស្តង់ដារ បើប្រៀបធៀបជាមួយនឹងកម្រិតបទដ្ឋានគុណភាពទឹកផឹកថ្នាក់ជាតិ របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្មនៃព្រះរាជាណាចក្រកម្ពុជា។ ចំណែកឯថាវរូប០៣ទៀតមានដូចជាៈ Total Disolved Solid (TDS) និង Total Hardness ($CaCO_3$) មានបរិមាណ 0.00/5.0, 94.00/800.0 and 49.72/300.0 ពោលគឺមានបរិមាណទាបជាងកំរិតស្តង់ដារ បើប្រៀបធៀបជាមួយនឹងកម្រិតបទដ្ឋានគុណភាពទឹកផឹកថ្នាក់ជាតិរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្មនៃព្រះរាជាណាចក្រកម្ពុជា។

៦៩. **លក្ខណៈគីមីៈ** នៅក្នុងចំណោមថាវរូប១៥ផ្សេងទៀតគឺ៖ Chloride (Cl), Sulphate (SO_4), Flore (F), Nitrite (NO_2), Nitrate (NO_3), Iron (Fe), Manganese (Mg), Arsenic (As), Copper (Cu), Lead (Pb), Nickel (Ni), Zinc (Zn), Cobalt (Co), Cadmium (Cd) and Mercury (Hg) ក្នុងនោះមានតែ Cobalt ប៉ុណ្ណោះដែលមានបរិមាណ 0.003mg/l ប៉ុន្តែថាវរូបនេះនៅមិនទាន់មានកំណត់នៅក្នុងកម្រិតស្តង់ដារគុណភាពទឹកផឹកថ្នាក់ជាតិរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្មនៃព្រះរាជាណាចក្រកម្ពុជា ទេ (ឧបសម្ព័ន្ធ៥-៣ តារាងទី១ លទ្ធផលវិភាគទឹករបស់ក្រសួងបរិស្ថានលេខ ១៤១ ពស ចុះថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ២០១៤)។

៧០. តាមរយៈលទ្ធផលនៃការវិភាគគុណភាព **ទឹកសំណាកទី២** (ទឹកអូរក្រេង ភូមិស្រែសនន ឃុំកន្ទួត ស្រុកចិត្របុរី ខេត្តក្រចេះ ចំណុចនិយាមកាលេខ ៦៤១៣០៨-១៣៧៥៣៣០) ដែលទទួលបានពីមន្ទីរពិសោធន៍របស់ក្រសួងបរិស្ថាន បានបង្ហាញថាៈ

៧១. លក្ខណៈរូបៈ ចំពោះតុល្យភាពអ៊ីយ៉ុងអ៊ីដ្រូសែន pH = 7. 39/6.50-8.5 ពោលគឺមានលក្ខណៈចន្លោះស្តង់ដារ។ ចំណែកឯថាវូប០៣ ផ្សេងទៀតដូចជា៖ Biological Oxygen Demand (BOD) , Oil & Grease, Ammonia (NH_3) មានបរិមាណ 2.04, 0.91, 0.05 តែថាវូបទាំងនេះក៏មិនទាន់បានកំណត់ក្នុងកម្រិតស្តង់ដារគុណភាពទឹកនៅតាមតំបន់ទឹកសាធារណៈសម្រាប់អភិវឌ្ឍន៍ជីវៈចំរុះនៅក្នុងទឹក និងការពារសុខភាពសាធារណៈរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលទេ។ ដោយឡែកមានថាវូប០២ ផ្សេងទៀតគឺ TSS និង Total Nitrogen (TN) គឺមានបរិមាណច្រើនជាងកម្រិតស្តង់ដារគុណភាពទឹកនៅតាមតំបន់ទឹកសាធារណៈសម្រាប់អភិវឌ្ឍន៍ជីវៈចំរុះនៅក្នុងទឹក និងការពារសុខភាពសាធារណៈរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដោយក្នុងនោះពិនិត្យឃើញថា៖ TSS មានចំនួន ៥៣-៤ដង ច្រើនជាង ពោលគឺ ៥៣ម.ក្រ លើ ១-១៥ម.ក្រ/លីត្រ និង TN មានចំនួន ១៣,៥-២,២៥ដង ពោលគឺ ១,៣៥ម.ក្រ លើ ០,១-០,៦ម.ក្រ/លីត្រ។ ប៉ុន្តែ TP មានបរិមាណស្ថិតចន្លោះកម្រិតស្តង់ដារពោលគឺ 0.02/0.005-0.05mg/l។

៧២. លក្ខណៈគីមីៈ នៅក្នុងចំណោមថាវូប០៥ ផ្សេងទៀតមានថាវូបចំនួន ៣៖ Asenic (As), Mercury (Hg) និង Chemical Oxygen Demand (COD) សុទ្ធតែមានវត្តមាននៅក្នុងសំណាកទឹកអូរនេះទាំងអស់ ប៉ុន្តែមានបរិមាណតិចជាងកំរិតស្តង់ដារពោលគឺៈ 0.0003/0.01, 0.0002/0.01 mg/l និង 2.04/1.0-8.0 mg/l។ ដោយឡែក Cadmium (Cd) និង Lead (Pb) មិនបានពិនិត្យឃើញមានវត្តមាននៅក្នុងសំណាកទឹកនេះទេ (ឧបសម្ព័ន្ធ៥-៣ លទ្ធផលវិភាគទឹករបស់ក្រសួងបរិស្ថានលេខ ៩៨ ពស ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៤)។

៧៣. តាមរយៈលទ្ធផលនៃការវិភាគគុណភាពទឹកសំណាកទី៣ (ទឹកអូរក្រុង ភូមិស្រែនន ឃុំកន្ទួត ស្រុកចិត្របុរី ខេត្តក្រចេះ ចំណុចនិយាមកាលេខ ៦៤១៨១២-១៣៧៤៦៦៤) ដែលទទួលបានពីមន្ទីរពិសោធន៍របស់ក្រសួងបរិស្ថាន បានបង្ហាញថាៈ

៧៤. លក្ខណៈរូបៈ ចំពោះតុល្យភាពអ៊ីយ៉ុងអ៊ីដ្រូសែន pH = 6.47/6.50-8.5 ពោលគឺមានលក្ខណៈទាបជាងស្តង់ដារបន្តិច។ ចំណែកឯថាវូប០៣ ផ្សេងទៀតដូចជា៖ Biological Oxygen Demand (BOD) , Oil & Grease, Ammonia (NH_3) មានបរិមាណ 1.6, 0.94, 0.08mg/l តែថាវូបទាំងនេះក៏មិនទាន់បានកំណត់ក្នុងកម្រិតស្តង់ដារគុណភាពទឹកនៅតាមតំបន់ទឹកសាធារណៈសម្រាប់អភិវឌ្ឍន៍ជីវៈចំរុះនៅក្នុងទឹក និងការពារសុខភាពសាធារណៈរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលទេ។ ដោយឡែក TSS គឺមានបរិមាណ៤៧ម.ក្រ/លីត្រ ពោលគឺប្រមាណជា ៤៧-៣,៥ដង ច្រើនជាងកម្រិតស្តង់ដារគុណភាពទឹកនៅតាមតំបន់ទឹកសាធារណៈសម្រាប់អភិវឌ្ឍន៍ជីវៈចំរុះនៅក្នុងទឹក និងការពារសុខភាពសាធារណៈរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល។ ប៉ុន្តែចំពោះ TN និង TP មានបរិមាណស្ថិតចន្លោះកម្រិតស្តង់ដារពោលគឺ 0.04/0.1-0.6mg/l និង 0.02/0.005-0.05mg/l ដោយឡែកៗពីគ្នា។

៧៥. លក្ខណៈគីមីៈ នៅក្នុងចំណោមថាវូប០៥ ផ្សេងទៀតមានថាវូបចំនួន ៣គឺ៖ Arsenic (As), Mercury (Hg) និង Chemical Oxygen Demand (COD) សុទ្ធតែមានវត្តមាននៅក្នុងសំណាកទឹកអូរនេះទាំងអស់ ប៉ុន្តែមានបរិមាណតិចជាងកំរិតស្តង់ដារពោលគឺៈ 0.0001/0.01, 0.0001/0.01 និង 3.83/1.0-8.0។ ដោយឡែក Cadmium (Cd) និង Lead (Pb) មិនបានពិនិត្យឃើញមានវត្តមាននៅក្នុងសំណាកទឹក

Draft

នេះទេ (ឧបសម្ព័ន្ធ៥-៣ លទ្ធផលវិភាគទឹករបស់ក្រសួងបរិស្ថានលេខ ៩៩ ពស ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៤)។

៧៦. តាមរយៈលទ្ធផលនៃការវិភាគគុណភាព**ទឹកសំណាកទី៤** (ទឹកព្រែកទេរ ភូមិម្បៀរ ឃុំថ្មី ស្រុកចិត្របុរី ខេត្តក្រចេះ ចំណុចនិយាមកាលេខ ៦៤៤៤៨៣-១៣៧៧៧៦៤) ដែលទទួលបានពីមន្ទីរពិសោធន៍របស់ក្រសួងបរិស្ថាន បានបង្ហាញថា:

៧៧. លក្ខណ:រូប: ចំពោះតុល្យភាពអ៊ីយ៉ុងអ៊ីដ្រូសែន pH = 7.06/6.50-8.5 ពោលគឺមានលក្ខណៈចន្លោះស្តង់ដារ។ ចំណែកឯថារូប០៣ ផ្សេងទៀតដូចជា៖ Biological Oxygen Demand (BOD), Oil & Grease, Ammonia (NH_3) មានបរិមាណ 2.36, 1.09, 0.12mg/l តែថារូបទាំងនេះក៏មិនទាន់បានកំណត់ក្នុងកម្រិតស្តង់ដារគុណភាពទឹកនៅតាមតំបន់ទឹកសាធារណៈសម្រាប់អភិវឌ្ឍន៍ជីវៈចំរុះនៅក្នុងទឹក និងការពារសុខភាពសាធារណៈរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ទេ។ ដោយឡែក TSS គឺមានបរិមាណ ៥០ម.ក្រ/លីត្រ ពោលគឺប្រមាណជាពី ៥០-៤ដង ច្រើនជាងកម្រិតស្តង់ដារគុណភាពទឹកនៅតាមតំបន់ទឹកសាធារណៈសម្រាប់អភិវឌ្ឍន៍ជីវៈចំរុះនៅក្នុងទឹក និងការពារសុខភាពសាធារណៈរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល។ ប៉ុន្តែចំពោះ TN និង TP មានបរិមាណស្ថិតចន្លោះកម្រិតស្តង់ដារពោលគឺ 0.45/0.1-0.6mg/l និង 0.03/0.005-0.05mg/l ដោយឡែកៗពីគ្នា។

៧៨. លក្ខណៈគីមី: នៅក្នុងចំណោមថារូប០៥ ផ្សេងទៀតមានថារូបចំនួន៥គឺ៖ Chemical Oxygen Demand (COD), Asenic (As), Cadmium (Cd), Lead (Pb) និង Mercury (Hg) សុទ្ធតែមានត្តមាននៅក្នុង សំណាកទឹកនេះទាំងអស់ ប៉ុន្តែមានបរិមាណតិចជាងកំរិតស្តង់ដារ ពោលគឺ៖ 4.15/1.0-8.0, 0.0003/0.01, 0.0002/0.001, ND/0.01, and 0.0004/0.0005mg/l (ឧបសម្ព័ន្ធ៥-៣ លទ្ធផលវិភាគទឹករបស់ក្រសួងបរិស្ថានលេខ ១០០ ពស ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៤)។

៧៩. តាមរយៈលទ្ធផលនៃការវិភាគគុណភាព**ទឹកសំណាកទី៥** (ទឹកអូរប្រើម ភូមិស្វាយជ្រុំ ឃុំថ្មី ស្រុកចិត្របុរី ខេត្តក្រចេះ ចំណុចនិយាមកាលេខ ៦៤០៨១-១៣៨១០៥៦) ដែលទទួលបានពីមន្ទីរពិសោធន៍របស់ក្រសួងបរិស្ថាន បានបង្ហាញថា:

៨០. លក្ខណៈរូប: ចំពោះតុល្យភាពអ៊ីយ៉ុងអ៊ីដ្រូសែន pH = 6.98/6.50-8.5 ពោលគឺមានលក្ខណៈចន្លោះស្តង់ដារ។ ចំណែកឯថារូប០៣ ផ្សេងទៀតដូចជា៖ Biological Oxygen Demand (BOD) , Oil & Grease, Ammonia (NH_3) មានបរិមាណ 1.89, 0.85, 0.14mg/l តែថារូបទាំងនេះក៏មិនទាន់បានកំណត់ក្នុងកម្រិតស្តង់ដារគុណភាពទឹកនៅតាមតំបន់ទឹកសាធារណៈសម្រាប់អភិវឌ្ឍន៍ជីវៈចំរុះនៅក្នុងទឹក និងការពារសុខភាពសាធារណៈរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ទេ។ ដោយឡែក TSS គឺមានបរិមាណ ៤១ម.ក្រ/លីត្រ ពោលគឺប្រមាណជាពី ៤១-៤ដង ច្រើនជាងកម្រិតស្តង់ដារគុណភាពទឹកនៅតាមតំបន់ទឹកសាធារណៈសម្រាប់អភិវឌ្ឍន៍ជីវៈចំរុះនៅក្នុងទឹក និងការពារសុខភាពសាធារណៈរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល។ ប៉ុន្តែចំពោះ TP មានបរិមាណស្ថិតចន្លោះកម្រិតស្តង់ដារពោលគឺ 0.45/0.1-0.6mg/l និង 0.03/0.005-0.05mg/l ដោយឡែកៗពីគ្នា។ ការវិភាគបង្ហាញថា បរិមាណ TN នៅក្នុងសំណាកទឹកគឺមានចំនួន ០,៧១ម.ក្រម.ក្រ/លីត្រ លើសកម្រិតបទដ្ឋានពី ០,៦១-០,១១ម.ក្រម.ក្រ/លីត្រ។

Draft

៨១. លក្ខណៈគីមីៈ នៅក្នុងចំណោមថារូប០៥ ផ្សេងទៀតមានថារូបចំនួន០២ គឺ៖ Chemical Oxygen Demand (COD) និង Mercury (Hg) សុទ្ធតែមានវត្តមាននៅក្នុងសំណាកទឹកនេះទាំងអស់ ប៉ុន្តែមានបរិមាណតិចជាងកំរិតស្តង់ដារ ពោលគឺ៖ 3.92/1.0-8.0 និង 0.0001/0.0005 ដោយឡែកចំពោះ Arsenic (As), Cadmium (Cd) និង Lead (Pb) គឺមិនបានពិនិត្យឃើញមាននៅក្នុងសំណាកទឹកនេះទេ (ឧបសម្ព័ន្ធ ៥-៣ លទ្ធផលវិភាគទឹករបស់ក្រសួងបរិស្ថានលេខ ១០១ ពស ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៤)។

Draft

តារាង៥-១៣ ៖ តារាងលទ្ធផលនៃការវិភាគទឹក

ល.រ	ប៉ារ៉ាម៉ែត្រ	ខ្នាត	ស្តង់ដា		លទ្ធផល				
			ទឹកក្រោមដី	ទឹកលើដី	សំណាកទី១	សំណាកទី២	សំណាកទី៣	សំណាកទី៤	សំណាកទី៥
១	pH		6.5-8.5	6.5-8.5	-	7.39	6.47	7.06	6.98
២	Total suspended Soild(TSS)	mg/l	-	1.0 – 15	-	53.00	47.00	50.00	41
៣	Biological Oxygen Demand (BOD)	mg/l	-	NV	-	2.04	1.6	2.36	1.89
៤	Chemical Oxygen Demand (COD)	mg/l	-	1.0 – 8.0	-	4.68	3.83	4.15	3.92
៥	Oil & Grease. Total Nitrogen (TN)	mg/l	-	NV	-	0.91	0.94	1.09	0.85
៦	Ammonia (NH3). Asenic (As)	mg/l	-	NV	-	0.05	0.08	0.12	0.14
៧	Total Nitrogen (TN)	mg/l	-	0.1 – 0.6	-	1.35	0.04	0.45	0.71
៨	Total Phosphorus (TP)	mg/l	-	0.005 – 0.05	-	0.02	0.02	0.03	0.02
៩	Asenic (As)	mg/l	0.5	0.01	ND	0.0003	0.0001	0.0003	ND
១០	Cadmium (Cd)	mg/l	0.003	0.001	ND	ND	ND	0.0002	ND
១១	Lead (Pb)	mg/l	0.01	0.01	ND	0.0002	ND	ND	ND
១២	Mercury (Hg)	mg/l	0.001	0.0005	ND	ND	0.0001	0.0004	0.0001
១៣	Conductivity (EC)	µS/m	NV		116,00				
១៤	Turbidity	NTU	5.0		0.00				

Draft

១៥	Total Dissolved Solid (TDS)	mg/l	800		94.00				
១៦	Total Hardness(as $CaCO_3$)	mg/l	300		49.72				
១៧	Chloride (Cl)	mg/l	250		3.05				
១៨	Sulphate (SO4)	mg/l	250		0.35				
១៩	Fluoride (F)	mg/l	1.50		0.16				
២០	Nitrite (NO_2)	mg/l	3.0		ND				
២១	Nitrate (NO_3)	mg/l	50		0.11				
២២	Iron (F)	mg/l	0.3		0.27				
២៣	Maganese (Mn)	mg/l	0.1		0.03				
២៤	Copper (Cu)	mg/l	1.0		0.004				
២៥	Lead (Pb)	mg/l	0.01		ND				
២៦	Nickel (Ni)	mg/l	0.02		0.0004				
២៧	Znc (Zn)	mg/l	3.0		0.01				
២៨	Cobalt (Co)	mg/l	NV		0.003				
២៩	Total Coliform	MPN/100ml	0		$2.0X10^3$				
៣០	Total Bacteria	Count/ml	100		385				

ប្រភព៖ មន្ទីរពិសោធន៍ទឹកនៃក្រសួងបរិស្ថាន

៥.៤.១.៣ គុណភាពដី

៨២. ក្រុមហ៊ុន **ដូទីសាយហ្គូន-ប៊ីហ្សៀក (អេស ប៊ី ខេ)** បានសហការជាមួយក្រុមហ៊ុន **Paperbark Forestry Consulting** ដើម្បីរៀបចំ **Soil Mapping and Interpretation for Rubber Plantation Development** នៅក្នុងដែនសម្បទានរបស់ក្រុមហ៊ុន។ យោងរបាយការណ៍ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៤ នេះ (ឧបសម្ព័ន្ធទី៥-៧) បង្ហាញនូវលទ្ធផលដូចខាងក្រោម៖

៥.៤.១.៣.១ ការអង្កេតនៅទីវាល

៨៣. ការសិក្សាបានគ្របដណ្តប់លើផ្ទៃដីទំហំ ២.២០០ហិកតា នៅរៀងរាល់ទំហំ ៥០០ម × ៣០០ម ម្តង។ ប៉ុន្តែជាក់ស្តែង ទំហំផ្ទៃដីដែលបានសិក្សាគឺមានទំហំធំជាងការកំណត់ខាងដើមច្រើនទៅទៀត គឺដោយសារវត្តមានប្រព័ន្ធប្រឡាយដែលមាននៅតាមសងខាងប្រព័ន្ធផ្លូវនៅក្នុងចំការ។ រាល់ទីតាំង (រណ្តៅ) អង្កេតនិមួយៗ (សរុបជាង១៤៦រណ្តៅ) ត្រូវបានកំណត់នូវចំណុចនិយាមកា និងធ្វើការវាយតម្លៃតាមរយៈការប្រើឧបករណ៍ខួងរណ្តៅ ខួងជម្រៅ ១,២០ម (ប្រសិនបើអាច) ឬតាមរយៈការជីករះពិនិត្យមើលមុខថ្មីនៅតាមប្រព័ន្ធប្រឡាយ ហើយធ្វើការវាយតម្លៃទៅលើចំណុចមួយចំនួនដូចជា៖ វាយនភាព, បរិមាណកាបូនសរីរាង្គ, បរិមាណល្បាយគ្រួស, កម្រាស់របស់ស្រទាប់និមួយៗ និងលក្ខណៈរបស់ស្រទាប់ខាងក្រោម, ពណ៌, ទម្រង់រូបភាព, សំណើម និង ជម្រៅរបស់ដីស្រទាប់លើ។

៥.៤.១.៣.២ ការធ្វើចំណាត់ថ្នាក់ដី

៨៤. ការធ្វើចំណាត់ថ្នាក់ដី គឺផ្អែកលើលទ្ធភាពរបស់ដីក្នុងការទ្រទ្រង់ដល់ដំណើរការលូតលាស់របស់ដំណាំកៅស៊ូរួមមាន៖

- ជម្រៅរបស់ដីស្រទាប់លើដល់ចំណុចដែលឬសចាក់ចុះក្រោមលែងបាន
- សណ្ឋានរបស់ដីដែលបង្ហាញអំពីកម្រិត, ជម្រៅ និងលក្ខណៈរបៀមទឹកដែលប្រែប្រួលទៅតាមរដូវកាល
- វត្តមានរបស់ថ្មអាចម៍ផ្កាយ, ថ្ម និងខ្សែថ្ម
- កត្តាដែលជះឥទ្ធិពលដល់លទ្ធភាពរក្សាទឹករបស់ដីពោលគឺ៖ ជម្រៅ និងវាយនភាពរបស់ដី និងភាគរយរបស់ថ្ម និងឬគ្រួសអាចម៍ផ្កាយ
- ជីជាតិរបស់ដីតាមការពិនិត្យអំពីកម្រាស់របស់ដីស្រទាប់លើ, បរិមាណកាបូនសរីរាង្គ និងវាយនភាព។

៨៥. ភាពជ្រាបទឹកបណ្តោះអាសន្ន ឬតាមរដូវកាលអាចកំណត់បានតាមរយៈពណ៌ ឬភាពចម្រុះរបស់ពណ៌នៅលើម៉ាទ្រិករបស់ដី ដូចជា៖ ពណ៌ក្រហមចាំងដូចពណ៌របស់ក្រូម និងពណ៌លឿងទុំ ឬមានលាយពណ៌ខ្មៅនៅកណ្តាលបញ្ជាក់ថាមានវត្តមានរបស់ដែក (Fe) និងម៉ង់ហ្គាណែស (Mn)។ វត្តមាន និងអវត្តមានលក្ខណៈទាំងនេះនៅក្នុងរង្វង់ជីកម្រាស់ ៥០ស.ម ខាងលើអាចព្យាករណ៍បានថាជាដីជាំទឹកតាមរដូវកាល និងអចិន្ត្រៃយ៍ និងមានលក្ខណៈជាតំបន់ទំនាបដីសើម។ បរិមាណរបស់គ្រួស ឬគ្រួសអាចម៍ផ្កាយត្រូវបានប៉ាន់ស្មាននៅក្នុងកម្រិតកំណើនពី ២៥ភាគរយ ទៅច្រើនជាង ២៥ភាគរយ ពោលគឺ ២៥, ៥០ និង ៧៥ភាគរយ។

Draft

៨៦. ដើម្បីធ្វើជាមូលដ្ឋានក្នុងការប្រៀបធៀប ដីត្រូវបានធ្វើចំណាត់ថ្នាក់ទៅតាមប្រព័ន្ធម៉ាឡេស៊ី (Parama-nanthan, 2012) និង South African and World Reference Base for Soil Resource Classification Systems (Soil Classification Working Group, 1991; FAO, 2006)។ ដោយសារការធ្វើចំណាត់ថ្នាក់ដី មានលក្ខណៈសាំញ៉ាំ និងដើម្បីរៀបចំនូវមូលដ្ឋានជាក់លាក់ក្នុងការផ្ដល់នូវអនុសាសន៍គ្រប់គ្រងដី **Paperbark Forestry Consulting** បានសម្រេចកំណត់យកការវិនិច្ឆ័យទៅលើភាពសមស្របនិងឬលទ្ធភាពរបស់ដីសម្រាប់ដំណាំកៅស៊ូតាមរយៈការពិនិត្យអំពីលក្ខណៈរបស់ដី ដែលជះឥទ្ធពលផ្ទាល់ទៅលើដំណុះរបស់រុក្ខជាតិដូចជា៖ ជម្រៅ និងកម្រិតនៃការបៀមទឹក, ភាគរយរបស់គ្រួស ឬគ្រួសអាចម៍ផ្កាយ, វាយនភាពរបស់ដី, រចនាសម្ព័ន្ធ និងបរិមាណកាបូនសរីរាង្គ។ យោងតាម Chan et all. (1975), Pushparajah and Amin (1977), Pushparajah and Yew (1997) បានធ្វើចំណាត់ថ្នាក់ទៅតាមលំដាប់ធ្លាក់ចុះនូវភាពសមស្របនិងឬ សក្ដានុពលភាពសម្រាប់ការដាំកៅស៊ូ មាន ០៥ចំណាត់ថ្នាក់ដូចមានបង្ហាញជូនក្នុង**តារាង៥-១៤**ខាងក្រោម៖

- **S1:** Highly Suitable, No limitations;
- **S2:** Very Suitable, few/some limitations;
- **S3:** Moderately Suitable, moderately limitations;
- **S4:** Marginally Suitable, many limitations;
- **S5:** Marginally Suitable to Unsuitable, serious limitations;

៨៧. ក្រៅពីចំណាត់ថ្នាក់ទាំង ០៥ខាងលើគឺមាន ០២ចំណាត់ថ្នាក់ផ្សេងទៀតគឺ

- **R1:** មានប្រព័ន្ធប្រឡាយរំដោះទឹកអចិន្ត្រៃយ៍ ឬពាក់កណ្ដាលអចិន្ត្រៃយ៍
- **R2:** មានប្រព័ន្ធប្រឡាយរំដោះទឹកតាមរដូវកាល ឬមានន័យថារីងស្ងួតនៅរដូវប្រាំង ប៉ុន្តែបានបន្សល់ទុកនូវស្នាមទឹកហូរនៅក្នុងរដូវវស្សា។

តារាង៥.១៤ លក្ខខ្នានសម្រាប់កំណត់ចំណាត់នៃភាពសមស្របរបស់ដីសម្រាប់ដំណាំកៅស៊ូ

អធិប្បាយ	ចំណាត់ថ្នាក់					ទ្រនាប់ប្រព័ន្ធផ្លូវទឹក	
	S1	S2	S3	S4	S5	R1	R2
ការកំណត់	គ្មាន	តិច	បង្គួរ	ច្រើន	ធ្ងន់ធ្ងរ	ទឹកអចិន្ត្រៃយ៍	ទឹករដូវកាល
						ខ្សែទឹក ឬដីសើម	ខ្សែទឹក ឬ ប្រឡាយ
សក្ដានុពលផលិតកម្ម	ខ្ពស់	បង្គួរ	ទាប-បង្គួរ	ទាប	ទាបខ្លាំង	គ្មានពត៌មាន	គ្មានពត៌មាន
ទិន្នផល(គក្រ/ឆ្នាំ)	>១៨០០	១២៥០-១៨០០	១១០០-១២៥០	១០០០-១១០០	<១០០០	គ្មានពត៌មាន	គ្មានពត៌មាន
លក្ខណៈរបស់ដី							
ជម្រៅដល់ស្រទាប់ថ្ម	>១០០	>៨០	<១០%	>២០	<២០	គ្មានពត៌មាន	គ្មានពត៌មាន
កម្រិតសំណើម*(៥០ស.ម)	-	-	W_1	W_2	W_3	គ្មានពត៌មាន	គ្មានពត៌មាន
បរិមាណគ្រួស (៥០ស.ម)	<១០%	<២៥%	<៥០%	<៥០%	<៧៥%	គ្មានពត៌មាន	គ្មានពត៌មាន
បរិមាណកាបូនសរីរាង្គ*	>បង្គួរ	>បង្គួរ	>ទាប	>ទាបខ្លាំង	>ទាបខ្លាំង	គ្មានពត៌មាន	គ្មានពត៌មាន
រចនាសម្ព័ន្ធរបស់ដី	a	w	m	s/l	-	-	-
បរិមាណដីឥដ្ឋ (៥០ស.ម)	>៣៥%	>២០%	>១០%	<១០%	-	-	-

*សំគាល់៖

- *កម្រិតសំណើមក្នុងរង្វង់កម្រាស់ដី ៥០ស.មខាងលើ
  - មានបៀមទឹកម្ដងម្កាល (ពណ៌ចម្រុះ មាននៅលើពណ៌ត្នោត)
  - មានបៀមតាមរដូវកាល, ដង្ហើមទឹកប្រែប្រួល (គ្មានពណ៌ចម្រុះ មាននៅលើពណ៌ប្រផេះ)

- មានបៀមទឹកអចិន្ត្រៃយ៍ (មានរលាំទឹកក្នុងរង្វង់កម្រាស់ដី ៥០ស.មខាងលើ)
- ᵇបរិមាណកាបូនសរីរាង្គ
  - ខ្ពស់ (មានមោគច្រើនជាង២ភាគរយ)
  - បង្គួរ (មានមោគពី ១-២ភាគរយ)
  - ទាប (មានមោគពី ០,៥-១ភាគរយ)
  - ទាបខ្លាំង (មានមោគតិចជាង ០,៥ភាគរយ)
- ᶜរចនាសម្ព័ន្ធរបស់ដី
  - a - មានរចនាសម្ព័ន្ធជាដីដែលសម្បូរណ៍ជាជាតិ
  - w- ដីមានរចនាសម្ព័ន្ធខ្សោយ
  - m-មានរចនាសម្ព័ន្ធជាដីបង្គួរ
  - s - មានរចនាសម្ព័ន្ធជាដីស្អិត
  - l - មានរចនាសម្ព័ន្ធជាដីដែលសម្បូរណ៍ដោយថ្ម ឬមានថ្មជានៅពីក្រោម

៥.៤.១.៣.៣ របាយនៃប្រភេទដី និងការការគ្រប់គ្រងដី

៨៨. ដីនៅក្នុងដែនសម្បទាបរបស់ក្រុមហ៊ុន **ដូទីសាយហ្គុន-ប៊ិញហ្វឿក (អេស ប៊ី ខេ)** ជាទូទៅមានសណ្ឋានជាដីដែលកំណត់អំពីកម្រិតនៃការចាក់ឫស, បរិមាណនៃការរីកធំធាត់របស់ឫស, លទ្ធភាពរក្សាដី និងទឹក, ការដេកដង្ហើមរបស់ដី ដូចជាមានបរិមាណគ្រួសច្រើន, ជាដីបៀមទឹក, សម្បូរណ៍ថ្មរឹង (Plinthite or Laterite) ហើយនិងនៅកន្លែងមួយចំនួនជាដីដែលមានល្បាយខ្សាច់ច្រើន។ យោងលើភាពសមស្របសម្រាប់ដំណាំកៅស៊ូ ដីនៅក្នុងដែនសម្បទានរបស់ ក្រុមហ៊ុន **ដូទីសាយហ្គុន-ប៊ិញហ្វឿក (អេស ប៊ី ខេ)** ត្រូវបានបែងចែកជា ០៦ប្រភេទ ភាគច្រើនជាដីទាមទារឲ្យមានការកែលម្អ (Amelioration Potential), ត្រូវការប្រព័ន្ធរំដោះទឹក, ដី និងប្រឡាយនិងការហូរច្រោះ (**តារាង៥-១៥ និង៥-១៦ និង៥-១៧** នៃរបាយការណ៍ដី)។ ក្នុងដីទាំង ០៦ចំណាត់ថ្នាក់នេះ ដីមានលក្ខណៈសមស្របជាងគេគឺស្ថិតនោះក្នុងចំណាត់ថ្នាក់ប្រភេទ **B** និង **C1** (**តារាង៥-១៧** នៃរបាយការណ៍ដី)។ ប៉ុន្តែដីទាំង០២ប្រភេទនេះ មានទំហំសរុបប្រមាណតែ ៥០០ហិកតា ក្នុង០១ប្រភេទប៉ុណ្ណោះ ហើយដីទាំង០២ប្រភេទនេះ មានសណ្ឋានជាជម្រាលដែលមានមុំទាបទៅទាបមធ្យម (**រូបភាព ៥-១ ផែនទី៥-១៦** នៃរបាយការណ៍ដី)។ ដីដែលមានស្រទាប់ជ្រៅ (Soil Association A) ពិនិត្យឃើញមាននៅផ្នែកពាយ័ព្យ និងផ្នែកខាងជើងរបស់ដីសម្បទាននេះ ហើយជាដីដែលមានសណ្ឋានរាបស្មើ និងមិនទាន់ទទួលការសឹកដាច់ ឬហូរច្រោះនៅឡើយទេ (**រូបភាព ៥-១ ផែនទី៥-១៦** នៃរបាយការណ៍ដី)។ ដីនេះមានទំហំ ប្រមាណជា ១៥ភាគរយនៃផ្ទៃដីសរុបដែលបានអង្កេត (**តារាង៥-១៦** នៃរបាយការណ៍ដី)។ ដីដែលមានចំណាត់ថ្នាក់ជាប្រភេទ **C2** មានទំហំសរុបប្រមាណជា ៥ភាគរយនៃផ្ទៃដីដែលបានអង្កេត ហើយស្ថិតនៅរាយប៉ាយនៅទូទាំងតំបន់សិក្សា។ ដីប្រភេទ **C2** ដែលមានទំហំធំគឺ ៧១ ហិកតា ស្ថិតនៅផ្នែកខាងកើតនៃដីដែលទើបតែឈូសសម្អាតហើយថ្មីៗ (**រូបភាព ៥-១, ៥-២ ផែនទី៥-១៦, ៥-១៧ និងតារាង ៥-១៧** នៃរបាយការណ៍ដី)។ ដីដែលមានចំណាត់ថ្នាក់ជាប្រភេទ **D** និង**E** ភាគច្រើនជាដីទំហំសរុបប្រមាណជា ២៥ភាគរយ នៃផ្ទៃដីដែលបានអង្កេត និងជាដីដែលរាបស្មើហើយលាត

សន្និងរហូតដល់ព្រំខាងលិចរបស់ដីសម្បទាន (តារាង៥-១៥ និងតារាង ៥-១៧ និង រូបភាពទី១-២ (ផែនទី៥-១៦, ៥-១៧) នៃរបាយការណ៍ដី)។

៨៩. **ដីប្រភេទ A (Soil Association A)** ៖ ជាដីដែលមានបរិមាណគ្រួសតិច ជាដីល្បាយខ្សាច់មានដីជាតិល្អ មានពណ៌លឿង ត្នោត ហើយកន្លែងខ្លះជាដីឥដ្ឋល្បាយខ្សាច់ (**តារាង៥-១៥** នៃរបាយការណ៍ដី)។

៩០. **ដីប្រភេទ B (Soil Association B)** ៖ ជាដីដែលមានបរិមាណគ្រួសច្រើនបង្ករនៅ៥០ស.មខាងលើ (ប្រមាណជា ២៥-៥០ភាគរយ) ហើយភាគច្រើនជាថ្មរឹង។ ប៉ុន្តែកន្លែងខ្លះគ្មានវត្តមានថ្មនៅក្នុងដីស្រទាប់លើនោះទេ។ ដីប្រភេទនេះពិនិត្យឃើញមាននៅផ្នែកខាងលិចរបស់ដីសម្បទាន (**រូបភាពទី៥-១ (ផែនទី ៥-១៦)** នៃរបាយការណ៍ដី)។ ដោយសារដីស្រទាប់លើរាក់ កម្រិតរំដោះទឹកខ្សោយ ហើយសម្បូរណ៍ថ្ម ដូច្នេះ ដីប្រភេទនេះត្រូវបានធ្វើចំណាត់ថ្នាក់ថាជាដីប្រភេទ S3-S4 (**តារាង ៥-១៤ តារាង ៥-១៥ និងតារាង ៥-១៧ (រូបភាព ៥-១, ៥-២ ផែនទី៥-១៦,៥-១៧)** នៃរបាយការណ៍ដី)។

៩១. **ដីប្រភេទ C1 និង C2 (Soil Association C1 and C2)** ៖ ដីប្រភេទនេះភាគច្រើនពិនិត្យឃើញមាននៅផ្នែកកណ្ដាលរបស់ដីសម្បទាន ដែលមានសណ្ឋានជាដីកូនភ្នំតូចៗ សម្បូរណ៍ថ្មដែលភាគច្រើនពិនិត្យឃើញមាននៅតាមទីទួល ជាដីមានពណ៌ក្រហមព្រឿងៗ ហើយបរិមាណគ្រួសនៅក្នុងកម្រាស់៥០ស.ម ខាងលើមានបរិមាណច្រើនជាង ៥០ភាគរយ (**តារាង៥-១៥** នៃរបាយការណ៍ដី)។ ជាញឹកញាប់ពិនិត្យឃើញថា វត្តមានគ្រួសមានជម្រៅជ្រៅជាង ៥០ស.ម ជាគ្រួសរឹង **(Plinthite)**។ ដោយសារដីនេះសម្បូរណ៍ថ្ម ដូច្នេះ លទ្ធភាពរក្សាទឹកគឺទាបខ្លាំងណាស់ ហើយដីប្រភេទនេះត្រូវបានធ្វើចំណាត់ថ្នាក់ថាជាដីប្រភេទ S5។

តារាង៥-១៥៖ ការពណ៌នាអំពីទំនាក់ទំនងរវាងប្រភេទដី និងភាពសមស្របសម្រាប់ដំណាំកៅស៊ូ

ប្រភេទដី	A	B	C1	C2	D	E
អធិប្បាយ	វាយនភាពម៉ត់, ជម្រៅជ្រៅ, ជង្រើមទឹកប្រែប្រួល មានថ្ម <២៥ភាគរយ	ស្រទាប់ដីរាក់, ខ្សែថ្មនៅកម្រាស់ ៥០ស.ម ខាងលើ ជៀម ទឹកតាមរដូវកាល	គ្រួសមាន កម្រាស់>៥០ស.ម ជាថ្មរឹង ជៀមទឹក តាមរដូវកាល ឬអចិន្ត្រៃយ៍	គ្រួសមានកម្រាស់ >៥០ស.ម មាន ថ្មច្រូងច្រាង កម្រាស់១០០ស.ម និងជៀមទឹក នៅកម្រាស់៥០ស.ម	ល្បាយខ្សាច់ច្រើន ថ្មតិច តែជង្រើមទឹក មានជម្រៅ៥០ស.ម	ល្បាយខ្សាច់ច្រើន ថ្មអាចម៍ផ្កាយតិច ថ្ម Plinthite មាន កម្រាស់៥០ស.ម
ទម្រង់ដី	**Avalon (Av),** Sepane (Se), Clovelly (Cv)	**Westleigh (We),** Longlands (Lo), Mispash (Ms), Pinedene (Pn)	**Oakleaf (Oa),** Tukulu (Tu), Kroonstad (Kd), Glenceo (Gc)	**Oakleaf (Oa),** Tukulu (Tu), Clovelly (Cv), Avalon (Av)	**Longlands (Lo),** Westleigh (We)	**Westbank (Wa),** Dresden (Dr)
ក្រុមរបស់ដី	Acrisols Lixisols Planosols	Plinthosols Leptosols Gleysols	Plinthosols	Regosols	Plinthosols Arenosols Spodosols	Plinthosols Arenosols
សេរីដី (ម៉ាឡេស៊ី)	Kohoi Kuah	Pedu Gajah Mati Nerang	Malacca	Jitra	(Rasau)	-
ជម្រៅដល់ ស្រទាប់ថ្ម	៥០-១០០	<៥០	គ្មានពត៌មាន	>៥០	៤០-៨០	>៥០
Limiting Horizon	**Soft Plinthite** Predocutanic B Weathering Material	**Stone Line (Gravel)** Soft Plinthite B Gley	**Gravel** Hard Plinthite B Soft Plinte B	**Gravel** Weathering Material	**Sandy E Horizon** Soft Plinthite B	**Sandy E Horizon** hard Plinthite B

Draft

ភាគរយថ្មអាចម៍ផ្កាយ	០-២៥ភាគរយ	២៥-៥០ភាគរយ	>៥០ភាគរយ	>៥០ភាគរយ	០-១០ភាគរយ	០-១០ភាគរយ
វាយនភាពរបស់ដី* (A) (B) (C)	SL/SCL/CL - SCL/SC/C	SL/SCL/CL SL SL/SCL/SC	SL/SCL LS/SL SC	SL/SCL - (SCL)	S/LS S SC	S/LS S -
ការរំដោះទឹករបស់ដី	បង្គួរ-ល្អ	ខ្សោយ	លឿន-ខ្សោយ	បង្គួរ	ខ្សោយ	ខ្សោយខ្លាំង
កាបូនសរីរាង្គ	ទាប-បង្គួរ	ទាប-បង្គួរ	ខ្សោយខ្លាំង	បង្គួរ	ខ្សោយ	ខ្សោយខ្លាំង
Available Water Capacity	បង្គួរ-ខ្ពស់	ទាប-បង្គួរ	ខ្សោយខ្លាំង	ខ្សោយ	ខ្សោយខ្លាំង	ខ្សោយខ្លាំង

សំគាល់៖

- [a] S – Sand; LS – Loamy Sand; SL – Sandy Loam; SCL – Sandy Clay Loam; SC – Sandy Clay; CL – Clay Loam; C – Clay

តារាង៥-១៦៖ ការពណ៌នាអំពីទំនាក់ទំនងរវាងប្រភេទដី និងភាពសមស្របសម្រាប់ដំណាំកៅស៊ូ

ប្រភេទដី	A	B	C1	C2	D	E
Suitability Class	S1-S3	S3-S4	S5	S4	S4	S5
Ameliorated Class	S1-S2	S2-S3	S4	S3	S3	S4
Erosion Risk	Low-Moderate	Moderate-High	High	Moderate-High	High	Very High
ការរៀបចំដី	ខួងជម្រៅ៨០ស.ម	ខួងជម្រៅ៨០ស.ម	ស្តង់ដារ	ស្តង់ដារ	ស្តង់ដារ Soil Should Not be Ripped	ស្តង់ដារ Soil Should Not be Ripped
តម្រូវការប្រព័ន្ធរំដោះទឹក	គ្មាន	ត្រូវការ ប្រឈមនិងការហូរច្រោះខ្ពស់ (R2) ហាមភ្ជួរដី	គ្មាន ប្រឈមនិងការហូរច្រោះខ្ពស់ (R2) ហាមភ្ជួរដី	គ្មាន គ្មាន	ត្រូវការ ប្រឈមនិងការហូរច្រោះខ្ពស់ (R2) ហាមភ្ជួរដី	ត្រូវការ ប្រឈមនិងការហូរច្រោះខ្ពស់ (R2) ហាមភ្ជួរដី
ការអភិរក្សទឹក	មិនសំខាន់	មិនសំខាន់	សំខាន់ខ្លាំង	សំខាន់	សំខាន់ខ្លាំង	សំខាន់ខ្លាំង
ជីជាតិដី	បង្គួរ	បង្គួរ-ខ្សត់ជីជាតិ	ខ្សត់ជីជាតិខ្លាំង	ខ្សត់ជីជាតិ	ខ្សត់ជីជាតិខ្លាំង	ខ្សត់ជីជាតិខ្លាំង
តម្រូវការផ្តល់ជី [a]	ModNPK	ModNPK	Very HighN, HighP and ModK Organic Manure[c]	HighNP and ModK Organic Manure[c]	Very HighN, HighP and ModK Organic Manure[c] Split Fertilizers	Very HighN, HighP and ModK Organic Manure[c] Split Fertilizers
N Fixing Cover Crops	ត្រូវការ	ត្រូវការ	ត្រូវការចាំបាច់	ត្រូវការចាំបាច់	ត្រូវការចាំបាច់	ត្រូវការចាំបាច់
របបនៃការផ្តល់ជី [b]	Clay Loam	Clay Loam	Sandy	Sandy	Sandy	Sandy

សំគាល់៖

- [a] អាស្រ័យនឹងលទ្ធផលនៃការវិភាគដី
- [b] អាស្រ័យនឹងកាលវិភាគនៃការផ្តល់ជីពីមុនមក
- [c] ជីលាមកសត្វ និងជីសរីរាង្គអាចត្រូវធ្វើការកែសម្រួល ដោយអាស្រ័យនឹងលទ្ធផលនៃវិភាគដី ព្រោះថាដីសម្បូរណ៍ខ្សាច និងថ្មត្រូវការជីច្រើន

Draft



Paperbark Forestry Consulting

រូបភាព៥.១ ផែនទី៥-១៦ របាយ និងទំហំនៃប្រភេទដី ដែលអាចធ្វើការកែលម្អបាន

រូបភាព៥.២ ផែនទី៥-១៧ របាយ និងទំហំនៃប្រភេទដី នៅផ្នែកពាយ័ព្យនៃដីសម្បទានដែលអាចធ្វើការកែលម្អបាន

៩២. **ដីប្រភេទ D និង E៖** ដីប្រភេទ D និង E ពិនិត្យឃើញមាននៅតាមស្នាមផ្លូវទឹកចាស់ៗ ព្រោះឃើញមានដីខ្សាច់ និងល្បាយខ្សាច់ម៉ត់នៅពីខាងលើ។ ចំពោះដីល្បាយខ្សាច់ (E) និងស្រទាប់ថ្មទន់ (Soft Plinthite) នៅពីក្រោមបញ្ជាក់អំពីបម្រែបម្រួលដង្ហើមទឹកដែលស្ថិតក្នុងចន្លោះពី ៤០-១០០ស.ម (D) ឬក៏មានការប្រែប្រួលភ្លាមៗណាមួយដែលធ្វើអោយដីប្រភេទ E នៅពីលើថ្មរឹង (Hard Plinthite/Laterite) តែទោះជាមានករណី០២យ៉ាងនេះក្តី ដីប្រភេទនេះភាគច្រើនគឺគ្មានគ្រួស ឬក៏មានតិចជាង ១០ភាគរយ (**តារាង ៥-១៤** នៃរបាយការណ៍ដី)។

៩៣. **ទំនាបដីសើម ឬដីនៅតាមប្រព័ន្ធផ្លូវទឹក៖** ទំនាបដីសើម និងដីតាមដងប្រព័ន្ធផ្លូវទឹកក៏ត្រូវបានធ្វើការកំណត់នៅក្នុងការសិក្សានេះដែរ តែដីប្រភេទមិនមានលក្ខណៈសមស្របសម្រាប់ការដាំដុះទេ។ ជាក់ស្តែង ដីប្រភេទ R1 ភាគច្រើននៅតាមបណ្តោយប្រព័ន្ធប្រឡាយរំដោះទឹក ដែលមានទឹកហូរជាអចិន្ត្រៃយ៍ ឬក៏ស្ថិតនៅខាងក្រោមផ្ទៃ (មុខ) លើបន្តិចតែប៉ុណ្ណោះ។ ដូច្នេះ ដីប្រភេទនេះមិនអាចធ្វើការភ្ជួររាស់បានទេ។ ចំពោះដីប្រភេទ R2 វិញជាដីដែលស្ថិតនៅតាមប្រព័ន្ធរំដោះទឹកដែរ តែមានទឹកតាមរដូវកាល ដីប្រភេទនេះក៏មិនអាចធ្វើការភ្ជួររាស់បានដែរ ព្រោះដីទាំងពីរប្រភេទនេះប្រឈមនឹងការហូរច្រោះ ឬសឹកដាច់ខ្ពស់ណាស់ (**តារាង៥-១៦** នៃរបាយការណ៍ដី)។

៩៤. **ការទាមទារឲ្យមានការកែលម្អដី (Soil Amelioration Potential)៖** យោងតាមការបកស្រាយខាងលើ ដីភាគច្រើន (៨០ភាគរយ) នៅក្នុងដែនសម្បទាន ជាដីដែលមិនសមស្របសម្រាប់ការលូតលាស់របស់ដំណាំកៅស៊ូ (S4-S5) ដីទាំងនេះភាគច្រើនសម្បូរណ៍គ្រួស ដីស្រទាប់លើរាក់ ជាដីបៀមទឹក និងខ្សោះជីជាតិ (**តារាង៥-១៦** និង**តារាង៥-១៧(a)** នៃរបាយការណ៍ដី)។ ប៉ុន្តែ ប្រសិនមានផែនការកែលម្អដូចបញ្ជាក់ជូននៅក្នុង **តារាង ៥-១៥** នៃរបាយការណ៍ដី នោះប្រភេទដីមួយចំនួនអាចទៅជាសមស្របសម្រាប់ដំណាំកៅស៊ូវិញ។ ប្រភេទដីដែលត្រូវធ្វើការកែលម្អគឺ ដីប្រភេទ **A** និង **B, C** និង **D**។ ហើយក៏មានការជឿជាក់ដែរថា ដីប្រភេទ **C1** និង **E** ក៏អាចធ្វើការកែលម្អបានដែរប្រសិនបើមានការអន្តរាគមន៍ និងគ្រប់គ្រងច្បាស់លាស់ ហើយផលចំណេញក្នុងការលូតលាស់ ក្នុង០១ឯកតា សម្រាប់ការគ្រប់គ្រង គឺមានចំនួនតិចជាងដីប្រភេទ A និង B ព្រោះដីពីប្រភេទនេះនៅមានចំណុចខ្វះចន្លោះច្រើនដែលត្រូវធ្វើការកែលម្អ (S4)។ ដូច្នេះការអន្តរាគមន៍ និងគ្រប់គ្រងច្បាស់លាស់អាចបង្កើនលទ្ធភាពដី ពីដីដែលមានលទ្ធភាពបង្ហូរ, ទាប ឬខ្សោះជីជាតិ ឡើងដល់ទៅ៥០ភាគរយ នៅលើទំហំផ្ទៃដីសរុបដែលបានសិក្សា (**តារាង ៥-១៧(b)** នៃរបាយការណ៍ដី)។ ប្រភេទដីដែលសមស្របសម្រាប់ធ្វើការកែលម្អនៅក្នុងដែនសម្បទានរបស់ក្រុមហ៊ុនដូទីសាយហ្គូន-ប៊ិញហ្សឿក (អេស ប៊ី ឌេ) មានបង្ហាញជូនក្នុងរូបភាព ៥-១ និង៥-២(**ផែនទី៥-១៦, ៥-១៧**) នៃរបាយការណ៍ដី។

តារាង ៥-១៧ ៖ទំហំប្រភេទដីនិមួយៗ និងភាពសមស្របរបស់ដី (a)

ដីដែលមិនអាចធ្វើការកែលម្អ	ប្រភេទចំណាត់ថ្នាក់ដី						សរុប
	A	B	C1	C2	D	E	
ភាពសមស្រប	ហិកតា						
S1	៤៦,០	០,០	០,០	០,០	០,០	០,០	៤៦,០
S2	៤២,២	០,០	០,០	០,០	០,០	០,០	៤២.២

S3	១៩៧,៥	១២៤,៥	០,០	០,០	០,០	០,០	៣២២.០
S4	៣៤,៥	៣៧៧,៦	០,០	១១៦,២	៣៥៨,៤	០,០	៨៨៦.៨
S5	០,០	០,០	៥៤៤,៨	០,០	០,០	៣០១,០	៨៤៥.៨
R1/R2							៣៣១,៤
	៣២០,៣	៥០២,១	៥៤៤,៨	១១៦,២	៣៥៨.៤	៣០១,០	
							២.៤៧៤,២

តារាង ៥ -១៧ ៖ទំហំប្រភេទដីនិមួយៗ និងភាពសមស្របរបស់ដី និងក្រោយពេលកែលម្អ (b)

ដីដែលអាចធ្វើការកែលម្អ	ប្រភេទចំណាត់ថ្នាក់ដី						សរុប
	A	B	C1	C2	D	E	
ភាពសមស្រប	ហិកតា						
S1	៨៨,០	០,០	០,០	០,០	០,០	០,០	៨៨,០
S2	១៩៧,៥	១២៤,៥	០,០	០,០	០,០	០,០	៣២២.០
S3	៣៤,៦	៣៧៧,៦	០,០	១១៦,២	៣៥៨,៤	០,០	៨៨៦.៨
S4	០,០	០,០	៥៤៤,៨	០,០	០,០	៣០១,០	៨៤៥.៨
S5	០,០	០,០	០,០	០,០	០,០	០,០	០,០
R1/R2							៣៣១,៤
	៣២០,៣	៥០២,១	៥៤៤,៨	១១៦,២	៣៥៨.៤	៣០១,០	
							២.៤៧៤,២

Draft

សំគាល់៖ បទពិសោធន៍ក្នុងការរៀបចំដីកន្លងមកគឺភ្ជួរត្រឡប់យកឬស និងរៀបចំប្រព័ន្ធរំដោះទឹក។ បទពិសោធន៍បាននាំមកនូវកំណត់សំគាល់មួយចំនួនដូចខាងក្រោម៖

- ការហូរច្រោះបណ្តាលមកពីការភ្ជួរ និងរាស់នៅធ្លានៃប្រព័ន្ធរំដោះទឹកធម្មជាតិ
- បំណែក (គំនរ) ដីដែលកើតពីការខួងរណ្តៅ នៅលើប្រភេទដីដែលមានដង្ហើមទឹករាក់
- រណ្តៅមានជម្រៅ ១ម និងអង្កត់ផ្ចិត ៦០ស.ម ដោយខួងទម្លុះស្រទាប់ខាងក្រោម ក្នុងករណីនេះ បើមើលពីលើទៅឃើញមានការរំខានប្រមាណតែ ១,៥ភាគរយនៃផ្ទៃលើប៉ុណ្ណោះ ប៉ុន្តែបានធ្វើមិនឲ្យទឹកជ្រាបទៅក្រោមបាន

៩៥. ដីចំណាត់ថ្នាក់ប្រភេទ A និង B អាចធ្វើការកែលម្អបានតាមរយៈការភ្ជួរជ្រោយអោយបានជ្រៅ ដើម្បីកែលម្អការរំដោះទឹក និងបង្កើនលទ្ធភាពផលិតកម្ម។ ដីសម្បូរណ៍ថ្ម ដែលជួបប្រទះនៅក្នុងចំណាត់ថ្នាក់ដីប្រភេទ C1 និង C2 និងល្បាយខ្សាច់ច្រើនដែលជួបប្រទះនៅក្នុងចំណាត់ថ្នាក់ដីប្រភេទ D និង E មិនចាំបាច់ធ្វើការភ្ជួរជ្រោយអោយជ្រៅទេ ពីព្រោះវាមិនអាចមានលទ្ធផលល្អ ហើយម៉្យាងទៀតវានឹងធ្វើអោយមានការហូរច្រោះខ្លាំង។ ការភ្ជួររាស់បំបែកដីអាចធ្វើបាននៅលើប្រភេទដី A និង B នៅក្នុងរដូវប្រាំងនៃឆ្នាំបន្ទាប់ នៅតាមចន្លោះរងដើម្បីកែលម្អការរំដោះទឹក និងការចាក់ឫសរបស់ដំណាំដែលបានដាំរួច។

៥.៤.២ រុក្ខអេកូឡូស៊ី

៥.៤.២.១ ស្ថានភាពព្រៃក្នុងតំបន់សិក្សា

៩៦. តាមការគណនាលើប្រព័ន្ធព័ត៌មានភូមិសាស្ត្រ ដោយប្រើប្រាស់ផែនទីគម្របព្រៃឈើឆ្នាំ ២០១០ របស់រដ្ឋបាលព្រៃឈើ (មើលវិធីសាស្ត្រក្នុងជំពូកទី២ ចំណុច២.២.១.១) និងទិន្នន័យប្រើប្រាស់ដីបច្ចុប្បន្ន របស់ក្រុមហ៊ុនដូទីសាយហ្គន-ប៊ិញហ្សៀក (អេស ប៊ី ខេ) បានបង្ហាញថា ផ្ទៃដីព្រៃមានប្រមាណ ៥៩០០ហិកតា ឬស្មើនឹង ៦១% នៃទំហំផ្ទៃដីសរុបដែលបានធ្វើការសិក្សាវាយតម្លៃ ក្នុងនោះដីព្រៃប្រមាណ ៣២ហិកតា ត្រូវបានរក្សាទុកជាព្រៃសម្រាប់កប់ខ្មោចរបស់សហគមន៍ជនជាតិភាគតិច ដែលមានចំណុចនិយាមកា ៦៤១៤១០-១៣៧១៩១៥ (រូបភាពទី ៥-៤៖ ផ្នូរកប់ខ្មោចរបស់ជនជាតិ)។ រូបភាពបង្ហាញអំពីស្ថានភាពព្រៃឈើក្នុងតំបន់ដីសម្បទានដែលមិនទាន់ធ្វើការឈូសឆាយដើម្បីដាំកៅស៊ូ មានបង្ហាញនៅខាងក្រោម (រូបភាព៥-៣ ដល់ ៥-៩)។

៩៧. យោងតាមការធ្វើចំណាត់ថ្នាក់ប្រភេទព្រៃបង្ហាញថា ស្ថានភាពព្រៃក្នុងតំបន់គម្រោងក្នុងពេលបច្ចុប្បន្ននេះអាចធ្វើការបែងចែកជា ០៣ប្រភេទសំខាន់រួមមាន៖ ព្រៃពាក់កណ្តាលស្រោង ២៩០ហិកតា ព្រៃល្បោះ ៥.៦៩៦ហិកតា និងព្រៃគុម្ពោតស្ងួត ៦៥ហិកតា (ព្រៃនេះមិនត្រូវបានយកមកសិក្សាទេព្រោះមានលក្ខណៈជាព្រៃបុស្ស) និងក្រៅពីនេះជាដីគ្មានគម្របព្រៃឈើ ៦២៩ហិកតា (ដីពាក់ព័ន្ធនឹងប្រជាពលរដ្ឋ) និងដីដែលក្រុមហ៊ុនបាននឹងកំពុងរៀបចំដាំដុះដំណាំកៅស៊ូ។ ស្ថានភាពព្រៃឈើក្នុងតំបន់នេះត្រូវបានរំខានស្ទើរទាំងស្រុងដោយសារការធ្វើចម្ការរបស់ពលរដ្ឋ ទាំងក្នុងស្រទាប់ព្រៃពាក់កណ្តាលស្រោង និងព្រៃល្បោះ (ផែនទី៥-១០)។

រូបភាពទី៥-៣៖ ស្ថានភាពព្រៃល្បោះ(ព្រៃរក្សាទុកកប់ខ្មោចរបស់ជនជាតិ) ឡូត៍ទី១២(៦៤១៤១០-១៣៧១៩១៥)

រូបភាពទី៥-៤៖ ផ្នូរកប់ខ្មោចរបស់ជនជាតិ ចំនុចនិយាមកា (៦៤១៥១៦-១៣៧២០៥៨)

រូបភាពទី ៥-៥៖ ស្ថានភាពព្រៃពាក់កណ្តាលស្រោង ឡូត៍-អនុឡូត៍ P4. UTM (641162-1375694)

Draft



រូបភាពទី ៥-៦៖ ស្ថានភាពសារព័ន្ធរុក្ខជាតិតាមដងអូរ ក្នុងព្រៃពាក់កណ្តាលព្រៃស្រោង (៦៤១៣១៤-១៣៧៥៤៥៨)



រូបភាពទី ៥-៧៖ស្ថានភាពសារព័ន្ធរុក្ខជាតិតាមដងអូរ ក្នុងព្រៃល្បោះ (៦៤៤៥១៣-១៣៧៧៨៦០)



រូបភាពទី ៥-៨៖ សកម្មភាពដាក់តាំងឡូត៍-អនុឡូត៍គម្រូ ឡូត៍ទី ២០(និយាមកា ៤៣៦០៤៣-១៥៦៨៧០៣)

រូបភាពទី ៥-៩៖ព្រៃពាក់កណ្តាលស្រោង ឡូត៍ទី ៥(និយាមកា ៦៣៩៩១៣-១៣៧៦០៨០)

៥.៤.២.២ សារព័ន្ធរុក្ខជាតិក្នុងតំបន់សិក្សា

៩៨. យោងលទ្ធផលសិក្សាអំពីសារព័ន្ធរុក្ខជាតិនៅក្នុងតំបន់សម្បទាននេះបង្ហាញថា មានសារព័ន្ធរុក្ខជាតិប្រមាណជា ៧១ប្រភេទ ជាឈើខ្ពស់ៗ និង២៩ប្រភេទ ជារុក្ខជាតិស្រទាប់ចម្រុះ មានដូចជាពពួកមើម វល្លិ ស្មៅ និងស្បូវជាដើម ដែលក្រុមការងារបានជួបប្រទះ និងកត់ត្រា នៅក្នុងឡូត៍-អនុឡូត៍គម្រូទាំងអស់ (ឧបសម្ព័ន្ធ៥-៤ **តារាងទី៥-១៨៖ស្តីពីប្រភេទសារព័ន្ធរុក្ខជាតិ និងការប្រើប្រាស់របស់វា**)។ ក្នុងចំណោមឈើទាំង ៧១ប្រភេទនេះ មាន ៤៦ប្រភេទ បានកត់ត្រាក្នុងឡូត៍-អនុឡូត៍ នៅក្នុងព្រៃល្បោះ ៣៨ប្រភេទ កត់ត្រាក្នុងឡូត៍-អនុឡូត៍គម្រូ ក្នុងព្រៃពាក់កណ្តាលស្រោងរេចរឹល និង ២៨ប្រភេទ កត់ត្រាក្នុងឡូត៍-អនុឡូត៍ នៅក្នុងព្រៃតាមដងអូរ។ តាមឯកសាររុក្ខជាតិប្រើប្រាស់នៅកម្ពុជាសិក្សាស្រាវជ្រាវដោយ ឌីផុន ប៉ូលីន ឆ្នាំ២០០០ និងរបាយការណ៍ភូមិគាមសាស្ត្ររុក្ខជាតិរបស់ក្រសួងបរិស្ថាន ឆ្នាំ២០០២ បានបង្ហាញថា ប្រទេសកម្ពុជាមានរុក្ខជាតិប្រមាណជា ២៣០៨ប្រភេទក្នុងចំណោម ៨០០០ប្រភេទ ដែលបានពិពណ៌នានៅតំបន់ឥណ្ឌូចិន ដែលត្រូវបានគេចាត់ជា ៨៥២ប្រភេទ ១៦៤គ្រួសារ។ ដូច្នេះ សារព័ន្ធរុក្ខជាតិដែលមានវត្តមាន

ក្នុងតំបន់សិក្សានេះគឺមានប្រមាណតែ ៤,៣៣ភាគរយ នៃប្រភេទរុក្ខជាតិសរុប ២៣០៨ប្រភេទ ដែលមាននៅក្នុងប្រទេសកម្ពុជាប៉ុណ្ណោះ។

៩៩. មានឈើចំនួន ១៨ប្រភេទ ក្នុងចំណោមឈើ ៧១ប្រភេទ ត្រូវបានចាត់ទុកថាជាប្រភេទឈើពាណិជ្ជកម្ម ដែលត្រូវបានកំណត់ទំហំអប្បបរមាសម្រាប់ការដកហូតមកប្រើប្រាស់ កំណត់ដោយប្រកាសលេខ០៨៩ប្រ.ក/ក.ស.ក ចុះថ្ងៃទី១៤ខែកុម្ភៈឆ្នាំ២០០៥ ស្តីពី "ផលអនុផលព្រៃឈើដែលត្រូវហាមឃាត់ប្រមូលផល" នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ប្រភេទឈើទាំង ១៨ប្រភេទនេះរួមមាន៖ ឈើប្រណិត ០៥ប្រភេទ ឈើលេខ១ ០៦ប្រភេទ ឈើលេខ២ ០៣ប្រភេទ និង ឈើលេខ៣ ០៤ប្រភេទ។ តាមការសម្ភាសន៍ជាមួយប្រជាពលរដ្ឋមូលដ្ឋាន ឲ្យដឹងថាប្រភេទឈើប្រណិតមានតំលៃពាណិជ្ជកម្មដូចជា បេង នាងនួន និងធ្នង់ (ដោយខ្ញែក ច្រេស និងត្រយឹងគ្មានតម្លៃពាណិជ្ជកម្ម) បច្ចុប្បន្នបាននឹងកំពុងទទួលរងការគំរាមកំហែងយ៉ាងខ្លាំង ហើយសឹងតែបាត់បង់វត្តមាននៅក្នុងតំបន់គម្រោងផងដែរ លើកលែងតែឈើដែលមានទំហំអង្កត់ផ្ចិតតូចៗប៉ុណ្ណោះ។ ក្រៅពីនេះ នៅមានប្រភេទឈើប្រមាណជា ២០-២៥ប្រភេទផ្សេងទៀត ដោយរាប់បញ្ចូលទាំងប្រភេទឈើ ក្រៅលំដាប់ថ្នាក់ទៀតនោះត្រូវបានប្រើប្រាស់ជាញឹកញាប់សម្រាប់ជាឈើគ្រឿងសំណង់ដូចជា ធ្វើសសរ ក្តារបន្ទះ រឺគ្រឿងសង្ហារឹមជាដើម។

១០០. យោងតាមបទពិសោធន៍របស់សហគមន៍មូលដ្ឋានលើការប្រើប្រាស់រុក្ខជាតិ ឯកសារស្រាវជ្រាវរបស់ឌីផុន ប៉ូលីន (២០០០)[2] និង មជ្ឈមណ្ឌលជាតិស្រាវជ្រាវវេជ្ជសាស្ត្របុរាណ (២០០៦)[3] បានបង្ហាញថារុក្ខជាតិចំនួន ២២ ប្រភេទ អាចបរិភោគបាន និងប្រើប្រាស់ជាលក្ខណៈប្រពៃណីដូចជា បរិភោគផ្លែទុំ ឬគ្រាប់ និងស្លឹក ឬត្រួយធ្វើជាបន្លែ។ ក្រៅពីនេះ ក៏នៅមានរុក្ខជាតិប្រមាណជា ៣៩ភាគរយ នៃសារព័ន្ធរុក្ខជាតិដែលបានកត់ត្រាក្នុងឡូត៍-អនុឡូត៍ ត្រូវបានចាត់ទុកថា ជាប្រភេទរុក្ខជាតិឱសថដែលប្រជាជនមូលដ្ឋានប្រើប្រាស់ជាលក្ខណៈប្រពៃណី ដូចជា៖ សំបក ស្លឹក ឫស ផ្លែ និងគ្រាប់ជាដើម (**ឧបសម្ព័ន្ធ៥-៤ តារាង៥-១៨៖** ប្រភេទសារព័ន្ធរុក្ខជាតិ និងការប្រើប្រាស់របស់វា, **តារាង១៩, តារាង២០៖** ប្រភេទរុក្ខជាតិ និង**តារាង២១៖**រុក្ខជាតិឱសថ)។

តារាង៥-២២ ៖ ចំនួនប្រភេទរុក្ខជាតិ និងចំនួនរុក្ខជាតិទៅតាមប្រភេទព្រៃ

សារព័ន្ធរុក្ខជាតិ	កូនដំណុះ		កូនឈើ		ឈើ(D = 5-10cm)		ឈើ(D>10cm)	
	ចំនួនប្រភេទ	ចំនួនដើមឈើ	ចំនួនប្រភេទ	ចំនួនដើមឈើ	ចំនួនប្រភេទ	ចំនួនដើមឈើ	ចំនួនប្រភេទ	ចំនួនដើមឈើ
ព្រៃពាក់កណ្តាលស្រោង	២៣	៦៥	១២	១៩	២១	៣៧	៣២	១៣៥
ព្រៃល្បោះ	១៩	១២៥	១៤	៤៤	១៣	៣៤	៣៧	២៤០
តាមដងអូរ	៩	២៧	៥	៧	៨	១៥	២២	៩៦

[2] ឌីផុន ប៉ូលីន (២០០០) ស្តីពី "រុក្ខជាតិប្រើប្រាស់នៅកម្ពុជា"

[3] មជ្ឈមណ្ឌលជាតិស្រាវជ្រាវវេជ្ជសាស្ត្របុរាណ (២០០៦) រុក្ខជាតិឱសថកម្ពុជា, ក្រសួងសុខាភិបាល។

៥.៤.២.២.១ ប្រភេទសារព័ន្ធរុក្ខជាតិនៅក្នុងព្រៃពាក់កណ្ដាលស្រោង

១០១. ការសិក្សាអំពីសារព័ន្ធរុក្ខជាតិនៅក្នុងស្រទាប់ព្រៃពាក់កណ្ដាលស្រោង បានបង្ហាញថា មានរុក្ខជាតិចំនួន ៣៨ប្រភេទ ស្មើនឹង ២៥៦ដើម ក្នុងនោះរុក្ខជាតិស្រទាប់ក្រោមមានចំនួន ២៣ប្រភេទ ស្មើនឹង ៦៥ដើម ត្រូវបានកត់ត្រានៅក្នុងអនុឡូត៍គំរូសិក្សាកូនដំណុះដែលមានកំពស់ទាបជាង ១ម, ១២ប្រភេទ ស្មើនឹង ១៩ដើម ត្រូវបានជួបក្នុងអនុឡូត៍សិក្សាកូនឈើមានកំពស់ខ្ពស់ជាង ១ម និងអង្កត់ផ្ចិតតូចជាង ៥ស.ម, ២១ប្រភេទ ស្មើនឹង ៣៧ដើម មានអង្កត់ផ្ចិតពី ៥-១០ ស.ម និង ៣២ប្រភេទ ស្មើនឹង ១៣៥ដើម ត្រូវបានកត់ត្រាក្នុងឡូត៍ធំដែលសិក្សាលើឈើអង្កត់ផ្ចិតធំជាង ១០ស.ម (**តារាង ៥-២៣ (a,b,c)**)។

តារាង៥-២៣ ៖ បញ្ជីសារព័ន្ធរុក្ខជាតិ និងដង់ស៊ីតេរបស់វាតាមប្រភេទព្រៃ

a) សារព័ន្ធរុក្ខជាតិក្នុងឡូត៍អនុឡូត៍ដាក់តាមជងអួរ

ល.រ	ប្រភេទឈើ	ឈ្មោះវិទ្យាសាស្ត្រ	កូនដំណុះ	កូនឈើ	ដើមឈើ DBH=5-10cm	ដើមឈើ DBH>10cm
	Luxury Wood					
១	ធ្នង់	*Pterocapus imdicus*	1	0	1	0
២	នាងនួន	*Dalbergia bariensis*, Pierre	0	0	2	0
៣	បេង	*Afzelia xylocarpa*, (Kurz) Craib	0	0	0	1
	Graded 1st					
៤	សុក្រម	*Xylia dolabriformis*, Benth	0	0	4	5
៥	ស្រឡៅ	*Lagerstroemia calyculata* Kurz	2	0	0	2
៦	ត្រសេក	*Peltophorum ferrugineum* Benth	8	0	0	1
	Graded 3rd					
៧	កណ្ដោល	*Careya sphaeriea*, Pierre	2	0	0	0
	None Class					
៨	ជ្រៃ	*Ficus rumphii* Blume	0	0	0	11
៩	ចំបក់	*Irvingia malayana* Oliv. ex Benn.	0	0	1	0
១០	ក្រខុបព្រៃ	*Scolopia spinosa* (Roxb.)Warb	1	1	0	12
១១	ជើងគោ	*Bauhinia variegate* L.	0	0	0	4
១២	ត្របែកព្រៃ	*Lagerstroemia floribunda* Jack	0	0	1	1
១៣	ឈ្លីកពក	*Bridelia retusa* Spreng.	0	0	0	1
១៤	តាតែក	N/A	0	0	0	1
១៥	ញរព្រៃ	*Morinda tomentosa* Roth	0	2	0	4
១៦	បាយក្ដាំង	*Guioa cambodiana* Pierre	0	0	0	3
១៧	នាងនួនទឹក	N/A	0	2	0	0

Draft

ល.រ	ប្រភេទឈើ	ឈ្មោះវិទ្យាសាស្ត្រ	កូនដំណុះ	កូនឈើ	ដើមឈើ DBH=5-10cm	ដើមឈើ DBH>10cm
១៨	បាក់ដង	*Gardenia philastrei* Pierre ex Pit.	0	0	0	1
១៩	ម្រេញទឹក	*Milletia erythrocalyx* Gagnep.	3	1	2	5
២០	ក្លៅនាង	*Adenanthera pavonina* var.	3	0	0	18
២១	ពោនស្វា	N/A	2	0	0	2
២២	ពង្រ	*Schleicheria oleosa* (Lour.)Oken	0	1	1	5
២៣	ស្ពូល	*Dalbergianigreseens* Kurzvar	0	0	0	3
២៤	សង្កែ	*Combretum quadrangulare* Kurz.	0	0	0	1
២៥	រកា	*Bombax ceiba* L.	5	0	0	0
២៦	ស្ដៅ	*Azadirchta idica* Ant.Juss	0	0	3	13
២៧	ឪឡោក	*Hymenodictyon orixense* (Roxb.)Mabb.	0	0	0	1
២៨	ស្លែង	*Strychnos nux*-vomica L.	0	0	0	1
		ចំនួនដើមឈើដែលបានកត់ត្រា	27	7	15	96
		ចំនួនប្រភេទឈើ	9	5	8	22

b) សារពើន្ធរុក្ខជាតិក្នុងឡូត៍អនុឡូត៍ដាក់តាំងក្នុងព្រៃល្បោះ

ល.រ	ប្រភេទឈើ	ឈ្មោះវិទ្យាសាស្ត្រ	កូនដំណុះ	កូនឈើ	ដើមឈើ DBH=5-10cm	ដើមឈើ DBH>10cm
	ឈើប្រណិត					
១	ត្រយឹង	*Diosspyros pilosanthera var.helferi* (C.B.Clarke) Bakh	0	0	0	2
២	ធ្នង់	*Pterocapus imdicus*	0	0	0	1
៣	ប្រេស	*Albizia lebbeck,*(L.)Benth.	0	0	0	4
	ឈើលេខ ១					
៤	សុក្រម	*Xylia dolabriformis,* Benth	0	0	3	1
៥	ធ្នឹក	*Shorea obtuse,* Wall. exBlume	10	0	0	2
៦	ត្រសេក	*Peltophorum ferrugineum* Benth	16	0	0	0
៧	ឈ្លីក	*Terminalia alata,* F.Heyne ex Roth	0	0	0	1
	ឈើលេខ២					
៨	ខ្វាវ	*Haldinia cordifolia* (Roxb.) Ridsdale	4	1	0	43

Draft

ល.រ	ប្រភេទឈើ	ឈ្មោះវិទ្យាសាស្ត្រ	កូនដំណុះ	កូនឈើ	ដើមឈើ DBH=5-10cm	ដើមឈើ DBH>10cm
៩	ខ្លុង	*Dipterocarpus tuberculatus* Roxb.	9	0	3	47
	ឈើលេខ៣					
១០	កណ្ដោល	*Careya sphaeriea,* Pierre	0	0	0	1
១១	ប្រាំដំឡឹង	*Terminalia mucronata,*Graib et Huth	0	1	0	3
១២	ព្រីង	*Eugenia* spp	0	0	2	6
១៣	លៀង	*Cratoxylon prunifolium* ,Dyer	0	0	2	8
១៤	ស្មាក្របី	*Knema corticosa,* Lour.	2	0	0	2
	ឈើក្រៅលំដាប់					
១៥	កន្ទួតព្រៃ	*Phyllaanthus emblica* L.	4	0	0	4
១៦	កន្ទុយកំប្រុក	*Helicteres hirsute* Lour.	13	9	8	22
១៧	ក្រពាត់ជ្រូក	*Sida cordifolia* L.	22	9	6	29
១៨	ខ្ទុំ	N/A	0	0	0	2
១៩	ចារ	*Butea monosperma* (Lam.)Taub.	0	0	1	1
២០	ចេកសំពោច	*Uvaria purpurea* Blume.	0	0	0	1
២១	ឈ្លីកពក	*Bridelia retusa* Spreng.	0	1	2	3
២២	ផ្តៅស្រែង	*Cananga latifolia* (Hook.f.& Thomson) Finet&Gagnep.	9	6	0	0
២៣	ជ័យជំរី	N/A	3	0	1	1
២៤	ញរព្រៃ	*Morinda tomentosa* Roth	0	0	0	1
២៥	ដើមទឹកដោះ	*Holarrhena curtisi* King &Gamble	2	0	0	0
២៦	ត្រសេវ	N/A	0	0	0	3
២៧	ផ្មៀ	*Acacia caesia var.subnuda*	4	0	0	4
២៨	បាក់ដង	*Gardenia philastrei* Pierre ex Pit.	0	1	2	2
២៩	ទ្រមាក់	*Dalbergia assamica* Benth var.assamica	2	1	0	1
៣០	ពពលខែ	*Alstonia scholaris* (L.) R.Br	7	0	0	0
៣១	ពភ្លា	*Microcos tomentosa* Sm	0	0	0	2
៣២	ពង្រ	*Schleichera oleosa* (Lour.) Oken	0	0	0	2
៣៣	ពូវែក	N/A	0	0	0	4
៣៤	ភ្លូង	*Memecylon laevigatum* Blume	0	1	1	3

Draft

ល.រ	ប្រភេទឈើ	ឈ្មោះវិទ្យាសាស្ត្រ	កូនដំណុះ	កូនឈើ	ដើមឈើ DBH=5-10cm	ដើមឈើ DBH>10cm
៣៥	ពោនស្វា	N/A	3	2	0	0
៣៦	មឿត	N/A	1	3	2	0
៣៧	ព្នូច	*Rhodomyrtus tomentosa* (Aiton) Hassk.	0	1	0	0
៣៨	រកា	*Bombax ceiba* L.	0	5	0	0
៣៩	រមាំង	*Diospyros ehretioides* Wallich ex G.Don	0	0	0	1
៤០	លាំងជ័យ	*Buchanania reticulate* Hance	0	0	0	4
៤១	រាំង	*Barringtonia asiatica*(L.) Kurz	0	3	0	3
៤២	ស្នួល	*Dalbergianigreseens* Kurzvar	3	0	1	10
៤៣	ស្ដៅ	*Azadirchta idica* Ant.Juss	4	0	0	8
៤៤	ល្វេ	*Dillenia pentagyna* Roxb.	0	0	0	2
៤៥	ឪឡេក	*Hymenodictyon orixense* (Roxb.)Mabb.	0	0	0	6
៤៦	សំរង	*Scaphium macropodium* (Miq) Beumee	7	0	0	0
		ចំនួនដើមឈើដែលបានកត់ត្រា	125	44	34	240
		ចំនួនប្រភេទឈើ	19	14	13	37

c) សារពើន្ធរុក្ខជាតិក្នុងឡូត៍អនុឡូត៍ដាក់តាំងក្នុងព្រៃពាក់កណ្ដាលស្រោង

ល.រ	ប្រភេទឈើ	ឈ្មោះវិទ្យាសាស្ត្រ	កូនដំណុះ	កូនឈើ	ដើមឈើ DBH=5-10cm	ដើមឈើ DBH>10cm
	ឈើប្រណិត					
១	ត្រយឹង	*Diosspyrospilosanthera var.helferi* (C.B.Clarke) Bakh	0	1	0	4
២	ធ្នង់	*Pterocapus imdicus*	1	0	1	2
៣	នាងនួន	*Dalbergia bariensis,* Pierre	1	0	0	0
៤	បេង	*Afzelia xylocarpa,* (Kurz) Craib	2	2	1	0
	ឈើលេខ ១					
៥	ស្រឡៅ	*Lagerstroemia calyculata* Kurz	1	2	0	3
៦	សុក្រម	*Xylia dolabriformis,* Benth	3	0	1	6
៧	ពពូល	*Vitex* sp	0	1	0	4

ល.រ	ប្រភេទឈើ	ឈ្មោះវិទ្យាសាស្ត្រ	កូនដំណុះ	កូនឈើ	ដើមឈើ DBH=5-10cm	ដើមឈើ DBH>10cm
៨	ត្រសេក	*Peltophorum ferrugineum* Benth	5	0	0	11
៩	ឈ្លីក	*Terminalia alata,* F.Heyne ex Roth	0	0	0	0
	ឈើលេខ២					
១០	ត្រឡាត់	*Vatica philastreana,* pierre	1	0	0	7
	ឈើលេខ៣					
១១	ប្រាំដំឡឹង	*Terminalia mucronata,* Graib et Huth	4	2	3	2
១២	ព្រីង	*Eugenia* spp	1	1	1	8
១៣	ល្ងៀង	*Cratoxylon prunifolium,* Dyer	1	0	2	1
១៤	ស្មាក្របី	*Knema corticosa,* Lour.	0	0	1	8
១៥	កណ្តោល	*Careya sphaeriea,* Pierre	6	3	1	9
	ឈើក្រៅលំដាប់					
១៦	ខាន់ឡាក់	N/A	0	0	2	1
១៧	ឆ្អឹងត្រី	N/A	0	0	1	3
១៨	កន្ទុយប្រើស	N/A	0	0	0	6
១៩	ក្រខុបព្រៃ	*Scolopia spinosa* (Roxb.) Warb	0	0	0	2
២០	ត្រចៀកដំរី	N/A	0	0	4	2
២១	ឈ្លីកពក	*Bridelia retusa* Spreng.	0	1	0	9
២២	ញរព្រៃ	*Morinda tomentosa* Roth	3	0	4	14
២៣	ទឹកដោះព្រៃ	*Holarrhena curtisi* King &Gamble	1	1	2	4
២៤	ទ្រមាក់	*Dalbergia assamica* Benth var.assamica	3	0	0	1
២៥	ពង្រ	*Schleicheria oleosa* (Lour.) Oken	2	0	0	0
២៦	បាយក្តាំង	*Guioa cambodiana* Pierre	2	0	0	0
២៧	ភ្លៅនាង	*Adenanthera pavonina* var.	0	0	3	2
២៨	ភ្លៅមាន់	*Decaschistia parviflora* Kurz.	1	2	1	0
២៩	ពោនស្វា	N/A	0	0	0	3
៣០	ល្វាដី	*Ficus hirta* Vahl	9	0	0	2
៣១	ម្រេញទឹក	*Milletia erythrocalyx* Gagnep.	3	0	2	4
៣២	រលោយ	*Neonauclea sessiliflora*	1	0	1	1

Draft

ល.រ	ប្រភេទឈើ	ឈ្មោះវិទ្យាសាស្ត្រ	កូនដំណុះ	កូនឈើ	ដើមឈើ DBH=5-10cm	ដើមឈើ DBH>10cm
		(Roxb.) Merr.				
៣៣	រកា	*Bombax ceiba* L.	0	1	1	1
៣៤	ស្រឡៅជូរ	*Lagerstroemia ovalifo lia* Teijsm.& Binn.	4	0	1	5
៣៥	ខ្ទឹងឡោក	*Hymenodictyon orixense* (Roxb.)Mabb.	0	0	1	1
៣៦	ស្នួល	*Dalbergianigreseens* Kurzvar	7	0	3	5
៣៧	សង្កែ	*Combretum quadran gulare* Kurz.	0	2	0	1
៣៨	ស្លែង	*Strychnos nux*-vomica L.	3	0	0	3
ចំនួនដើមឈើដែលបានកត់ត្រា			65	19	37	135
ចំនួនប្រភេទឈើ			23	12	21	32

១០២. ការកត់ត្រា និងលទ្ធផលនៃការវិភាគលើដង់ស៊ីតេឈើបានបង្ហាញថា ក្នុងស្រទាប់ព្រៃពាក់កណ្តាលស្រោងនេះពុំមានវត្តមានប្រភេទឈើដែលមានអង្កត់ផ្ចិតធំជាង ៣០ស.ម ទេ ក្នុងនោះរួមមានដើមបេង (*Afzelia xylocarpa,* (Kurz) Craib ដើមនាងនួន (*Dalbergia bariensis,* Pierre) និងធ្នង់ (*Pterocapus imdicus*)។ ហើយប្រភេទដើមឈើដែលលប់ក្នុងស្រទាប់ព្រៃនេះមានប្រភេទត្រសេក (*Peltophorum ferrugineum* Benth) រកា (*Bombax ceiba* L.) និងក្រខុបព្រៃ (*Scolopia spinosa* (Roxb.) Warb)។ វត្តមាននៃប្រភេទឈើឈានមុខខាងលើ បង្ហាញអំពីភាពរេចរឹលនៃព្រៃក្នុងតំបន់នេះ ដែលប្រហែលជាត្រូវបានរុករកនទន្រ្ទាន ឬកាប់ឈើធ្វើអាជីវកម្មជាដើម។ ទន្ទឹមនឹងនេះក៏មានស្លាក ស្នាមនានាដូចជា ផូស៊ីលនៃឈើពុកផុយ (កាកសំណល់ឈើធ្វើអាជីវកម្ម) ដែលបានបន្សល់ទុកតាំងពីយូរយារណាស់មកហើយ។

៥.៤.២.២.២ ប្រភេទសារព័ន្ធរុក្ខជាតិនៅក្នុងព្រៃល្បោះ

១០៣. ការសិក្សាអំពីសារព័ន្ធរុក្ខជាតិនៅក្នុងស្រទាប់ព្រៃល្បោះបានបង្ហាញថា សារព័ន្ធរុក្ខជាតិគឺលប់ទៅដោយពពួក Dipterocarpus។ ក្នុងស្រទាប់ព្រៃនេះក្រុមការងារបានកត់ត្រាវត្តមានរុក្ខជាតិប្រមាណ ៤៦ប្រភេទ ស្មើនឹង ៤៤៣ដើម ក្នុងនោះរុក្ខជាតិស្រទាប់ក្រោមមានចំនួន ១៩ប្រភេទ ស្មើនឹង១២៥ដើម ត្រូវបានកត់ត្រានៅក្នុងឡូត៍សិក្សាកូនដំណុះកំពស់ទាបជាង ១ម, ១៤ប្រភេទ ស្មើនឹង ៤៤ដើម ត្រូវបានជួបក្នុងឡូត៍សិក្សាកូនឈើកំពស់ខ្ពស់ជាង១ម និងអង្កត់ផ្ចិតតូចជាង ៥ស.ម កូនឈើចំនួន ១៣ប្រភេទ ស្មើនឹង ៣៤ដើម មានអង្កត់ផ្ចិតពី ៥-១០ ស.ម និង ៣៧ប្រភេទ ស្មើនឹង ២៤០ដើម ត្រូវបានកត់ត្រាក្នុងឡូត៍ធំ ឬមានអង្កត់ផ្ចិតធំជាង ១០ស.ម (តារាងទី៥-២១ (b))ខាងលើ។ សារព័ន្ធរុក្ខជាតិក្នុងព្រៃល្បោះនេះសម្បូរណ៍ទៅដោយដើមផ្ចឹក (*Shorea siamensis* Miq.) ឈ្លីក (*Terminalia alata,*F.Heyne ex Roth) ខ្លុង (*Dipterocarpus tuberculatus* Roxb.) ប្រាំដំឡឹង (*Terminalia mucronata,*Graib et Huth) និងសុក្រម (*Xylia dolabriformis.*Benth) ជាដើម។ ដោយឡែកសារព័ន្ធរុក្ខជាតិស្រទាប់ក្រោមសម្បូរណ៍ដោយ កន្ទុយកំប្រុក (*Helicteres hirsute* Lour.) ឬស្សីព្រិច (*Arundinaria pusilla*) និងស្បូវ (Imperata cylindrical (L.) Rausch)។



រូបភាព ៥-១០ កន្ទុយកំប្រុក (*Helicteres hirsute* Lour.)



រូបភាព ៥-១១ កូនផ្ទីក និងសុក្រម

៥.៤.២.២.៣ ប្រភេទសារព័ន្ធរុក្ខជាតិនៅតាមដងអូរ

១០៤. ការសិក្សាអំពីសារព័ន្ធរុក្ខជាតិនៅក្នុងស្រទាប់ព្រៃតាមដងអូរបានបង្ហាញថា មានសារព័ន្ធរុក្ខជាតិចំនួន ២៨ប្រភេទ ស្មើនឹង ១៤៥ដើម ត្រូវបានកត់ត្រាក្នុងឡូត៍-អនុឡូត៍ ដែលបានដាក់តាំងក្នុងស្រទាប់ព្រៃពាក់កណ្តាលស្រោង និងព្រៃល្បោះ។ រុក្ខជាតិស្រទាប់ក្រោមមានចំនួន ០៩ប្រភេទ ស្មើនឹង ២៧ដើម បានកត់ត្រានៅក្នុងឡូត៍សិក្សាកូនដំណុះដែលមានកំពស់ទាបជាង ១ម៉ែត្រ ០៥ប្រភេទ ស្មើនឹង ៧ដើម បានកត់ត្រាក្នុងឡូត៍សិក្សាកូនឈើដែលមានកំពស់ខ្ពស់ជាង ១ម៉ែត្រ និងអង្កត់ផ្ចិតតូចជាង ៥ស.ម កូនឈើចំនួន ០៨ប្រភេទ ស្មើនឹង ១៥ដើម មានអង្កត់ផ្ចិតពី ៥-១០ ស.ម និង ២២ប្រភេទ ស្មើនឹង ៩៦ដើម ត្រូវបានកត់ត្រាក្នុងឡូត៍ធំ ឬមានអង្កត់ផ្ចិតធំជាង ១០ស.ម (**តារាងទី៥-២៣** (c))ខាងលើ។ រចនាសម្ព័ន្ធព្រៃឈើដុះតាមដងអូរត្រូវបានរំខានដោយសារការកាប់រានដីធ្វើចម្ការ ដែលជំនួសមកវិញនូវពពួកព្រិច និងឫស្សីដូចរូបទី ៥-៥ និងរូបទី ៥-៨ និង៥-៩ ខាងលើ។ សារព័ន្ធរុក្ខជាតិ ដុះតាមដងអូរនៅក្នុងតំបន់សិក្សាស្រាវជ្រាវពុំសូវមានរុក្ខជាតិមានតម្លៃពាណិជ្ជកម្មទេ ភាគច្រើនលុបដោយប្រភេទរុក្ខជាតិ លិចទឹកដូចជា ព្រាលខ្យាច់ *(Helicteres elliptica)* បាយក្តាំង(*Guioa cambodiana* Pierre) ក្រវ៉ាន់បាត *(Amomum krervanh)* វល្លិ៍ធ្មេញត្រី និងពន្លៃព្រៃ។

១០៥. លទ្ធផលនៃការសិក្សានេះ គឺបានបង្ហាញអំពីភាពស្រដៀងគ្នាទៅនឹងការសិក្សាពីមុនមកដោយ **Tran & Kol** (១៩៩៥), **Schweitheim & Chhay** (២០០៧) និង **Chhang** (២០០៩) ដែលបានបញ្ជាក់ថាប្រភេទលប់ក្នុងព្រៃល្បោះស្ងួតគឺមានតែ ផ្ទីក និងឈ្លីក និងរុក្ខជាតិស្រទាប់ក្រោមសម្បូរណ៍ទៅដោយវាលស្មៅ ស្បូវ និងព្រិច។ លើសពីនេះទៀត ការសិក្សាក៏បានបង្ហាញលទ្ធផលស្រដៀងគ្នានឹង **Tran & Kol** (១៩៩៥) ដែលបញ្ជាក់ថា ដើមឈើដែលលប់ក្នុងពាក់កណ្តាលស្រោងភាគច្រើនជាឈើមានតម្លៃពាណិជ្ជកម្មដូចជាឈើទាល ស្រឡៅ ប្រម៉ាស់ ក្រកោះ និងស្វាយព្រៃ។ ដោយឡែកស្ថានភាពរុក្ខជាតិស្រទាប់ក្រោមសម្បូរណ៍ដោយប្រភេទចុល្លព្រឹក្ស និងតិណទេស (រុក្ខជាតិគ្មានជាតិឈើ) ជាពិសេសរុក្ខជាតិឱសថដុះលាយលំគ្នាបង្កើតជាបណ្តុំនៃសង្គមរុក្ខជាតិមួយដែលមានលក្ខណៈស្មុគស្មាញ។ ចំពោះ សារព័ន្ធរុក្ខជាតិដុះតាមដងអូរវិញ ភាគច្រើនមានវត្តមានរុក្ខជាតិដែលជាប្រភេទដុះលើដីសើម និងពេលខ្លះវាអាចដុះក្នុងទឹក

ឬជាតិណទេស និងចុល្លព្រឹក្សដែលអាចដុះក្នុងទឹកបាន។ នៅក្នុងព្រៃរងទឹកភ្លៀងតំបន់ត្រូពិច មានប្រភេទរុក្ខជាតិដុះក្នុងព្រៃតាមដងអូរផ្សេងៗគ្នា ប៉ុន្តែរុក្ខជាតិទាំងនោះមានអន្តរកម្មរវាងជលសាស្ត្រ និងអេកូឡូស៊ីដែលមានភាពស្រដៀងគ្នា ដូចដែលកើតមាននៅតាមតំបន់ភូមិសាស្ត្រដទៃទៀត ដូចជាប្រភេទស្មៅស្លាបទា ស្មៅកក់ ប្រោះស្វា ពន្លៃព្រៃ ផ្ទីងត្រី និងជើងគោជាដើម។ ដូច្នេះអាចបញ្ជាក់ថា ការសិក្សាស្រាវជ្រាវនៅក្នុងតំបន់នេះ គឺមានភាពស្រដៀងគ្នានឹងទ្រឹស្តីខាងលើដែរ។ ដោយក្នុងនោះក្រុមការងារបានជួបប្រទះ និងកត់ត្រានូវប្រភេទរុក្ខជាតិស្រទាប់ក្រោមមួយចំនួនដូចជាស្មៅស្លាបទា ពន្លៃព្រៃ ព្រាលខ្យាច់ ជើងគោ បាយក្តាំង និងអង្រៃដែកជាដើម ដែលរុក្ខជាតិទាំងនេះមិនត្រឹមតែមានតម្លៃសម្រាប់ប្រព័ន្ធអេកូឡូស៊ីទេ ថែមទាំងអាចប្រើប្រាស់ជាឱសថបូរាណ។

៥.៤.២.៣ ប្រភេទឈើត្រូវបានការពារដោយច្បាប់

៥.៤.២.៣.១ ប្រភេទឈើដែលមានដោយកម្រ

១០៦. ប្រភេទឈើប្រណិតសំខាន់ៗចំនួន ៣ប្រភេទ ត្រូវបានចាត់ទុកជាប្រភេទដែលជិតផុតពូជបំផុត និងរងការគំរាមកំហែងទាំងក្នុងប្រទេសកម្ពុជា និងលើសកលលោក។ ប្រភេទឈើទាំងនេះត្រូវបានជួបប្រទះ និងកត់ត្រាតាមបណ្តាទីតាំងផ្សេងៗគ្នា ក្នុងតំបន់សិក្សាដោយក្រុមការងារសិក្សាស្រាវជ្រាវ ជាពិសេសនៅឡូត៍ទី៤, ទី៥ និងទី៦។ ប្រភេទឈើទាំង ៣ប្រភេទដែលមានបង្ហាញជូនក្នុងតារាងទី៥-២៤ ខាងក្រោមនេះ ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី ២ ស្តីពីប្រភេទរុក្ខជាតិមានដោយកម្រ[1] ដែលបានកំណត់ដោយប្រកាសលេខ ០៨៩ប្រ.ក/ក.ស.ក ចុះថ្ងៃទី១៤ខែកុម្ភៈឆ្នាំ២០០៥ ស្តីពី "ផលអនុផលព្រៃឈើដែលត្រូវហាមឃាត់ប្រមូលផល" នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ប្រភេទឈើទាំងនេះមានអត្រាប៉ាយ..បនៅក្នុងព្រៃធម្មជាតិនៃតំបន់សិក្សាស្រាវជ្រាវ ដែលអាចនិយាយថាបច្ចុប្បន្នការបន្តពូជក្នុងធម្មជាតិមានសក្តានុពលទាប ដូច្នេះវាមានតម្លៃផ្នែកវិទ្យាសាស្ត្រ វប្បធម៌ និងអាចប្រឈមមុខចំពោះការគំរាមកំហែង ឬផុតពូជពីក្នុងតំបន់សិក្សា បើសិនជាពុំមានវិធានការសមស្របណាមួយអនុវត្តទាន់ពេលវេលា។

តារាងទី ៥-២៤៖ ប្រភេទឈើចាំបាច់ត្រូវការពារក្នុងប្រទេសកម្ពុជា

ល.រ	ប្រភេទ	ឈ្មោះវិទ្យាសាស្ត្រ	ចំណាត់ថ្នាក់	ការពារដោយ ប្រក/ក.ស.ក	កម្រិតគំរាមកំហែងក្នុងកម្ពុជា[1]	បញ្ជីក្រហម IUCN[2]
១	បេង	*Afzelia xylocarpa*, (Kurz) Craib	ប្រណិត	✓	៥	EN
២	នាងនួន	*Dalbergia bariensis*.Pierre	ប្រណិត	✓	៥	EN
៣	ធ្នង់	*Pterocarpus pedatus*, Pierre	ប្រណិត	✓	៥	

កំណត់ចំណាំ៖ [1] កម្រិតនៃការគំរាមកំហែង៖ ៥ = ជិតផុតពូជបំផុត, ៤ = ជិតផុតពូជ, ១-៣ = រងគំរាមកំហែង

[2] IUCN Red list: EN=Endangered (ជិតផុតពូជ), កំពុងប្រឈមមុខនឹងគ្រោះថ្នាក់ធ្ងន់ធ្ងរជិតផុតពូជនៅក្នុងព្រៃ;
VU= Vulnerable (ងាយរងគ្រោះ), កំពុងប្រឈមមុខនឹងគ្រោះថ្នាក់ធ្ងន់ធ្ងរជិតផុតពូជនៅក្នុងព្រៃ,
LC= Least Concern (ប្រភេទមានដោយបង្គួរ)

[1] ឧបសម្ព័ន្ធទី ២ ស្តីពីប្រភេទរុក្ខជាតិមានដោយកម្រ នៃប្រកាសលេខ ០៨៩ប្រ.ក/ក.ស.ក ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ ២០០៥ ស្តីពី "ផលអនុផលព្រៃឈើដែលត្រូវហាមឃាត់ប្រមូលផល" របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

* ម្យ៉ាងវិញទៀតប្រភេទឈើបេង និងនាងនួន ត្រូវបានសិក្សាស្រាវជ្រាវលើរបាយដងស៊ីតេលើពិភពលោកដោយ អង្គការ IUCN ត្រូវបានចាត់បញ្ចូលទៅក្នុងបញ្ជីក្រហម **IUCN Red List** ជាប្រភេទដែលរងគ្រោះថ្នាក់ជិតផុតពូជ។

៥.៤.២.៣.២ ប្រភេទអនុផលព្រៃឈើ ប្រើប្រាស់ដោយសហគមន៍មូលដ្ឋាន

១០៧. ក្រៅពីផ្តល់មុខងារការពារទីជម្រាល និងការហូរច្រោះ ព្រៃតាមដងអូរបានផ្តល់នូវអនុផលព្រៃឈើ ដែលជាមុខងារសំខាន់មួយសម្រាប់ប្រជាជនមូលដ្ឋានដូចជាម្ហូបអាហារ ថ្នាំសង្កូវ និង គ្រឿងសំណង់សម្រាប់ ប្រើប្រាស់ជាលក្ខណៈប្រពៃណីផងដែរ។ តាមចំណេះដឹងដើមរបស់ប្រជាជនក្នុងតំបន់សិក្សាបានបង្ហាញនូវ អត្ថប្រយោជន៍ ក៏ដូចជាការប្រើប្រាស់រុក្ខជាតិមួយចំនួន ជាពិសេសការប្រើប្រាស់ផ្នែកឱសថជាដើម ដូចមានរៀបរាប់លំអិតក្នុង **តារាង៥-១៨៖** ស្តីពីប្រភេទសារព័ន្ធរុក្ខជាតិ និងការប្រើប្រាស់របស់វា។

១០៨. ប្រភេទអនុផលព្រៃឈើ ដែលក្រុមការងារបានជួបប្រទះក្នុងកំឡុងពេលសិក្សាស្រាវជ្រាវ រួមមាន ទំពាំង ផ្សិតដែក ឫស្សី ទំពាំងបាយជូរព្រៃ ក្តាំងបាយ និងអ័រគីដេព្រៃជាដើម (ដូចរូបភាពខាងក្រោម)។



រូបភាព ៥-១២៖ ទំពាំងឫស្សី និងសំបកទំពាំងឫស្សីឃ្លៃដែលប្រជាជនបានប្រមូលពីព្រៃ

រូបភាព ៥-១៣៖ ផ្សិតដែក



រូបភាព ៥-១៤៖ ឫស្សី



រូបភាព ៥-១៥៖ ទំពាំងបាយជូរព្រៃ
(*Ampelocissus arachnoidea*)



រូបភាព៥- ១៦ ៖ បាយក្តាំង

- ទំពាំងបាយជូរព្រៃ៖ ផ្លែអាចបរិភោគ តែមិនសូវនិយមឡើយ ដោយវាធ្វើឲ្យរមាស់ក តែផ្លែរបស់វាអាចធ្វើជ្រក់ ឬទឹកខ្មេះ។ ឫសធ្វើថ្នាំរំងាប់ស្វាយ ប្រមេះ។ ដើម និងឫសធ្វើថ្នាំបញ្ចុះទឹកនោម។
- ក្តាំងបាយ៖ឈើសម្រាប់សង់ផ្ទះតូចតាចបាន និងឫសរបស់វាគេអាចស្ងោរផឹកសម្រាប់ព្យាបាលជម្ងឺប្រមេះ។

រូបភាព ៥-១៧៖ ពពួកអ័រគីដេព្រៃ

- វត្តមានអ័រគីដេបច្ចុប្បន្នក្នុងតំបន់គម្រោងអាចនឹងមានការថយចុះ ខណៈពេលដែលតម្រូវការវាលើទីផ្សារនៅប្រទេសវៀតណាម នៅតែឲ្យតំលៃខ្ពស់ក្នុងការប្រមូលទិញ ដូចជាអ័រគីដេដែលមានគុណភាពល្អ(ដើមធំៗ) អាចនឹងមានតម្លៃ ២៥០០០ រៀល/គ.ក្រ និងលេខ ២ អាចមានតម្លៃត្រឹមតែ ១៥០០០រៀល/គ.ក្រ ប្រសិនបើការដឹកជញ្ជូនដល់ច្រកព្រំដែនកម្ពុជា-វៀតណាម។

៥.៤.២.៤ ដង់ស៊ីតេ និងមាឌឈើ

១០៩. តារាងទី ៥-២៥ ខាងក្រោម បង្ហាញអំពីលទ្ធផលនៃការប៉ាន់ស្មានដង់ស៊ីតេឈើ និងមាឌឈើឈរក្នុងផ្ទៃដី ១ហិកតា។ ការធ្វើចំណាត់ថ្នាក់ប្រភេទឈើខាងក្រោមនេះ គឺផ្អែកលើតារាង៥-២៤៖ ស្តីពីប្រភេទឈើពាណិជ្ជកម្ម ក្នុងប្រកាសលេខ ០៨៩ប្រ.ក/ក.ស.ក ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ ២០០៥ ស្តីពី "ផល-អនុផលព្រៃឈើដែលត្រូវហាមឃាត់ប្រមូលផល" របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

តារាងទី ៥-២៥៖ ការប៉ាន់ស្មានដង់ស៊ីតេឈើ និងមាឌឈើ

ប្រភេទឈើ	កូនឈើ និងចំណាត់ថ្នាក់អង្កត់ផ្ចិត	ព្រៃពាក់កណ្តាលស្រោង		ព្រៃល្បោះ	
		ដង់ស៊ីតេ± SE. (ដ/ហ.ត)	មាឌ ± SE. (ម³/ហ.ត)	ដង់ស៊ីតេ± SE. (ដ/ហ.ត)	មាឌ ± SE. (ម³/ហ.ត)
	កូនដំណុះ	៣២៥០០ ±៧៥០០		៣៨០០០ ±៨០២៦	
	កូនឈើ	១៥២០ ±១១៨០		២០៤០±៤៧១	
ប្រណិត	D = ៥-១៥ស.ម	១៤០ ±៦០	៧,០៨៧ ±៣,១៥៦	២៤ ±៩	១,២៩១±០,៣៣៣
	D = ១៥-៣០ស.ម	១៦ ±៥	៣,៩៧៦ ±១,៦៦៦	២៧ ±៥	៣,០០៦ ±០,៥៩៦
	D ≥ ៣០ស.ម			៣០ ±៣	១៥,៣៧០ ±១,៣៩៧
លេខ ១	D = ៥-១៥ស.ម	៦០០ ±២២២	៣០,៩៩៥±១២,០០៩	១៧២ ±៣៧	៨,៦១៣±១,៦០៩
	D = ១៥-៣០ស.ម	៥០ ±១៣	១១,៥៧១±៤,១១៧	៦៩ ±១៥	១០,៧០០±២,៣៤៦
	D ≥ ៣០ស.ម			១៥ ±២	៦,៣៨៩±០,៧៨៣
លេខ ២	D = ៥-១៥ស.ម			៥០ ±១២	៣,៣៨៣±០,៧៧០
	D = ១៥-៣០ស.ម	២០ ±៦	៤,៥៩៤ ±១,២៩១	៥០ ±១២	១០,៦៦៩±២,៥៤៤
	D ≥ ៣០ស.ម			១០±១	៥,៧៨៨±០,៥២៦
លេខ ៣	D = ៥-១៥ស.ម	៣៦៧ ±១១៦	២០,៩៣១ ±៦,៨១៤	៣០±៤	២,៣០៤±០,៣៤២
	D = ១៥-៣០ស.ម	៤០ ±១៤	៥,៧២៣ ±១,៩១៦	១២±២	១,៦៨១±០,២៩២
	D ≥ ៣០ស.ម				
ក្រៅលំដាប់	D = ៥-១៥ស.ម	៨៨០ ±៣១០	៣៩,៩០០±១២,៩២៤	២៩៨±៥៦	១៦,៥៣០±២,៩១៦
	D = ១៥-៣០ស.ម	៧៤ ±១៩	១១,២៧៣ ±២,៨៩០	៤៦±១០	៦,៤៨៣±១,៥៣១
	D ≥ ៣០ស.ម			២០±៣	៣៥,៤៦៦±៩.៩០៤

ចំណាំ ៖ **D (dbh)** : **Diameter (diameter at breast height)** (អង្កត់ផ្ចិតកំពស់ត្រឹមទ្រូង)

SE. : **Standard Error** (កំរិតលំអៀង)

៥.៤.២.៤.១ ដង់ស៊ីតេ និងមាឌឈើនៅក្នុងព្រៃពាក់កណ្តាលស្រោង

១១០. កូនដំណុះឈើដែលមានកំពស់ទាបជាង ១ម៉ែត្រ ជាមធ្យម ៣២៥០០±៧៥០០ដើម/ហិកតា ចំណែកកូនឈើដែលមានកំពស់ធំជាង ១ម៉ែត្រ និងអង្កត់ផ្ចិតតូចជាង ៥ស.ម មាន ២០៤០±៤៧១ដើម/ហិកតា។ ចំពោះប្រភេទឈើដែលមានអង្កត់ផ្ចិតធំជាង៥ស.ម ឡើងទៅគឺមានបង្ហាញជូនដូចខាងក្រោម៖

a. **ប្រភេទឈើប្រណិត** (អង្កត់ផ្ចិត)
   - **D** = ៥-១៥ស.ម ដង់ស៊ីតេ ១៤០ដើម/ហ.ត±៦០ស្មើនឹងមាឌ ៧,០៨៧ ម³/ហ.ត±៣,១៥៦
   - **D** = ១៥-៣០ស.ម ដង់ស៊ីតេ១៦ដើម/ហ.ត±៥ស្មើនឹងមាឌ ៣,៩៧៦ ម³/ហ.ត ±១.៦៦៦

b. **ប្រភេទឈើលេខ ១**
   - **D** = ៥-១៥ស.ម ដង់ស៊ីតេ ៦០០ដើម/ហ.ត ±២២២ ស្មើនឹងមាឌ ៣០,៩៩៥ ម³/ហ.ត ±១២,០០៩
   - **D** = ១៥-៣០ស.ម មានដង់ស៊ីតេ ៥០ ដើម/ហ.ត±១៣ស្មើនឹងមាឌ ១១,៥៧១ម³/ហ.ត±៤,១១៧

c. **ប្រភេទឈើលេខ ២**
   - **D** = ១៥-៣០ស.មមានដង់ស៊ីតេ ២០ដើម/ហ.ត±៦ស្មើនឹងមាឌ ៤,៥៩៤ ម³/ហ.ត±១,២៩១

d. **ប្រភេទឈើលេខ ៣**

- D = ៥-១៥ស.ម មានដង់ស៊ីតេ ៣៦៧ដើម/ហ.ត±១១៦ស្មើនឹងមាឌ ២០,៩៣១ម^{៣}/ហ.ត ±៦,៨១៤
- D = ១៥-៣០ស.ម មានដង់ស៊ីតេ ៤០ដើម/ហ.ត±១៤ស្មើនឹងមាឌ៥,៧២៣ ម^{៣}/ហ.ត±១,៩១៦

a. ប្រភេទឈើក្រៅលំដាប់

- D = ៥-១៥ស.ម ដង់ស៊ីតេ ៨៨០ដើម/ហ.ត ±៣១០ស្មើនឹងមាឌ ៣៩,៩០០ ម^{៣}/ហ.ត ±១២,៩២៤
- D = ១៥-៣០ស.ម មានដង់ស៊ីតេ ៧៤ដើម/ហ.ត±១៩ ស្មើនឹងមាឌ ១១,២៧៣ម^{៣}/ហ.ត±២,៨៩

១១១. ជារួមប្រភេទឈើនៅក្នុងព្រៃពាក់កណ្ដាលស្រោងនេះប្រមាណជា ៩០ភាគរយ ជាប្រភេទឈើបង្គោល ដែលមានអង្កត់ផ្ចិតចន្លោះពី ៥ទៅ ១៥ស.ម និង១០ភាគរយ ជាប្រភេទឈើដែលមានអង្កត់ផ្ចិតពី ១៥-៣០ ស.ម។ កម្រិតលំអៀង (S.E) មានតម្លៃតូចដែលបញ្ជាក់ថា លទ្ធផលដែលបានរកឃើញប្រមាណជា ៧០-៨៥% អាចទទួលយក។ យ៉ាងណាមិញ ភាពជឿជាក់អាចនឹងកើតមានធំជាង ៨៥% លុះត្រាណាការសិក្សាត្រូវបាន ដាក់តាំងឡូត៍-អនុឡូត៍គម្រូបន្ថែម រីស្ថានភាពឡូត៍-អនុឡូត៍គម្រូនោះមានភាពប្រហាក់ប្រហែលគ្នា។

៥.៤.២.៤.២ ដង់ស៊ីតេ និងមាឌឈើនៅព្រៃល្បោះ

១១២. កូនដំណុះឈើដែលមានកំពស់ទាបជាង ១ម៉ែត្រ ជាមធ្យម ៣៨០០០ដើម/ហិកតា ±៨០២៦ ចំពោះ កូនឈើដែលកំពស់ខ្ពស់ជាង១ម៉ែត្រ និងអង្កត់ផ្ចិតតូចជា ៥ស.ម មានប្រហែល ២៤៤០ដើម/ហិកតា±៤៧១។ ដោយឡែកឈើប្រភេទឈើដែលមានវត្តមាននៅក្នុងប្រភេទព្រៃនេះ មានតែប្រភេទឈើលេខ ១ ឈើលេខ៣ និងឈើក្រៅលំដាប់ថ្នាក់ ហើយភាគច្រើនមានអង្កត់ផ្ចិត ចន្លោះពី ៥ស.ម ទៅ៣០ស.ម។ ចំពោះប្រភេទឈើ ដែលមានអង្កត់ផ្ចិតធំជាង៥ស.ម ឡើងទៅគឺមានបង្ហាញជូនដូចខាងក្រោម៖

a. ប្រភេទឈើប្រណិត

- D = ៥-១៥ស.ម ដង់ស៊ីតេ ២៤ដើម/ហ.ត+ ៩ ស្មើនឹងមាឌ ១,២៩១ ម^{៣}/ហ.ត±០,៣៣៣
- D = ១៥-៣០ស.ម ដង់ស៊ីតេ ២៧ដើម/ហ.ត±៥ ស្មើនឹងមាឌ ៣,០០៦ ម^{៣}/ហ.ត ±០,៥៩៦
- D ≥ ៣០ស.ម ដង់ស៊ីតេ ៣០ដើម/ហ.ត ± ៣ ស្មើនឹងមាឌ ១៥,៣៧០ ម^{៣}/ហ.ត ±១,៣៩៧

b. ប្រភេទឈើលេខ ១

- D = ៥-១៥ស.ម មានដង់ស៊ីតេ ១៧២ដើម/ហ.ត±៣៧ ស្មើនឹងមាឌ៨,៦១៣ម^{៣}/ហ.ត±១,៦០៩
- D = ១៥-៣០ស.មមានដង់ស៊ីតេ ៦៩ដើម/ហ.ត±១៥ ស្មើនឹងមាឌ១០,៧០០ម^{៣}/ហ.ត២,៣៤៦
- D ≥ ៣០ស.ម មានដង់ស៊ីតេ ១៥ដើម/ហ.ត ±២ ស្មើនឹងមាឌ ៦,៣៨៩ម^{៣}/ហ.ត ±០,៧៨៣

c. ប្រភេទឈើលេខ ២

- D = ៥-១៥ស.ម មានដង់ស៊ីតេ ៥០±១១,៨១៨ដើម/ហ.ត ស្មើនឹងមាឌ ៣,៣៨៣ ម^{៣}/ហ.ត±០,៧៧០
- D = ១៥-៣០ស.ម មានដង់ស៊ីតេ ៥០±១២,១៤២ដើម/ហ.ត ស្មើនឹងមាឌ ១០,៦៦៩ម^{៣}/ហ.ត±២,៥៤៤
- D ≥ ៣០ស.ម មានដង់ស៊ីតេ ១០±០,៩០៩ដើម/ហ.ត ស្មើនឹងមាឌ ៥,៧៨៨ម^{៣}/ហ.ត ±០,៥២៦

d. ប្រភេទឈើលេខ ៣

- D = ៥-១៥ស.ម មានដង់ស៊ីតេ ៣០ដើម/ហ.ត ±៤ ស្មើនឹងមាឌ ២,៣០៤ ម^{៣}/ហ.ត ±០,៣៤២
- D = ១៥-៣០ស.មមានដង់ស៊ីតេ ១២ដើម/ហ.ត±២ ស្មើនឹងមាឌ១,៦៨១ ម^{៣}/ហ.ត±០,២៩២

e. ប្រភេទឈើក្រៅលំដាប់

- D = ៥-១៥ស.មមានដង់ស៊ីតេ ២៩៨ដើម/ហ.ត±៥៦ ស្មើនឹងមាឌ ១៦,៥៣០ ម^{៣}/ហ.ត ±២,៩១៦
- D = ១៥-៣០ស.ម មានដង់ស៊ីតេ ៤៦ដើម/ហ.ត±១០ ស្មើនឹងមាឌ ៦,៤៨៣ ម^{៣}/ហ.ត±១,៥៣១
- D ≥ ៣០ស.ម ដង់ស៊ីតេ ២០ដើម/ហ.ត ±៣ ស្មើនឹងមាឌ ៣៥,៤៦៦ ម^{៣}/ហ.ត ±៩,៩០៤

Draft

១១៣. ជារួមប្រភេទឈើនៅក្នុងព្រៃល្បោះនេះប្រមាណជា ៦៧ភាគរយជាប្រភេទឈើបង្គោល ដែលមានអង្កត់ផ្ចិតចន្លោះពី ៥ ទៅ ១៥ស.ម ២៤ភាគរយ ជាប្រភេទឈើដែលមានអង្កត់ផ្ចិតពី ១៥-៣០ស.ម និងឈើដែលមានអង្កត់ផ្ចិតធំជាង ៣០ស.ម មានត្រឹមតែ ៩ភាគរយប៉ុណ្ណោះ។ លទ្ធផលដែលបានរកឃើញមានភាពជឿជាក់ប្រមាណជា ៨៥% ខណៈដែល១៥%ទៀត ជាកម្រិតលំអៀង(S.E) មានតម្លៃតូចដែលប្រែប្រួលជុំវិញតម្លៃមធ្យមដង់ស៊ីតេ និងមាឌឈើក្នុងមួយហិកតា។ យ៉ាងណាមិញ ភាពជឿជាក់អាចនឹងកើតមានធំជាង ៨៥% លុះត្រាណាការសិក្សា ត្រូវបានដាក់តាំងឡូត៍-អនុឡូត៍គម្រូបន្ថែម ឬស្ថានភាពឡូត៍-អនុឡូត៍គម្រូនោះមានភាពប្រហាក់ប្រហែលគ្នា។

៥.៤.២.៥ ការប៉ាន់ស្មានជីវម៉ាស់ព្រៃឈើ

តារាងទី ៥-២៦ ៖ ការប៉ាន់ស្មានជីវម៉ាស់ឈើលើដី ក្រោមដី និងការស្តុកកាបូន

ប្រភេទព្រៃ	ជីវម៉ាស់ឈើ ±S.E (t/ha)			ការស្តុកកាបូន ±S.E (t/ha)	ការស្រូប CO_2 ±S.E (t/ha)
	លើដី (AGB)	ក្រោមដី (BGB)	សរុប		
ព្រៃពាក់កណ្តាលស្រោង	៤៦,៥២២±៦,៧១២	១៣,៩៥៧±២,០១៣	៦០,៤៧៩	៣០,២៣៩±៤,៣៦២	១១០,៨៧៨±១៥,៩៩៦
ព្រៃល្បោះ	៦៥,៧៨៣±១៧,៩៤៣	១៩,៧៣៥±៥,៣៨៣	៨៥,៥១៧	៤២,៧៥៩±១១,៦៦៣	១៥៦,៧៨០±៤២,៧៦៥

ចំណាំ៖ ចំពោះការប៉ាន់ស្មានជីវម៉ាស់ក្រោមដី របាយការណ៍សិក្សាស្រាវជ្រាវរបស់ **Nophea,** ឆ្នាំ ២០០៧ បង្ហាញថាតម្លៃជីវម៉ាស់ក្រោមដីជាទូទៅស្មើនឹង ៣០%នៃជីវម៉ាស់លើដី ។

១១៤. ការប៉ាន់ស្មានជីវម៉ាស់ឈើលើដី និងការស្តុកកាបូនក្នុងតារាងទី៥-២៦ គឺផ្អែកលើសមីការដែលបានស្រាវជ្រាវ និងរៀបចំចងក្រងដោយអង្គការអន្តរជាតិគាំទ្រការត្រួតពិនិត្យ និងវាយតម្លៃកាបូនព្រៃឈើ **Winrock**។ លទ្ធផលជីវម៉ាស់ឈើក្នុងព្រៃពាក់កណ្តាលស្រោងមាន ៦០,៤៧៩តោន/ហិកតា និងព្រៃល្បោះមានប្រមាណជា ៨៥,៥១៧តោន/ហិកតា។ បរិមាណជីវម៉ាស់ឈើដែលបានប៉ាន់ស្មានខាងលើបង្ហាញថា ព្រៃល្បោះមានជីវម៉ាស់ឈើប្រហាក់ប្រហែលគ្នានឹងលទ្ធផលសិក្សាស្រាវជ្រាវរបស់អង្គការ **JICA** ឆ្នាំ ២០០២ និងរាជរដ្ឋាភិបាលកម្ពុជាឆ្នាំ២០០៧ ខណៈជីវម៉ាស់ក្នុងព្រៃពាក់កណ្តាលស្រោងមានកម្រិតទាបជាងលទ្ធផលសិក្សាវាយតម្លៃរបស់អង្គការ **IUCN** និង **UNEP-WCMC** (២០១០) សហការជាមួយរដ្ឋបាលព្រៃឈើ។ ដោយឡែកបរិមាណកាបូនស្តុកវិញគឺមានតម្លៃស្មើនឹង ៥០% នៃជីវម៉ាស់ឈើ។ ដូច្នេះ ការស្តុកកាបូនក្នុងតំបន់សិក្សាតាមប្រភេទព្រៃនីមួយៗ ក្នុងតំបន់គម្រោង គឺព្រៃពាក់កណ្តាលស្រោង មានកាបូនស្តុក ៣០,២៣៩តោន/ហិកតា±៤,៣៦២ និងព្រៃល្បោះមាន ៤២,៧៥៩±១១,៦៦៣តោន/ហិកតា។ ជារួម លទ្ធផលខាងលើបើធៀបនឹងទិន្នន័យពីអង្គការ **IUCN** និង **UNEP-WCMC** (២០១០) អាចសន្និដ្ឋានថា តំបន់គម្រោងអភិវឌ្ឍន៍របស់ក្រុមហ៊ុន ដូទីសាយហួន-ប៊ិញហឿក (អេស ប៊ី ខេ) គឺស្ថិតនៅក្នុងកម្រិតកាបូនទាបចន្លោះតម្លៃពី ០-១១៤តោន/ហិកតា ។

Draft

៥.៤.២.៦ ការពិភាក្សាអំពីនិន្នាការនៃការផ្លាស់ប្តូរជម្រក ឬសារព័ន្ធរុក្ខជាតិ

១១៥. ការសិក្សាលើថាមវន្តនៃការប្រើប្រាស់ដី និងគម្របព្រៃឈើរយៈពេល១០ឆ្នាំកន្លងមក ដោយប្រើប្រាស់ប្រព័ន្ធព័ត៌មានភូមិសាស្ត្រ និងទិន្នន័យរូបភាពពីលើអាកាស (ប្រព័ន្ធព័ត៌មានភូមិសាស្ត្រ និងទិន្នន័យ រូបភាពពីលើអាកាសរបស់រដ្ឋបាលព្រៃឈើឆ្នាំ ២០០២ ឆ្នាំ ២០០៦ និងឆ្នាំ ២០១០) ទាំងបីដំណាក់កាល បង្ហាញថា ស្ថានភាពព្រៃឈើក្នុងតំបន់គម្រោងបាត់បង់ជាមធ្យមប្រចាំឆ្នាំប្រមាណជា ០,៥-១% ដោយសារការកាប់រានទន្ទ្រានចាប់យកដីធ្វើកសិកម្ម និងសង់លំនៅដ្ឋានដោយប្រជាជនមូលដ្ឋាន និងប្រជាជនចំណាកស្រុក។ សកម្មភាពទាំងនេះមានឥទ្ធិពលយ៉ាងខ្លាំងលើការផ្លាស់ប្តូរនានាភាពប្រភេទជីវចម្រុះក្នុងតំបន់នេះ តាំងពីមុនពេលគម្រោងអភិវឌ្ឍដំណាំកៅស៊ូបានចាប់ផ្តើម ជាពិសេសការប៉ះពាល់ដល់សង្គមរុក្ខជាតិ និងជម្រកសត្វព្រៃ។ ការផ្លាស់ប្តូរសង្គមរុក្ខជាតិ មានន័យថាវាបានធ្វើឲ្យមានការរំខាន ឬបាត់បង់ទីជម្រកសុវត្ថិភាពសត្វព្រៃឈើគ្រប់ប្រភេទក្នុងតំបន់នេះ ក៏ដូចជាការធ្វើឲ្យបាត់បង់វដ្តនៃចំណីអាហារសត្វផងដែរ។

១១៦. ដោយផ្អែកលើលទ្ធផលនៃការវិភាគលើដងស៊ីតេ និងមាឌឈើក្នុងតំបន់គម្រោងបង្ហាញថា ទីតាំងសិក្សាមានបរិមាណដងស៊ីតេ និងមាឌឈើទាប ជាពិសេសឈើដែលមានអង្កត់ផ្ចិតធំជាង ៣០ស.ម បើធៀបនឹងឈើអង្កត់ផ្ចិត ចន្លោះពី ៥-៣០ស.ម។ ម្យ៉ាងវិញទៀតសារព័ន្ធរុក្ខជាតិជាកូនដំណុះ និងកូនឈើមានបរិមាណច្រើនបង្គួរ ដែលបង្ហាញអំពីដំណាក់កាលអន្តរកម្មនៃការដុះលូតលាស់នៃព្រៃឈើឡើងវិញ បន្ទាប់ពីការដកហូតនូវប្រភេទឈើពាណិជ្ជកម្មក្នុងតំបន់នេះកន្លងមក។ បើពិនិត្យលើគម្របព្រៃឈើឆ្នាំ ២០០២ ២០០៦ និងឆ្នាំ ២០១០ បង្ហាញពីសហគមន៍រុក្ខជាតិមួយដែលបានកើនក្នុងឆ្នាំ ២០០២ និងឆ្នាំ ២០០៦ ប៉ុន្តែក្លាយទៅជាសហគមន៍ដាច់ដោយឡែកៗក្នុងឆ្នាំ ២០១០(សូមមើលផែនទី៥-៨,៩,១០៖ ផែនទីគម្របព្រៃឈើ ឆ្នាំ ២០០២ ២០០៦ និង ឆ្នាំ ២០១០)។

១១៧. ការសិក្សាសារព័ន្ធរុក្ខជាតិក្នុងរដូវវស្សាបានរកឃើញថាមានដើមឈើខ្ពស់ៗ ដែលមានតម្លៃពាណិជ្ជកម្មតិច តូចបំផុតបន្សល់ទុកពីការធ្វើអាជីវកម្មនៅក្នុងប្រភេទព្រៃតាមដងអូរ។ បើពិនិត្យលើស្ថានភាពព្រៃក្នុងតំបន់គម្រោងភាគច្រើនទទួលរងការរំខាន និងត្រូវបានកាត់ផ្តាច់ជាបំណែកៗដូចស្បែកខ្លាដោយចម្ការរបស់ប្រជាពលរដ្ឋដែលរស់នៅក្នុង និងជុំវិញតំបន់នេះ ដែលអាចសន្និដ្ឋានបានថាកាត់ផ្តាច់នូវច្រករបៀងសម្រាប់សត្វព្រៃបម្លាស់ទីទៀតផង។

៥.៤.២.៧ ពិភាក្សា

១១៨. សារព័ន្ធរុក្ខជាតិក្នុងតំបន់សម្បទានរបស់ក្រុមហ៊ុន **ដូទីសាយហ្គន ប៊ីញហ្វឿក (អេស ប៊ី ខេ)** មានប្រមាណជា ៧១ប្រភេទជាដើមឈើខ្ពស់ៗ និង ២៩ប្រភេទផ្សេងទៀត ជារុក្ខជាតិស្រទាប់ចម្រុះដូចជា ពពួកមើម វល្លិ ស្មៅ និងស្បូវជាដើម ដែលបានជួបប្រទះ និងកត់ត្រាក្នុងឡូត៍-អនុឡូត៍គម្រូ។ ប្រភេទឈើទាំងនេះមានវត្តមានទាំងក្នុងព្រៃពាក់កណ្តាលស្រោង និងព្រៃល្បោះ មានចំនួនប្រមាណជា ៤,៣៣ភាគរយ នៃប្រភេទរុក្ខជាតិសរុបនៅកម្ពុជា ២៣០៨ប្រភេទ។ មានរុក្ខជាតិប្រមាណជា ២០-៣០ប្រភេទ ពិនិត្យឃើញ មាននៅតាមព្រៃពាក់កណ្តាលស្រោង និងតាមដងអូរ។ ក្នុងនោះមាន១៨ប្រភេទ ជាប្រភេទឈើពាណិជ្ជកម្មតែឈើទាំងនេះមានតម្លៃតិចតួចបំផុត (អង្កត់ផ្ចិតតូច) រួមមាន៖ ឈើប្រណិតចំនួន ៥ប្រភេទ (៣ប្រភេទកំណត់ក្នុងបញ្ជីក្រហម **IUCN Red List**) ឈើលេខ១ ចំនួន ៦ប្រភេទ ឈើលេខ ២ ចំនួន ៣

ប្រភេទ និង ឈើលេខ៣ ចំនួន ៤ ប្រភេទ។ ប្រភេទឈើក្នុងបញ្ជីក្រហម **IUCN Red List** រួមមាន បេង នាងនួន និងធ្នង់ បច្ចុប្បន្នបាននិងកំពុងជិតផុតពូជ។ ទំហំអង្កត់ផ្ចិតដែល ជួបប្រទះគឺ ១៥-២០ស.ម គឺកម្រិតដង់ស៊ីតេ ១៦ដើម/ហ.ត សម្រាប់ព្រៃពាក់ កណ្តាលស្រោង និង ២៧ ដើម /ហ.ត សម្រាប់ ព្រៃល្បោះ។ បើធៀបនឹងកូនឈើដែលមានអង្កត់ផ្ចិតពី ៥-១៥ស.ម គឺកូនឈើទាំងនេះ មានចំនួនច្រើនក្នុង កម្រិត ដង់ស៊ីតេ ១៤០ដើម/ហ.ត ក្នុងព្រៃពាក់កណ្តាលស្រោង និង ២៤ដើម/ហ.ត ក្នុងព្រៃល្បោះ។ ដោយឡែកប្រភេទរុក្ខជាតិឱសថមានជាបង្គួរដែលប្រមាណជា៣៩ភាគរយ នៃសារព័ន្ធរុក្ខជាតិ ដែលបាន កត់ត្រាក្នុង ឡូត៍-អនុឡូត៍ត្រូវបានចាត់ទុកថាជាប្រភេទរុក្ខជាតិឱសថដ៏សំខាន់រួមទាំងមើម សំបក ឬស និងស្លឹក ដែលប្រើប្រាស់ជាលក្ខណៈប្រពៃណីដោយប្រជាជនមូលដ្ឋានដូចជា៖ សំបក ស្លឹក ឬស ផ្លែ និងគ្រាប់ជា ដើម។

១១៩. ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ លទ្ធផលសិក្សាលើការប្រែប្រួលគម្របព្រៃឈើតាមប្រព័ន្ធព័ត៌មានសាស្រ្ត ដោយប្រើប្រាស់ទិន្នន័យគម្របព្រៃឈើឆ្នាំ ២០១០ និងរូបភាពផ្កាយរណប **Landsat 8 OLI** ឆ្នាំ ២០១៤ បង្ហាញអំពីកម្រិតនៃការបាត់បង់ព្រៃឈើប្រចាំឆ្នាំប្រមាណជា ០,៥-១% ដែលជាអត្រាដ៏ខ្ពស់មួយកំពុងនឹងគម្រាមកំហែង លើសារព័ន្ធរុក្ខជាតិក្នុងតំបន់សិក្សាផងដែរ។

១២០. ជារួមការសិក្សាបង្ហាញថា ភាពសម្បូរណ៍បែបនៃនានាភាពប្រភេទជីវចម្រុះក្នុងតំបន់គម្រោងអភិវឌ្ឍន៍មានកម្រិតទាប ដែលអាចនិយាយបានថាប្រព័ន្ធអេកូឡូស៊ីក្នុងទីតាំងសិក្សាស្រាវជ្រាវត្រូវបានរំខានដោយសារសកម្មភាពមនុស្សតាំងពី ៥ ទៅ ៧ឆ្នាំមុនមកម្ល៉េះ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយការធ្វើផែនការគ្រប់គ្រងជីវចម្រុះក្នុងតំបន់ ជាពិសេសព្រៃតាមដងអូរ ដែលជាផ្នែកមួយដ៏សំខាន់ ដើម្បីធានាដល់ការរក្សាទុកនូវប្រភពធនធានសេនេទិច តម្លៃផ្នែកទីជម្រាល និងច្រករបៀងសត្វព្រៃដ៏សំខាន់ និងធានាដល់ការអភិវឌ្ឍន៍ប្រកបដោយចិរភាព។

៥.៤.៣ សត្វអេកូឡូស៊ី

១២១. តាមតារាងទី៥-២៧ និងទី៥-២៨បានបង្ហាញឲ្យដឹងថា ការសិក្សាបានកត់ត្រាវត្តមានសត្វស្លាបចំនួន៧៩ប្រភេទដែលមានចំនួន៣៩១ក្បាល និងតាមរយៈដានជើង លាមក និងស្នាមកាយ មានថនិកសត្វចំនួន០៤ប្រភេទដូចជា ប្រើស ឈ្លូស ជ្រូក និងសំពោច។

១២២. បើយោងតាមប្រកាសលេខ០២០ ប្រក កសក ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០០៧ ស្តីពីចំណាត់ថ្នាក់ និងបញ្ជីឈ្មោះប្រភេទសត្វព្រៃ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រភេទសត្វព្រៃដែលបានកត់ត្រានេះ សុទ្ធតែជាប្រភេទបង្គួរ ដែលមានរបាយធំទូលំទូលាយ មានសក្តានុពលបន្តពូជឆាប់រហ័ស និងរងការគំរាមកំហែងតិចតួចក្នុងតម្រូវការសង្គម សេដ្ឋកិច្ច។ ដោយឡែកបើយោងតាមសៀវភៅបញ្ជីក្រហមឆ្នាំ ២០១៣ (IUCN Red List-2013) សត្វស្លាបសារិកាកែវវង (Hill Myan *Crascula religiosa*) ត្រូវបានចាត់ទុកជាប្រភេទដែលមានទិន្នន័យមិនគ្រប់គ្រាន់ដែលត្រូវធ្វើការពារនិងអភិរក្ស។

១២៣. ការសិក្សាពុំបានប្រទះឃើញវត្តមានសត្វព្រៃជាប្រភេទមានដោយកម្រនិងជិតផុតពូជ ដែលត្រូវយកចិត្តទុកដាក់យ៉ាងសំខាន់សម្រាប់ការអភិរក្សនោះទេ។ ប្រភេទដែលជាចំណាប់អារម្មណ៍ និងត្រូវយកចិត្តទុកដាក់សម្រាប់ការអភិរក្សមានដូចជាថនិកសត្វ៖ ត្រកូលខ្លា ខ្លាឃ្មុំ គោសាទិស ដំរី រមាំង ក្តាន់ កែះ ទោច កេ

ញើ ស្វាក្រវាត់ ស្វាអង្កត់ និងសត្វស្លាបៈ ត្រដក់ធំ ត្រយ៉ង ទាព្រៃស្លាបស អង្កត់ខ្មៅ ក្រៀល ត្មាត មាន់ទោ សេកសោម។ល។

១២៤. តាមការសំភាសន៍អ្នកនាំផ្លូវដែលជាអ្នកតែងតែចូលព្រៃកត្រើ ប្រមាញ់ និងប្រមូលផលអនុផលព្រៃឈើបានឲ្យដឹងថាវត្តមានប្រភេទសំខាន់ដូចជា ដំរី ខ្ទីង ទន្សោង ខ្លាឃ្មុំ មេាំង ខ្លាធំបង ស្វាក្រវាត់ ស្វាអង្កត់ បានដាច់ពូជពីក្នុងតំបន់នេះជាង៥ឆ្នាំកន្លងទៅហើយ ដោយសារការប្រមាញ់យ៉ាងខ្លាំងក្លា។ បច្ចុប្បន្ន តំបន់នេះនៅមានវត្តមានតិចតួចនូវប្រភេទសត្វព្រៃ ដូចជា ប្រើស ខ្លាត្រី ជ្រូកព្រៃ ឈ្លូស ទន្សាយ ក្ងាន់ព្រៃ សំពោច ស្កា និងកាំប្រម៉ា។ ការសន្និដ្ឋាននេះ គឺស្របទៅនឹងលទ្ធផលនៃការសិក្សាដែលបានកត់ត្រាវត្តមាន ដានជើងជ្រូកព្រៃ១៩ដង ឈ្លូស០៩ដង ប្រើស០១ដង ដានជើងនិងលាមកសំពោច០៦ដង។

១២៥. បន្ថែមលើសពីនេះ **លោក សំ អាង** ដែលជាអ្នកនាំផ្លូវបានឲ្យដឹងផងដែរថា កាលពីខែមេសាឆ្នាំ២០១៣ រូបគាត់បានឃើញក្ងោក៥ក្បាល ត្រដក់តូច២ក្បាល និងមាន់ទោជាប់អន្ទាក់១ក្បាលនៅក្នុងតំបន់ឡូត៍សិក្សាទី១ (Tr-I) និងទី២ (Tr-II) និងបានឮប្រជាជនថាធ្លាប់បានឃើញដានខ្លាកាលពី២ឆ្នាំមុននៅតំបន់ឡូត៍សិក្សាទី៥ (Tr-V)។ លទ្ធផលនេះបញ្ជាក់ឲ្យឃើញថាវត្តមានសត្វព្រៃក្រុមប្រភេទមានដោយបង្គួរនៅមានវត្តមាននៅឡើយ។

៥.៤.៣.១ ថនិកសត្វ

១២៦. តារាងទី ៥-២៧ បង្ហាញអំពីប្រភេទនិងចំនួនថនិកសត្វដែលកត់ត្រាក្នុងតំបន់សិក្សា តាមរយៈការឃើញដោយផ្ទាល់ ឮសម្លេង លាមក ដានជើងស្នាមកាយ និងស្នាមកកិតតាមដើមឈើ និងចំណាត់ថ្នាក់សម្រាប់ការអភិរក្សថ្នាក់ជាតិនិងសាកល។

តារាងទី ៥-២៧ ៖ ចំនួនថនិកសត្វដែលបានអង្កេតក្នុងតំបន់សិក្សាក្នុងទីតាំងដីក្រុមហ៊ុន

ឈ្មោះខ្មែរ	ឈ្មោះ អង់គ្លេស	ឈ្មោះវិទ្យាសាស្ត្រ	ចំណាត់ថ្នាក់ កសក ២០០៧	ចំណាត់ថ្នាក់ IUCN ២០១៣	ចំនួនកត់ត្រា
ឈ្លូស	Red muntjac	*Muntiacus muntjak*	C	LC	9
ជ្រូក	Wild pig	*Sus scrofa*	C	LC	19
សំពោច	Civet	*Viverra spp*	C	LC	6
ប្រើស	Samba		C	LC	1
ចំនួនប្រភេទកត់ត្រាសរុប					4
ចំនួនសត្វបានរាប់សរុប					35

សំគាល់៖

- ប្រកាសក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឆ្នាំ២០០៧ ស្តីពីចំណាត់ថ្នាក់និងបញ្ជីឈ្មោះប្រភេទសត្វព្រៃ(កសក ២០០៧)។ E - ក្រុមប្រភេទជិតផុតពូជ R - ក្រុមប្រភេទមានដោយកម្រ C - ក្រុមប្រភេទមានដោយបង្គួរ។

- ចំណាត់ថ្នាក់និងបញ្ជីឈ្មោះប្រភេទសត្វព្រៃជាអន្តរជាតិ តាមសៀវភៅបញ្ជីក្រហមឆ្នាំ២០១៣ (IUCN Red List 2013)។ CR - ប្រភេទជិតផុតពូជបំផុត EN - ប្រភេទជិតផុតពូជ VU - ប្រភេទកំពុងរងគ្រោះថ្នាក់ NT- ប្រភេទកំពុងរងការគំរាមកំហែង LR- ប្រភេទមានគ្រោះថ្នាក់តិចតួច LC- ប្រភេទបង្គួរ DD- គ្មានទិន្នន័យគ្រប់គ្រាន់។ ដកស្រង់ចេញពី IUCN Red List of Threatened Species, and version 2013.1។

១២៧. កន្លងទៅតំបន់នេះពុំមានការសិក្សាពីវត្តមាននិងរបាយសត្វព្រៃឡើយ។ ប៉ុន្តែតាមការសម្ភាសន៍តំបន់នេះធ្លាប់មានវត្តមានប្រភេទសត្វសំខាន់ៗសម្រាប់ធ្វើការការពារនិងអភិរក្ស។ លទ្ធផលនៃការសិក្សាបានកត់ត្រាវត្តមានដង់ស៊ីតេសត្វនៅតំបន់នេះមានចំនួនតិចតួចបំផុត។ មានដានជើងជ្រូកព្រៃ១៩ដង ឈ្លូស០៩ដង និងដានជើងនិងលាមកសំពោច ០៦ដង ត្រូវបានកត់ត្រានៅក្នុងឡូត៍សិក្សាទាំង៥ លើកលែងតែដានប្រើស១ក្បាលបានកត់ត្រានៅក្នុងតំបន់ព្រៃឈ្មោះក្នុងឡូត៍សិក្សាទី៣ (Tr-III)។

៥.៤.៣.២ សត្វស្លាប

១២៨. តារាងទី៥-២៨ ប្រភេទនិងចំនួនសត្វស្លាបកត់ត្រាក្នុងតំបន់សិក្សា តាមរបៈការឃើញដោយផ្ទាល់និងឮសម្លេង និងចំណាត់ថ្នាក់សម្រាប់ការអភិរក្សថ្នាក់ជាតិនិងសាកល។

តារាងទី ៥-២៨ ៖ ចំនួនសត្វស្លាប ដែលបានអង្កេតក្នុងតំបន់សិក្សាក្នុងទីតាំងដីក្រុមហ៊ុន

ឈ្មោះខ្មែរ	ឈ្មោះអង់គ្លេស	ឈ្មោះវិទ្យាសាស្ត្រ	កសក	IUCN	សរុប
លលកបាយ	Spotted Dove	*Streptopelia chinensis*			25
ពពិចក្បាលខ្មៅចុងខ្នងស	Sooty-headed Bulbul	*Pycnonotus aurigaster*			19
ចករកកំប៉ោយស	White-crested Laughingthrush	*Garrulax leucolophus*			18
ចាបដង្កូវស្លាបច្រេះ	Rufescent Prinia	*Prinia rufescen*			16
ចាបដូនតា	Oriental Reed Warbler	*Acrocephalus orientalis*			14
ពពិចពុកមាត់លឿង	Stripe-throated Bulbul	*Pycnonotus finlaysoni*			14
កញ្ចៀត	Vinous-breasted Starling	*Sturnus burmannicus*			11
ចាបតេតព្រៃ	Dark-necked Tailorbird	*Orthotomus atrogularis*			11
ចាបដូនតាក្បាលប្រផេះ	Pale-legged Leaf Warbler	*Phylloscopus fenellipes*			9
ទាវខៀវ	Indian Roller	*Coracias benghalensis*			9
ប៉ោលគោកក្បាលព្រលែត	Lineated Barbet	*Megalaima lineata*			9
សារិកាកែវក្របី	White-vented Myna	*Acridotheres grandis*			8
ចាបក្រច	Yellow-vented Bulbul	*Pycnonotus goiavier*			8

Draft

ពពិចត្រចៀកឆ្នូត	Streak-eared Bulbul	*Pycnontus blanfordi*			8
ចាបកន្លង់	Olive-backed Sunbird	*Nectarinia jugularis*			7
ចាបដូនតាទូរស័ព្ទ	Striped Tit Babbler	*Macronous gularis*			7
ឆ្កងឆ្អកលឿង	Rufous Treepie	*Dendrocitta vagabunda*			7
ពពិចក្បាលខ្មៅកំប៉ោយ	Black-crested Bulbul	*Pycnonotus melanicterus*			7
កញ្ជាក់ស្លា	White-browed Fantail	*Rhipidura aureola*			7
ចេកទេសធំ	Scarlet Minivet	*Pericrocotus flammeus*			6
ត្រដេវក្បាលបៃតង	Blue-tialled Bee-eater	*Merops philippinus*			6
ត្រសេះតូចខ្នងភ្លើង	Common Flameback	*Dinopium javanense*			6
ទទា	Chinese Francolin	*Francolinus pintadeanus*			6
ពពូល	Orange-breasted Green Pigeon	*Treron bicincta*			6
ចេកទុំ	Black-naped Oriole	*Oriolus chinensis*			5
ចេកទុំក្បាលខ្មៅ	Black-hooded Orioles	*Oriolus xanthornus*			5
ពពិចបំពង់កសទ្រូងលឿង	Puff-throated Bulbul	*Criniger pallidus*			5
មាន់ព្រៃ	Red Junglefowl	*Gallus gallus*			5
អន្ទេបខ្មៅផ្លេក	Bronzed Drongo	*Dicrurus aeneus*			5
គ្រលីងគ្រលោង	Black-collared Straling	*Sturnun nigricollis*			4
ចកកៃវណ្ណទ្រូងខ្មៅ	Lesser-necklaced Laughingthrush	*Garrulax monleger*			4
ចចាតក្រឹម	Common Kingfisher	*Alcedo atthis*			4
ចាបដូនតាគូទលឿង	White-bellied Yuhina	*Yuhina zantholeuca*			4
ចេកខ្ចីស្លាបខៀវ	Blue-winged Leafbird	*Chloropsis cochinchinnensis*			4
ចេកទេសតូច	Small Minivet	*Pericrocotus cinnamomeu*			4
ត្រដេវវិចទូល	Red-wattled Lapwing	*Vanellus indicus*			4
បាគូ	Common Hoopoe	*Upupa epops*			4
ពពូលជើងលឿង	Yellow-footed Green Pigeon	*Treron phoenicoptera*			4
លលកទ្រាំង	Red-collared Dove	*Streptopelia tranquebarica*			4
ល្លាចេកព្រៃ	White-rumped Shama	*Copsychus malabaricus*			4
អន្ទេបប្រផេះ	Ashy Drongo	*Dicrurus leucophaeus*			4

Draft

អល់អែកស្លាបខ្មៅធ្នូត ស	Bar-winged Flycatcher Shrike	*Hemipus picatus*			4
លលកខ្មោច	Emerald Dove	*Chalcophaps indica*			4
ក្រួច	Small Buttunquail	*Turnix sylvatica*			3
ចាបកន្លង់តូចពីងពាង	Little Spider hunter	*Arachnothera logirostra*			3
តុកកាគូ	Green-billed Malkoha.	*Phaenicophaeus tristis*			3
ពពិចថ្មខ្មៅចុងខ្នងស	Pied Bushchat	*Saxicola caprata*			3
ពពិចបំពង់កសទ្រូងប្រផេះ	Ochraceous Bulbul	*Alophoixus ochraceus*			3
រអាតត្នោត	Rufous-winged Buzzard	*Butastus liventer*			3
សេកសក	Red-breasted Parakeet	*Spittacula alexandri*			3
ស្ទាំងតូចស្លាបស្រួច	Collared Falconet	*Polihierax insignis*			3
ចាបដូនតាចំពុះលឿង	White-browed Scimitar Babbler	*Pomatorhinus schisticeps*			2
ចេកចៅ	Common Iora	*Aegithina tipha*			2
ចេកទេសផ្កាឈូក	Swinhoe's Minivet	*Pericrocotus cantonensis*			2
ត្រដេវក្បាលត្នោតខ្ចី	Chestnut-headed Bee-eater	*Merops leschenaulti*			2
ត្រដេវតូច	Green Bee-eater	*Merops orientalis*			2
ត្រសេះធំកំប៉ោយលឿង	Greater Yellownape	*Picus flavinucha*			2
ត្រសេះត្នោតចំពុះខ្មៅ	Rusfous Woodpecker	*Celeus brachyurus*			2
ត្រសេះបៃតងក្បាលខ្មៅ	Black-headed Woodpecker	*Picus erythropygius*			2
ទ្រមាក់ខ្លា	Racket-tailed Treepie	*Crypsirina temia*			2
ពពូលបំពង់កលឿង	Pompadour Green Pigeon	*Treron pompadora*			2
សារិកាកែវរឹក	Common Myna	*Acridotheres tristis*			2
សេកក្រិច	Vernal Hanging Parakeet	*Loriculus vernalis*			2
អន្ទេបទងកន្ទ្រៃ	Greater Racket-tail Drogo	*Dicrurus paradiseus*			2
ភាវខៀវ	Indian Roller	*Coracias benghalensis*			2
កដិបក្បាលខ្មៅ	Black-capped Kingfisher	*Halcyon pileata*			1
ចាបចៀប	Orange-breasted Trogon	*Harpactes oreskios*			1
ចេកទុំប្រាក់	Silver Orioles	*Oriolus mellianus*			1
ត្រដក់តូច	Lesser Adjutant	*Leptoptilos javanicus*			1

Draft

ត្រសេះតូចពោះត្នោត	Chestnut-belled Nuthatch	*Sitta castanea*			1
ប៉ោលតោកត្រចៀកបៃតង	Green-eared Barbet	*Megalaima faiostricta*			1
ពពិចថ្មទ្រូងត្នោត	Common Stonechat	*Saxicola torquata*			1
មៀមតូច	Asian-barred Owlet	*Glaucidium cucloides*			1
ល្អុតធំ	Greater Cuocal	*Centropus sinensis*			1
សារិកាកែវវង	Hill Myna	*Gracula religiosa*			1
ស្ទាំងលលក	Black-shouldered Kite	*Elanus coerusleus*			1
អកត្រី	Lesser Fish Eagle	*Ichthyophaga humillis*			1
អកព្រៃច្រើនពណ៌	Changgeable Hawk Eagle	*Spizaetus cirrhatus*			1
អល់អែកមធ្យម	Larger Woodshrike	*Tephrodornis vigatus*			1
ចំនួនប្រភេទសរុប					79
ចំនួនរបាយនិមួយៗសរុប					391

សំគាល់៖

- ប្រកាសក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឆ្នាំ២០០៧ ស្តីពីចំណាត់ថ្នាក់និងបញ្ជីឈ្មោះប្រភេទសត្វព្រៃ(កសក ២០០៧) E - ក្រុមប្រភេទជិតផុតពូជ R-ក្រុមប្រភេទមានដោយកម្រ C - ក្រុមប្រភេទមានដោយបង្គួរ។
- ចំណាត់ថ្នាក់និងបញ្ជីឈ្មោះប្រភេទសត្វព្រៃជាអន្តរជាតិ តាមសៀវភៅបញ្ជីក្រហមឆ្នាំ ២០១៣ (IUCN Red List 2013)។ CR - ប្រភេទជិតផុតពូជបំផុត EN - ប្រភេទជិតផុតពូជ VU - ប្រភេទកំពុងរងគ្រោះថ្នាក់ NT - ប្រភេទកំពុងរងការគំរាមកំហែង LR - ប្រភេទមានគ្រោះថ្នាក់តិចតួច LC - ប្រភេទបង្គួរ DD - គ្មានទិន្នន័យគ្រប់គ្រាន់។ ដកស្រង់ចេញពី IUCN Red List of Threatened Species, and version 2013.1។

១២៩. ការសិក្សាបានកត់ត្រាវត្តមានភាគច្រើនជាប្រភេទដែលរស់នៅតាមកន្សោមស្លឹក ដូចជាពពួកពពិច ចាបដង្កូវ អន្ទេប ចាបតេតព្រៃ លលក និងចាបផ្ទូនតា។ ការសិក្សានេះគឺដូចគ្នាទៅនឹងការសិក្សាសត្វព្រៃនៅភាគខាងជើងខេត្តមណ្ឌលគិរីរបស់លោក Joe Walston និងសមាជិកដទៃទៀតក្នុងឆ្នាំ២០០០ ដែលបាននិយាយថាប្រភេទទាំងនេះជាប្រភេទសម្បូរបែបនៅភាគខាងត្បូងឥណ្ឌូចិន ជាពិសេសក្នុងប្រទេសកម្ពុជា (សេដ្ឋានិង Poole-២០០៣)។ ប្រភេទ ចក់វក់កំប៉ោយ ចាបចៀប លលកខ្មោច ប៉ោតោក ជាប្រភេទដែលតែងតែប្រទះឃើញរស់នៅតាមព្រៃស្រោងនិងតាមដងអូរ។ ល្អុតធំ កញ្ជាក់ស្លា ត្រមាក់ខ្លា ជាប្រភេទដែលចូលចិត្តរស់នៅតាមតំបន់ព្រៃលិចទឹកតាមដងអូរ ស្ទឹង ដំណុះព្រៃក្មេង និងព្រៃឫស្សី (សេដ្ឋា និង Poole - ២០០៣) ។

១៣០. មានប្រភេទស៊ីសត្វល្អិតជាអាហារជាច្រើន ដូចជាពពួកចាបដង្កូវ ចាបផ្ទូនតា មានវត្តមាននៅក្នុងតំបន់សិក្សា។ នេះប្រហែលបណ្តាលមកពីរដូវវស្សាធ្វើឲ្យរុក្ខជាតិស្រទាប់ក្រោមដុះលូតលាស់ល្អ ជាជម្រក

Draft

ដល់ពពួកសត្វល្អិតរស់នៅនិងពងកូន។ ក្រៅពីនេះ ក៏បានកត់ត្រាប្រភេទសត្វស្លាបដូចជា មាន់ព្រៃ ទទាក្រួច ដែលជាប្រភេទពង កូន និងរកចំណីនៅផ្ទាល់ដីផងដែរ។

១៣១. មានការកត់ត្រាប្រភេទសត្វស្លាបទឹកតិចតួច ដូចជាប្រភេទចចាតក្រឹម និងត្រដក់តូចតែប៉ុណ្ណោះនៅក្នុងតំបន់សិក្សា។ ការមានវត្តមានសត្វស្លាបទឹកដ៏ទាបបែបនេះ អាចបណ្តាលមកពីទឹកហូរជោរជន់ពេញអូរធ្វើឲ្យប្រភេទសត្វស្លាបទឹកទាំងនោះពិបាកក្នុងការរកចំណី ក៏ត្រូវផ្លាស់ទីទៅតំបន់ដែលមានទឹកនឹង ងាយស្រួលក្នុងការរកចំណី តាមបឹង ត្រពាំង ឬវាលភក់នានា។ ដោយឡែក ដោយតំបន់ព្រៃនៅជុំវិញតំបន់សិក្សាបានបង្វែរទៅជាតំបន់កសិកម្ម ធ្វើឲ្យតំបន់នេះមានលក្ខណៈជាវាលលំហតាមជាយព្រៃ ទាក់ទាញវត្តមានប្រភេទសត្វស្លាបមួយចំនួនដូចជា ស្ទាំងលលក ល្មាចេក កញ្ជ្រៀត អាអូតស្បូវ លលក សារិកាកែវ។ល។

៥.៤.៤ អំពីមច្ឆាជាតិ

១៣២. យោងតាមការសម្ភាសន៍ជាមួយប្រជានេសាទរស់នៅជុំវិញតំបន់សិក្សា និងកម្មករដែលមានបទពិសោធន៍ក្នុងការនេសាទតាមព្រែកទេ បានបង្ហាញថាមានប្រភេទត្រីចំនួន ១៦៥ប្រភេទដែលបែងចែកជា ៨៥ពួកផ្សេងគ្នា។ ក្នុងនោះពួកដែលសម្បូរច្រើនជាងគេគឺ៖

១៣៣. ពួក PAGAS មាន ១១ប្រភេទដូចជា៖ ត្រីពោ *(Pangasius larnaudii)*, ត្រីឈ្វៀតក្ដារ *(Pangasius pleurotaenia)*, ត្រីឈ្វៀតស្មើកន្ទុយ *(Pangasius polyuranodon)*, ត្រីឈ្វៀត *(Pangasius siamensis sat)*, ត្រីប្រាខ្ចៅ *(Pangasius bocourti)*, ត្រីប្រាកែ ឬត្រីកែ *(Pangasius cochophilus)*, ត្រីប្រា *(Pangasius djambal)*, ត្រីបុងឡាវ *(Pangasius krempfi)*, ត្រីឈ្វៀតដូង *(Pangasius micronema)*, ត្រីឈ្វៀតធ្មូត *(Pangasius macronema)*, ត្រីប្រាក្របី *(Pangasius mekongensis)*។

១៣៤. ពួក BOTIA មាន ៧ប្រភេទដូចជា៖ ត្រីកញ្ជ្រូកខ្មៅ *(Boita helodes)*, ត្រីកញ្ជ្រូកលឿង *(Botia lecontei)*, ត្រីកញ្ជ្រូកក្រហម *(Botia modesta)*, ត្រីកញ្ជ្រូក *(Botia morleti, Botia caudipunctata, Botia eos* និង *Botia longidorsalis)*។

១៣៥. ពួក MYSTUS មាន ៦ប្រភេទដូចជា៖ ត្រីកញ្ចុះបាយ *(Mystus albolineatus)*, ត្រីកញ្ចុះបាយ *(Mystus atrifasciatus)*, ត្រីកញ្ចុះធ្មូតធំ *(Mystus multuradiatus)*, ត្រីកញ្ចុះធ្មូតតូច *(Mystus mysticetus)*, ត្រីកញ្ចុះបាយស *(Mystus singaringan)*, ត្រីកញ្ចុះ *(Mystus wolffii)*។

១៣៦. ពួក RASBOR មាន ៧ប្រភេទដូចជា៖ ត្រីចង្វារធ្មូត *(Rasbora paviei)* ត្រីចង្វារមូល *(Rasbora amplistriga, Rasbora atridorsalis, Rasbora aurotaenia, Rasbora hobelmani, Rasbora myersi* និង *Rasbora tornieri)*។

៥.៤.៤.១ ប្រភេទត្រី

១៣៧. ការសិក្សាអំពីមច្ឆាជាតិ (ប្រភេទត្រី ការបំលាស់ទីរបស់ក្រុមត្រី និងការពងកូន) បានរៀបចំឡើងតាមវិធីសាស្ត្រ៖ (ក) ចំណេះដឹងក្នុងស្រុក និង (ខ) ការចាប់ជាក់ស្តែង ដែលមានបង្ហាញនៅក្នុងជំពូកទី២ ចំណុច២.២.៣ ការសិក្សាអំពីមច្ឆាជាតិ។ ប្រភេទត្រីទាំង ១៦៥ប្រភេទត្រូវបានបែងចែកជា ៣ក្រុមធំៗផ្សេងគ្នា (ជ្យាក្រាម៥-៧) ដូចជា៖

Draft

ក. ក្រុមត្រីខ្មៅជាប្រភេទត្រីដែលពងកូនមិនរើសតំបន់ និងរស់នៅជាប្រចាំក្នុងតំបន់ទំនាបលិចទឹក ហើយមិនផ្លាស់ទីចេញពីតំបន់នោះវិញទេ។ ក្រុមត្រីខ្មៅនេះមានចំនួន ១៥ប្រភេទ ដូចជាត្រីកញ្ចនជ័យ ត្រីអោស ត្រីខ្យាន និងត្រីរស់ជាដើម (**ឧបសម្ព័ន្ធ៥-៤ តារាង៥-២៩**)។

ខ. ក្រុមត្រីសជាប្រភេទត្រីដែលពងកូនតាមចរន្តទឹកហូរ និងផ្លាស់ទីឆ្ងាយ ដែលចេញពីទន្លេទៅតំបន់លិចទឹក និងពីតំបន់លិចទឹកទៅទន្លេវិញ។ ក្រុមត្រីសនេះមានចំនួន ៤៨ ប្រភេទដូចជាត្រីឆ្កោក ត្រីឆ្ពិន ត្រីរាជជាដើម (**ឧបសម្ព័ន្ធ៥-៤ តារាង៥-២៩**)។

គ. ក្រុមត្រីប្រផេះ មិនមែនជាប្រភេទត្រីដែលមានពណ៌ប្រផេះដូចតាមការហៅនោះទេ តែជាប្រភេទត្រីដែលផ្លាស់ទីជិតៗ និងពងកូននៅតាមតំបន់លិចទឹកតាមមាត់ព្រៃកទេវ។ ក្រុមត្រីប្រផេះនេះមានចំនួន ១០២ប្រភេទ ដូចជាត្រីក្រាយក្របី ត្រីព្រលូង និងត្រីពុកមាត់បីជាដើម (**ឧបសម្ព័ន្ធ៥-៤ តារាង៥-២៩**)។

ដ្យាក្រាម៥-៧៖ ចំនួនត្រីរាប់តាមក្រុម



៥.៤.៤.២ ស្ថានភាពនៃព្រៃកទេវ

១៣៨. បន្ទាប់ពីធ្វើការសាកសួរនិងចូលរួមធ្វើការគូផែនទីដោយផ្ទាល់របស់ប្រជានេសាទ ដែលតែងតែធ្វើការនេសាទនៅទីនោះ ក៏ដូចជាកម្មករដែលធ្វើការក្នុងតំបន់ដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន និងការត្រួតពិនិត្យតាមអូរ ធ្វើឲ្យយើងដឹងថា៖ បាតនៃពាមទេវនេះមានសណ្ឋានជាថ្មភាគច្រើន និងកន្លែងខ្លះជាខ្សាច់ និងមានអន្លង់តូចធំជាច្រើនកន្លែងផងដែរ ដូចជា៖ អន្លង់គ្រុងធំ អន្លង់គ្រុងតូច អន្លង់ពាមព្រះ អន្លង់កែស អន្លង់ក្រវិល អន្លង់ស្រែនន និងអន្លង់កោរប្រើស។

៥.៤.៤.៣ ឧបករណ៍នេសាទ

១៣៩. ជាទម្លាប់អ្នកនេសាទទាំងអស់ប្រើឧបករណ៍ដូចជា៖

- មង៖ ជាទូទៅត្រូវបានប្រើចាប់ពីខែមិថុនាដល់ខែតុលាដែលមានទំហំពី២.៥ ទៅ៥សង់ទីម៉ែត្រ
- សន្ទូច៖ (លេខ១២, ១៧ និង១៨) ជាទូទៅត្រូវបានប្រើចាប់ពីខែកក្កដាដល់ខែវិច្ឆិកា
- លប៖ត្រូវបានគេប្រើចាប់ពីវិច្ឆិកាដល់ខែមិនា
- សំណាញ់៖ជាឧបករណ៍ប្រើជាទូទៅ

- ថ្នងៈជាឧបករណ៍ដែលគេពេញនិយមប្រើប្រាស់ ជាពិសេសនៅរដូវទឹកឡើង ជាទូទៅក្មេងៗនិងស្ត្រីជាអ្នកប្រើ។



រូបភាពទី៥-១៨៖ ឧបករណ៍ថ្នង

៥.៤.៤.៤ ប្រភេទត្រីដែលចាប់បាន

១៤០. ដោយការចាប់នេះមានតែរយៈពេលចំនួនបីថ្ងៃ និងក្នុងខែសីហានេះជារដូវទឹកឡើងខ្លាំង ដូច្នេះពុំសូវមានប្រជានេសាទធ្វើនេសាទច្រើននោះទេ និងមិនមានប្រើប្រាស់ឧបករណ៍នេសាទច្រើនផងដែរ។ ពួកគាត់ទៅនេសាទត្រីសម្រាប់តែបរិភោគក្នុងគ្រួសារតែប៉ុណ្ណោះ។ ភាគច្រើនពួកគាត់ប្រើប្រាស់សំណាញ់ និងមងដែលមានទំហំសំណាញ់ចាប់ពី ២,៥-៥,៥ សង់ទីម៉ែត្រ ដែលមានប្រវែងតិចបំផុត១០ម៉ែត្រ និងប្រវែងវែងបំផុត ៨០ម៉ែត្រ។ ជាទំលាប់ពួកគាត់ដាក់មងនៅវេលាម៉ោង ៦ឬ៧ល្ងាច ហើយទៅសារវិញនៅម៉ោង៥ ឬ៦ព្រឹក។ ពួកគាត់ចាប់បានត្រីចំនួន ៣៨ប្រភេទ ដែលបែងចែកជា៣៥ពួក ក្នុងនោះប្រភេទត្រីអំបូរ CYPRINIDAE មានច្រើនជាងគេ ដូចជា៖ ពួក Cyclotheilichthys: ត្រីស្រកាក្តាមក្រហម *(Cyclotheilichthys apogon)*: ត្រីស្រកាក្តាមតូច *(Cyclotheilichthys lagleri)*: ត្រីស្រកាក្តាមខ្មៅ *(Cyclotheilichthys repasson)* និងត្រីស្រកាក្តាម *(Cyclotheilichthys tapiensis)*។ ពួក Hypsibarbus: ត្រីឆ្ពិនខៀវ *(Hypsibarbus pierrei)*; ត្រីឆ្ពិនមាស *(Hypsibarbus wetmorei)*។ ពួក Puntioplites: ត្រីច្រកែង *(Puntioplites proctozysron)*; ត្រីច្រកែងព្រុយក្តោង *(Puntioplites falcife)*។ ពួក Puntius: ត្រីអង្កត់ប្រាក់ *(Puntinus binotatus)* និងត្រីអង្កប្រាក់ក្រហម *(Puntius mombeus)*។ ពួក Rasbora: ត្រីចង្វាម្សូល *(Rasbora myersi)* និង ត្រីចង្វាម្សូល *(Rasbora mombeus)*។ ពួក Osteochilus: ត្រីក្រុសមេម៉ាយ *(Osteochilus hasselti)* ត្រីក្រុសខ្មៅ *(Osteochilus microvephalus)*។ ពួក Henicorhynchus: ត្រីរៀល *(Henicorhynchus lobatus)* ត្រីរៀលតុប *(Hentchorhynchus siamensis)*។ ពួក Lobocheilos: ត្រីចង្វានរនោង *(Lobocheilos melanotaenia)*។ ពួក Paralaubuca: ត្រីស្លឹកឫស្សី *(Paralaubuca barroni)*។ ពួក Babonymus: មានត្រីឆ្ពិនប្រាក់ (*Barbonymus gonionotus*)។ ពួក Cirrhinus: ត្រីផ្កាចារ (*Cirrhinus jullieni*)។ ពួក Corica:

(Corica laciniata) និង ពួក Hapala: ត្រីកំភរ ឬត្រីខ្នាន់ *(Hapala macrolepidota)* (**ឧបសម្ព័ន្ធ៥-៤ តារាង៥-៣២**)។

៥.៤.៤.៥ ផលចាប់

១៤១. តាមរយៈការចាប់ដាក់ស្តែងតាមទីតាំងដែលត្រូវបានកំណត់។ យើងទទួលបានលទ្ធផលដូចខាងក្រោម៖

- មង (ដាក់ចាប់ពីម៉ោង ៥ល្ងាចដល់ព្រឹកថ្ងៃស្អែកម៉ោង៦) ចាប់បានត្រីចំនួន ៣០ប្រភេទដែលមានទម្ងន់សរុប៩គីឡូក្រាម។

៥.៤.៤.៦ ពិភាក្សា

១៤២. បន្ទាប់ពីបានធ្វើការសម្ភាសន៍ជាមួយអ្នកភូមិដែលមានបទពិសោធន៍ក្នុងការនេសាទ និងកម្មករដែលតែងតែធ្វើការនេសាទនៅតាមព្រែកទេរ ទាំង៤ក្រុមរួចមក យើងអាចសន្និដ្ឋានបានថានៅក្នុងតំបន់នេះមានត្រីចំនួន១០៤ប្រភេទ ត្រូវបានបែងចែកជា ៥៥ពួក (**ឧបសម្ព័ន្ធ៥-៤ តារាងទី៥-៣០**)។ ប្រភេទត្រីដែលស្ថិតនៅក្នុងអំបូរ CYPRINIDAE មានច្រើនជាងគេនៅតាមព្រែកទេរ។ ក្នុងចំណោមប្រភេទត្រីទាំងអស់មានប្រភេទត្រីចំនួន៦ប្រភេទ ដែលកម្រនឹងប្រទះឃើញគឺ ត្រីថ្ព *(Pristis microdon)* ត្រីច្លកព្រុយខ្លី *(Anguilla Bicolor)* ត្រីច្លក *(Anguilla marmorata)* ត្រីក្របីមានពីរប្រភេទ(*Bagarius suchus* និង *Bagarius yarrelli*) និងត្រីអណ្តែងងាំង *(Clarias nieuhofi)*។ ប្រភេទត្រីដែលប្រជានេសាទទាំង៤ ក្រុមធ្លាប់ជួបប្រទះមានបង្ហាញជូននៅក្នុង**ឧបសម្ព័ន្ធ៥-៤ តារាងទី៥-៣០, ៥-៣១, ៥-៣២, ៥-៣៣, ៥-៣៤** និងប្រភេទត្រីដែលនេសាទបានក្នុងពេលសិក្សា នៅក្នុង**ឧបសម្ព័ន្ធ៥-៤ តារាងទី៥-៣៥**។ រូបភាពត្រីដែលដូចគ្នានឹងការសម្ភាសន៍ទាំង៤ក្រុម មានបង្ហាញជូននៅក្នុង**ឧបសម្ព័ន្ធ៥-៤ រូបភាព៥-២១** និងបញ្ជីឈ្មោះប្រជានេសាទដែលសម្ភាសន៍ទាំង៤ក្រុម មានបង្ហាញជូននៅក្នុង**ឧបសម្ព័ន្ធ៥-៤ តារាងទី៥-៣៦**។

រូបភាពទី៥-១៩៖ សកម្មភាពធ្វើបទសម្ភាសន៍ជាមួយប្រជានេសាទ នៅថ្ងៃទី១៣-១៤ ខែសីហា ឆ្នាំ២០១៤



ក្រុមទី១ (ភូមិអាលច ឃុំកន្ទួត)



ក្រុមទី២ (ភូមិស្រែនន ឃុំកន្ទួត)

Draft

ក្រុមទី៣ (ភូមិស្រែនន ឃុំកន្ទួត)

ក្រុមទី៤ (ភូមិឧបសម្ព័ន្ធយ៉េ ឃុំថ្មី)



សកម្មភាពដើរពិនិត្យតាមមាត់ព្រែកទេរ

រូបភាពទី៥-២០៖ សកម្មភាពដាក់មង និងដោះមង នៅត្រង់ចំណុចនិយាមកា (៦៣៥៩៣៨-១៣៧០២០០, ៦៤០៩៧៤-១៣៧០៤១៩ និង៦៤៦៤៣៥-១៣៧៥២០៣)



សកម្មភាពរាប់ប្រភេទត្រី



ត្រីដែលដាក់មងបាន

សកម្មភាពដោះមង



សកម្មភាពដែលប្រជានេសាទបាចត្រីនៅក្នុងដីសម្បទានក្រុមហ៊ុន

៥.៤.៥ ស្ថានភាពសេដ្ឋកិច្ចសង្គមក្នុងសហគមន៍ដែលប្រឈមនឹងការទទួលរងឥទ្ធិពលអវិជ្ជមាន

៥.៤.៥.១ ស្ថានភាពភូមិសាស្ត្រ

១៤៣. ឃុំកន្ទួតមានទីតាំងតាមបណ្តោយ និងសងខាងផ្លូវជាតិលេខ៧ (លើកំណាត់ផ្លូវជាតិប្រវែង១៧គ.ម) ក្នុងទិសដៅពីក្រចេះ-ស្នួល ចំងាយប្រមាណ ២២គីឡូម៉ែត្រពីទីរួមខេត្តក្រចេះ។ រីឯឃុំថ្មីមានទីតាំងនៅខាងជើងផ្លូវជាតិលេខ៧ ចំងាយប្រមាណ ៣១គីឡូម៉ែត្រពីទីរួមខេត្តក្រចេះ។ ដើម្បីទៅកាន់ឃុំថ្មី គេធ្វើដំណើរតាមផ្លូវជាតិលេខ៧ពីក្រចេះ-ស្នួលបត់ឆ្វេងចូលតាមផ្លូវលំក្រាលគ្រួសក្រហមត្រង់ចំណុចផ្សារកន្ទួត (ចម្ងាយប្រមាណ ២២គីឡូម៉ែត្រពីទីរួមខេត្តក្រចេះ ក្នុងឃុំកន្ទួត) ប្រមាណជា ៩គីឡូម៉ែត្រពីផ្លូវជាតិទើបដល់សាលាឃុំថ្មី។ ការសិក្សាវាយតម្លៃបានធ្វើឡើងនៅក្នុងភូមិចំនួន៥ នៃឃុំថ្មី និងភូមិ១ (រាប់ទាំងភូមិឧបសម្ព័ន្ធ១) នៃឃុំកន្ទួត ស្រុកចិត្របុរី ខេត្តក្រចេះ ដែលឋិតនៅក្បែរតំបន់ដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ដូទីសាយហ្គន-ប៊ិញហ្វឿក (អេស ប៊ី ខេ)។ ភូមិអាលចជាភូមិពាក់ព័ន្ធមួយនៅក្នុងឃុំកន្ទួតដែលមាន ៣៣៣គ្រួសារ (ប្រជាជនសរុប ១៥៨៥នាក់) រួមទាំងភូមិឧបសម្ព័ន្ធស្រែននដែលមាន ៤៤គ្រួសារ (ប្រជាជនសរុប ២៣០នាក់)។ ឯឃុំថ្មីមានភូមិពាក់ព័ន្ធ ៥ គឺភូមិប្លៀរ មាន ២២៩គ្រួសារ (ប្រជាជនសរុប ១២១៤នាក់) ភូមិក្រសាំងមាន ១២១គ្រួសារ (ប្រជាជនសរុប ៦២៦នាក់) ភូមិថ្មីមាន ២៤៦គ្រួសារ (ប្រជាជនសរុប ១២៧២នាក់) ភូមិស្វាយជ្រុំ ៧៤គ្រួសារ (ប្រជាជនសរុប ៤២៧នាក់) និងភូមិត្នោតមាន ១៤៣គ្រួសារ (ប្រជាជនសរុប ៨៤៤នាក់) (តារាង៥-៣៧)។

តារាង ៥-៣៧៖ ស្ថិតិប្រជាពលរដ្ឋពាក់ព័ន្ធ (ស្ថិតិឃុំឆ្នាំ ២០១៤)

ខេត្ត	ស្រុក	ឃុំ	ភូមិ	ចំនួនគ្រួសារ	ចំនួនពលរដ្ឋ	ចំនួនស្ត្រី
ក្រចេះ	ចិត្របុរី	កន្ទួត	អាលច	៣៣៣	១.៥៨៥នាក់	៧១១នាក់
		ថ្មី	ប្លៀរ	២២៩	១.២១៤នាក់	៦១៩នាក់
			ក្រសាំង	១២១	៦២៦នាក់	៣០៩នាក់
			ថ្មី	២៤៦	១.២៧២នាក់	៦៥២នាក់
			ស្វាយជ្រុំ	៧៤	៤២៩នាក់	២១០នាក់
			ត្នោត	១៤៣	៨៤៤នាក់	៤៣២នាក់
សរុប				១.១៤៦	៥.៩៧០នាក់	២.៩៣៣នាក់

៥.៤.៥.២ ស្ថានភាពប្រជាសាស្ត្រ

១៤៤. ប្រជាសាស្ត្រ និងទំហំគ្រួសារៈ តាមឯកសារព័ត៌មានស្តីពីស្ថានភាពឃុំថ្មីឆ្នាំ២០១៣ (ឧបសម្ព័ន្ធ ៥-៥) បានបង្ហាញថា ក្នុងឃុំនេះមានប្រជាពលរដ្ឋ ២.១០៥គ្រួសារ ស្មើនឹង ១០.៩៨៣នាក់ (មានស្រី ៥.៤៤៤នាក់ ស្មើនឹង ៤៩,៥៧%)។ ក្នុងចំណោមពលរដ្ឋទាំង ២.១០៥គ្រួសារ មាន ២.០៤៩គ្រួសារ ឬស្មើនឹង ៩៧,៣៤% មានមេគ្រួសារជាបុរស និង ៥៦គ្រួសារ ឬស្មើនឹង ២,៦៦% មានស្ត្រីជាមេគ្រួសារ។ ទំហំគ្រួសារមធ្យមមាន ៥,២២នាក់ក្នុងមួយគ្រួសារ។ ប្រជាពលរដ្ឋក្នុងឃុំថ្មីនេះមានអត្រាកំណើនប្រចាំឆ្នាំ

២%។ ដូចគ្នានេះដែរ តាមឯកសារព័ត៌មានស្តីពីស្ថានភាពឃុំកន្ទួតឆ្នាំ ២០១៤ (ឧបសម្ព័ន្ធ៥-៥) បានឲ្យដឹងថា ក្នុងឃុំនេះមានប្រជាពលរដ្ឋ ១.៤៨៣គ្រួសារ ស្មើនឹង ៦.៨៦៥នាក់ (មានស្រី ៣.៣៩១នាក់ ស្មើនឹង ៤៩,៤០%)។ ក្នុងចំណោមពលរដ្ឋទាំង ១.៤៨៣គ្រួសារ មាន ១.២៤៩គ្រួសារ ឬស្មើនឹង ៨៤,២% មានមេគ្រួសារជាបុរស និង ២៣៤គ្រួសារ ឬស្មើនឹង ១៥,៨% មានស្ត្រីជាមេគ្រួសារ (ដ្យាក្រាម ៥-៨)។ ទំហំគ្រួសារមធ្យមក្នុងឃុំនេះស្មើនឹង ៤,៦នាក់ ក្នុងមួយគ្រួសារ។ ឃុំកន្ទួតនេះមានអត្រាកំណើនប្រចាំឆ្នាំ ៤,២%។

ដ្យាក្រាម ៥-៨៖ មធ្យមភាគមេគ្រួសារគិតតាមភេទ (ឯកសារព័ត៌មានស្តីពីស្ថានភាពឃុំថ្មីឆ្នាំ២០១៣ និងឃុំកន្ទួតឆ្នាំ២០១៤)



១៤៥. តាមលទ្ធផលនៃការសិក្សាវាយតម្លៃដោយការសម្ភាសន៍ បានបង្ហាញថា ក្នុងភូមិទាំងប្រាំមួយដែលជាកម្មវត្ថុនៃការសិក្សា ភូមិក្រសាំងមានចំនួនគ្រួសារដែលមានសមាជិក ពី១ ទៅ ៣នាក់/គ្រួសារ ច្រើនជាងគេ (២៦,៧%) គឺខុសពីភូមិត្នោតដែលមានគ្រួសារប្រភេទនេះតិចជាងគេ (៤,៣%)។ ភូមិល្ពៅមានគ្រួសារដែលមានសមាជិក ៤-៦នាក់ ច្រើនជាងគេ (៧១,៤%) និងមានតិចជាងគេនៅភូមិក្រសាំង (៤៦,៧%)។ ភូមិអាលច និងស្រែននជាភូមិដែលមានចំនួនគ្រួសារមានសមាជិកពី ៧-៩នាក់ច្រើនជាងគេ (២៨,២%) ខណៈដែលភូមិស្វាយជ្រុំមានប្រភេទគ្រួសារនេះតិចជាងគេ (១៨,៨%)។ ភូមិស្វាយជ្រុំមានគ្រួសារធំៗដល់ទៅ១០-១២នាក់ ច្រើនជាងគេ (១២,៥%) ផ្ទុយពីភូមិផ្សេងទៀត ដូចជាភូមិក្រសាំង ល្ពៅ ត្នោត និងថ្មី ដែលគ្មានគ្រួសារប្រភេទនេះទាល់តែសោះ (ដ្យាក្រាម៥-៩)។ ជារួម ប្រជាពលរដ្ឋនៅតំបន់ដីសម្បទាននេះចំនួន ១៤,២% មានសមាជិកគ្រួសារពី១-៣នាក់, ពី៤-៦នាក់ មាន៥៩,៩%, ពី៧-៩នាក់មាន២៤.១% និងពី១០-១២នាក់ មាន១.៩%។ យោងតាមការវិភាគទិន្នន័យឃុំថ្មី និងកន្ទួតឆ្នាំ២០១៣ យើងឃើញថាគ្រួសារប្រជាពលរដ្ឋក្នុងភូមិពាក់ព័ន្ធទាំង៦ មានទំហំប្រហាក់ប្រហែលគ្នា ដែលជាមធ្យមមានចំនួន ៥នាក់

ក្នុងមួយគ្រួសារ ក្នុងនោះភូមិអាលចមានទំហំគ្រួសារជាមធ្យម ៤,៨នាក់/គ្រួសារ ភូមិប្អៀរមាន ៥,៣នាក់/គ្រួសារ ភូមិក្រសាំងមាន ៥,២នាក់/គ្រួសារ ភូមិថ្មីមាន៥,២នាក់/គ្រួសារ ភូមិស្វាយជ្រុំមាន ៥,៨នាក់/គ្រួសារ និងភូមិត្នោតមាន ៥,៩នាក់ក្នុងមួយគ្រួសារ។

ដ្យាក្រាម៥-៩៖ ទំហំគ្រួសារប្រជាពលរដ្ឋរស់នៅតាមភូមិនីមួយៗ (លទ្ធផលនៃការសម្ភាសន៍)



១៤៦. នៅក្នុងឃុំពាក់ព័ន្ធទាំងពីរ សមាជិកគ្រួសារដែលអាយុស្ថិតក្នុងចន្លោះតិចជាងមួយឆ្នាំដល់៤ឆ្នាំមានជាមធ្យម ៥%, ក្នុងចន្លោះពី៤-១០ឆ្នាំ មាន១៦%, ពី១១ឆ្នាំដល់១៥ឆ្នាំ មាន១៣,៨%។ យុវវ័យអាយុពី១៦ដល់២៥ឆ្នាំ ដែលជាវ័យពោរពេញដោយកំលាំងពលកម្មក្នុងឃុំទាំងពីរនេះមានភាគរយច្រើនជាងគេ គឺមានរហូតដល់ទៅ ២៥,៤%។ រីឯប្រជាពលរដ្ឋមានអាយុក្នុងចន្លោះពី២៦-៣៥ឆ្នាំមាន ១៤,៤% ពី ៣៦-៤៥ឆ្នាំមាន ១២,០% ពី៤៦-៦៤ឆ្នាំ មាន ១០,៩% និងអាយុពី៦៥ឆ្នាំឡើងទៅមានតែ ២,៦% ប៉ុណ្ណោះ (ដ្យាក្រាម៥-១០)។

ដ្យាក្រាម៥-១០៖ មធ្យមភាគចំនួនគ្រួសារតាមចន្លោះអាយុ (លទ្ធផលនៃការសម្ភាសន៍)



Draft

១៤៧. **ជនជាតិខ្មែរ និងជនជាតិដើមភាគតិច:** ក្នុងឃុំថ្មីក្រុមការងារបានប្រទះឃើញមានជនជាតិដើមភាគតិចព្នង កួយ និងខោញរស់នៅលាយឡំជាមួយនឹងជនជាតិខ្មែរដែរ។ យោងតាមឯកសារព័ត៌មានស្តីពីស្ថានភាពឃុំឆ្នាំ ២០១៣ ក្នុងចំណោមប្រជាពលរដ្ឋសរុប ២.១០៥គ្រួសារ ស្មើនឹង ១០.៩៨៣នាក់ (ស្រី ៥.៤៤៤នាក់ ស្មើនឹង ៤៩,៥៧%) នៃឃុំថ្មីនេះ មានជនជាតិភាគតិចព្នងចំនួន ៦៥៧គ្រួសារ ស្មើនឹង ៣.៤២៦នាក់ (៣១,១៩%) ជនជាតិកួយមាន ៨៩៣គ្រួសារ ស្មើនឹង ៤.៤៩១នាក់ (៤០,៨៩%) និងខោញមាន ១៦៦គ្រួសារ ស្មើនឹង ៧៥៣នាក់ (៦,៨៦%)។ តាមឯកសារព័ត៌មានស្តីពីស្ថានភាពឃុំកន្ទួតឆ្នាំ ២០១៤ បានឲ្យដឹងថា ក្នុងចំណោមប្រជាពលរដ្ឋសរុប ១.៤៨៣គ្រួសារ ស្មើនឹង ៦.៨៦៥នាក់ (ស្រី ៣.៣៩១នាក់ ស្មើនឹង ៤៩,៤០%) នៃឃុំកន្ទួតនេះ មានជនជាតិដើមភាគតិចព្នងចំនួន ៣៦៩គ្រួសារ ស្មើនឹង ១.៩០១នាក់ (២៧,៦៩%) រស់នៅ និងមិនមានជនជាតិកួយ និងខោញឡើយ (ដ្យាក្រាម៥-១១)។ តាមរយៈការពិភាក្សាជាក្រុមបានបង្ហាញថា ភាគច្រើននៃអ្នកចូលរួមក្នុងការពិភាក្សាជាក្រុមនេះមានជនជាតិខ្មែរ៥៧,៤% ជនជាតិដើមភាគតិចព្នង ៣៧% និងជនជាតិកួយ៥,៦%។ ជនជាតិដើមភាគតិច និងជនជាតិខ្មែរ ដែលរស់នៅក្នុងតំបន់ដីសម្បទានរបស់ក្រុមហ៊ុន គោរពសាសនា និងប្រតិបត្តិប្រពៃណីរៀងៗខ្លួនទៅតាមទំនៀមទំលាប់ពីដូនតា ហើយពុំមានជម្លោះក្នុងការប្រកាន់ពូជសាសន៍នោះទេ បើទោះជាគេរស់នៅលាយឡំចម្រុះគ្នាក៏ដោយ។ មិនត្រឹមតែប៉ុណ្ណោះទេ ជនជាតិដើមភាគតិចទាំងនេះ មានរបរចិញ្ចឹមជីវិតដូច ឬប្រហាក់ប្រហែលនឹងជនជាតិខ្មែរដែរ។ កត្តាទាំងនេះអាចបណ្តាលមកពីក្រុមជនជាតិទាំងអស់ (ទាំងខ្មែរ និងជនជាតិដើមភាគតិច) ចាប់ផ្តើមធ្វើសមាហរណកម្មលើសាសនា ប្រពៃណី ការផ្លាស់ប្តូររបៀបរបបរស់នៅ តាមរយៈសកម្មភាពសេដ្ឋកិច្ច-សង្គមប្រចាំថ្ងៃ និងជាពិសេសមានចំណងអាពាហ៍ពិពាហ៍មួយចំនួន គឺត្រូវបានធ្វើឡើងរវាងជនជាតិខ្មែរ និ.ជនជាតិដើមភាគតិចទាំងនោះទៀតផង។

ដ្យាក្រាម៥-១១៖ របាយជនជាតិដើមភាគតិចនៅតាមភូមិពាក់ព័ន្ធនីមួយៗ (ឯកសារព័ត៌មានស្តីពីស្ថានភាពឃុំថ្មីឆ្នាំ២០១៣ និងឃុំកន្ទួតឆ្នាំ២០១៤)



Draft

៥.៤.៥.៣ ស្ថានភាពផ្ទះសម្បែង និងទ្រព្យសម្បត្តិរបស់គ្រួសារ

៥.៤.៥.៣.១ ស្ថានភាពផ្ទះសម្បែង:

១៤៨. ដោយសារកំរិតជីវភាពរបស់ប្រជាពលរដ្ឋនៅតំបន់នោះនៅមានកំរិតទាបនៅឡើយ ពួកគាត់មិនមានលទ្ធភាពធ្វើផ្ទះថ្មនោះទេ។ ប្រជាជននៅតំបន់នោះមានផ្ទះដែលមានទំហំតូចជាងគេ គឺផ្ទះខ្ទមផ្ទាល់ដី ដែលមានទំហំជាមធ្យម ១៨ម² ហើយប្រភេទផ្ទះដែលធំជាងគេជាផ្ទះឈើដំបូលក្បឿង ឬហ្វីប្រូ ដែលមានទំហំជាមធ្យម ៩០ម²។ យោងតាមការវិភាគទិន្នន័យក្នុងឯកសារព័ត៌មានស្ដីពីស្ថានភាពឃុំថ្មីឆ្នាំ ២០១៣ ឃើញថាចំនួនប្រជាពលរដ្ឋទូទាំងឃុំមាន២.១០៥គ្រួសារ ប៉ុន្តែចំនួនផ្ទះសរុបគឺមាន ១.៩៨៦ខ្នងប៉ុណ្ណោះ ដូច្នេះមានន័យថា ពលរដ្ឋចំនួន ១.៩៨៦គ្រួសារមានផ្ទះសម្បែងជាកម្មសិទ្ធិរបស់ខ្លួនពិតប្រាកដ រីឯប្រជាពលរដ្ឋចំនួន ១១៩គ្រួសារ (៥,៦៥%) ទៀតពុំទាន់មានផ្ទះសម្បែងរបស់ខ្លួនច្បាស់លាស់នៅឡើយ។ នៅក្នុងចំណោមផ្ទះទាំង ១.៩៨៦ខ្នងនេះមានៈ ផ្ទះដំបូលប្រក់ស្បូវចំនួន ១.០៩៨ខ្នង ឬស្មើនឹង ៥៥,២៩% ផ្ទះដំបូលប្រក់ស័ង្កសី/ហ្វីប្រូ ៣២៧ខ្នង ឬស្មើនឹង ១៦,៤៧% (ក្នុងនោះផ្ទះដំបូលប្រក់ស័ង្កសីតិចជាង២០សន្លឹកមាន ២១ខ្នង ឬស្មើនឹង ១,០៦%) និងផ្ទះដំបូលប្រក់ក្បឿង ៥៦១ខ្នង ឬស្មើនឹង ២៨,២៥% (ដ្យាក្រាម៥-១២)។ ដូចគ្នានេះដែរ យោងតាមការវិភាគទិន្នន័យក្នុងឯកសារព័ត៌មានស្ដីពីស្ថានភាពឃុំកន្ទួតឆ្នាំ ២០១៤ ឃើញថាចំនួនប្រជាពលរដ្ឋទូទាំងឃុំមាន១.៤៨៣គ្រួសារ ប៉ុន្តែចំនួនផ្ទះសរុបគឺមាន ១.២៣៧ខ្នងប៉ុណ្ណោះ ដូច្នេះសឲ្យឃើញថា ប្រជាពលរដ្ឋចំនួន ១.២៣៧គ្រួសារមានផ្ទះសម្បែងជាកម្មសិទ្ធិរបស់ខ្លួនពិតប្រាកដ រីឯពលរដ្ឋ ២៤៦គ្រួសារ (១៦,៥៩%) ទៀតពុំទាន់មានផ្ទះសម្បែងរបស់ខ្លួនច្បាស់លាស់នៅឡើយ។ នៅក្នុងចំណោមផ្ទះទាំង ១.២៣៧ខ្នងនេះមានៈ ផ្ទះដំបូលប្រក់ស្បូវចំនួន ៣៨៣ខ្នង ឬស្មើនឹង ៣០,៩៦% ផ្ទះដំបូលប្រក់ស័ង្កសី/ហ្វីប្រូ ៤៥១ខ្នង ឬស្មើនឹង ៣៦,៤៦% (ក្នុងនោះផ្ទះដំបូលប្រក់ស័ង្កសីតិចជាង២០សន្លឹកមាន ២៤ខ្នង ឬស្មើនឹង ១,៩%) ផ្ទះដំបូលប្រក់ក្បឿង ៣៩៧ខ្នង ឬស្មើនឹង ៣២,០៩% ផ្ទះថ្មមិនមែនបេតុង ៤ខ្នង ឬស្មើនឹង ០,៣២% និងផ្ទះថ្មល្វែងចំនួន ២ខ្នង ឬស្មើនឹង ០,១៦% (ដ្យាក្រាម៥-១២)។

ដ្យាក្រាម៥-១២៖ ស្ថានភាពផ្ទះសម្បែងប្រជាពលរដ្ឋនៅក្នុងឃុំថ្មី និងឃុំកន្ទួត (ឯកសារព័ត៌មានស្ដីពីស្ថានភាពឃុំថ្មីឆ្នាំ២០១៣ និងឃុំកន្ទួតឆ្នាំ២០១៤)



Draft

១៤៩. យោងតាមការវិភាគនូវស្ថានភាពជីវភាពរស់នៅរបស់គ្រួសារប្រជាពលរដ្ឋក្នុងឃុំទាំងពីរ បានបង្ហាញថា នៅក្នុងឃុំថ្មី គ្រួសារដែលរស់នៅលើផ្ទះដំបូលប្រក់ស្បូវមានចំនួន ៥៣,៤០% លើផ្ទះដំបូលប្រក់ស័ង្កសី/ហ្វីប្រូមាន ១៧,៤៨% (ក្នុងនោះលើផ្ទះដំបូលប្រក់ស័ង្កសីតិចជាង២០សន្លឹកមាន ១,០%) នៅលើផ្ទះដំបូលប្រក់ក្បឿងមាន ២៩,១២%។ ចំណែកឯនៅក្នុងឃុំកន្ទួតវិញ គ្រួសារដែលរស់នៅលើផ្ទះដំបូលប្រក់ស្បូវមានចំនួន ២៨,៧% នៅលើផ្ទះដំបូលប្រក់ស័ង្កសី/ហ្វីប្រូមាន ៣៩,៧% (ក្នុងនោះលើផ្ទះដំបូលប្រក់ស័ង្កសីតិចជាង២០សន្លឹកមាន ៤,០%) នៅលើផ្ទះដំបូលប្រក់ក្បឿងមាន ៣១,២% នៅលើផ្ទះថ្មមិនមែនបេតុងមាន ០,៣% និងនៅលើផ្ទះថ្មល្វែងមាន ០,១% (ដ្យាក្រាម៥-១៣)។ បើយោងតាមលទ្ធផលនៃការសម្ភាសន៍វិញ បានឲ្យដឹងថា ៣៨,៩% នៃប្រជាជននៅក្នុងឃុំទាំងពីរ មានផ្ទះឈើដំបូលស្លឹក ឬស័ង្កសី ដែលមានទំហំជាមធ្យម ៤៣ម², ៣៧% ទៀតមានផ្ទះឈើដំបូលក្បឿង ឬហ្វីប្រូ ដែលមានទំហំជាមធ្យម ៩០ម², ១៥,៤% មានផ្ទះខ្ទមផុតពីដី ដែលមានទំហំជាមធ្យម ៣០ម², ៥,៦% មានផ្ទះខ្ទមផ្ទាល់ដី ដែលមានទំហំជាមធ្យម ១៨ម² និង ៣,១% ទៀតធ្វើផ្ទះស្លឹក ឬស័ង្កសី ដែលមានទំហំជាមធ្យម ៣៣ម²។

ដ្យាក្រាម៥-១៣៖ មធ្យមភាគគ្រួសារប្រជាពលរដ្ឋរស់នៅតាមប្រភេទលំនៅដ្ឋាន (ឯកសារព័ត៌មានស្តីពីស្ថានភាពឃុំថ្មីឆ្នាំ២០១៣ និងឃុំកន្ទួតឆ្នាំ២០១៤)



៥.៤.៥.៣.២ ទ្រព្យសម្បត្តិគ្រួសារៈ

១៥០. មធ្យោបាយធ្វើដំណើរ និងដឹកជញ្ជូនៈ ប្រជាពលរដ្ឋក្នុងតំបន់នេះ ប្រើប្រាស់មធ្យោបាយដឹកជញ្ជូនផ្លូវគោកមានដូចជា កង់ ម៉ូតូ រទេះគោក្របី រថយន្តដឹកទំនិញធុនតូច និងរថយន្តប្រើប្រាស់ក្នុងគ្រួសារ។ ចំណែកមធ្យោបាយដឹកជញ្ជូនផ្លូវទឹកវិញមាន ទូកអុំសម្រាប់នេសាទ ទូកម៉ាស៊ីនដឹកទំនិញធុនតូច និងដឹកទំនិញធុនធំ។ ក្នុងចំណោមមធ្យោបាយធ្វើដំណើរទាំងឡាយ ម៉ូតូជាមធ្យោបាយធ្វើដំណើរសំខាន់របស់ប្រជាពលរដ្ឋនៅតំបន់ដាច់ស្រយាល ឬនៅឆ្ងាយពីទីប្រជុំជនសំរាប់ធ្វើដំណើរទៅកាន់ទីផ្សារ និងមន្ទីរពេទ្យជាដើម។ ចំណែកមធ្យោបាយដឹកជញ្ជូនវិញ រទេះគោក្របីមានសារៈសំខាន់ណាស់ក្នុងសកម្មភាពរកប្រាក់ចំណូលគ្រួសារ ដូចជា ការដឹកជញ្ជូនផលដំណាំ ដឹកទឹកលក់ និងការស៊ីឈ្នួលដឹកឈើ ឬស្បូវ អុសជាដើម។ យោងតាមទិន្នន័យក្នុងឯកសារព័ត៌មានស្តីពីស្ថានភាពឃុំឆ្នាំ២០១៣ បង្ហាញថា នៅឃុំថ្មីមានរថយន្តតូចប្រើប្រាស់ក្នុងគ្រួសារ

០៩គ្រឿង រថយន្តកែច្នៃ ០២គ្រឿង រថយន្តដឹកទំនិញធុនតូច ០៥គ្រឿង ម៉ូតូ ៧៩៤គ្រឿង កង់ ២០៥ គ្រឿង កាណូតដឹកទំនិញធុនតូច ០២គ្រឿង ទូកម៉ាស៊ីនសម្រាប់នេសាទ ០៣គ្រឿង និងទូកអុំ-ចែវសម្រាប់នេសាទ ៥៥គ្រឿង។ ចំណែកឯនៅឃុំកន្ទួតវិញ យោងតាមទិន្នន័យក្នុងឯកសារព័ត៌មានស្ដីពីស្ថានភាពឃុំឆ្នាំ ២០១៤ បង្ហាញថា មានរថយន្តដឹកទំនិញធុនតូច ០៧គ្រឿង រថយន្តដឹកទំនិញធុនធំ ១០គ្រឿង រថយន្តគ្រួសារ ៣៣គ្រឿង គ្រឿងយន្ត ឬគ្រឿងចក្រផ្សេងៗ ០៥គ្រឿង ម៉ូតូ ៧០៨គ្រឿង កង់ ៤១៥គ្រឿង កាណូតដឹកទំនិញធុនធំ ០១គ្រឿង កាណូតដឹកទំនិញធុនតូច ០៩គ្រឿង និងទូកអុំ-ចែវសម្រាប់នេសាទ ០៦គ្រឿង (តារាង៥-៣៨)។ ក្រៅពីនោះ ពួកគាត់ខ្លះមានសំភារៈទាន់សម័យ ផ្សេងទៀត ដែរ ដូចជាទូរស័ព្ទចល័ត អាគុយ ទូរទស្សន៍ ក្បាលចាក់វីដេអូ។ល។ ក្នុងចំណោមផ្ទះប្រជាពលរដ្ឋនៅក្នុងឃុំថ្មីទាំង ១.៩៨៦ខ្នង មានផ្ទះចំនួន៦០៣ខ្នង (៣០,៣៦%) មានទូរទស្សន៍ប្រើប្រាស់។ ដូចគ្នានេះដែរ ក្នុងចំណោមផ្ទះប្រជាពលរដ្ឋនៅក្នុងឃុំថ្មីទាំង ១.២៣៧ខ្នង មានផ្ទះចំនួន៦៥៣ខ្នង (៥២,៨%) មានទូរទស្សន៍ប្រើប្រាស់។

តារាង៥-៣៨៖ មធ្យោបាយធ្វើដំណើរ និងដឹកជញ្ជូន (ឯកសារព័ត៌មានស្ដីពីស្ថានភាពឃុំថ្មីឆ្នាំ២០១៣ និងឃុំកន្ទួតឆ្នាំ២០១៤)

ឃុំ	មធ្យោបាយធ្វើដំណើរ និងដឹកជញ្ជូន	ចំនួន (គ្រឿង)
ថ្មី	កង់	២០៥
	ម៉ូតូ	៧៩៤
	រថយន្តកែច្នៃ	២
	រថយន្តដឹកទំនិញធុនតូច	៥
	រថយន្តប្រើប្រាស់ក្នុងគ្រួសារ	៩
	ទូកចែវ-ទូកអុំសម្រាប់នេសាទ	៥៥
	ទូកម៉ាស៊ីន-កាណូតសម្រាប់នេសាទ	៣
	ទូកម៉ាស៊ីន-កាណូតសម្រាប់ដឹកទំនិញធុនតូច	២
កន្ទួត	កង់	៤១៥
	ម៉ូតូ	៧០៨
	រថយន្តដឹកទំនិញធុនតូច	៧
	រថយន្តដឹកទំនិញធុនធំ	១០
	រថយន្តប្រើប្រាស់ក្នុងគ្រួសារ	៣៣
	គ្រឿងយន្ត និងគ្រឿងចក្រផ្សេងៗ	៥
	ទូកចែវ-ទូកអុំសម្រាប់នេសាទ	៦
	ទូកម៉ាស៊ីន-កាណូតសម្រាប់ដឹកទំនិញធុនតូច	៩
	ទូកម៉ាស៊ីន-កាណូតសម្រាប់ដឹកទំនិញធុនធំ	១

Draft

១៥១. គ្រឿងយន្តកសិកម្មៈ អ្នកមានជីវភាពធូរធារអាចមានលទ្ធភាពប្រើប្រាស់ត្រាក់ទ័រ គោយន្ត ម៉ាស៊ីនស្ទូងស្រូវ ម៉ាស៊ីនបោកស្រូវ ម៉ាស៊ីនកិនស្រូវធុនតូច ម៉ាស៊ីនបូមទឹក ផងដែរ។ នៅឃុំថ្មីមានត្រាក់ទ័រ ០២គ្រឿង គោយន្ត ២១គ្រឿង ម៉ាស៊ីនបោកស្រូវ ៧៦គ្រឿង និងម៉ាស៊ីនច្រូតនិងបោកស្រូវ ០៦គ្រឿង។ ចំណែកឯនៅឃុំកន្ទួតវិញមានត្រាក់ទ័រ ០១គ្រឿង គោយន្ត ៣៧គ្រឿង ម៉ាស៊ីនស្ទូងស្រូវ ១៥គ្រឿង ម៉ាស៊ីនច្រូតស្រូវ ០២គ្រឿង និងម៉ាស៊ីនបោកស្រូវ ២៩គ្រឿង (តារាង៥-៣៩)។

តារាង៥-៣៩៖ គ្រឿងយន្តកសិកម្ម (ឯកសារព័ត៌មានស្តីពីស្ថានភាពឃុំថ្មីឆ្នាំ២០១៣ និងឃុំកន្ទួតឆ្នាំ២០១៤)

ឃុំ	គ្រឿងយន្ត	ចំនួន (គ្រឿង)
ថ្មី	ត្រាក់ទ័រសម្រាប់ភ្ជួរដី	២
	គោយន្តសម្រាប់ភ្ជួរដី	២១
	ម៉ាស៊ីនបោកស្រូវ	៧៦
	ម៉ាស៊ីនច្រូត និងបោកស្រូវ	៦
កន្ទួត	ត្រាក់ទ័រសម្រាប់ភ្ជួរដី	១
	គោយន្តសម្រាប់ភ្ជួរដី	៣៧
	ម៉ាស៊ីនស្ទូងស្រូវ	១៥
	ម៉ាស៊ីនច្រូតស្រូវ	២
	ម៉ាស៊ីនបោកស្រូវ	២៩

១៥២. សត្វគោក្របីៈ ក្នុងឃុំថ្មីមានប្រជាកសិករ ១.៩៤៧គ្រួសារ (៩២,៤៩%) បានចិញ្ចឹមគោសរុបចំនួន ៦.៥៩៨ក្បាល និងប្រជាពលរដ្ឋ ១.៣៤១គ្រួសារ (៦៣,៧១%) បានចិញ្ចឹមក្របី សរុបចំនួន ៣.៣០៤ក្បាល។ ដោយឡែកនៅក្នុងឃុំកន្ទួតវិញ មានគ្រួសារប្រជាកសិករប្រមាណជា ៩១៤គ្រួសារ (៦១,៦៣%) បានចិញ្ចឹមគោ ក្នុងចំនួនសរុប ៤.២០៧ក្បាល និងគ្រួសារកសិករ ៩៤គ្រួសារ (៦,៣៤%) បានចិញ្ចឹមក្របីចំនួន ២៥៤ក្បាល (តារាង៥-៤០)។

១៥៣. សត្វមាន់ និងទាៈ ក្នុងឃុំថ្មីមានប្រជាកសិករ ១.៧៧៧គ្រួសារ (៨៤,៤២%) បានចិញ្ចឹមមាន់ក្នុងចំនួនសរុប ១៤.៤៤០ក្បាល និងប្រជាពលរដ្ឋ ១៤០គ្រួសារ (៤,៩៤%) បានចិញ្ចឹមទាសរុបចំនួន ៧៤០ក្បាល។ ដោយឡែកនៅក្នុងឃុំកន្ទួតវិញ មានគ្រួសារប្រជាកសិករប្រមាណជា ៨១០គ្រួសារ (៥៤,៦២%) បានចិញ្ចឹមមាន់ក្នុងចំនួនសរុប ៤.៦០៤ក្បាល និងគ្រួសារកសិករ ២៣៣គ្រួសារ (១៥,៧១%) បានចិញ្ចឹមទាចំនួន ៩៤១ក្បាល (តារាង៥-៤០)។

១៥៤. សត្វជ្រូកៈ ក្នុងឃុំថ្មីមានប្រជាកសិករ ១.០៥៩គ្រួសារ (៥០,៣១%) បានចិញ្ចឹមជ្រូកក្នុងចំនួនសរុប ៣.៣៤០ក្បាល។ ដោយឡែកនៅក្នុងឃុំកន្ទួតវិញ មានគ្រួសារប្រជាកសិករប្រមាណជា ២៣,៦០% បានចិញ្ចឹមជ្រូកក្នុងចំនួនសរុប ៨២៣ក្បាល (តារាង៥-៤០)។

Draft

តារាង៥-៤០៖ ស្ថានភាពនៃការចិញ្ចឹមសត្វ (ឯកសារព័ត៌មានស្ដីពីស្ថានភាពឃុំថ្មីឆ្នាំ២០១៣ និងឃុំកន្ទួតឆ្នាំ ២០១៤)

ឃុំ	ប្រភេទសត្វ	ចំនួនគ្រួសារ	ភាគរយគ្រួសារ	ចំនួនសត្វ (ក្បាល)
ថ្មី	គោ	១.៩៤៧	៩២,៤៩%	៦.៥៩៨
	ក្របី	១.៣៤១	៦៣,៧១%	៣.៣០៤
	ជ្រូក	១.០៥៩	៥០,៣១%	៣.៣៤០
	មាន់	១.៧៧៧	៨៤,៤២%	១៤.៤៤០
	ទា	១៤០	៤,៩៤%	៧៤០
កន្ទួត	គោ	៩១៤	៦១,៦៣%	៤.២០៧
	ក្របី	៩៤	៦,៣៤%	២៥៤
	ជ្រូក	៣៥០	២៣,៦០%	៨២៣
	មាន់	៨១០	៥៤,៦២%	៤.៦០៤
	ទា	២៣៣	១៥,៧១%	៩៤១

៥.៤.៥.៤ ប្រភពទឹកសំខាន់សម្រាប់បរិភោគ

១៥៥. ជាទូទៅប្រជាពលរដ្ឋមួយចំនួនប្រើប្រាស់ទឹកព្រែកទេរ ខ្លះប្រើទឹកអណ្ដូង និងខ្លះទៀតប្រើប្រាស់ទឹកពីស្រះ ឬត្រពាំង ឬអាងទំនប់ទឹកសម្រាប់ទាំងការចំអិនអាហារ បោកគក់ ងូត និងបរិភោគ។ ចំពោះខែវស្សាប្រជាពលរដ្ឋមានការធូរស្រាលច្រើនជាងរដូវប្រាំង ដោយការត្រងទឹកភ្លៀងទុកសម្រាប់ប្រើប្រាស់ក្នុងគោលបំណងដូចខាងលើ។ ឯនៅរដូវប្រាំងវិញ ប្រជាជនមានការលំបាកក្នុងការប្រើប្រាស់ទឹក ដោយសារត្រូវដឹកជញ្ជូនទឹកពីប្រភពទឹកទាំងអស់នោះទាំងស្រុង។ ប្រជាជនក្នុងភូមិអាលច ភូមិឧបសម្ព័ន្ធស្រែននៃឃុំកន្ទួត និងភូមិប្លៀរនៃឃុំថ្មី មានប្រភពទឹកសំខាន់មួយគឺ ព្រែកទេរ។ លើសពីនេះទៅទៀត យើងសង្កេតឃើញមានអណ្ដូងស្នប់ និងអណ្ដូងជីកដាក់លូស្ថិតនៅក្នុងភូមិផងដែរ ប៉ុន្តែអណ្ដូងស្នប់ទាំងនោះខូចស្ទើរទាំងអស់ទៅហើយ។ ដោយឡែកនៅភូមិស្រែនន ដែលជាភូមិឧបសម្ព័ន្ធរបស់ភូមិអាលច ពុំមានអណ្ដូងស្នប់ ឬអណ្ដូងជីកប្រើប្រាស់ទេ។ ចំណែកនៅភូមិស្វាយជ្រុំ ថ្មី ក្រសាំង និងត្នោត ពួកគាត់ប្រើប្រាស់អណ្ដូងស្នប់ ឬអណ្ដូងជីកសម្រាប់ការចំអិនអាហារ បោកគក់ ងូត និងបរិភោគ។

១៥៦. តាមលទ្ធផលពីការសម្ភាសន៍បានបង្ហាញថា ក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ប្រជាជនប្រមាណជា ២៥,៣% ប្រើប្រាស់ប្រភពទឹកចម្បងដើម្បីចំអិនអាមារពីទឹកអណ្ដូងស្នប់, ២២,៨% ពីអណ្ដូងជីកមានគម្រប, ១,៩% ពីអណ្ដូងជីកគ្មានគម្រប, ៤៣,៨% ពីព្រែកទេរ (សំរាប់ប្រជាពលរដ្ឋនៅភូមិអាលច ភូមិស្រែនន និងភូមិប្លៀរ), ៣,១% ប្រើទឹកភ្លៀង និង៣,១% ទិញទឹករទេះឯកជន។ ដោយឡែកសម្រាប់ការប្រើប្រាស់ទូទៅ បោកគក់ ងូត និងបរិភោគវិញ ពួកគាត់ ៣០,២% ទៅដងពីអណ្ដូងស្នប់, ១៩,៨% ដងពីអណ្ដូងជីកមានគម្រប, ០,៦% ដងពីអណ្ដូងជីកគ្មានគម្រប, ៤៥,៧% ដងពីព្រែកទេរ ស្រះ ឬត្រពាំង ឬអាងទំនប់ទឹក,

១,២% ពីការត្រងទឹកភ្លៀងទុក និង២,៥% ពីការទិញទឹករទេះឯកជន (ដ្យាក្រាម ៥-១៤)។ ចំពោះការដាំទឹកឲ្យឆ្អិនមុនបរិភោគ ត្រូវបានបញ្ជាក់ពីមេឃុំទាំងពីរថានៅមានកម្រិតទាបជាង ៣០% នៅឡើយ។

ដ្យាក្រាម ៥-១៤៖ ស្ថានភាពនៃការប្រើប្រាស់ទឹក (លទ្ធផលនៃការសម្ភាសន៍)



Draft

៥.៤.៥.៥ ថាមពលសម្រាប់បំភ្លឺ និងចំអិនអាហារ

១៥៧. សម្រាប់ប្រជាពលរដ្ឋនៃឃុំថ្មី ដែលរស់នៅតំបន់ខាងក្នុងឆ្ងាយពីផ្លូវជាតិ គឺមិនមានបណ្តាញអគ្គិសនីរដ្ឋ ឬឯកជនចូលទៅដល់ឡើយ។ តាមការវិភាគទិន្នន័យក្នុងឯកសារព័ត៌មានស្តីពីស្ថានភាពឃុំថ្មីឆ្នាំ ២០១៣ បង្ហាញថា គ្មានផ្ទះប្រជាពលរដ្ឋណាមួយ ដែលមានតភ្ជាប់នូវបណ្តាញអគ្គិសនីសម្រាប់បំភ្លឺទាល់តែសោះ។ ភាគច្រើនផ្ទះពួកគាត់ចំនួន ១.៤៥៨ខ្នង (៧៣,៤១%) ប្រើប្រាស់អំពូលអាគុយ និងមានផ្ទះចំនួនតែ ៥ខ្នង ប៉ុណ្ណោះដែលប្រើប្រាស់បន្ទះសូឡាទាញយកថាមពលព្រះអាទិត្យសម្រាប់បំភ្លឺនៅពេលយប់។ ដោយឡែកនៅក្នុងឃុំកន្ទួតវិញ ដោយសារពួកគាត់រស់នៅតាមបណ្តោយផ្លូវជាតិលេខ៧ ដូចនេះគឺមានបណ្តាញអគ្គិសនីរដ្ឋទៅដល់ ប៉ុន្តែអ្នកដែលមានលទ្ធភាពតភ្ជាប់បណ្តាញនេះមានចំនួនតិចតួចបំផុត។ យោងតាមឯកសារព័ត៌មានស្តីពីស្ថានភាពឃុំកន្ទួតឆ្នាំ ២០១៤ បង្ហាញថា មានផ្ទះរបស់ពលរដ្ឋចំនួនតិចតួចគឺ ១៨៣ខ្នង ស្មើនឹង ១៤,៨% ប៉ុណ្ណោះមានលទ្ធភាពតបណ្តាញអគ្គិសនីប្រើប្រាស់។ ក្រៅពីនេះ ផ្ទះពលរដ្ឋភាគច្រើនគឺ ៧៤៧ខ្នង ស្មើនឹង ៦០,៤% ប្រើអំពូលអាគុយសម្រាប់បំភ្លឺនៅពេលយប់។ បើយោងតាមលទ្ធផលនៃការសម្ភាសន៍វិញ មានប្រជាពលរដ្ឋក្នុងឃុំទាំងពីរចំនួន ៧៩% ប្រើភ្លើងអាគុយ ១១,១% ប្រើចង្កៀងប្រេងកាត ៥,៦% មានភ្លើងរដ្ឋប្រើ និង៤,៣% ផ្សេងទៀតប្រើពិលសម្រាប់បំភ្លឺនៅពេលយប់ (ដ្យាក្រាម ៥-១៥)។

ដ្យាក្រាម ៥-១៥៖ ប្រភពថាមពលសម្រាប់បំភ្លឺនៅពេលយប់ (លទ្ធផលនៃការសម្ភាសន៍)



១៥៨. យោងតាមលទ្ធផលនៃការសម្ភាសន៍គ្រួសារប្រជាពលរដ្ឋក្នុងឃុំទាំងពីរ បានឲ្យដឹងថា ពួកគាត់ស្ទើរទាំងអស់គ្នាប្រើអុស ឬធ្យូងសម្រាប់ការចំអិនអាហារ។ ប្រជាជនក្នុងតំបន់នោះ ៨៨,៥% ប្រើអុសជាប្រភពថាមពលសំខាន់ក្នុងការចំអិនម្ហូបអាហារ ហើយ ១០,៤% ប្រើធ្យូង និងមានតែ ១% ប៉ុណ្ណោះដែលមានលទ្ធភាពប្រើហ្គាស (ដ្យាក្រាម ៥-១៦)។

ដ្យាក្រាម ៥-១៦៖ ប្រភពថាមពលសម្រាប់ចំអិនអាហារ (លទ្ធផលនៃការសម្ភាសន៍)



Draft

៥.៤.៥.៦ ការគ្រប់គ្រង និងការកាន់កាប់ដីធ្លី

១៥៩. យោងតាមឯកសារព័ត៌មានស្តីពីស្ថានភាពឃុំឆ្នាំ២០១៣ ឃុំថ្មីមានផ្ទៃដីសរុបចំនួន ៥.៩២៨ហិកតា បានបែងចែកជា ផ្ទៃដីលំនៅដ្ឋាន ២៣០ហិកតា (៣,៨៨%) ផ្ទៃដីកសិកម្ម ៣.០៧៨ហិកតា ((៥១,៩២%) ក្នុងនោះមានដីស្រែវស្សា ២.៩៩១ហិកតា និងដីចំការរយៈពេលខ្លី ៨៧ហិកតា) និងផ្ទៃដីផ្សេងៗ ២.៦២០ហិកតា (៤៤,២០%)។ យោងតាមឯកសារព័ត៌មានស្តីពីស្ថានភាពឃុំឆ្នាំ២០១៤ ឃុំកន្ទួតមានផ្ទៃដីសរុបចំនួន ១២.៥០០ហិកតា (មកទល់នឹងឆ្នាំ ២០១១ មានត្រឹមតែ ៤.១៥៥ហិកតាប៉ុណ្ណោះ) ហើយមិនមានទិន្នន័យច្បាស់លាស់អំពីផ្ទៃដីលំនៅដ្ឋាន ផ្ទៃដីកសិកម្ម និងផ្ទៃដីផ្សេងៗឡើយ។

១៦០. ដីកសិកម្ម៖ យោងតាមលទ្ធផលនៃការសម្ភាសន៍ បានឲ្យដឹងថា ប្រជាជនមានដីស្រែស្ថិតនៅខាងក្រោយភូមិកររបស់ខ្លួន ចំណែកដីចំការស្ថិតនៅប្រមាណ ២គ.ម ទៅ ៣គ.មពីផ្ទះ។ ប្រជាជនភាគច្រើន (៧៦,៣%) មានដីចំការតែមួយកន្លែងតែប៉ុណ្ណោះ ហើយ ២០% ទៀតមានដីពីរកន្លែង ២,២% មានដីចំ

ការបីកន្លែង និង១,៥% មានដីបួនកន្លែង (ដ្យាក្រាម ៥-១៧) ហើយប្រជាជននៅតំបន់នោះមានដីស្រែចំការជាមធ្យមទំហំ២,៣ហិកតាក្នុងមួយគ្រួសារ។ ប្រជាពលរដ្ឋនៅភូមិត្នោតមានទំហំដីតូចជាងគេ ដែលជាមធ្យមមានទំហំ ១,៨ហិកតា ស្របពេលដែលអ្នកភូមិស្វាយជ្រុំមានដីស្រែដែលមានទំហំធំជាងគេគឺ ២,៨ ហិកតា។ ចំណែកឯអ្នកភូមិផ្សេងៗទៀតមានដីស្រែទំហំប្រហាក់ប្រហែលនឹងអ្នកភូមិស្វាយជ្រុំដែរ គឺអ្នកភូមិអាលចមានដីជាមធ្យម ២,៥ហិកតា ភូមិថ្មីមាន ២,៤ហិកតា ភូមិក្រសាំង និងប្បៀរមានដីទំហំមធ្យម ២,២ហិកតាក្នុងមួយគ្រួសារ (ដ្យាក្រាម ៥-១៨)។ យោងតាមលទ្ធផលនៃការសម្ភាសន៍ ប្រជាពលរដ្ឋក្នុងឃុំទាំងពីរមានដីស្រែចំការភាគច្រើនជាដីកេរ្តិ៍ឪពុកម្តាយ ហើយគ្មានប័ណ្ណកម្មសិទ្ធិទេ ប៉ុន្តែនៅពេលលក់ដូរធ្វើសំបុត្រផ្ទិតមេដៃទទួលស្គាល់ដោយអាជ្ញាធរភូមិឃុំ។ ដីចំការមួយចំនួនទៀតជាដីកាប់រានដីព្រៃ ខ្លះមានប័ណ្ណកម្មសិទ្ធិដែលវាស់វែងដោយយុវជនស្ម័គ្រចិត្តរបស់សម្តេចតេជោ ហ៊ុន សែន ប៉ុន្តែភាគច្រើនពុំមានប័ណ្ណកម្មសិទ្ធនៅឡើយ។ ដីពួកគាត់ខ្លះនៅជាប់ព្រំដីក្រុមហ៊ុនចម្ងាយប្រមាណ ២០-៤៣០ម។ លើដីចំការទាំងនេះ ពួកគាត់ភាគច្រើនដាំពោត និងដំឡូងមី។ ដោយសារតំបន់នេះ ជាតំបន់ដាច់ស្រយាលពុំមានផ្លូវល្អចូលដល់ និងម្យ៉ាងទៀតបរិមាណផលិតផលតិចតួចផងនោះ ដូចនេះពួកឈ្មួញមិនចូលមករកទិញ ធ្វើឲ្យដំណាំពោតក្រហម និងដំឡូងមី ពុំទាន់មានទីផ្សារច្បាស់លាស់នៅឡើយ។ ហេតុនេះពួកគាត់ខ្លះដាំពោតស ដំឡូង និងបន្លែផ្សេងៗគ្រាន់ទុកសម្រាប់ហូបក្នុងគ្រួសារប៉ុណ្ណោះ។

ដ្យាក្រាម ៥-១៧៖ ស្ថានភាពនៃការកាន់កាប់ដីកសិកម្មរបស់សមាជិកគ្រួសារ (លទ្ធផលនៃការសម្ភាសន៍)

ដ្យាក្រាម ៥-១៨៖ មធ្យមភាគនៃទំហំដីកសិកម្មរបស់គ្រួសារប្រជាពលរដ្ឋ (លទ្ធផលនៃការសម្ភាសន៍)



Draft

១៦១. **ដីលំនៅដ្ឋាន:** ជាទូទៅប្រជាពលរដ្ឋនៅតំបន់នោះមានដីពី ៣០០ម²-២៥០០ម²។ ប៉ុន្តែ មានគ្រួសារខ្លះគ្មានដីលំនៅដ្ឋានទេ (ប្រហែល ១%)។ អ្នកដែលគ្មានដីលំនៅដ្ឋាន បានសុំដីគេសង់ផ្ទះនៅបណ្ដោះអាសន្ន ហើយអ្នកដែលមានដីលំនៅដ្ឋាន គឺភាគច្រើន មានដោយសារកេរ្តិ៍ពីឪពុកម្ដាយ និងខ្លះទៀត មានដីដោយសារទិញពីគេ តែពុំមានប័ណ្ណកម្មសិទ្ធទេ គឺគ្រាន់តែមានការទទួលស្គាល់ពីអាជ្ញាធរភូមិ ឃុំប៉ុណ្ណោះ។

១៦២. **ដីព្រៃ:** មុនការវិនិយោគ ពួកគាត់អាចចូលព្រៃរកសត្វ ឈើធ្វើផ្ទះ ឫស្សី ជ័រទឹក ទំពាំង អុស និងបន្លែព្រៃបានសម្រាប់លក់យកប្រាក់ចំណូល ឬសម្រាប់ទុកហូបក្នុងគ្រួសារ។ ប៉ុន្តែបច្ចុប្បន្ន ព្រៃនោះបានក្លាយទៅជាចំការកៅស៊ូមួយភាគធំទៅហើយ ដែលស្ថិតនៅចំងាយប្រមាណ ២០ម-៤៣០ម ពីព្រំដីរបស់ពួកគាត់ ហើយៈនៅសល់តែដីមួយផ្នែក (អនុតំបន់III និងអនុតំបន់IV) ដែលក្រុមហ៊ុនកំពុងធ្វើការឈូសឆាយបន្ត។ នៅភូមិរៀមានព្រៃសហគមន៍មួយឈ្មោះថា ព្រៃសហគមន៍ភូមិភ្លៀវ ដែលមានផ្ទៃដីប្រមាណជា ៤៧០ហិកតា។ នៅក្នុងភូមិថ្មីមានព្រៃសហគមន៍មួយឈ្មោះ ភ្នំគ្រង់ ដែលមានផ្ទៃដីប្រមាណជា ៨៨១ហិកតា។ មេព្រៃសហគមន៍នេះមានឈ្មោះថា លោក ណេត ម៉េត។

១៦៣. យោងតាមការវិភាគទិន្នន័យ និងព័ត៌មានដែលទទួលបានពីការសិក្សាស្រាវជ្រាវ បានរកឃើញថា ក្រុមហ៊ុនបានទទួលសិទ្ធិប្រទានដីសម្បទានចំនួន ៦.៤៣៦ហិកតា សម្រាប់វិនិយោគដាំកៅស៊ូ ដំឡូងមី ស្វាយចន្ទី និងបង្កើតរោងចក្រកែច្នៃក៏ពិតមែន ប៉ុន្តែនៅពេលដែលក្រុមការងារចុះវាស់វែងកំណត់ព្រំដី បានប្រទះឃើញនូវផ្ទៃដីពាក់ព័ន្ធប្រជាពលរដ្ឋ ដែលស្ថិតនៅរាយប៉ាយក្នុងដីសម្បទានចំនួន ១.០០០ហិកតាទៀតដែលត្រូវបានកាត់ចេញដោយក្រុមការងារ ហើយប្រគល់ជូនទៅប្រជាពលរដ្ឋរួចស្រេចផងដែរ ដូច្នេះផ្ទៃដីនៅសល់សម្រាប់ធ្វើអាជីវកម្ម-ផលិតកម្មគឺ ៥.៤៣៦ហិកតា (៦.៤៣៦ហិកតា - ១.០០០ហិកតា = ៥.៤៣៦ហិកតា) ប៉ុណ្ណោះ។

១៦៤. យោងតាមការបញ្ជាក់របស់តំណាងក្រុមហ៊ុន ដូទីសាយហ្គន-ប៊ិញហ្វឿក (អេស ប៊ី ខេ) បានឲ្យដឹងថា ក្រុមហ៊ុនបានអនុវត្តនូវបទបញ្ជាលេខ ០១ របស់រដ្ឋាភិបាល ដោយសហការជាមួយក្រុមនិស្សិតស្ម័គ្រចិត្តចុះមកវាស់វែងដោះស្រាយដីពាក់ព័ន្ធជាមួយប្រជាពលរដ្ឋរួចទាំងស្រុងហើយ។ ក្នុងនោះក្នុងអនុតំបន់ទី១ ក្រុមនិស្សិតបានចុះវាស់វែងកាត់នូវផ្ទៃដីចំនួន ១៨៥,៤១ហិកតា ក្នុងអនុតំបន់ទី២ បានកាត់ដីអស់ចំនួន ២៦៣,៩២ហិកតា ក្នុងអនុតំបន់ទី៣ បានកាត់ចេញនូវផ្ទៃដី ១១៨,៣៦ហិកតា និងក្នុងអនុតំបន់ទី៤ បានកាត់ចេញនូវផ្ទៃដី ១៣១,៤២ហិកតា ហើយដីទាំងអស់នេះត្រូវបានរៀបចំធ្វើប្លង់ និងប្រគល់សិទ្ធិកាន់កាប់ជូនប្រជាពលរដ្ឋរួចអស់ហើយដែរ។

១៦៥. លើសពីនេះទៅទៀត ទោះបីជាមានការវាស់វែង និងកាត់ដីពាក់ព័ន្ធជូនប្រជាពលរដ្ឋជាបន្តបន្ទាប់ហើយក៏ដោយ ក៏ក្រុមហ៊ុនបាន និងកំពុងដោះស្រាយជូនប្រជាពលរដ្ឋនូវផ្ទៃដីពាក់ព័ន្ធមួយចំនួនតូច ដែលពលរដ្ឋបានកាន់កាប់ជាក់ស្តែង ដោយអនុវត្តតាមរូបមន្តស្បែកខ្លាបន្តទៀត។ ប៉ុន្តែ ប្រជាពលរដ្ឋភូមិភ្លៀវនៅតែធ្វើការទាមទារដីចំនួន ៥៤៥,២៤ហិកតា និងដី៤៣០ម៉ែត្រពីបង្គោលឡាក់ចំនួន ១១,៥ហិកតាបន្ថែមទៀត ហើយក្រុមហ៊ុនក៏ព្យាយាមដោះស្រាយជាមួយនឹងអាជ្ញាធរដែនដីពាក់ព័ន្ធ និងអ្នកភូមិភ្លៀវនេះចំនួន ៩ ដងរួចមកហើយ ហើយចុងក្រោយនេះ តាមការសម្របសម្រួលរបស់អាជ្ញាធរខេត្តគឺតម្រូវឲ្យក្រុមហ៊ុនកាត់ជូនពួកគាត់នូវផ្ទៃដីចំនួន ៥៤៥,២៤ហិកតាទៀត នេះមិនទាន់រាប់បញ្ចូលនូវដីដែលអ្នកភូមិភ្លៀវបានកាន់កាប់

ជាក់ស្តែងផង។ ដូច្នេះ បច្ចុប្បន្នក្រុមហ៊ុនបានធ្វើសម្បទានដោះស្រាយនូវបញ្ហាដីធ្លីពាក់ព័ន្ធនៅក្នុងអនុតំបន់ទី I ទី II ទី III និងទី IV ជាមួយប្រជាពលរដ្ឋបានចប់សព្វគ្រប់ទាំងស្រុងហើយ។ ទន្ទឹមនឹងគោលជំហរដោះស្រាយបញ្ហាដីធ្លីឲ្យទៅប្រជាពលរដ្ឋប្រកបដោយស្មារតីសម្បទានខ្ពស់នេះ បច្ចុប្បន្នក្រុមហ៊ុនក៏មានការជម្រុញឲ្យមានការចុះបញ្ជីដីធ្លីរដ្ឋរបស់ក្រុមហ៊ុនផងដែរ ជាក់ស្តែងក្រុមហ៊ុន **ដូទីសាយហ្គន-ប៊ិញហ្វឿក (អេស ប៊ី ខេ)** បានធ្វើលិខិតទៅមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និង សុរិយោដីខេត្តក្រចេះ តាមរយៈលិខិតលេខ ១១២០១៣ ដទ-បហ ចុះថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ២០១៣ ដើម្បីស្នើសុំចុះបញ្ជីដីធ្លីរដ្ឋ។

១៦៦. បន្ទាប់ពីក្រុមហ៊ុន ដូទីសាយហ្គន-ប៊ិញហ្វឿកបានដោះស្រាយកាត់ដីជាង ៥៤៥,២៤ហិកតា ឲ្យប្រជាពលរដ្ឋភូមិប្អៀរចំនួន ២២៩គ្រួសារ នៅមានក្រុមហ៊ុនកូរៀងដែលបានកាត់ដីឲ្យទៅអ្នកភូមិប្អៀរចំនួនជាង ១.០០០ ហិកតាសម្រាប់ប្រើប្រាស់ និងក្រុមហ៊ុនម៉ូហ៊ីបាក៏បានកាត់ដីឲ្យទៅភូមិប្អៀរចំនួនប្រហែលជា ៥២០ ហិកតា ផងដែរ។ ក្រៅពីនេះ អ្នកភូមិប្អៀរនេះមានដីព្រៃសហគមន៍ចំនួន៤៧០ហិកតាទៀត ដូច្នេះបើយើងធ្វើការបូកសរុបទៅឃើញថា អ្នកភូមិប្អៀរមានដីព្រៃជាង ២.៥៣៥ហិកតាសម្រាប់ប្រើប្រាស់។

១៦៧. ប្រជាពលរដ្ឋភាគច្រើនមានក្តីពឹងលើការងារកសិកម្ម ដោយពួកគាត់បានចាប់ផ្តើមងាកទៅរកការរានពង្រីកដី និងសំអាតដីសម្រាប់ចំការដំឡូង ឬពោត និងដំណាំផ្សេងៗដែលមានតម្រូវការទីផ្សារខ្ពស់ជាងពេលមុនៗ ហើយលែងពឹងផ្អែកតែលើធនធានព្រៃឈើ និងអនុផលព្រៃឈើតទៅទៀតដែរ។ ដោយឡែកក៏មានអ្នកមកពីតំបន់ឆ្ងាយចូលមករុករានដីដើម្បីធ្វើការដាំដុះផងដែរ ជាហេតុធ្វើឲ្យតម្លៃដីលំនៅដ្ឋាន និងដីកសិកម្មបានកើនឡើងនាពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។

៥.៤.៥.៧ លទ្ធភាពនៃការអាស្រ័យផលពីធនធានធម្មជាតិ

១៦៨. ដោយសារកំណើនប្រជាពលរដ្ឋក្នុងឃុំថ្មី បានធ្វើឲ្យតម្រូវការធនធានធម្មជាតិក៏កាន់កើនឡើង និងដោយសារតែតំបន់ក្បែរដែលធ្លាប់ទទួលបានធនធានធម្មជាតិត្រូវបានគ្រប់គ្រងដោយក្រុមហ៊ុនផងនោះ ដូចនេះធនធានធម្មជាតិដែលនៅជិតៗបានប្រែជាខ្សត់ទៅៗ ជាហេតុនាំឲ្យប្រជាពលរដ្ឋនាំគ្នាទៅកាន់តំបន់ព្រៃឆ្ងាយៗ រហូតដល់ ១០-២៦គ.មពីភូមិដើម្បីស្វែងរកផល និងអនុផលព្រៃឈើ។ លើសពីនេះទៅទៀត ប្រជាពលរដ្ឋនៅឃុំកន្ទួតត្រូវទៅតំបន់ព្រៃឆ្ងាយៗរហូតដល់ ៥៧គ.មពីភូមិ។ ប្រជាជនក្នុងតំបន់នេះធ្វើដំណើរទៅព្រៃជាញឹកញាប់ដែលមានភាគរយរហូតដល់ ៤៩,៤%។

១៦៩. ស្ថានភាពជីវភាពរបស់ប្រជាពលរដ្ឋមានការប្រែប្រួលយ៉ាងខ្លាំង ដោយសារឱកាសទទួលបានធនធានធម្មជាតិ ដូចជា ឈើ សត្វព្រៃ និងអនុផលព្រៃឈើកាន់តែថយចុះក្នុងរយៈ៥ឆ្នាំចុងក្រោយ ហេតុដូចនេះ ហើយទើបប្រជាពលរដ្ឋងាកមករកការងារកសិកម្ម និងការងារស៊ីឈ្នួលគេវិញ។ នៅពេលដែលឱកាសទទួលធនធានធម្មជាតិធ្លាក់ចុះ ប្រជាពលរដ្ឋមួយចំនួនបានបាត់បង់មុខរបររបស់ខ្លួន ដូចនេះដើម្បីឲ្យមានតុល្យភាពក្នុងជីវភាព ពួកគាត់ត្រូវបង្កើនការយកចិត្តទុកដាក់លើការងារកសិកម្ម ជំនួសការស្វែងរកផល-អនុផលព្រៃឈើនៅតំបន់ទីឆ្ងាយៗ។ ចំណែកឯអ្នកដែលគ្មាន ឬមានដីស្រែតិចតួចប្រមាណ ២០% នៅបន្តការរុករកផល អនុផលព្រៃឈើដើម្បីជីវភាពប្រចាំថ្ងៃដដែល។ ៥៧,៣% នៃប្រជាជននៅក្នុងសហគមន៍បានអាស្រ័យផលធនធានធម្មជាតិ ដូចជាទទួលផលពីព្រៃកទេរ និងព្រៃស្រោងជាដើម។ ប្រជាពលរដ្ឋប្រមាណ

Draft

៤៣,៨% បានដងទឹកពីព្រែកទេរយកមកសម្រាប់ប្រើប្រាស់ក្នុងការចំអិនអាហារ និង៤៥,៧% សម្រាប់ប្រើប្រាស់ទូទៅ ងូត បោកគក់ និងបរិភោគ។ ដោយភូមិសាស្ត្រនៃភូមិឃ្លៀស្ថិតនៅជិតនឹងព្រែកទេរជាងគេ ប្រជាពលរដ្ឋក្នុងភូមិឃ្លៀទាំងអស់បានអាស្រ័យផលពីព្រែកទេរបានច្រើនជាងភូមិដទៃទៀត។ ក្នុងចំណោមប្រភពទឹកទាំងអស់ដែលមាន អ្នកភូមិឃ្លៀចំនួន ៩២,៩% បានប្រើប្រាស់ទឹកព្រែកទេរជាចម្បងដើម្បីចំអិនអាហារ បោកគក់ ងូត និងបរិភោគ។ ក្រៅពីនេះពួកគាត់ប្រមាណជា ៧,១-១៥,៤% មានប្រាក់ចំណូលពីការនេសាទត្រីនៅតាមដងព្រែកទេរនេះទៀតផង។

១៧០. ប្រជាជន ៦៩,៤%បានបញ្ជាក់ ថាព្រៃស្រោងមានការថយចុះក្នុងកំឡុងពេលប្រាំឆ្នាំចុងក្រោយនេះ ម្យ៉ាងវិញទៀត ប្រជាជនបានធ្វើដំណើរកាន់តែឆ្ងាយដើម្បីរកអនុផលព្រៃឈើទាំងនោះ។ ស្របពេលនេះដែរ ប្រជាជន ១៨,៥% បានបញ្ជាក់ថាព្រៃស្រោងមានការកើនឡើង និង១២%ទៀត មិនបានដឹងថាព្រៃស្រោងមានការកើនឡើង ឬថយចុះឡើយ។

១៧១. ប្រជាជនក្នុងឃុំពាក់ព័ន្ធទាំងពីរប្រមាណ ៦៤,៨% បានប្រាប់ថា មិនបានដឹងពីស្ថានភាពប្រព័ន្ធអូរ ឬព្រែកនៅក្នុងតំបន់ដីសម្បទានថាមានការប្រែប្រួលយ៉ាងណាក្នុងកំឡុងពេល៥ឆ្នាំនេះទេ តែមានប្រជាជន ២៦,៤% ប៉ុណ្ណោះបានបញ្ជាក់ថាប្រព័ន្ធអូរ ឬព្រែកមានការថយចុះក្នុងកំឡុងពេលប្រាំឆ្នាំចុងក្រោយនេះ។

១៧២. **ប្រភេទនៃធនធានធម្មជាតិៈ** ប្រសិនបើតំបន់ដីសម្បទានមិនត្រូវបានហាមឃាត់ចំពោះការអាស្រ័យផល អនុផលព្រៃឈើទេនោះ ប្រជាជនក្នុងសហគមន៍ ៤២,៤% បានអះអាងថាពួកគាត់នឹងអាចទាញយកអុស ឬឈើសម្រាប់ធ្វើធ្យូងពីក្នុងព្រៃ, ១៨,៦% ថាពួកគាត់នឹងរកគល់ឈើធំៗ ហើយ ១៨,៦% ទៀតនឹងបានច្រូតស្បូវ, ៨,៥% នឹងរកសត្វព្រៃ, ៥,៩% នឹងរកថ្នាំបុរាណ, ៣,៤% នឹងរកវល្លិ ឬផ្តៅ និង ២,៥% ថាគាត់នឹងរកជ័រទឹកបានពីក្នុងព្រៃនៃតំបន់នោះ (ដ្យាក្រាម៥-១៩)។

ដ្យាក្រាម ៥-១៩៖ ប្រភេទធនធានធម្មជាតិដែលប្រជាពលរដ្ឋអាចអាស្រ័យបាន (លទ្ធផលនៃការសម្ភាសន៍)



៥.៤.៥.៨ ប្រភពចំណូលសំខាន់របស់គ្រួសារ

៥.៤.៥.៨.១ មុខរបរចិញ្ចឹមជីវិត

១៧៣. ប្រជាជនក្នុងសហគមន៍នេះភាគច្រើនសុទ្ធតែមានការងារធ្វើ ហើយមុខរបររបស់គាត់ គឺអាស្រ័យទៅនឹងលទ្ធភាពទុន និងធនធានមនុស្សដែលពួកគាត់មាន។ ជាទូទៅ ប្រជាពលរដ្ឋភាគច្រើន (៦៣%) មានមុខរបរទី១គឺបរកសិកម្ម ដូចជាធ្វើស្រែ និងចំការ ដោយសារតែគាត់មានដីកសិកម្ម ដីស្រែចម្ការសម្រាប់បង្កបង្កើនផលជាប្រចាំជាជាងទុកដីឲ្យនៅទំនេរ។ ក្រៅពីនេះ ពលរដ្ឋខ្លះទៀតដែលមិនសូវមាន ឬគ្មានដីសម្រាប់បង្កបង្កើនផលចំនួន ១៤,២% មានមុខរបរទី១ជាការធ្វើជំនួញខ្នាតតូច (លក់ដូរ និងសិប្បកម្ម) នៅក្នុងសហគមន៍, ៨,៦% បានលក់កំលាំងពលកម្ម (ស៊ីឈ្នួលកាប់ឫស្សី និងដឹកឈើ), ៨% ប្រមូលអនុផលពីព្រៃឈើ ហើយមានប្រជាជនតិចតួច (៣,១%) ដែលធ្វើជាអ្នកនេសាទ និង៣,១% ទៀតចិញ្ចឹមសត្វ (ដ្យាក្រាម៥-២០)។ ពីមុខរបរទី១នេះ ពួកគាត់អាចរកចំណូលជាមធ្យមបានប្រមាណជា ៦៨ដុល្លាអាមេរិក/ខែ។

ដ្យាក្រាម៥-២០៖ ប្រភពចំណូលទី១ (លទ្ធផលនៃការសម្ភាសន៍)



១៧៤. ក្រៅពីមុខរបរទី១នេះ ប្រជាពលរដ្ឋមួយចំនួនក៏មានមុខរបរទី២ ដើម្បីរកនូវប្រាក់កម្រៃផងដែរ។ ជាក់ស្តែង ពួកគាត់ចំនួន ៤៧,៧% មានចំណូលទី២ពីការលក់កម្លាំងពលកម្ម, ១៧,២% បានពីការចិញ្ចឹមសត្វ, ៩,៩% បានពីការលក់ដូរ, ៨,៦% បានពីការនេសាទត្រី, ៦,៦% បានពីការប្រមូលអនុផលព្រៃឈើ, ៦,៦% បានពីការធ្វើស្រែចំការ និង៣,៣% បានកម្រៃពីការធ្វើពលករក្នុងក្រុមហ៊ុន (ដ្យាក្រាម៥-២១)។ ជាទូទៅ ប្រជាពលរដ្ឋទទួលបានចំណូលជាមធ្យមពីប្រភពទី២នេះប្រហែល ១១៧ដុល្លាអាមេរិកក្នុង១ខែ។ តាមការសិក្សារបស់ក្រុមការងារ បានរកឃើញថា ប្រាក់ចំណូលពីមុខរបរទី២នេះភាគច្រើនគឺបានមកពីការលក់កម្លាំងពលកម្ម ហើយទំហំទឹកប្រាក់ដែលទទួលបានមានចំនួនតិច ឬច្រើនគឺអាស្រ័យទៅលើកម្លាំងពល

ករដែលមាននៅក្នុងគ្រួសារ (ចំនួនសមាជិកគ្រួសារដែលលក់កម្លាំង) សមត្ថភាព ជំនាញ ការប្រឹងប្រែងតស៊ូព្យាយាម និងចំនួនថ្ងៃធ្វើការរបស់ពួកគាត់។ ជាក់ស្តែង អ្នកភូមិក្រសាំងចំនួន ៥៧,១% និងអ្នកភូមិថ្មី ៦៥,៤% បានរកស៊ីលក់កម្លាំងពលកម្ម ហើយចំណូលមធ្យមប្រចាំខែគឺ អ្នកភូមិក្រសាំងទទួលបាន ១៧៣ ដុល្លា និងអ្នកភូមិថ្មីបាន ១៦៣ដុល្លាអាមេរិក។ ដោយឡែក អ្នកភូមិស្វាយជ្រុំ ៤៦,៧% វិញ ក៏បានលក់កម្លាំងពលកម្មដូចគ្នាដែរ ប៉ុន្តែផ្ទុយទៅវិញពួកគាត់ទទួលបានត្រឹមតែ៥១ដុល្លាអាមេរិកក្នុង១ខែប៉ុណ្ណោះ។

ដ្យាក្រាម៥-២១៖ ប្រភពចំណូលទី២ (លទ្ធផលនៃការសម្ភាសន៍)



១៧៥. លើសពីនេះទៅទៀត ពួកគាត់ខ្លះទៀតនៅមានចំណូលដែលបានមកពីមុខរបរបន្ទាប់បន្សំ (ប្រភពចំណូលទី៣)។ ជាក់ស្តែង ពួកគាត់ចំនួន ៥០% បានពីការចិញ្ចឹមសត្វ, ១៦,៧% បានពីការលក់កម្លាំងពលកម្ម, ១១.៥% បានពីលក់ដូរ, ១១,៥% បានពីការរកត្រី និង១០,៣% បានពីការធ្វើស្រែចំការ (ដ្យាក្រាម ៥-២២)។ ជាមធ្យមពួកគាត់ទទួលបានចំណូលពីប្រភពទី៣នេះប្រហែល ៧៩ដុល្លាអាមេរិកក្នុង១ខែ។ តាមការសិក្សារបស់ក្រុមការងារ បានរកឃើញថា ប្រាក់ចំណូលពីមុខរបរទី៣នេះ ភាគច្រើនគឺបានមកពីការចិញ្ចឹមសត្វគោក្របី ហើយការចិញ្ចឹមគោក្របីរបស់ប្រជាពលរដ្ឋរស់នៅក្នុងតំបន់នេះ មិនប៉ះពាល់ដល់មុខរបរទី១ និងទី២របស់ពួកគាត់ទេ គឺពួកគាត់ព្រលែងវាចោលទៅក្នុងព្រៃឲ្យវារកស្មៅស៊ីដោយសេរីតែម្តង ទាល់តែដល់រដូវភ្ជួររាស់ ឬត្រូវការលក់ ទើបពួកគាត់ទៅកៀងវាពីព្រៃមកវិញ។ ទំហំទឹកប្រាក់ដែលទទួលបានពីការចិញ្ចឹមសត្វនេះមានចំនួនតិច ឬច្រើនគឺអាស្រ័យទៅលើលទ្ធភាពទុន ប្រភេទ និងចំនួនសត្វរបស់ពួកគាត់។ ជាក់ស្តែង អ្នកភូមិក្រសាំងចំនួន ៤២,៩% និងអ្នកភូមិថ្មី ៦៤,៣% បានរកស៊ីចិញ្ចឹមគោក្របី ហើយចំណូលមធ្យមប្រចាំខែគឺ អ្នកភូមិក្រសាំងទទួលបាន ១០៥ដុល្លា និង អ្នកភូមិថ្មីបាន ១១៦ដុល្លាអាមេរិក។ ដោយឡែក អ្នកភូមិស្វាយជ្រុំ ៣៦,៤% ក៏បានចិញ្ចឹមសត្វដូចគ្នាដែរ ប៉ុន្តែផ្ទុយទៅវិញពួកគាត់ទទួលបានត្រឹមតែ ២៤ដុល្លាអាមេរិកក្នុង១ខែតែប៉ុណ្ណោះ។

Draft

ដ្យាក្រាម៥-២២៖ ប្រភពចំណូលទី៣ (លទ្ធផលនៃការសម្ភាសន៍)



១៧៦. ការធ្វើស្រែ: ប្រជាកសិករនៅក្នុងតំបន់នេះប្រកបរបរធ្វើស្រែស្រូវធ្ងន់ ស្រូវស្រាល (ឬស្រែប្រាំង) ស្រូវចំការ។ ក្នុងការធ្វើស្រែស្រូវធ្ងន់ ពួកគាត់ប្រើប្រាស់គោក្របី១នឹម និងកំលាំងមនុស្សចំនួន ២-៣នាក់ ឬច្រើនជាងនេះតាមលទ្ធភាពនៃសមាជិកក្នុងគ្រួសារទាំងបុរសទាំងនារី និងតាមទំហំដីស្រែដែលពួកគាត់មាន ដោយពឹងផ្អែកលើទឹកភ្លៀងទាំងស្រុង។ ពួកគាត់ពុំមានប្រើប្រាស់ជីគីមីទេ តែគ្រួសារខ្លះប្រើប្រាស់ជីធម្មជាតិ ដើម្បីបង្កើនទិន្នផលស្រូវ។ ពួកគាត់ចាប់ផ្តើម ធ្វើការភ្ជួររាស់ដកស្ទូងពីខែកក្កដា រហូតដល់ខែធ្នូទើបប្រមូលផល។ ពួកគាត់ធ្វើស្រែតាមទំលាប់របស់ខ្លួន ទោះបីជាមានការបំពាក់បំប៉នពីអង្គការនានាដូចជា CEDAC ដែលបានបង្រៀនបច្ចេកទេសស្ទូងស្រូវ និងការថែទាំដល់ពួកគាត់ក៏ដោយ។ ប្រជាពលរដ្ឋមិនអនុវត្តតាមការបង្រៀននេះ ដោយសារស្ថានភាពដីមិនសមស្រប និងមានឧបសគ្គផ្សេងទៀត ដូចជាមានសត្វក្តាមច្រើនស៊ីដើមស្រូវជាដើម។ យោងតាមឯកសារព័ត៌មានស្តីពីស្ថានភាពឃុំថ្មីឆ្នាំ ២០១៣ ប្រជាកសិករនៅឃុំថ្មីធ្វើស្រែវស្សាបានគ្រប់ផែនការ ១០០% លើដីស្រែវស្សាសរុបចំនួន ២.៩៩១ហិកតា ហើយ ទទួលបានទិន្នផលគឺ ៤.៤៨៦,៥០តោន (១,៥តោនក្នុង១ហិកតា)។ ពួកគាត់បានធ្វើស្រែចំការលើដីទំហំ ៨៧ហិកតា ទទួលបានផល ៨៧តោន (១តោន/ហិកតា)។ ពួកគាត់លក់ស្រូវក្នុងតម្លៃជាមធ្យម ១.០២០រៀល/គក្រ។ ដូចគ្នានេះដែរ យោងតាមឯកសារព័ត៌មានស្តីពីស្ថានភាពឃុំឆ្នាំ២០១៤ ប្រជាកសិករនៅឃុំកន្ទួតធ្វើស្រែវស្សាបាន ៩២,៨% នៃផែនការលើដីស្រែវស្សាសរុបចំនួន ៩១១ហិកតា ហើយទិន្នផលទទួលបានគឺ ១.៦៩០តោន (២តោនក្នុង១ហិកតា)។ ក្រៅពីនេះ ពួកគាត់ខ្លះបានធ្វើស្រែប្រាំង (៧ហិកតា) ស្រែបង្កើនរដូវ (១០ហិកតា) និងស្រែចំការ (៧ហិកតា) ហើយទទួលបានផល ១-២តោន/ហិកតា)។ ពួកគាត់លក់ស្រូវក្នុងតម្លៃជាមធ្យម ១.០០០រៀល/គក្រ។

១៧៧. ការស៊ីឈ្នួលកាប់ឫស្សី: ប្រជាពលរដ្ឋភាគច្រើនប្រកបរបរស៊ីឈ្នួលកាប់ឫស្សីឲ្យគេ ឬកាប់ឫស្សីលក់ ពីខែកក្កដាដល់ចុងខែកញ្ញា នៅពេលប្រព័ន្ធព្រែកអូរនានាមានទឹកហូរព្រៀប តាមលក្ខណៈបណ្តែតជាក្បូន ឬប្រើប្រាស់រទេះគោ១នឹម ដោយត្រូវការកំលាំងបុរស ២-៣នាក់។ ក្នុងមួយថ្ងៃពួកគាត់ម្នាក់អាចកាប់ឫស្សីបានពី ១៥ទៅ២០ដើម ហើយអាចទទួលបានកម្រៃ ១.០០០រៀលក្នុងមួយដើម។

១៧៨. **ការស៊ីឈ្នួលដឹកឈើ:** ក្រោយពីភ្ជួររាស់រួច ប្រជាពលរដ្ឋប្រកបរបរស៊ីឈ្នួលដឹកឈើឲ្យគេ ដោយប្រើរទេះគោ ឬគោយន្ត និងកំលាំងបុរស២-៣នាក់។ ក្នុងមួយថ្ងៃពួកគាត់ម្នាក់អាចរកកម្រៃបាន ៣ម៉ឺន-៤ម៉ឺនរៀលសម្រាប់រទេះគោ ហើយសម្រាប់គោយន្តអាចទទួលបានកម្រៃ ៥ម៉ឺនរៀលក្នុងមួយថ្ងៃ។ ការកាប់ឈើជាអំពើខុសច្បាប់ ទោះបីមានការហាមឃាត់ពីសមត្ថកិច្ច ប៉ុន្តែដោយសារជីវភាពមានកំរិត ប្រជាពលរដ្ឋមួយចំនួននៅតែលបកាប់ដើម្បីរកប្រាក់ចំណូលបំពេញសេចក្តីត្រូវការក្នុងគ្រួសារ។

១៧៩. **ការរកសត្វព្រៃ:** បុរសៗនៅភូមិនេះភាគច្រើនដើររកសត្វព្រៃតាមទំលាប់ជាពួក ២-៣នាក់ ដោយបណ្តើរឆ្កែ ឬដាក់អន្ទាក់។ សត្វដែលពួកគេរកបានមានដូចជា: ជ្រូកព្រៃ ឈ្លូស ត្រកួត ពស់ អណ្តើក។ល។ ពួកគេអាចរកសត្វបានស្ទើរតែគ្រប់រដូវទាំងអស់។

១៨០. **ការចិញ្ចឹមមាន់ និងទា:** ក្នុងឃុំថ្មីមានប្រជាកសិករ ១.៧៧៧គ្រួសារ (៨៤,៤២%) បានចិញ្ចឹមមាន់ក្នុងចំនួនសរុប ១៤.៤៤៦ក្បាល និងប្រជាពលរដ្ឋ ១៤០គ្រួសារ (៤,៩៤%) បានចិញ្ចឹមទា ដែលមានចំនួនសរុប ៧៤០ក្បាល។ ដោយឡែកនៅក្នុងឃុំកន្ទួតវិញ មានគ្រួសារប្រជាកសិករប្រមាណជា ៥៤,៦% បានចិញ្ចឹមមាន់ក្នុងចំនួនសរុប ៤.៦០៤ក្បាល និងគ្រួសារកសិករ ១៥,៧% បានចិញ្ចឹមទាចំនួន ៩៤១ក្បាល។ សមាជិកក្នុងគ្រួសារ ទាំងបុរស ទាំងស្ត្រី អាចមើលថែមាន់ទាំងអស់គ្នា។ មាន់ពេញវ័យមួយក្បាលអាចលក់បាន ២ម៉ឺនរៀល។ មានប្រជាពលរដ្ឋខ្លះអាចលក់មាន់រកប្រាក់ចំណូល ក្នុងមួយឆ្នាំបាន ១០-១៥ក្បាល តែភាគច្រើននៃប្រជាពលរដ្ឋចិញ្ចឹមមាន់សម្រាប់ហូបក្នុងគ្រួសារប៉ុណ្ណោះ។ ការចិញ្ចឹមមាន់អាចចិញ្ចឹមបានគ្រប់រដូវ។ មានអង្គការ CEDAC និង RULIP បង្រៀនអំពីការចិញ្ចឹមសត្វមាន់ វិធីបង្ការជំងឺ និងព្យាបាលមួយចំនួនផងដែរ ប៉ុន្តែពុំមាននិរន្តរភាពដោយសារខ្វះខាតទុន ធនធានចំណី និងឧបករណ៍ចាំបាច់ផ្សេងៗផង ប្រជាពលរដ្ឋក៏ឈប់អនុវត្តតាម ហើយចិញ្ចឹមតាមទំលាប់ធម្មតាជាលក្ខណៈគ្រួសារវិញ។

១៨១. **ការចិញ្ចឹមជ្រូក:** ក្នុងឃុំថ្មីមានប្រជាកសិករ ១.០៥៩គ្រួសារ (៥០,៣១%) បានចិញ្ចឹមជ្រូកក្នុងចំនួនសរុប ៣.៣៤០ក្បាល។ ដោយឡែកនៅក្នុងឃុំកន្ទួតវិញ មានគ្រួសារប្រជាកសិករប្រមាណជា ២៣,៦% បានចិញ្ចឹមជ្រូកក្នុងចំនួនសរុប ៨២៣ក្បាល។ សមាជិកក្នុងគ្រួសារទាំងអស់ ទាំងបុរសទាំងស្ត្រីអាចមើលថែទាំជ្រូកទាំងអស់គ្នា។ ជ្រូកពេញវ័យមួយក្បាលអាចលក់បាន ៨០ម៉ឺនរៀល។ មានប្រជាពលរដ្ឋខ្លះអាចលក់ជ្រូករកប្រាក់ចំណូលក្នុងមួយឆ្នាំបាន ១-២ក្បាល។ ការចិញ្ចឹមជ្រូកអាចដាមធ្យោបាយដោះទ័លហើយអាចចិញ្ចឹមបានគ្រប់រដូវ។

១៨២. **ការចិញ្ចឹមគោក្របី:** ក្នុងឃុំថ្មីមានប្រជាកសិករ ១.៩៤៧គ្រួសារ (៩២,៤៩%) បានចិញ្ចឹមគោសរុបចំនួន ៦.៥៩៨ក្បាល និងប្រជាពលរដ្ឋ ១.៣៤១គ្រួសារ (៦៣,៧១%) បានចិញ្ចឹមក្របីសរុបចំនួន ៣.៣០៤ក្បាល។ ដោយឡែកនៅក្នុងឃុំកន្ទួតវិញ មានគ្រួសារប្រជាកសិករប្រមាណជា ៦១,៦% បានចិញ្ចឹមគោក្នុងចំនួនសរុប ៤.២០៧ក្បាល និងគ្រួសារកសិករ ៦,៣% បានចិញ្ចឹមក្របីចំនួន ២៥៤ក្បាល។ គោមួយក្បាលអាចលក់បានពី ១,៥-១,៧លានរៀល ក្របីមួយក្បាលថ្លៃ ២-៣,៥លានរៀល អាចចិញ្ចឹមបានគ្រប់រដូវ ចិញ្ចឹមដោយដេញឲ្យទៅរកស៊ីស្មៅតាមទំលាប់ គឺតាមដីវាលដែលសំបូរស្មៅជាដើម។ ស្រប ពេលដែលកសិកម្មនៅក្នុងភូមិជាមុខរបរចំបងរបស់ប្រជាជនក្នុងសហគមន៍ យើងសង្កេតឃើញមានអង្គការ CEDAC និង RULIP បានចុះទៅរៀបចំវគ្គបំពាក់បំប៉នលើការធ្វើស្រែ និងចិញ្ចឹមមាន់ខ្លះដែរ ប៉ុន្តែមកដល់

ពេលនេះ ប្រជាពលរដ្ឋមិនបានបន្តការអនុវត្តន៍តាមវិធីសាស្ត្រទាំងនោះទៀតទេ ដោយសារស្ថានភាពដីជាក់ស្តែងមិនសមស្រប និងមានឧបសគ្គផ្សេងៗមួយចំនួនទៀត ដូចជាសណ្ឋានដីមិនរាបស្មើ សម្បូរសត្វក្តាម កំលាំងទឹកហូរខ្លាំងនៅរដូវវស្សា។ល។ មួយវិញទៀត មានការខ្វះខាតធនធានសម្រាប់ដំណើរការឲ្យមាននិរន្តរភាពដូចជា ខ្វះខាតពូជ ថ្នាំព្យាបាល ឬរាំក់សាំងការពារជាដើម។ល។

១៨៣. ការដាំពោតៈ មានអ្នកភូមិមួយចំនួនដាំពោតសសម្រាប់ហូបក្នុងគ្រួសារ ខ្លះដាំពោតក្រហមសម្រាប់លក់។ ពូជពោតក្រហមក្នុងមួយគីឡូក្រាមថ្លៃ ១២.០០០រៀល ហើយក្នុងមួយហិកតាត្រូវការពូជប្រហែល ២០គ.ក។ ទិន្នផលដែលទទួលបានអាចលក់ក្នុងតម្លៃ ៥០០រៀល/គ.ក។ យោងតាមទិន្នន័យក្នុងឯកសារព័ត៌មានស្តីពីស្ថានភាពឃុំឆ្នាំ២០១៤ ប្រជាពលរដ្ឋនៅឃុំកន្ទួត បានដាំពោតលើផ្ទៃដីចំការ ២៤ហិកតា ហើយទទួលផលបាន ៩៦តោន (៤តោនក្នុងមួយហិកតា)។ ពោតអាចដាំបានពីខែមេសា និងអាចប្រមូលផលនៅខែកក្កដា។ ពួកគាត់ដាំពោតសតាមទំលាប់សម្រាប់ទុកហូបក្នុងគ្រួសារ។ ចំណែកពោតក្រហមមិនទាន់មានទីផ្សារច្បាស់លាស់ ដោយសារឈ្មួញមិនចូលមករកទិញ។

១៨៤. ការដាំដំឡូងមីៈ បច្ចុប្បន្នប្រជាពលរដ្ឋមានពូជដំឡូងខ្លួនឯង មិនចាំបាច់ទិញពូជពីតំបន់ផ្សេង ឬពីប្រទេសជិតខាងឡើយ។ គេអាចដាំពីខែមេសាបន្ទាប់ពីមានភ្លៀងធ្លាក់ដំបូង ហើយប្រមូលផលនៅខែមករានៃឆ្នាំបន្ទាប់ ហើយទិន្នផលដែលទទួលបាន អាចលក់ក្នុងតម្លៃ ៥០១រៀល/គីឡូក្រាម។ យោងតាមទិន្នន័យក្នុងឯកសារព័ត៌មានស្តីពីស្ថានភាពឃុំឆ្នាំ២០១៣ ប្រជាពលរដ្ឋនៅឃុំថ្មី បានដាំដំឡូងមីលើផ្ទៃដីចំការ ៨៧ហិកតា ហើយទទួលផលបាន ៦០៩តោន (៧តោន/ហិកតា)។ ដូចគ្នានេះដែរ យោងតាមទិន្នន័យក្នុងឯកសារព័ត៌មានស្តីពីស្ថានភាពឃុំឆ្នាំ ២០១៤ ប្រជាពលរដ្ឋនៅឃុំកន្ទួត បានដាំដំឡូងមីលើផ្ទៃដីចំការ ២៣០ហិកតា ហើយទទួលផលបាន ១.១៥០តោន (៥តោន/ហិកតា)។ ក្នុងបំណងបង្កើននូវទិន្នផលនៃដំណាំដំឡូងមីរបស់ខ្លួន ពួកគាត់ខ្លះបានទៅដកស្រង់បទពិសោធន៍បច្ចេកទេសលើការដាំដំឡូងមីនៅឯប្រទេសវៀតណាម។ ដំណាំដំឡូងមិនទាន់មានទីផ្សារច្បាស់លាស់នៅឡើយ ដោយសារឈ្មួញមិនចូលមករកទិញ និងម្យ៉ាងទៀតដោយសារមានហានិភ័យទឹកជំនន់ផង ជាហេតុធ្វើឲ្យពួកគាត់ដាំដំណាំកសិកម្មមួយនេះក្នុងបរិមាណតិចតួច។

៥.៤.៥.៨.២ ប្រាក់ចំណូលប្រចាំគ្រួសារ

១៨៥. បច្ចុប្បន្នប្រាក់ចំណូល ដែលបានពីធនធានធម្មជាតិកាន់តែចុះខ្សោយ បើប្រៀបធៀបទៅនឹងស្ថានភាពកាលពីរយៈពេល៥ឆ្នាំមុន តែវានៅតែជាប្រភពចំណូលសំខាន់ សម្រាប់គ្រួសារប្រជាពលរដ្ឋមួយ ចំនួនធំដែលគ្មាន ឬមានដីកសិកម្មតិចតួច ឬគ្មានមុខរបរចិញ្ចឹមជីវិតពិតប្រាកដ។ មានសមាជិកគ្រួសារប្រជាពលរដ្ឋមួយចំនួនបានចូលធ្វើការជាកម្មករក្រុមហ៊ុន ដោយបានកម្រៃជាមធ្យម៥ដុល្លាក្នុងមួយថ្ងៃ។ ចំណែកឯប្រជាជនក្នុងឃុំថ្មី (ភូមិល្បៀរ) ភាគតិចណាស់ដែលធ្វើជាពលកររបស់ក្រុមហ៊ុន ដោយសារតែនៅឆ្ងាយពីក្រុមហ៊ុនផង ពិបាកក្នុងការធ្វើដំណើរផង ព្រោះត្រូវធ្វើដំណើរតាមផ្លូវព្រៃ។ ប៉ុន្តែពួកគាត់ភាគច្រើនបានលក់កម្លាំងពលកម្ម ទៅឲ្យពួកឈ្មួញរកស៊ីដឹកឈើ កាប់ឫស្សី ស៊ីឈ្នួលដកស្ទូង ដាំពោត ដាំដំឡូង ប្រមូលផលដំណាំដែលរដូវកាលអាចរកកម្រៃបានលើសពីការទៅធ្វើជាកម្មករក្រុមហ៊ុនទៀតផង។

១៨៦. ជាមធ្យមប្រជាជនក្នុងតំបន់ដីសម្បទាននេះរកចំណូលបាន ៦៨ដុល្លាក្នុងមួយខែពីមុខរបរទី១ ប៉ុន្តែ

ពួកគាត់អាចរកចំណូលបានពីមុខរបរទី២ និងមុខរបរទី៣ បានច្រើនជាងមុខរបរទី១នេះទៅទៀត ដោយក្នុងមួយខែពួកគាត់អាចរកបានដល់ទៅ ១១៧ដុល្លាពីមុខរបរទី២ និង៧៩ដុល្លាពីមុខរបរទី៣ ជាពិសេសចំណូលពីការស៊ីឈ្នួលលក់កម្លាំងពលកម្ម និងការចិញ្ចឹមសត្វគោក្របី។ ដោយឡែក ក្នុងចំណោមភូមិពាក់ព័ន្ធទាំងនោះ ភូមិស្វាយជ្រុំជាភូមិដែលរកកម្រៃបានតិចជាងគេ គឺពួកគាត់រកចំណូលបានពីមុខរបរទី១ ជាមធ្យមក្នុងមួយខែ ៤៧ដុល្លា ហើយពីមុខរបរទី២បានជាមធ្យម ៥១ដុល្លា និងពីមុខរបរទី៣បានជាមធ្យមតែ ២៤ដុល្លាប៉ុណ្ណោះ (ដ្យាក្រាម៥-២៣) ដោយសារពួកគាត់ភាគច្រើន (៦៨,៨%) ប្រកបមុខរបរទី១ គឺកសិកម្ម ដែលត្រូវចំណាយខ្ពស់លើការជួលសេវាក្ជួររាស់ ពីព្រោះពួកគាត់គ្មានមធ្យោបាយផលិតកម្ម (គោក្របី ឬគោយន្ត) និងមុខរបរទី២ គឺការលក់កម្លាំងពលកម្មឲ្យកសិករធ្វើស្រែចម្ការក្នុងស្រុក ដែលមានតម្លៃថោកជាងប្រាក់ឈ្នួលក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ចអភិវឌ្ឍន៍ដំណាំកៅស៊ូ និងជាពិសេសគឺចំនួនអ្នកអាចរកចំណូលក្នុងគ្រួសារមានចំនួនតិចផងដែរ។

១៨៧. ក្នុងចំណោមភូមិពាក់ព័ន្ធទាំង៦ ប្រជាជនក្នុងភូមិអាលចអាចរកកំរៃបានខ្ពស់ជាងភូមិដទៃទៀត ដោយសារភូមិនេះឋិតនៅជាប់នឹងផ្លូវជាតិលេខ៧ ដែលធ្វើឲ្យពួកគាត់មានឱកាសក្នុងការប្រកបមុខរបរធ្វើជំនួញខ្នាតតូច (លក់ដូរ) បានដោយខ្លួនឯងផ្ទាល់ និងសម្បូរអតិថិជនទៀតផង ដែលក្នុងមួយខែៗ ពួកគាត់អាចរកចំណូលបានជាមធ្យម ១០៨ដុល្លាអាមេរិក។ លើសពីនេះទៅទៀត ពួកគាត់អាចលក់កំលាំងពលកម្មសម្រាប់រកចំណូលបន្ទាប់បន្សំជួយដល់គ្រួសារបានជាមធ្យម ៨៥ដុល្លាក្នុងមួយខែបន្ថែមទៀតផងដែរ។ ប្រជាពលរដ្ឋនៅភូមិក្រសាំងមានប្រាក់ចំណូលខ្ពស់រហូតដល់១៧៣ដុល្លា/ខែ និង១០៥ដុល្លា/ខែ ដែលបានមកពីការលក់កំលាំងពលកម្ម និងចិញ្ចឹមសត្វ ដូចគ្នានឹងភូមិថ្មីដែលទទួលបានប្រាក់ចំណូលបន្ថែមប្រមាណ ១៦៣ដុល្លា/ខែ និង១១៦ដុល្លា/ខែពីមុខរបរទី២ និងទី៣នេះ (ដ្យាក្រាម៥-២៣)។

ដ្យាក្រាម៥-២៣៖ មធ្យមភាគនៃប្រាក់ចំណូលប្រចាំខែរបស់ប្រជាពលរដ្ឋ(លទ្ធផលនៃការសម្ភាសន៍)



១៨៨. កំរិតនៃភាពក្រីក្រ៖ យោងតាមវិធីសាស្ត្រវាយតម្លៃកំរិតនៃភាពក្រីក្រ ដែលមានកំណត់តាមរូបមន្តនៅខាងលើ និងតាមលទ្ធផលនៃការសម្ភាសន៍តាមគ្រួសារ យើងបានរកឃើញថា ប្រជាពលរដ្ឋក្នុងឃុំពាក់ព័ន្ធទាំងពីរមានប្រាក់ចំណូលមធ្យមប្រចាំខែចំនួន ២៦៤ដុល្លា/គ្រួសារ ស្មើនឹង ១.០៥៦.០០០រៀល។ យើង

Draft

យកចំនួននេះមកចែកនឹង ៣០ថ្ងៃ រួចចែកនឹងចំនួនសមាជិកគ្រួសារ ៥,៣៧នាក់ នោះយើងបានលទ្ធផលជាប្រាក់ចំណូលមធ្យមប្រចាំថ្ងៃចំនួន ៦៥៥៤,៩៣រៀល/ម្នាក់/ថ្ងៃ។ ដូចនេះ បើយើងប្រៀបធៀបទៅនឹងកំរិតបន្ទាត់នៃភាពក្រីក្រឆ្នាំ ២០០៩ ដែលមានត្រឹមតែ ៤៣១៤,៧៥រៀល/ម្នាក់/ថ្ងៃ នោះយើងអាចសន្និដ្ឋានបានថា នាពេលបច្ចុប្បន្នកំរិតជីវភាពរបស់ប្រជាពលរដ្ឋក្នុងតំបន់នោះល្អប្រសើរជាងមុន ដោយសារពួកគាត់មានប្រាក់ចំណូលប្រមាណជា ២២៤០,១៨រៀល/ម្នាក់/ថ្ងៃ កើនលើសកាលពីឆ្នាំ ២០០៩ ក្នុងអត្រាកំណើន ៥១,៩%។ ក៏ប៉ុន្តែតាមការវិភាគកម្រិតនៃភាពក្រីក្រតាមភូមិនីមួយៗវិញ យើងបានរកឃើញថា ផ្ទុយពីអ្នកភូមិពាក់ព័ន្ធដទៃទៀតដែលមានកម្រិតជីវភាពធូរធារជាងមុន ប្រជាពលរដ្ឋនៅភូមិស្វាយជ្រុំបែរជាមានកម្រិតជីវភាពធ្លាក់ចុះដុនដាបទៅវិញ ព្រោះប្រាក់ចំណូលមធ្យមប្រចាំថ្ងៃរបស់ពួកគាត់គឺបានត្រឹមតែ ២៨០៤,៦០ រៀល/ម្នាក់/ថ្ងៃប៉ុណ្ណោះ ពោលគឺទាបជាងកម្រិតបន្ទាត់នៃភាពក្រីក្ររហូតដល់ជិត២ដង ជាមួយនឹងអត្រាអវិជ្ជមាន -៣៥% (ដ្យាក្រាម៥-២៤)។

ដ្យាក្រាម៥-២៤៖ ប្រាក់ចំណូលជាមធ្យមប្រចាំថ្ងៃធៀបនឹងកម្រិតបន្ទាត់នៃភាពក្រីក្រ (ការអង្កេតសេដ្ឋកិច្ច-សង្គមកម្ពុជាឆ្នាំ ២០០៩) (លទ្ធផលនៃការសម្ភាសន៍)



Draft

៥.៤.៥.៩ សេវាកម្មសាធារណៈ

១៨៩. ការអភិវឌ្ឍន៍សេវាកម្មសាធារណៈជាយុទ្ធសាស្ត្រមួយដ៏ល្អប្រសើរ ដើម្បីធ្វើការលើកស្ទួយជីវភាពប្រជាជនក្នុងតំបន់ ជាពិសេស ប្រព័ន្ធផ្លូវគមនាគមន៍ សាលារៀន មណ្ឌលសុខភាព បណ្តាញថាមពលអគ្គិសនី អណ្តូងទឹកស្អាត និងបង្គន់អនាម័យដែលជាតម្រូវការចាំបាច់ក្នុងការអភិវឌ្ឍន៍ជនបទ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងយុទ្ធនាការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

១៩០. ផ្លូវគមនាគមន៍: ផ្លូវលំក្នុងឃុំថ្មីជាផ្លូវគ្រួសក្រហមខ្សាច់ក្នុំមានប្រវែង ១៥គ.ម មានសភាពទ្រុឌទ្រោមដោយសារទឹកភ្លៀង និងទឹកជំនន់ហូរកាត់។ ក្នុងឃុំកន្ទួតវិញមានផ្លូវជាតិលេខ៧ ក្រាលកៅស៊ូមានប្រវែង ១៧គ.ម ផ្លូវបេទីមីណឹមានប្រវែង ២៧០០០ម៉ែត្រ និងផ្លូវគ្រួសក្រហមខ្សាច់ក្នុំមានប្រវែង ៣០គ.ម។ ប៉ុន្តែប្រជាជននៅក្នុងតំបន់ដីសម្បទាននោះ នៅជួបប្រទះនូវការលំបាកក្នុងការធ្វើដំណើរពីភូមិនិមួយៗ ទៅកាន់ផ្លូវជាតិ មណ្ឌលសុខភាព និងសាលារៀន។ ជាក់ស្តែងក្នុងឃុំថ្មី ផ្លូវទៅកាន់ភូមិស្មៀរមានសភាពទ្រុឌ

ទ្រោម និងជាប់ផុងដោយអន្លើ ដែលបង្កឲ្យមានការលំបាកក្នុងការធ្វើដំណើរ ហើយប៉ះពាល់ដល់ការធ្វើដំណើរទៅសិក្សារបស់កុមារ និងការប្រកបរបរផ្សេងៗទៀត ក៏ដូចជាការធ្វើទំនាក់ទំនងអាជីវកម្មជាមួយសហគមន៍ផ្សេងៗក្នុងតំបន់ ឬនៅតំបន់ផ្សេងៗផងដែរ។

១៩១. ការប្រើប្រាស់ទឹកៈ យោងតាមការវិភាគទិន្នន័យក្នុងឯកសារព័ត៌មានស្តីពីស្ថានភាពឃុំឆ្នាំ ២០១៣ នៅក្នុងឃុំថ្មីមានអណ្តូងស្នប់ចំនួន ៧៩អណ្តូង អណ្តូងដីកគ្មានការពារ ២៩អណ្តូង និងស្រះទឹក ០១កន្លែង។ ប្រជាពលរដ្ឋក្នុងឃុំថ្មីចំនួន ១.៧០៤គ្រួសារ ឬស្មើនឹង ៨០,៩៥% (ភាគច្រើននៅក្នុងភូមិរៀង) ប្រើប្រាស់ទឹកអណ្តូងស្នប់, ១៨៩គ្រួសារ ឬស្មើនឹង ៨,៩៨% ប្រើអណ្តូងដីកគ្មានការពារ, ១០គ្រួសារ ឬស្មើនឹង ០,៤៨% ប្រើទឹកស្រះ និង២០២គ្រួសារ ឬស្មើនឹង ៩,៦% ប្រើទឹកព្រែកទេ។ ដូច្នេះ ភាគរយគ្រួសារពលរដ្ឋឃុំថ្មីដែលមានទឹកស្អាតប្រើប្រាស់ស្មើនឹង ៨០,៩៥%។ គ្រួសារពលរដ្ឋឃុំថ្មីដែលទំលាប់បរិភោគទឹកស្អាតមានចំនួន ១.៩៩៧គ្រួសារ ឬស្មើនឹង ៩៤,៨៧% ក្នុងនោះ ១.២៦០គ្រួសារ ឬស្មើនឹង ៥៩,៨៦% ប្រើឧបករណ៍ចម្រោះទឹក និង៧៣៧គ្រួសារ ឬស្មើនឹង ៣៥,០១% បានប្រើទឹកឆ្អិនដាំពុះ។ បើតាមឯកសារព័ត៌មានស្តីពីស្ថានភាពឃុំកន្ទួតឆ្នាំ ២០១៤ វិញ នៅទូទាំងឃុំមានអណ្តូងស្នប់ចំនួន ៣៨អណ្តូង អណ្តូងដីកមានការពារ ៤៥អណ្តូង និងអណ្តូងដីកគ្មានការពារ ៦២អណ្តូង។ ប្រជាពលរដ្ឋក្នុងឃុំកន្ទួតចំនួន ៤៣១ គ្រួសារ ឬស្មើនឹង ២៩,០៦% ប្រើប្រាស់ទឹកអណ្តូងស្នប់, ៣៥៨គ្រួសារ ឬស្មើនឹង ២៤,១៤% ប្រើអណ្តូងដីកមានការពារ, ៤០គ្រួសារ ឬស្មើនឹង ២,៧% ប្រើទឹកភ្លៀងមានការពារ, ៤៩៧គ្រួសារ ឬស្មើនឹង ៣៣,៥១% ប្រើអណ្តូងដីកគ្មានការពារ, និង១៥៧គ្រួសារ ឬស្មើនឹង ១០,៥៩% ប្រើទឹកព្រែកទេ។ ដូច្នេះ ភាគរយគ្រួសារពលរដ្ឋឃុំកន្ទួតដែលមានទឹកស្អាតប្រើប្រាស់ស្មើនឹង ៥៥,៩%។ គ្រួសារពលរដ្ឋឃុំកន្ទួតដែលទំលាប់បរិភោគទឹកស្អាតមានចំនួន ៨២៥គ្រួសារ ឬស្មើនឹង ៥៥,៦៣% ក្នុងនោះ ៧០គ្រួសារ ឬស្មើនឹង ៤,៧២% ប្រើទឹកម៉ាស៊ីនឬទឹកបរិសុទ្ធ, ៨៧គ្រួសារ ឬស្មើនឹង ៥,៨៧% ប្រើឧបករណ៍ចម្រោះទឹក និង៦៦៨គ្រួសារ ឬស្មើនឹង ៤៥,០៤% បានប្រើទឹកឆ្អិនដាំពុះ (តារាង៥-៤១)។

តារាង៥-៤១៖ ស្ថានភាពនៃការប្រើប្រាស់ទឹក (ឯកសារព័ត៌មានស្តីពីស្ថានភាពឃុំថ្មីឆ្នាំ២០១៣ និងឃុំកន្ទួតឆ្នាំ២០១៤)

ឃុំ	ប្រភពទឹក	ការប្រើប្រាស់ទឹក	ស្ថានភាពអនាម័យ	ចំនួន	ភាគរយ
ថ្មី	អណ្តូងស្នប់			៧៩	
	អណ្តូងដីកគ្មានការពារ			២៩	
	ស្រះ			១	
	ព្រែក អូរ អាងទំនប់ទឹក			ព្រែកទេ	
		អណ្តូងស្នប់		១.៧០៤គ្រួសារ	៨០,៩៥%
		អណ្តូងដីកគ្មានការពារ		១៨៩គ្រួសារ	៨,៩៨%
		ស្រះ		១០គ្រួសារ	០,៤៨%
		ព្រែក អូរ អាងទំនប់ទឹក		២០២គ្រួសារ	៩,៦%
			បរិភោគទឹកស្អាតសរុប	១.៩៩៧គ្រួសារ	៩៤.៨៧%

Draft

			ប្រើឧបករណ៍ចម្រោះ	១.២៦០គ្រួសារ	៥៩,៨៦%
			ទឹកឆ្អិន	៧៣៧គ្រួសារ	៣៥,០១%
	អណ្តូងស្នប់			៣៨	
	អណ្តូងជីកមានការពារ			៤៥	
	អណ្តូងជីកគ្មានការពារ			៦២	
	ទឹកភ្លៀងមានការពារ			តាមផ្ទះ	
	ព្រែក អូរ អាងទំនប់ទឹក			ព្រែកទេរ	
		អណ្តូងស្នប់		៤៣១គ្រួសារ	២៩,០៦%
		អណ្តូងជីកមានការពារ		៣៥៨គ្រួសារ	២៤,១៤%
កន្ទួត		ទឹកភ្លៀងមានការពារ		៤០គ្រួសារ	២,៧%
		អណ្តូងជីកគ្មានការពារ		៤៩៧គ្រួសារ	៣៣,៥១%
		ព្រែក អូរ អាងទំនប់ទឹក		១៥៧គ្រួសារ	១០,៥៩%
			បរិភោគទឹកស្អាតសរុប	៨២៥គ្រួសារ	៥៥,៦៣%
			ទឹកសុទ្ធ	៧០គ្រួសារ	៤,៧២%
			ប្រើឧបករណ៍ចម្រោះ	៨៧គ្រួសារ	៥,៨៧%
			ទឹកឆ្អិន	៦៦៨គ្រួសារ	៤៥,០៤%

១៩២. **ការប្រើប្រាស់ថាមពលសម្រាប់បំភ្លឺ និងចំអិនអាហារ៖** សម្រាប់ប្រជាពលរដ្ឋនៃបាំថ្មី ដែលរស់នៅតំបន់ខាងក្នុងឆ្ងាយពីផ្លូវជាតិ គឺមិនមានបណ្តាញអគ្គិសនីរដ្ឋ ឬឯកជនចូលទៅដល់ឡើយ។ តាមការវិភាគទិន្នន័យក្នុងឯកសារព័ត៌មានស្តីពីស្ថានភាពឃុំថ្មីឆ្នាំ ២០១៣ បង្ហាញថា គ្មានផ្ទះប្រជាពលរដ្ឋណាមួយ ដែលមានតភ្ជាប់នូវបណ្តាញអគ្គិសនីសម្រាប់បំភ្លឺទាល់តែសោះ។ ភាគច្រើនផ្ទះពួកគាត់ចំនួន ១.៤៥៨ខ្នង (៧៣,៤១%) ប្រើប្រាស់អំពូលអាគុយ និងមានផ្ទះចំនួនតែ ៥ខ្នង (០,២៥%) ប៉ុណ្ណោះប្រើប្រាស់បន្ទះសូឡាទាញយកថាមពលព្រះអាទិត្យសម្រាប់បំភ្លឺនៅពេលយប់ (ដ្យាក្រាម៥-២៥)។ ដោយឡែកនៅក្នុងឃុំកន្ទួតវិញ ដោយសារពួកគាត់រស់នៅតាមបណ្តោយផ្លូវជាតិលេខ៧ ដូចនេះគឺមានបណ្តាញអគ្គីសនីរដ្ឋទៅដល់ ប៉ុន្តែអ្នកដែលមានលទ្ធភាពតភ្ជាប់បណ្តាញនេះ មានចំនួនតិចតួចបំផុត។ យោងតាមទិន្នន័យក្នុងឯកសារព័ត៌មានស្តីពីស្ថានភាពឃុំកន្ទួតឆ្នាំ ២០១៤ បង្ហាញថា មានផ្ទះរបស់ពលរដ្ឋចំនួនតិចតួចគឺ ១៨៣ខ្នង ស្មើនឹង ១៤,៨% មានលទ្ធភាពតបណ្តាញអគ្គិសនីប្រើប្រាស់។ ក្រៅពីនេះ ផ្ទះពលរដ្ឋភាគច្រើនគឺ ៧៤៧ខ្នង ស្មើនឹង ៦០,៤% ប្រើអំពូលអាគុយសម្រាប់បំភ្លឺនៅពេលយប់ (ដ្យាក្រាម៥-២៥)។ យោងតាមលទ្ធផលនៃការសម្ភាសន៍គ្រួសារប្រជាពលរដ្ឋក្នុងឃុំទាំងពីរ បានឲ្យដឹងថា មានប្រជាពលរដ្ឋ ៧៩% ប្រើភ្លើងអាគុយ ១១.១% ប្រើចង្កៀងប្រេងកាត ៥.៦% មានភ្លើងរដ្ឋប្រើ និង៤,៣% ផ្សេងទៀតប្រើពិលសម្រាប់បំភ្លឺនៅពេលយប់។

ដ្យាក្រាម៥-២៥៖ ការប្រើប្រាស់ថាមពលសម្រាប់បំភ្លឺនៅពេលយប់ (ឯកសារព័ត៌មានស្តីពីស្ថានភាពឃុំថ្មីឆ្នាំ ២០១៣ និងឃុំកន្ទួតឆ្នាំ២០១៤)



១៩៣. យោងតាមលទ្ធផលនៃការសម្ភាសន៍គ្រួសារប្រជាពលរដ្ឋក្នុងឃុំទាំងពីរ បានឲ្យដឹងថា ពួកគាត់ស្ទើរទាំងអស់គ្នាប្រើអុស ឬធ្យូងសម្រាប់ការចំអិនអាហារ។ ប្រជាជនក្នុងតំបន់នោះ ៨៨,៥% ប្រើអុសជាប្រភពថាមពលសំខាន់ក្នុងការចំអិនម្ហូបអាហារ ហើយ១០,៤% ប្រើធ្យូង និងមានតែ ១% ប៉ុណ្ណោះដែលមានលទ្ធភាពប្រើហ្គាស។

១៩៤. **ការអប់រំ៖** ចំណែកឯការសិក្សាអប់រំនៅក្នុងឃុំទាំងពីរវិញ សិស្សានុសិស្សមានការលំបាកក្នុងការទទួលបាននូវការសិក្សាមួយខ្ពស់ ដោយសារតែមិនមានអនុវិទ្យាល័យនៅជិតភូមិរបស់គាត់ គឺមាននៅតែទីប្រជុំជនឃុំឯណោះ ដែលមានចម្ងាយជាមធ្យមប្រមាណជា ៥,៤គ.ម។ យោងតាមឯកសារព័ត៌មានស្តីពីស្ថានភាពឃុំថ្មីឆ្នាំ ២០១៣ បានឲ្យដឹងថា នៅក្នុងឃុំថ្មីមានមតេយ្យសាលា០២កន្លែង បឋមសិក្សាមានចំនួន ០៨ មាន២៥បន្ទប់ ស្មើនឹង ៥០ថ្នាក់ និងអនុវិទ្យាល័យមាន ០១ មាន០៥បន្ទប់ ស្មើនឹង០៥ថ្នាក់ ប៉ុន្តែមិនមានវិទ្យាល័យទេ។ ឯនៅក្នុងសៀវភៅឯកសារព័ត៌មានស្តីពីស្ថានភាពឃុំកន្ទួតឆ្នាំ២០១៤វិញ បានបង្ហាញថា ឃុំកន្ទួត មានមតេយ្យសាលាចំនួន ០១កន្លែង បឋមសិក្សាមានចំនួន ០៦ មាន២៤បន្ទប់ ស្មើនឹង ៤៦ថ្នាក់ អនុវិទ្យាល័យមាន ០១ មាន០៦បន្ទប់ ស្មើនឹង០៦ថ្នាក់ និងមានវិទ្យាល័យ០១ មាន០៧បន្ទប់ ស្មើនឹង ០៦ថ្នាក់។

១៩៥. ជាទូទៅសាលាបឋមសិក្សាមានស្ទើរគ្រប់ភូមិ ដែលផ្តល់ការសិក្សាដល់កុមាររហូតដល់ថ្នាក់ទី៦ និងមានចំងាយជាមធ្យមមួយគីឡូម៉ែត្រពីផ្ទះរបស់ប្រជាជន។ ប៉ុន្តែពួកគេត្រូវជួបប្រទះការលំបាកក្នុងការបន្តការសិក្សាដល់ថ្នាក់អនុវិទ្យាល័យ ម្យ៉ាងដោយសារតែជីវភាពខ្វះខាត ពួកគេត្រូវបោះបង់ចោលការសិក្សា ដើម្បីរកការងារធ្វើជួយសម្រួលដល់ជីវភាពក្នុងគ្រួសារ និងម្យ៉ាងទៀត គឺដោយសារតែសាលានៅឆ្ងាយពេកពិបាកក្នុងការធ្វើដំណើរផងដែរ។

១៩៦. ការសិក្សាវាយតម្លៃក៏បានរកឃើញដែរថា បើទោះជាភូមិស្ទើរទាំងអស់មានសាលាបឋមសិក្សានៅក្នុងភូមិរបស់ពួកគាត់ក៏ដោយ កត្តាខ្វះខាតគ្រូបង្រៀន និងការបង្រៀនមិនទៀងទាត់ បានបង្កជាឧបសគ្គរាំងស្ទះដល់ការសិក្សារបស់កុមារផងដែរ។ ប្រជាជនបានត្អូញត្អែរថា ការបោះបង់ការសិក្សាមួយចំនួនធំបណ្តាល

Draft

មកពីការខ្វះខាតគ្រូបង្រៀន និងមិនមានសាលាថ្នាក់អនុវិទ្យាល័យដែលនៅជិតភូមិរបស់ពួកគាត់ ជាហេតុដែលឪពុកម្តាយមិនហ៊ានបណ្តោយកូនគាត់ត្រូវធ្វើដំណើរពី៥គ.មទៅ១០គ.ម ដើម្បីទៅកាន់សាលាអនុវិទ្យាល័យដែលស្ថិតនៅក្នុងទីប្រជុំជនរបស់ឃុំនិមួយៗ។ លើសពីនេះទៅទៀត កុមារទាំងនោះប្រឈមនឹងការលំបាកយ៉ាងខ្លាំងលើមធ្យោបាយធ្វើដំណើរទៅកាន់សាលារៀននៅរដូវវស្សា ជាក់ស្តែងពេលដែលមានភ្លៀងធ្លាក់ខ្លាំង សិស្សនៅក្នុងភូមិក្រសាំងត្រូវបានខកខានមិនបានទៅរៀន ដោយសារតែភ្លៀងខ្លាំងពេកបណ្តាលឲ្យទឹកហូរកាត់ដាច់ផ្លូវធ្វើដំណើរជាដើម។

១៩៧. កំរិតអប់រំរបស់មេ និងសមាជិកគ្រួសារ៖ យោងតាមការធ្វើសម្ភាសន៍តាមភូមិបានបង្ហាញថា មេគ្រួសារនៅឃុំពាក់ព័ន្ធទាំងពីរដែលមិនបានរៀនសូត្រសោះមាន២៥,៩%, មុនមត្តេយ្យសិក្សាមាន៣,១%, ត្រឹមមត្តេយ្យសិក្សាមាន ៣,១%, មិនចប់បឋមសិក្សាមាន ៥១,២%, ចប់បឋមសិក្សាមាន ៤,៩%%, មិនចប់អនុវិទ្យាល័យ មាន ៨,៦%, ចប់អនុវិទ្យាល័យមាន ០,៦%, មិនចប់វិទ្យាល័យមាន ១,៩%, ចប់វិទ្យាល័យមាន ០,៦%, មិនចប់មហាវិទ្យាល័យ -គ្មាន, ចប់មហាវិទ្យាល័យ -គ្មាន, មិនចប់វគ្គបណ្តុះបណ្តាលវិជ្ជាជីវៈ- គ្មាន, ចប់វគ្គបណ្តុះបណ្តាលវិជ្ជាជីវៈ -គ្មាន (ដ្យាក្រាម៥-២៦)។ ចំណែកឯសមាជិក គ្រួសារដែលមិនបានរៀនសូត្រសោះមាន ២០,៦%, មុនមត្តេយ្យសិក្សាមាន ៣,៧%, ត្រឹមមត្តេយ្យសិក្សាមាន ៤,៦%, មិនចប់បឋមសិក្សាមាន ៥៣,១%, ចប់បឋមសិក្សាមាន ៤,៨%, មិនចប់អនុវិទ្យាល័យមាន ៨,៩%, ចប់អនុវិទ្យាល័យមាន ១,៤%, មិនចប់វិទ្យាល័យមាន ១,៥%, ចប់វិទ្យាល័យមាន ១,១%, មិនចប់មហាវិទ្យាល័យមាន ០,១%, ចប់មហាវិទ្យាល័យមាន ០,១%, មិនចប់វគ្គបណ្តុះបណ្តាលវិជ្ជាជីវៈ -គ្មាន, ចប់វគ្គបណ្តុះបណ្តាលវិជ្ជាជីវៈ -គ្មាន (ដ្យាក្រាម៥-២៧)។

ដ្យាក្រាម៥-២៦៖ កម្រិតអប់រំរបស់មេគ្រួសារ (លទ្ធផលនៃការសម្ភាសន៍)

១៩៨. ដោយសារមូលហេតុដែលបង្កឲ្យមានការរាំងស្ទះដល់ការសិក្សា ដូចបានរៀបរាប់ខាងលើទាំងនេះហើយ បើយើងពិនិត្យមើលពីកំរិតការសិក្សាអប់រំរបស់សមាជិកក្នុងគ្រួសារនិមួយៗឃើញថា ពួកគេមិនបានរៀនខ្ពង់ខ្ពស់នោះទេ។ ៥៣,១% នៃប្រជាជននៅតំបន់នោះរៀនមិនបានចប់បឋមសិក្សា, ២០,៦% មិនដែលបានទទួលការសិក្សាទាល់តែសោះ, ៨,៩% រៀនមិនបានចប់ថ្នាក់អនុវិទ្យាល័យ, ៤,៨% បានរៀនចប់ថ្នាក់បឋមសិក្សា, ៤,៦% រៀនត្រឹមថ្នាក់មត្តេយ្យសិក្សា, ៣,៧% រៀនបានថ្នាក់មុនមត្តេយ្យ, ១,៥% រៀនមិន

បានចប់វិទ្យាល័យ, ១,៤% រៀនចប់អនុវិទ្យាល័យ និងមានតែ០,១% ប៉ុណ្ណោះដែលបានតស៊ូរៀនដល់ថ្នាក់មហាវិទ្យាល័យ (ដ្យាក្រាម៥-២៧)។

ដ្យាក្រាម៥-២៧៖ កម្រិតអប់រំរបស់សមាជិកគ្រួសារ (លទ្ធផលនៃការសម្ភាសន៍)

១៩៩. លទ្ធផលនៃការសិក្សាវាយតម្លៃបានបង្ហាញថា កុមារទាំងប្រុសទាំងស្រី អាយុចាប់ពី១៤ឆ្នាំឡើងទៅមានអត្រាបោះបង់ចោលនូវការសិក្សាខ្ពស់ខ្លាំង (៧១,៣%) នៅសល់តែចំនួនតិចតួច (២៨,៧%) ប៉ុណ្ណោះដែលនៅរៀនបន្ត។ មូលហេតុនៃការបោះបង់ចោលនូវការសិក្សានេះ មានដូចជា៖ ការរៀបការ គឺមានអត្រាខ្ពស់ជាងគេ (៤១,២%) បន្ទាប់មកគឺដើម្បីចូលធ្វើការងាររកកម្រៃជួយសម្រួលដល់បន្ទុកគ្រួសារ (២១,៦%) (មូលហេតុនេះគឺដូចគ្នាជាមួយនឹងលទ្ធផលពីការធ្វើការពិភាក្សាជាក្រុមដែរ), ដោយសារសាលានៅឆ្ងាយពេក (១៦,៦%), ការខ្វះខាតថវិកាក្នុងការបន្តការសិក្សា (១០,៣%) ហើយ ១០,១% ដោយសារតែនៅក្មេងពេកមិនទាន់គ្រប់អាយុចូលរៀន ឬចាស់ពេក និង០,២% ដោយសារមានជម្ងឺ (ដ្យាក្រាម៥-២៨)។

ដ្យាក្រាម៥-២៨៖ មូលហេតុនៃការបោះបង់ចោលការសិក្សា (លទ្ធផលនៃការសម្ភាសន៍)



១៩៩. យោងតាមការវិភាគទិន្នន័យក្នុងឯកសារព័ត៌មានស្ដីពីស្ថានភាពឃុំថ្មីឆ្នាំ ២០១៣ បានឲ្យដឹងថា នៅក្នុងឃុំទាំងមូលមានកុមារដែលមានអាយុចាប់ពី ៦ ដល់ ១១ឆ្នាំ ចំនួន ១.៩២៣នាក់ ប៉ុន្តែទៅរៀននៅសាលាបឋមសិក្សាបានត្រឹមតែ ១.៧២៤នាក់ ឬស្មើនឹង ៨៩,៦៥% ប៉ុណ្ណោះ នៅសល់ប្រមាណជា ១៩៩នាក់

Draft

(១០,៣៥%) ទៀតមិនបានទៅរៀន ក្នុងនោះ ១១៥នាក់ជាកុមារា និង ៨៤នាក់ជាកុមារី។ កុមារដែលមានអាយុចាប់ពី ១២ ដល់ ១៤ឆ្នាំមានចំនួនសរុប ១.០១៣នាក់ ប៉ុន្តែទៅរៀនបានត្រឹមតែ ៩៥៨នាក់ ឬស្មើនឹង ៩៤,៥៧% ប៉ុណ្ណោះ (ក្នុងនោះ១៥៣នាក់ទៅរៀននៅអនុវិទ្យាល័យ និង ៨០៥នាក់រៀននៅបឋមសិក្សា) ហើយនៅសល់ប្រមាណជា ៥៥នាក់ (៥,៤៣%) ទៀតមិនបានទៅរៀន ក្នុងនោះ ១៨នាក់ជាកុមារា និង ៣៧នាក់ជាកុមារី។ ក្មេងជំទង់ដែលមានអាយុចាប់ពី ១៥ ដល់ ១៧ឆ្នាំមានចំនួន ៨៧៣នាក់ ប៉ុន្តែទៅរៀនបានត្រឹមតែ ២១១នាក់ ឬស្មើនឹង ២៤,១៧% ប៉ុណ្ណោះ (ក្នុងនោះ៤៨នាក់ទៅរៀននៅវិទ្យាល័យ និង ១៦៣នាក់រៀននៅអនុវិទ្យាល័យ) នៅសល់ប្រមាណជា ៦៦២នាក់ (៧៥,៨៣%) ទៀតមិនបានទៅរៀន ក្នុងនោះ ៣៣៤នាក់ជាក្មេងប្រុស និង ៣២៨នាក់ជាក្មេងស្រី។ យុវជនដែលមានអាយុចាប់ពី ១៨ ដល់ ២៤ ឆ្នាំមានចំនួន ១.០១០នាក់ ប៉ុន្តែទៅរៀនបានត្រឹមតែ ២៨នាក់ ឬស្មើនឹង ២,៧៧% ប៉ុណ្ណោះ (ក្នុងនោះ១២ នាក់ជានារី) នៅសល់ប្រមាណជា ៩៨២នាក់ (៩៧,២៣%) ទៀតមិនបានទៅរៀន។

២០០. យោងតាមការវិភាគទិន្នន័យក្នុងឯកសារព័ត៌មានស្តីពីស្ថានភាពឃុំកន្ទួតឆ្នាំ ២០១៤ បានឲ្យដឹងថា នៅក្នុងឃុំទាំងមូលមានកុមារដែលមានអាយុចាប់ពី ៦ ដល់ ១១ឆ្នាំចំនួន ៨៨៦នាក់ ប៉ុន្តែទៅរៀននៅសាលាបឋមសិក្សាបានត្រឹមតែ ៧៧៦នាក់ ឬស្មើនឹង ៨៧,៥៨% ប៉ុណ្ណោះ នៅសល់ប្រមាណជា ១១០នាក់ (១២,៤២%) ទៀតមិនបានទៅរៀន ក្នុងនោះ ៦៨នាក់ជាកុមារា និង ៤២នាក់ជាកុមារី។ កុមារដែលមានអាយុចាប់ពី ១២ ដល់ ១៤ឆ្នាំមានចំនួនសរុប ៥៦១នាក់ ប៉ុន្តែទៅរៀនបានត្រឹមតែ ៤៨៥នាក់ ឬស្មើនឹង ៨៦,៤៥% ប៉ុណ្ណោះ (ក្នុងនោះ១០០នាក់ទៅរៀននៅអនុវិទ្យាល័យ និង ៣៨៥នាក់រៀននៅបឋមសិក្សា) នៅសល់ប្រមាណជា ៧៦នាក់ (៥,៤៣%) ទៀតមិនបានទៅរៀន ក្នុងនោះ ៣៨នាក់ជាកុមារា និង ៣៨ នាក់ជាកុមារី។ នៅក្នុងឯកសារព័ត៌មានស្តីពីស្ថានភាពឃុំឆ្នាំ ២០១៤នេះ មិនមានទិន្នន័យស្តីពីការសិក្សារបស់ក្មេងជំទង់ដែលមានអាយុចាប់ពី ១៥ ដល់ ១៧ឆ្នាំ និងយុវជនដែលមានអាយុចាប់ពី ១៨ ដល់ ២៤ឆ្នាំឡើយ។

២០១. **ស្ថានភាពអ្នកមិនចេះអក្សរ៖** យោងតាមការវិភាគទិន្នន័យក្នុងឯកសារព័ត៌មានស្តីពីស្ថានភាពឃុំថ្មីឆ្នាំ ២០១៣ បានឲ្យដឹងថា នៅក្នុងចំណោមប្រជាពលរដ្ឋដែលមានអាយុពី ១៥ ដល់ ៤៥ឆ្នាំ សរុប ៤.២៦០ នាក់ (ស្រី ២.១១៥នាក់) មានអ្នកដែលមិនចេះអក្សរ ៤៧២នាក់ ឬស្មើនឹង ១១,០៨% (ស្រី ២៣៥នាក់) ក្នុងនោះពលរដ្ឋស្ថិតក្នុងចន្លោះអាយុពី ១៥ ទៅ ១៧ឆ្នាំ មានអ្នកមិនចេះអក្សរ ៤៦នាក់ ឬស្មើនឹង ១,០៨% (ស្រី ២៧នាក់), ចន្លោះពី ១៨ ទៅ ២៤ឆ្នាំមាន ៥៩នាក់ ឬស្មើនឹង ១,៣៨% (ស្រី ៣៦នាក់), ចន្លោះពី ២៥ ទៅ ៣៥ឆ្នាំមាន ១៥៣នាក់ ឬស្មើនឹង ៣,៥៩% (ស្រី ៧៨នាក់), ចន្លោះពី ៣៦ ទៅ ៤៥ឆ្នាំមាន ២១៤នាក់ ឬស្មើនឹង ៥,០២% (ស្រី ៩៤នាក់)។ ដូចគ្នានេះដែរ តាមការវិភាគទិន្នន័យក្នុងឯកសារព័ត៌មានស្តីពីស្ថានភាពឃុំកន្ទួតឆ្នាំ ២០១៤ បានបង្ហាញថា នៅក្នុងចំណោមប្រជាពលរដ្ឋដែលមានអាយុពី ១៥ ដល់ ៤៥ឆ្នាំ សរុប ៣.៣១៤នាក់ មានអ្នកដែលមិនចេះអក្សរ ៤៧៦នាក់ ឬស្មើនឹង ១៤,៣៦% ក្នុងនោះពលរដ្ឋស្ថិតក្នុងចន្លោះអាយុពី ១៥ ទៅ ១៧ឆ្នាំ មានអ្នកមិនចេះអក្សរ ៥១នាក់ ឬស្មើនឹង ១,៥៤%, ចន្លោះពី ១៨ ទៅ ២៤ឆ្នាំមាន ១២៩នាក់ ឬស្មើនឹង ៣,៨៩%, ចន្លោះពី ២៥ ទៅ ៤៥ឆ្នាំមាន ២៩៦នាក់ ឬស្មើនឹង

Draft

៨,៩៣%។ នៅក្នុងឯកសារព័ត៌មានស្តីពីស្ថានភាពឃុំឆ្នាំ ២០១៤នេះ មិនមានទិន្នន័យស្តីពីអ្នកមិនចេះអក្សរ ភេទស្រីឡើយ (ដ្យាក្រាម៥-២៩)។

ដ្យាក្រាម៥-២៩៖ ស្ថានភាពអនក្ខរជន (ឯកសារព័ត៌មានស្តីពីស្ថានភាពឃុំថ្មីឆ្នាំ២០១៣ និងឃុំកន្ទួតឆ្នាំ ២០១៤)



២០២. **សេវាសុខភាព និងសុខមាលភាពសាធារណៈ ៖** នៅក្នុងឃុំនីមួយៗមានមណ្ឌលសុខភាពមួយ។ បញ្ហាសុខភាពនៅក្នុងសហគមន៍នេះមិនមានអ្វីចោទជាបញ្ហាធ្ងន់ធ្ងរនោះទេ។ ជម្ងឺដែលកើតឡើងញឹកញាប់នោះគឺជម្ងឺរាគ គ្រុនពោះវៀន គ្រុនចាញ់ រលាកពោះវៀន ផ្តាសាយ។ល។ ប៉ុន្តែ នៅពេលសមាជិកគ្រួសារណាម្នាក់មានជម្ងឺធ្ងន់ ប្រជាជនមានការលំបាកក្នុងការស្វែងរកសេវាសុខភាពសាធារណៈរបស់រដ្ឋ ពីព្រោះតែមណ្ឌលសុខភាព ឬមន្ទីរពេទ្យបង្អែកដែលអាចព្យាបាលជម្ងឺធ្ងន់ៗបាន ស្ថិតនៅឆ្ងាយពីភូមិខ្លាំងពេក ដូច្នេះប្រជាជនបានស្វែងរកសេវាព្យាបាលឯកជនដែលស្ថិតក្នុងភូមិ ប៉ុន្តែពួកគាត់ត្រូវបានចំណាយប្រាក់បង់ថ្លៃសេវាសុខភាពទាំងនេះថ្លៃជាងសេវាព្យាបាលរដ្ឋ។

២០៣. **ស្ថានភាពសុខភាព:** ប្រជាជនក្នុងតំបន់ពាក់ព័ន្ធនោះ ៥៦,៨% មានជម្ងឺញឹកញាប់, ២៧,២% មានជម្ងឺម្តងម្កាល, ២,៥% តែងតែឈឺជាប្រចាំក្នុងកំឡុងពេល៥ឆ្នាំចុងក្រោយ និងមានតែ ១៣,៦% ប៉ុណ្ណោះដែលមានសុខភាពល្អធម្មតា។ ជម្ងឺដែលប្រជាពលរដ្ឋរស់នៅក្នុងឃុំពាក់ព័ន្ធទាំងពីរជួបប្រទះញឹកញាប់ជាងគេគឺ ២៦,៩% ជាជម្ងឺរាគរូស និងគ្រុនពោះវៀន, ២០,៣% ជាជម្ងឺគ្រុនចាញ់, ១៩% ជាជម្ងឺរលាកក្រពះពោះវៀន, ១៥,៥% ជាជម្ងឺផ្តាសាយ គ្រុនក្តៅ ជម្ងឺផ្លូវដង្ហើម, ៦,៨% ជាជម្ងឺសន្លាក់ដៃជើង, ៤,៩% ជាជម្ងឺភ្នែក ច្រមុះ ត្រចៀក បំពង់ក, ៤,៦% ជាជម្ងឺបេះដូង លើសឈាម ស្ទះសរសៃឈាម, ១,៣% ជាជម្ងឺទឹកនោមផ្អែម និង០,៧% ជាជម្ងឺរបេង (ដ្យាក្រាម៥-៣០)។ ជម្ងឺគ្រុនចាញ់នៅតែជាបញ្ហាគួរឲ្យចាប់អារម្មណ៍ ទោះបីអ្នកខ្លះមិនបានចូលព្រៃក៏ដោយ។ ការិយាល័យសុខាភិបាល ឬបុគ្គលិកសុខភាពបានផ្សព្វផ្សាយនូវវិធានការការពារជម្ងឺគ្រុនចាញ់នេះ ព្រមទាំងជម្ងឺឆ្លងផ្សេងៗ និងអនាម័យដល់ភូមិកររបស់ប្រជាពលរដ្ឋ និងនៅតាមសាលារៀន ពិសេសនៅពេលមានទឹកជំនន់ទៀតផង។

Draft

ដ្យាក្រាម៥-៣០៖ ជម្ងឺដែលប្រជាពលរដ្ឋក្នុងតំបន់ពាក់ព័ន្ធឈឺញឹកញាប់ក្នុងរយៈពេល៥ឆ្នាំចុងក្រោយ (លទ្ធផលនៃការសម្ភាសន៍)



២០៤. ចម្ងាយផ្លូវទៅកាន់មណ្ឌលសុខភាព៖ នៅក្នុងឃុំកន្ទួត និងឃុំថ្មីសុទ្ធតែមានមណ្ឌលសុខភាពទាំងអស់ ប៉ុន្តែមណ្ឌលសុខភាពទាំងនោះស្ថិតនៅទីប្រជុំជនឃុំ ដែលឆ្ងាយពីភូមិពាក់ព័ន្ធទាំងនោះ ដូចជាភូមិអាលចស្ថិតនៅចម្ងាយ ១០គ.មពីមណ្ឌលសុខភាព និង៣០គ.មពីមន្ទីរពេទ្យបង្អែកខេត្តក្រចេះ, ភូមិប្បៀរមានចម្ងាយ ២៥គ.មពី មណ្ឌលសុខភាព និង៥៣គ.មពីមន្ទីរពេទ្យបង្អែកខេត្តក្រចេះ, ភូមិក្រសាំងមានចម្ងាយ ១គ.មពីមណ្ឌលសុខភាព និង៣៦គ.មពីមន្ទីរពេទ្យបង្អែកខេត្តក្រចេះ, ភូមិថ្មីមានចម្ងាយ ៥គ.មពីមណ្ឌលសុខភាព និង ៣២,៥ គ.មពីមន្ទីរពេទ្យបង្អែកខេត្តក្រចេះ ឯភូមិស្វាយជ្រុំវិញមានចម្ងាយ ៨គ.មពីមណ្ឌលសុខភាព និង៣៦គ.មពី មន្ទីរពេទ្យបង្អែកខេត្តក្រចេះ។ នៅក្នុងភូមិទាំងនេះមានពេទ្យឯកជន ដែលស្ថិតនៅក្នុងភូមិតែម្តង ប៉ុន្តែពេទ្យឯកជននេះអាចព្យាបាលបានតែជម្ងឺស្រាលៗ ហើយយកតម្លៃសេវាព្យាបាលខ្ពស់។

២០៥. តាមលទ្ធផលនៃការសម្ភាសន៍បានឲ្យដឹងថា នៅពេលមានសមាជិកក្នុងគ្រួសារណាម្នាក់មានជម្ងឺ ពួកគាត់តែងតែទៅរកសេវាកម្មគ្លីនិកសុខភាពឯកជន ឬមណ្ឌលសុខភាព ឬមន្ទីរពេទ្យដែលស្ថិតនៅចម្ងាយផ្សេងៗគ្នាពីផ្ទះរបស់ពួកគាត់។ ដើម្បីទៅកាន់គ្លីនិកឯកជន ប្រជាពលរដ្ឋប្រមាណជា ២៦,៤% ត្រូវធ្វើដំណើរចម្ងាយតិចជាង ២០០ម, ១៦% ចម្ងាយ ០,៥គ.ម, ១៥,១% ចម្ងាយពី ១-២គ.ម, ១៣,២% ចម្ងាយ ពី ៣-៤គ.ម, ១,៩% ចម្ងាយពី៥-៦គ.ម និង ពួកគាត់ភាគច្រើនដល់ទៅ ២៧,៤% ត្រូវធ្វើដំណើរឆ្ងាយលើសពី ៦គ.ម (ឧបសម្ព័ន្ធ៥-៦ តារាង១៨)។ ឯការទៅកាន់មណ្ឌលសុខភាព ឬមន្ទីរពេទ្យវិញ ពួកគាត់ ១៤,៥% ត្រូវធ្វើដំណើរចម្ងាយ១-៣គ.ម, ៩,៧% ចម្ងាយពី ៤-៦គ.ម, ៣,៤% ចម្ងាយពី ៧-៩គ.ម, ៤,៨% ចម្ងាយពី ១០-១២គ.ម, ៦,៩% ចម្ងាយពី ១៣-១៥គ.ម និងពួកគាត់ដល់ទៅ ៦០,៧% ត្រូវធ្វើដំណើរចម្ងាយលើសពី ១៦គ.ម (ឧបសម្ព័ន្ធ៥-៦ តារាង១៩)។ ពួកគាត់ភាគច្រើន (៨៥,២%) បានប្រើមធ្យោបាយធ្វើដំណើរទៅកាន់មណ្ឌលសុខភាព/មន្ទីរពេទ្យដោយម៉ូតូ, ៥,៦% ដោយថ្មើរជើង, ៤,៣% ដោយកង់, ២,៥% ដោយរថយន្តឈ្នួល និង២,៥% ដោយគោយន្ត (ឧបសម្ព័ន្ធ៥-៦ តារាង២០)។ ដើម្បីទៅរកសេវាសុខភាព ប្រជាពលរដ្ឋ

២១,៦% បានចំណាយរយៈពេលតិចជាង១៥នាទី, ២១,៦% ប្រើពេលពី១៦-៣០នាទី, ៨% ប្រើពេលពី៣១-៤៥នាទី, ១៤,២% ប្រើពេលពី ៤៦-៦០នាទី និងភាគ ច្រើនដល់ទៅ ៣៤,៦% ប្រើពេលលើសពី១ម៉ោង (ឧបសម្ព័ន្ធ៥-៦ តារាង២១)។ ជាទូទៅពួកគាត់ ៣១,៧% ទទួលបានសេវាកម្មពិនិត្យសុខភាព, ៤៤,១% ទទួលបានការព្យាបាល និងថ្នាំ, ២២,២% ទទួលបានការចាក់វ៉ាក់សាំង និង ២% ទទួលបានការវះកាត់ (ឧបសម្ព័ន្ធ៥-៦ តារាង២២)។

២០៦. **បង្គន់អនាម័យ៖** ចំពោះបញ្ហាអនាម័យវិញ នៅក្នុងតំបន់នេះចំនួនអ្នកមានបង្គន់អនាម័យប្រើប្រាស់នៅមានកម្រិតទាបនៅឡើយ។ ប្រជាជនដែលមានបង្គន់ប្រើប្រាស់ភាគច្រើនរស់នៅក្បែរផ្លូវជាតិ ឯប្រជាជនដែលរស់នៅឆ្ងាយពីទីប្រជុំជន និងឆ្ងាយៗពីផ្លូវជាតិពុំទាន់មានលទ្ធភាព ឬពុំមានការយកចិត្តទុកដាក់ក្នុងការសាងសង់បង្គន់សម្រាប់ប្រើប្រាស់នោះទេ។ ពុំមានព័ត៌មានដែលបង្ហាញថាមានក្រុមអប់រំសុខភាពណាមួយបានចុះទៅធ្វើការអប់រំផ្តល់ ឬបង្រៀនពីរបៀបសាងសង់បង្គន់អនាម័យដល់ប្រជាជនក្នុងសហគមន៍ឡើយ។ យោងតាមឯកសារព័ត៌មានស្តីពីស្ថានភាពឃុំឆ្នាំ ២០១៣ ប្រជាពលរដ្ឋក្នុងឃុំថ្មីប្រមាណជា ២០៧គ្រួសារ (៩,៨៣%) ប៉ុណ្ណោះដែលមានបង្គន់អនាម័យប្រើប្រាស់។ ភាគរយគ្រួសារដែលគ្មានបង្គន់អនាម័យប្រើប្រាស់មាន៖ ភូមិក្រសាំង ៨៩,៣%, ភូមិប្បៀរ ៩២,១%, ភូមិស្វាយជ្រុំ ៨៨,៧%, ភូមិថ្មី ៩៣,៩% និងភូមិត្នោត ៩១,៧%។ ដូចគ្នានេះដែរ ឯកសារព័ត៌មានស្តីពីស្ថានភាពឃុំឆ្នាំ ២០១៤ បានបញ្ជាក់ថា នៅក្នុងឃុំកន្ទួតមានប្រជាពលរដ្ឋតែ ១៥៩គ្រួសារ ឬស្មើនឹង ១០,៧២% ប៉ុណ្ណោះដែលមានបង្គន់អនាម័យ និង១៣៧គ្រួសារ ឬស្មើនឹង ៩,២៤% ប្រើប្រាស់បង្គន់មានបច្ចេកទេស ក្នុងនោះអ្នកភូមិអាលចប្រមាណជា ៨.៦% មានលទ្ធភាពប្រើប្រាស់បង្គន់មានបច្ចេកទេស ប៉ុន្តែនៅភូមិស្រែននដែលជាភូមិឧបសម្ព័ន្ធរបស់ភូមិអាលចវិញ មានគ្រួសារក្នុងចំនួនតិចតួចបំផុតដែលមានបង្គន់ប្រភេទនេះប្រើប្រាស់។

៥.៤.៥.១០ ស្ថានភាពនៃការគ្រប់គ្រងដីសម្បទានសេដ្ឋកិច្ច

២០៧. យោងតាមលទ្ធផលនៃការសិក្សាអំពីស្ថានភាពសង្គមកិច្ច (ស្តីពីវត្តមានដីសម្បទានសេដ្ឋកិច្ច) បង្ហាញថា មានប្រជាពលរដ្ឋ ៣០,២% ប៉ុណ្ណោះ ឆ្លើយថាដឹង ចំណែកឯ ៦៩,៨% ទៀតឆ្លើយថាមិនដឹង (ឧបសម្ព័ន្ធ៥-៦ តារាង៣៤)។ ពួកគាត់ ៣៧% ដឹងថាមានសន្តិសុខយាម តែគ្មានអាវុធ, ១៦,៧% ថាមានអាវុធ, ៩,៣% ថាគ្មានអ្នកយាម និង ៣៧% ផ្សេងទៀតឆ្លើយថាមិនដឹង (ឧបសម្ព័ន្ធ៥-៦ តារាង៣៥)។ ក្រោយពេលរាជរដ្ឋាភិបាលប្រគល់ដីសម្បទានសេដ្ឋកិច្ចនេះឲ្យទៅក្រុមហ៊ុនធ្វើការវិនិយោគ មានប្រជាពលរដ្ឋតែ ៤៨,៨% បានឆ្លើយថាបានចូលព្រៃប្រមូលអនុផលព្រៃឈើ តែមិនសូវញឹកញាប់, មាន ៤២,៦% ឆ្លើយថាមិនបានចូល និង ៧,៤% ថាចូលជាធម្មតា។ ដោយឡែកមានប្រជាពលរដ្ឋតែ ១,២% ប៉ុណ្ណោះ បានឆ្លើយថាចូលញឹកញាប់ជាងមុន (ឧបសម្ព័ន្ធ៥-៦ តារាង៣៦)។ ពាក់ព័ន្ធនឹងការចូលព្រៃរកផល និងអនុផលព្រៃឈើមានប្រជាពលរដ្ឋចំនួន ១៨,៥% ឆ្លើយថាមានការហាមឃាត់ និង ៣៥,២% ឆ្លើយថាគ្មានការហាមឃាត់ទេ. ៤០,៧% ផ្សេងទៀតឆ្លើយថាមិនបានចូល (ឧបសម្ព័ន្ធ៥-៦ តារាង៣៧)។ ក្នុងចំណោមអ្នកដែលបានចូលព្រៃទាំងអស់នោះ មាន ៥៩,៣% បានឆ្លើយថាគ្មានការបង់ប្រាក់ទេ មានតែ ៤,៣% ប៉ុណ្ណោះ ឆ្លើយថា បានបង់ប្រាក់ (ឧបសម្ព័ន្ធ៥-៦ តារាង៣៩)។

Draft

២០៨. ប្រជាជន ៦៤,២% បានបញ្ជាក់ថាក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ចបានហាមឃាត់មិនឲ្យប្រជាពលរដ្ឋចូលទៅរកធនធានធម្មជាតិក្នុងតំបន់នោះទេ ហើយពួកគាត់ ៤៥,៧% យល់ថាការហាមឃាត់បែបនេះប៉ះពាល់យ៉ាងខ្លាំងដល់ជីវភាពគ្រួសាររបស់ពួកគាត់ ព្រោះពួកគាត់មិនអាចរកចំណូលពីការអាស្រ័យផលធនធានទាំងនោះបានតទៅទៀត (ឧបសម្ព័ន្ធ៥-៦ តារាង៤៥)។ ដោយសារតែការហាមឃាត់របស់ក្រុមហ៊ុននេះហើយ ទើបប្រជាជននៅតំបន់ដីសម្បទានបានធ្វើដំណើរកាន់តែឆ្ងាយទៅៗរហូតដល់១០-៥៧គ.មពីភូមិ ដើម្បីរកធនធានធម្មជាតិ (ឧបសម្ព័ន្ធ៥-៦ តារាង៤១)។

២០៩. ប្រសិនបើតំបន់ដីសម្បទានមិនត្រូវបានហាមឃាត់ចំពោះការអាស្រ័យផល អនុផលព្រៃឈើទេនោះ ប្រជាជនក្នុងសហគមន៍ ៤២,៤% បានអះអាងថាពួកគាត់នឹងអាចទាញយកអុស ឬឈើសម្រាប់ធ្វើផ្សងពីក្នុងព្រៃ ១៨,៦%យល់ថាពួកគាត់នឹងរកគល់អុសធំៗ ហើយ១៨,៦%ទៀតនឹងបានច្រូតស្បូវ ៨,៥% នឹងរកសត្វព្រៃ ៥,៩%នឹងរកថ្នាំបុរាណ ៣,៤%នឹងរកវល្លិ ឬផ្តៅ ហើយ២,៥%យល់ថាគាត់នឹងរកជ័រទឹកបានពីក្នុងព្រៃនោះ (ឧបសម្ព័ន្ធ៥-៦ តារាង៣៨)។

២១០. ជំនួសឲ្យការបាត់បង់ឱកាសទទួលធនធានធម្មជាតិ ពួកគាត់ស្នើឲ្យក្រុមហ៊ុនផ្តល់អាទិភាពការងារដល់ប្រជាពលរដ្ឋដែលរស់នៅក្បែរតំបន់គំរោងឲ្យបានច្រើននាក់ ជៀសវាងការនាំយកកម្មករពីតំបន់ផ្សេងៗមកធ្វើការ។

៥.៤.៥.១១ ស្ថានភាពចំណាក-ចំណូលស្រុក

២១១. ថ្វីត្បិតតែមានការផ្លាស់ប្តូរមុខរបរនៅក្នុងសហគមន៍ តែប្រជាជន ៤៣,៥% នៅតែបន្តរស់នៅក្នុងសហគមន៍គេដដែល។ មានតែ ១៨,៧% តែប៉ុណ្ណោះដែលផ្លាស់ទីលំនៅទៅនៅក្នុងចំការរបស់គាត់ ដើម្បីធ្វើការងារកសិកម្ម និង១០,៨% ទៀតទៅស៊ីឈ្នួលលក់កំលាំងពលកម្មក្នុងការប្រមូលផលពីព្រៃឈើ។ ក្រៅពីការផ្លាស់ប្តូរទីលំនៅរបស់ប្រជាជនក្នុងតំបន់ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ក៏មានការធ្វើចំណូលស្រុកដើម្បីស្វែងរកដីកសិកម្ម និងឱកាសធ្វើជំនួញដែលមានការកើនឡើងគួរឲ្យកត់សំគាល់នៅតាមបណ្តោយផ្លូវជាតិលេខ៧ ធ្វើឲ្យតម្លៃដីលំនៅដ្ឋាន និងដីកសិកម្មមានតម្លៃកាន់តែកើនឡើង។ តាមលទ្ធផលនៃការធ្វើសម្ភាសន៍ ប្រជាពលរដ្ឋនៅក្នុងតំបន់ពាក់ព័ន្ធប្រមាណជា ៤៣,៥% បានប្រាប់ថាពួកគាត់បានកើតនៅទីនេះ, ១៩% ថាមកធ្វើការនៅទីនេះ, ១៨,៧% ថាមកស្វែងរកដីធ្វើកសិកម្ម, ១០,៨% ថាមកស៊ីឈ្នួលកាប់ឈើ, ៣,៨% ថាមកនេសាទត្រី, ៣,២% ថាមកកាប់អុស កាប់ឈើ និងដុតធ្យូង, ០,៦% ថាមកបរបាញ់សត្វ និងរកអនុផលព្រៃឈើ និង០,៣% ថាមកប្រមូលទិញអនុផលព្រៃឈើ (ឧបសម្ព័ន្ធ៥-៦ តារាង៤៦)។

៥.៤.៥.១២ សម្បត្តិវប្បធម៌ ទំនៀមទំលាប់ប្រពៃណី

២១២. ក្នុងចំណោមប្រជាពលរដ្ឋរស់នៅក្នុងឃុំកន្ទួត នឹងឃុំថ្មី មានជនជាតិដើមភាគតិច (ព្នង ខោញ និងកួយ) រស់នៅលាយឡំជាមួយជនជាតិខ្មែរ ហើយពួកគាត់ចេះនិយាយភាសាខ្មែរបានទាំងអស់គ្នា គោរពប្រពៃណីវប្បធម៌ និងសាសនាព្រះពុទ្ធដូចគ្នានឹងជនជាតិខ្មែរដែរ។ មិនត្រឹមតែប៉ុណ្ណោះ ពួកគាត់ថែមទាំងមានចំណងអាពាហ៍ពិពាហ៍ជាមួយនឹងជនជាតិខ្មែរទៀតផង។ ទំនៀមទំលាប់ប្រពៃណីនៃការរស់នៅរបស់ប្រជាជនក្នុងតំបន់នេះមានលក្ខណៈប្រហាក់ប្រហែលគ្នា នឹងប្រជាជនរស់នៅតំបន់ផ្សេងៗទៀតនៃស្រុកចិត្រ

Draft

បុរីជ័រ។ ឧទាហរណ៍ ដូចជាពិធីរៀបអាពាហ៍ពិពាហ៍ គឺធ្វើតាមប្រពៃណីខ្មែរ ដោយការតុបតែង ឬសំអាងការ ខ្លួនកូនក្រមុំការប្រគុំភ្លេងប្រពៃណី សែនព្រេន និងការអញ្ជើញភ្ញៀវចូលរួមជប់លៀងអាហារ ដើម្បីជូនពរនៅថ្ងៃមង្គលការរបស់កូនកំលោះកូនក្រមុំជាដើម។ តាមការរៀបរាប់របស់ប្រជាពលរដ្ឋតាមឃុំនិមួយៗ ដើម្បីទុកដាក់កូនចៅឱ្យមានគូស្រករពួកគាត់ត្រូវចំណាយលុយអស់ប្រហែល៤-៦លានរៀល។ ក្រៅពីនោះ ប្រជាពលរដ្ឋរស់នៅតំបន់នោះនៅមានជំនឿផ្សេងៗទៀត ដូចជា ការសែនចំការ និងការបន់ស្រន់ ការសែនព្រេនដាន់អារក្ស អ្នកតាទឹក អ្នកតាដី អ្នកតាភ្នំជាដើម។ នៅក្នុងតំបន់នេះ យើងមិនបានប្រទះឃើញសំណង់ប្រវត្តិសាស្ត្រ ប្រាសាទបុរាណ និងតំបន់ទេសចរណ៍ទេ ប៉ុន្តែប្រជាពលរដ្ឋបានឲ្យដឹងថា មានតំបន់ ព្រៃកប់ខ្មោច (បច្ចុប្បន្នហៅថាទីទួលសុវត្ថិភាព) មានទំហំជាង៣០ហិកតាស្ថិតនៅក្នុងតំបន់ដីសម្បទាន របស់ក្រុមហ៊ុនក្បែរភូមិឧបសម្ព័ន្ធស្រែនន។

៥.៤.៥.១៣ ទស្សនៈរបស់ប្រជាពលរដ្ឋចំពោះដីសម្បទានសេដ្ឋកិច្ច

Draft

២១៣. ប្រជាពលរដ្ឋភាគច្រើនយល់ឃើញថាការផ្តល់ដីសម្បទានសម្រាប់ការអភិវឌ្ឍន៍ ជាចេតនាល្អសម្រាប់ការវិនិយោគក្នុងតំបន់ និងការអភិវឌ្ឍន៍សម្រាប់រយៈពេលវែង។ ទោះជាយ៉ាងនេះក្តី ប្រជាពលរដ្ឋមួយចំនួនបានត្អូញត្អែរថាចាប់តាំងពីមានការឃាត់ឃាំងក្នុងការរុករកផល និងអនុផលព្រៃឈើក្នុងតំបន់ដែលពួកគាត់ធ្លាប់អាស្រ័យផលបានពីពេលមុនៗមក បណ្តាលអោយមានផលប៉ះពាល់ដល់ជីវភាពរស់នៅប្រចាំថ្ងៃ ហើយពួកគាត់ត្រូវបន្តស្វែងរកនៅតំបន់ឆ្ងាយៗផ្សេងទៀត។ ការមិនមានទុកដីបម្រុងសម្រាប់អ្នកភូមិព្រលែងគោក្របី ក៏ក្លាយជាការព្រួយបារម្ភណ៍ខ្លាំងមួយចំពោះការបាត់បង់ប្រាក់ចំណូលបន្ទាប់បន្សំប្រចាំគ្រួសារពីមុខរបរចិញ្ចឹមសត្វ ព្រោះវាបង្កឲ្យមានការលំបាកក្នុងការរកវាលស្មៅសម្រាប់គោក្របីរបស់ពួកគាត់។

៥.៤.៥.១៤ សំណូមពរ

២១៤. ឆ្លងកាត់ការពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋរួចមកពួកគាត់បានសុំសំណូមពរដូចខាងក្រោម៖

- ប្រជាពលរដ្ឋភូមិអាលចបានស្នើសុំឲ្យក្រុមហ៊ុនរក្សាទុកដីព្រៃរក្សាទុក ដែលតាមគោលការណ៍បានកំណត់ថាត្រូវរក្សាទុក ២០០មពីមាត់អូរឬព្រែក ដោយសារក្រុមហ៊ុនបានឈូសឆាយនៅសល់តែ ១០០ម ឬ ១៥០ម ពីមាត់អូរឬព្រែកប៉ុណ្ណោះ។
- ប្រជាពលរដ្ឋនៅភូមិស្រែននបានស្នើដល់ក្រុមហ៊ុនឲ្យទុកផ្លូវចូលទៅកាន់ទីទួលសុវត្ថិភាពឲ្យបានទូលាយបន្តិច (ទទឹង ៣០ម) ដើម្បីសំរាប់ការជន្លៀសប្រជាពលរដ្ឋ និងសត្វពាហនៈនៅពេលមានគ្រោះទឹកជំនន់។
- ប្រជាពលរដ្ឋនៅភូមិស្រែននសូមស្នើឲ្យជួយសាងសង់សាលាឆទានមួយក្នុងភូមិ សម្រាប់ការប្រារព្ធពិធីបុណ្យផ្សេងៗតាមប្រពៃណី ព្រោះបច្ចុប្បន្ននៅពេលមានបុណ្យទានម្តងៗ ប្រជាពលរដ្ឋនាំគ្នាធ្វើដំណើរទៅវត្តនៅឯភូមិអាលចចំងាយប្រមាណ ៧គ.ម។
- មេឃុំកន្ទួតស្នើសុំអណ្តូងទឹកមួយសម្រាប់អ្នកភូមិឧបសម្ព័នស្រែននប្រើប្រាស់ ដោយសំអាងលើការខូចឬពុលទឹកព្រែកទេរ ដែលបណ្តាលមកពីការប្រើប្រាស់ជី និងថ្នាំសម្លាប់សត្វល្អិតរបស់ក្រុមហ៊ុន។

- ប្រជាពលរដ្ឋទាំងអស់ស្នើឲ្យក្រុមហ៊ុនផ្តល់អាទិភាពការងារដល់ប្រជាពលរដ្ឋនៅក្បែរតំបន់គំរោងឲ្យបានច្រើននាក់ក្នុងគ្រួសារ ជៀសវាងការនាំយកពលករពីតំបន់ផ្សេងៗ។
- ស្នើសាងសង់ផ្លូវលំមួយខ្សែពីភូមិប្បៀរទៅដល់ភូមិស្វាយជ្រុំដែលមានចំងាយប្រមាណ ១៧គ.ម។
- ប្រជាពលរដ្ឋក្នុងភូមិក្រសាំងសុំផ្លូវលំមួយខ្សែ និងស្ពាន១កន្លែង តភ្ជាប់ពីភូមិក្រសាំងទៅដល់ភូមិត្នោតដែលមានចំងាយប្រមាណ ១គ.ម។
- ស្នើបង្កើតសាលារៀនសម្រាប់សិស្សតូចៗថ្នាក់ទី ១-២ ក្នុងភូមិក្រសាំង ដែលពួកគាត់ពិបាកដើរទៅរៀននៅសាលាឯភូមិត្នោត ពិសេសនៅពេលមានភ្លៀងធ្លាក់ខ្លាំងនៅតាមផ្លូវត្រូវទឹកហូរកាត់ខ្លាំង បង្កហានិភ័យដល់អាយុជីវិតកុមារទាំងនេះ។
- អ្នកភូមិស្វាយជ្រុំសុំផ្លូវលំមួយខ្សែក្នុងភូមិដែលមានចំងាយប្រមាណ ១,៥គ.ម ទទឹង ៤,៥ម។
- ប្រជាពលរដ្ឋក្នុងតំបន់នេះសំណូមពរដល់ក្រុមហ៊ុនកុំកាយចង្អូរព្រំដីដល់ក្លីស្រែរបស់ពួកគាត់។
- ស្នើជួយជីកអណ្តូងដាក់លូក្នុងភូមិ ក្នុងសមាមាត្រ ៥-៦គ្រួសារមានអណ្តូងមួយ។
- ស្នើជួសជុលសាលារៀន និងបន្ថែមថ្នាក់ឲ្យដល់ថ្នាក់ទី ៦ ដែលមានគ្រូគ្រប់គ្រាន់។
- ស្នើឲ្យមានមណ្ឌល ឬប៉ុស្តិ៍សុខភាពក្នុងភូមិ ជួយសំរួលចំពោះអ្នកដែលមានជីវភាពក្រីក្រ ដែលគ្មានមធ្យោបាយធ្វើដំណើរ ពិសេសនៅពេលមានអ្នកជំងឺឈឺធ្ងន់ ឬពេលស្ត្រីមានផ្ទៃពោះគ្រប់ខែ ត្រូវសំរាលកូនជាដើម។

៥.៤.៦ ប្រភេទ និងបរិមាណសំណល់រឹង រាវ និងឧស្ម័ន

Draft

២១៥. គម្រោងអភិវឌ្ឍន៍ដំណាំកសិ-ឧស្សាហកម្មរបស់ក្រុមហ៊ុន ដូទីសាយហ្គន-ប៊ិញហ្សឿក (អេស ប៊ី ខេ) បាន នឹងបញ្ចេញនូវប្រភេទ និងបរិមាណសំណល់ចំនួន០៣ ប្រភេទដូចខាងក្រោម៖

៥.៤.៦.១ សំណល់រឹង

២១៦. សំណល់រឹងដែលមិនអាចបំបែកបានតាមលក្ខណៈជីវសាស្ត្រៈ សំណល់នេះមានដូចជា សំបកដប, សំបកកំប៉ុង, ប្រអប់ ឬថង់ប្លាស្ទិក។ ចំនួនបុគ្គលិក និងកម្មករអចិន្ត្រៃយ៍របស់ក្រុមហ៊ុនក្នុងពេលបច្ចុប្បន្ន និងក្នុងពេលដំណើរការអាជីវកម្មប៉ាន់ស្មានថាមានចំនួន ៧០០នាក់ ហើយក្នុងម្នាក់ៗនឹងបញ្ចេញកាកសំណល់ចំនួន ៣០០ក្រាម/ថ្ងៃ។ ដូច្នេះ បរិមាណសំណល់រឹងដែលក្រុមហ៊ុននេះបញ្ចេញ ក្នុងមួយឆ្នាំ មានចំនួន ៣០០ក្រាម×៧០០នាក់×៣៦៥ថ្ងៃ = ៧៦,៦៥តោន/ឆ្នាំ។ ក្រៅពីសំណល់រឹងខាងលើនៅមានប្រភេទសំណល់រឹងផ្សេងៗទៀត មានដូចជា សំបកកង់ម៉ូតូ កង់ឡាន គ្រឿងបន្លាស់ចាស់ៗ ដែលប្រើការលែងកើត។ សំណល់នេះប៉ាន់ស្មានថាមានចំនួន១៥តោន/ឆ្នាំ។ ដូច្នេះ បរិមាណសំណល់រឹងដែលមិនអាចបំបែកបានតាមលក្ខណៈជីវសាស្ត្រ សរុបមានចំនួន ៩១,៦៥តោន/ឆ្នាំ។

២១៧. សំណល់រឹងដែលអាចបំបែកបានតាមលក្ខណៈជីវសាស្ត្រៈ សំណល់ទាំងនេះមានដូចជា សំណល់ពីផ្ទះបាយ។ ប៉ាន់ស្មានថាមនុស្សម្នាក់បញ្ចេញកាកសំណល់ចំនួន ៦០០ក្រាម/ថ្ងៃ។ ដូច្នេះ បរិមាណសំណល់រឹងដែលបញ្ចេញក្នុងមួយឆ្នាំមានចំនួន ៦០០ក្រាម×៧០០នាក់×៣៦៥ថ្ងៃ = ១៥៣,៣០តោន/ឆ្នាំ។ ប៉ុន្តែក្រោយពេលបំបែកធាតុ សំណល់នេះនឹងក្លាយទៅជាជីដែលមានប្រយោជន៍ដល់ការកែលម្អគុណភាពដី។

ក្រៅពីសំណល់រឹងដែលអាចបំបែកបានខាងលើ នៅមានសំណល់ដទៃទៀតដូចជាកាកសំណល់ឈើ (ជីវៈម៉ាស់)។ តាមការសិក្សាអំពីជីវៈម៉ាស់លើដី និងក្រោមដី (តារាង ៥.២៦) បង្ហាញថា ជីវៈម៉ាស់ក្រោមដីមានចំនួន ១៩,៧៣៥±៥,៣៨៣តោន/ហិកតា។ ដូច្នេះ នៅលើទំហំផ្ទៃដីអាជីវកម្មសរុប ៥.៤៣៦ហិកតា មានសំណល់ជីវៈម៉ាស់សរុបចោលនៅក្នុងដីចំនួន ១០៧.២៧៩,៤៦±២៩.២៦១,៩៨៨តោន។ សំណល់ទាំងនេះនឹងពុកផុយក្លាយជាមមោគផ្តល់ជីវជាតិដល់ដីនៅក្នុងរយៈពេលប្រមាណ ២-៤ឆ្នាំក្រោយ។ ចំណែកឯសំណល់ជីវៈម៉ាស់លើដីមានចំនួន ៦៥,៧៨៣±១៧,៩៤៣តោន/ហិកតា (គិតត្រឹមមែកទី១)។ តាមការប៉ាន់ស្មានជីវៈម៉ាស់ពីមែកទី១ រហូតដល់ចុងមានចំនួនប្រមាណ ១៩ភាគរយនៃជីវៈម៉ាស់សរុបលើដី ឬមានចំនួនប្រមាណ ១២,៥០តោន/ហិកតា។ ដូច្នេះ នៅលើទំហំផ្ទៃដីអាជីវកម្មសរុប ៥.៤៣៦ហិកតា មានសំណល់ជីវៈម៉ាស់លើដីសរុបចំនួន ៦៧.៩៥០តោន។

៥.៤.៦.២ សំណល់រាវ

២១៨. សំណល់រាវដែលបញ្ចេញចោលក្នុងម្នាក់ៗ មានចំនួន ៣០លីត្រ/ថ្ងៃ។ ដូច្នេះ បរិមាណសំណល់រាវដែលក្រុមហ៊ុននេះបញ្ចេញក្នុងមួយឆ្នាំមានចំនួន ៣០លីត្រ×៧០០នាក់×៣៦៥ថ្ងៃ = ៧.៦៦៥ម៣/ឆ្នាំ។

៥.៤.៦.៣ សំណល់ឧស្ម័ន

២១៩. ឧស្ម័នដែលបញ្ចេញពីសកម្មភាពគម្រោងនេះមាន ចំហេះប្រេងឥន្ធនៈរបស់គ្រឿងចក្រដែលប្រើសម្រាប់ឈូសព្រៃ និងការដុតព្រៃសម្អាតដី ដើម្បីដាំកៅស៊ូ។ ដើម្បីឈូសព្រៃសម្អាតដី ០១ហិកតា ត្រូវការប្រេងឥន្ធនៈចំនួន ២៥០លីត្រ (០១តោនប្រេងឥន្ធនៈមាន ១១៩០លីត្រ)។ ដូច្នេះ ដើម្បីសម្អាតព្រៃ ៥.៤៣៦ហិកតា ត្រូវការប្រេងឥន្ធនៈចំនួន ២៥០លីត្រ×៥.៤៣៦/១១៩០ = ១.១៤២តោន។ ចំហេះប្រេងឥន្ធនៈ ០១តោន ជាមួយនឹងកម្រិតចំហេះ (Octane) ៩៩ភាគរយ នឹងបំភាយឧស្ម័នកាបូនិក ៨៧,៣០៦៧៣គ.ក្រ[1]។ ដូច្នេះ ការប្រើប្រេងឥន្ធនៈចំនួន ១.១៤២តោន ត្រូវបំភាយឧស្ម័នកាបូនិកសរុបចំនួន ៩៩,៧០តោន។

២២០. ក្នុងចំណោមសំណល់ជីវៈម៉ាស់លើដីសរុបចំនួន ៦៧.៩៥០តោន មានប្រមាណ៣០ភាគរយ ឬស្មើនឹង ២០.៣៨៥តោន យកទៅប្រើប្រាស់សម្រាប់សំណង់។ ជីវៈម៉ាស់ចំនួន ៧០ភាគរយ ឬ ៤៧.៥៦៥តោន ដែលនៅសល់ មានប្រមាណ ២៥ភាគរយ ឬស្មើនឹង ១១.៨៩១,២៥តោន បានសេសសល់លើដី ក្រោយពីការប្រមូលគរនិងដុតចោល។ ចំណែកឯជីវៈម៉ាស់លើដីនៅសល់ចំនួន ៣៥.៦៧៣,៧៥ តោន ត្រូវបានដុតចោលដើម្បីសម្អាតដីដាំកៅស៊ូ។ ការដុតជីវៈម៉ាស់ចំនួន ៣៥.៦៧៣,៧៥តោននេះ នឹងបំភាយនូវឧស្ម័នមួយចំនួនដូចខាងក្រោម[2]៖

- ឧស្ម័នកាបូនិក - ៥៣.៩៧៤,០០តោន
- មេតាន - ១៤៨,០០តោន
- សូដ្យូមឌីអុកស៊ីដ - ១,៩៧តោន
- សូដ្យូមម៉ូណូអុកស៊ីដ - ៤៩.២៣តោន

[1] ITCC
[2] Conversion and Emission factors, www.fao.org

Draft

- កាបូម៉ូណូអុកស៊ីដ - ២.៤៦១,៤៩តោន
- NMVOC[3] - ២៩៥,៣៨តោន

២២១. ដូចគ្នានេះដែរ ប្រជាពលរដ្ឋដែលរស់នៅក្បែរ និងជុំវិញតំបន់គម្រោងចំនួន ១.១៤៦គ្រួសារ ស្មើនឹង ៥.៩៧០នាក់ (តារាង៥-៣៧) បាន នឹងបញ្ចេញពីផ្ទះរបស់ខ្លួននូវប្រភេទ និងបរិមាណសំណល់រឹង រាវ និងឧស្ម័នដូចខាងក្រោម៖

- សំណល់រឹង៖
  - សំណល់រឹងដែលមិនអាចបំបែកបានតាមលក្ខណៈជីវសាស្ត្រៈ ៣០០ក្រាម×៥.៩៧០នាក់×៣៦៥ថ្ងៃ = ៦៥៣,៧១៥តោន/ឆ្នាំ។
  - សំណល់រឹងដែលអាចបំបែកបានតាមលក្ខណៈជីវសាស្ត្រៈ ៦០០ក្រាម×៥.៩៧០នាក់×៣៦៥ថ្ងៃ = ១.៣០៧,៤៣០តោន/ឆ្នាំ។
- សំណល់រាវ៖ ៣០លីត្រ×៥.៩៧០នាក់×៣៦៥ថ្ងៃ = ៦៥.៣៧១,៥ម៣/ឆ្នាំ។
- សំណល់ឧស្ម័ន៖ តាមការប៉ាន់ស្មានថា គ្រួសារប្រជាពលរដ្ឋប្រើប្រាស់អុសសម្រាប់ចំអិនអាហារប្រមាណ ៤គក្រ/គ្រួសារ/ថ្ងៃ ដូច្នេះប្រជាពលរដ្ឋដែលរស់នៅក្បែរ និងជុំវិញតំបន់គម្រោងចំនួន ១.១៤៦គ្រួសារប្រើប្រាស់អុសប្រមាណ ៤គក្រ×១.១៤៦គ្រួសារ×៣៦៥ថ្ងៃ = ១.៦៧៣,១៦០តោន/ឆ្នាំ។ ការដុតអុសចំនួន ១.៦៧៣,១៦០តោននេះ នឹងបំភាយនូវឧស្ម័នមួយចំនួន រួមមាន៖

- ឧស្ម័នកាបូនិក - ២.៥៣១,៥០តោន/ឆ្នាំ
- មេតាន - ៦,៩៣តោន/ឆ្នាំ
- សូដ្យូមឌីអុកស៊ីដ - ០,០៩តោន/ឆ្នាំ
- សូដ្យូមម៉ូណូអុកស៊ីដ - ២,៣១តោន/ឆ្នាំ
- កាបូម៉ូណូអុកស៊ីដ - ១១៥,៤៥តោន/ឆ្នាំ
- NMVOC - ១៣,៨៥តោន/ឆ្នាំ

៥.៤.៧ សម្បត្តិវប្បធម៌ សំណង់ប្រវត្តសាស្ត្រ ប្រាសាទបុរាណ វត្តអារាម/ទំនៀមទំលាប់ប្រពៃណីជនជាតិដើម ឬជនជាតិភាគតិច

២២២. ក្រៅពីទួលកប់ខ្មោច នៅក្នុងទីតាំងសុវត្ថិភាពទំហំដាង ៣០ហិកតា នៅផ្នែកខាងជើងរបស់ភូមិស្រែនចេញ នៅក្នុងតំបន់នេះគ្មានសំណង់ប្រវត្តសាស្ត្រ និងប្រាសាទបុរាណទេ។

២២៣. អំពីវត្តអារាម/ទំនៀមទំលាប់ប្រពៃណីបញ្ហាជនជាតិដើម ឬជនជាតិភាគតិច សូមអានចំណុច ៥.៤.៥.២ (អំពីស្ថានភាពប្រជាសាស្ត្រ) ខាងលើ។

[3] Non Methane Volatile Organic Compound

Draft

Draft